សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale De Droit Et Des Sciences Économiques

Royal University of Law and Economics

## មុខវិជ្ជា: នីតិនគរូបនីយវិទ្យា

# កម្រងកិច្ចការស្រាវជ្រាវ

### មហាវិទ្យាល័យនីតិសាស្ត្រ

### និង

### រដ្ឋបាលសាធារណៈ

ក្រុម:L4C2

សាស្ត្រាចារ្យណែនាំ: បណ្ឌិត អ៊ុន សកក្តដា

រៀបរៀងដោយនិស្សិត:    លោក  យុត  សុត័ក្ត

លោក  សាត  សុខណា

ឆ្នាំសិក្សា: ២០១៤ - ២០១៥

## តារាងក្រុមកិច្ចការស្រាវជ្រាវនិស្សិតមុខវិជ្ជានីតិនគរូបនីយវិទ្យា

| ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី៤ |
|---|---|---|---|
| ១.ដួង សុកកញ្ញា | ១.យុន លាងហាក់ | ១.តី ដារ៉ូ | ១.ពុធ មករា |
| ២.ម៉េង រតនៈ | ២.សិត ចិត្រា | ២.ដាន់ សំអាង | ២.ធូ រិទ្ធី |
| ៣.ធី ពិសី | ៣.ខៀវ គីមហ៊ួរ | ៣.នុត សុម៉ារី | ៣.ឆាន់ យុសៃ |
| ៤.រិទ្ធិ ប៊ុណ្ណារ័ត្ន | ៤.អ៊ុក ច័ន្ទឆៃយ៉ា | ៤.ឆេង រ៉ុំ | ៤.ម៉េត ស្រីលាក់ |
| ៥.ហុង ឌីណា | ៥.សេង ច័ន្ទណារី | ៥.កែវ ស៊ីណា | ៥.សុន ដារា |
| ៦.សុខ លាងហោ | ៦.ម៉ែន សុគ័ន្ធទ្រា | ៦.អ៊ា ថូ | ៦.អ៊ាម ជួនមុំ |
| ៧.ម៉ៅ កុម្ភៈ | ៧.អ៊ាក ស៊ុងរ័ត្ន | ៧.ស៊ុយ ប៊ុនឡាយ | ៧.ចៀម វន្នី |
| ៨.នី រាជ | ៨.តិន ឈុនឡៀង | ៨.ឡក់ គីមហុង | ៨.សុខ អាន |
| ៩.លី ស្រីឡែន | ៩.វ៉ន់ រត្តា | ៩.យាន ទូច | ៩.ជីវ ធាហ៊ី |
| ១០.ផុស ណាលី | ១០.ហៃ ឆេងហុង | ១០.ខួន សារាយ | ១០.ផុន វុត្ថា |
| ១១.ស៊ុន ប៊ុនណាវ៉ាត់ | ១១.ម៉ាន់ រ៉ាវី | ១១.ខួយ ថុនា | ១១. ប៊ុត ប៊ុនថន |
| ១២.អេង គីមហុង | ១២.ឯក ស្រីលក្ខិណា | ១២.វិចិត្រ សម្បត្តិបញ្ញា | ១២.តាំង កែវពិសី |
| ១៣.ស៊ិន សីមុន្នី | | | |
| ១៤.កុយ សុគន្ធ | | | |

| ក្រុមទី៥ | ក្រុមទី៦ | ក្រុមទី៧ | |
|---|---|---|---|
| | ១. អ៊ិត ចន្ថា | ១.កែវ ដារ៉ា | |
| | ២. ម៉ិញ ច័ន្ទសីហា | ២.ម៉ី ម៉ុល | |
| | ៣.សុខ ស៊ីថា | ៣.គួយ ស៊ីនឹម | |
| | ៤.សន ពេជ្រ | ៤.វង សៀកឡាយ | |
| | ៥.អ៊ឹង លាងហួត | ៥.ឆាន់ ឈួយសាន្ត | |
| | ៦.អេង ម៉េងហឿន | ៦.ហាន សម្បត្តិ | |
| | ៧.សុវណ្ណ លីនដី | ៧.ជ័យ សុខជុម | |
| | ៨.ផេង សម្ផស្ស | ៨.ហុងដារីណា | |
| | ៩.ឡេង រាជសី | ៩.ឈឿន បារាំង | |
| | ១០.ផង់ សុគ័ន្ត្រា | ១០.ហើល ច័ន្ទវាសនា | |
| | ១១.រស់ ផុនលក្ខណា | ១១.ញ៉ុង ហេង | |
| | ១២.ភួង ស្រីឡេង | ១២.ឡាយ វង្សឃីម | |
| | ១៣.ថេង ស៊ាងឡេង | ១៣.ទេព ចិន្តា | |
| | ១៤.ដាន សុភាជ | ១៤.អ៊ុន ចិន្តា | |
| | | ១៥.នី គំនិត | |

# បញ្ជីប្រធានបទសម្រាប់ក្រុមនីមួយៗ

ក្រុមទី១ ៖ ប្រវត្តិស្ថាបត្យកម្មខ្មែរ ។

ក្រុមទី២ ៖ប្រវត្តិនៃការរៀបចំទីក្រុងសម័យអង្គរ ។

ក្រុមទី៣ ៖ ប្រវត្តិនៃការរៀបចំទីក្រុងក្នុងសម័យទំនើបឆ្នាំ១៩៥0ដល់១៩៧៥ ។

ក្រុមទី៤ ៖ ប្រវត្តិនៃការរៀបចំទីក្រុងចាប់ពី១៩៧៩ដល់បច្ចុប្បន្ន ។

ក្រុមទី៥ ៖ គុណសម្បត្តិនៃការសម្បទានដីសង្គមកិច្ច ។

ក្រុមទី៦ ៖ គុណសម្បត្តិ និងគុណវិបត្តិដីសម្បទានសេដ្ឋកិច្ច ។

ក្រុមទី៧ ៖ ប្រវត្តិនៃការរៀបចំទីក្រុងក្នុងបណ្តាប្រទេសអាស៊ាន ។

# មាតិកា

ទំព័រ

## គន្លឹះទី១

## ប្រវត្តិស្ថាបត្យកម្មខ្មែរ


ជំពូកទី១ ស្ថាបត្យកម្មសម័យបុរាណ ........ ១២
១.ស្ថាបត្យកម្មសម័យ នគរភ្នំ ........ ១២
១.១ ប្រវត្តិ នៃការកកើតរដ្ឋ សម័យនគរភ្នំ ឬហ្វូណន ........ ១២
១.២ ស្ថាបត្យកម្មសំខាន់ៗដែលបានស្ថាបនាឡើង ........ ១៣
២. ស្ថាបត្យកម្មសម័យ ចេនឡា ........ ១៨
២.១ ប្រាសាទសំបូរព្រៃគុក ........ ១៨
២.២ ប្រាសាទភ្នំជើងព្រៃ ........ ១៩
៣. ស្ថាបត្យកម្មសម័យអង្គរ ........ ២២
៣.១ រចនាបទអង្គរ ........ ២២
៣.២ ស្រះស្រង់ ........ ២៨
៣.៣ បារាយណ៍ទឹក ........ ២៩
៣. ៤ ប្រាសាទបាយ័ន ........ ៣០
៣.៥ ការរៀបចំមន្ទីពេទ្យ នាសម័យព្រះបាទជ័យវរ្ម័នទី៧ ........ ៣១
៣.៦ ប្រាសាទព្រះវិហារ ........ ៣៣
៤.ស្ថាបត្យកម្មសម័យក្រោយអង្គរ ........ ៣៤
៤.១ ស្ថាបត្យកម្មសម័យចតុមុខ ........ ៣៤
៤.២ ស្ថាបត្យកម្មសម័យលង្វែក ........ ៣៧
៤.៣ ស្ថាបត្យកម្មសម័យឧដុង្គ ........ ៣៩
ជំពូកទី២ ស្ថាបត្យកម្មសម័យទំនើប ........ ៤៤
១.ស្ថាបត្យកម្មសម័យ អាណានិគមបារាំង ........ ៤៤
២.ស្ថាបត្យកម្មសម័យ សង្គមរាស្ត្រនិយម ........ ៥៣
២.១ ពហុកីឡាដ្ឋានជាតិអូឡាំពិច ........ ៥៣
២.២ សំណង់ប៉ុលឌិញ ........ ៥៤
២.៣ ភ្នំពេញថ្មី ........ ៥៥

២.៤ វាយយន្តហោះប៉ូចិនតុង ..... ៥៥
២.៥ វិមានឯករាជ្យ ..... ៥៨
៣. ស្ថាបត្យកម្មសម័យ សាធារណៈរដ្ឋខ្មែរ ..... ៥៨
សេចក្តីសន្និដ្ឋាន ..... ៥៨
ឯកសារយោង ..... ៥៩
ឧបសម្ព័ន្ធ ..... ៦១

## គន្លឹះទី២

## ប្រវត្តិនៃការរៀបចំទីក្រុងសម័យអង្គរ

ជំពូកទី១លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ និងប្រវត្តិសាស្ត្រនៃកសាងក្រុងនាសម័យអង្គរ ..... ៧០
១. លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ ..... ៧០
២. លក្ខណៈពិសេសនៃទីតាំងប្រវត្តិសាស្ត្រ ..... ៧១
ជំពូកទី២ ដំណើរការរៀបចំ និងការកសាងក្រុងសម័យអង្គរ ..... ៧២
១. ការកសាងក្រុងនាសម័យអង្គរ ..... ៧២
១.១. រាជធានីមហេន្ទ្របរិត ..... ៧៣
១.២. ការវិលត្រឡប់មករាជធានីហរិហរាល័យ ..... ៧៣
១.៣. រាជាធានីយសោធបុរៈទី១ (ក្រុងអង្គរទី១) ..... ៧៤
១.៤. រាជធានីកោះកេរ្តិ៍ ..... ៧៥
១.៥. រាជាធានីយសោធរបុរៈទី២ (ក្រុងអង្គរទី២) ..... ៧៥
១.៦. រាជធានីយសោធបុរៈទី៣(ក្រុងអង្គរទី៣ ឬប្រាសាទអង្គរវត្ត) ..... ៧៦
១.៧. រាជធានីយសោធបុរៈទី៤ (អង្គរធំ ឬក្រុងអង្គរទី៤) ..... ៧៦
២. កត្តាជំរុញឲ្យមានការអភិវឌ្ឍន៍ និងការរីកចម្រើនក្រុងនាសម័យអង្គរ ..... ៧៧
២.១ កត្តាធនធានមនុស្ស ..... ៧៧
២.២. កសិកម្ម ..... ៧៨
២.៣. សិប្បកម្ម ..... ៨០
២.៤ គមនាគមន៍ ..... ៨១
២.៥. ពាណិជ្ជកម្ម ..... ៨២
២.៦ អប់រំសិក្សា ..... ៨៣
២.៧ សង្គមកិច្ច "វេជ្ជសាស្ត្រ" ..... ៨៥
៣. ការធ្លាក់ចុះនៃសម័យអង្គរ ..... ៨៥

៣.១. ដោយសារសង្គ្រាមឈ្លានពាន ........ ៨៥
៣.២. ដោយសារធម្មជាតិ ........ ៨៧
៣.៤. តំបាយប្រជាជន ........ ៨៨
៣.៣ ការធ្លាក់ចុះនៃផលិតផលកសិកម្ម ........ ៨៨
សេចក្តីសន្និដ្ឋាន ........ ៩០
ឯកសារយោង ........ ៩២
ឧបសម្ព័ន្ធ ........ ៩៣

## គន្លឹះទី៣

## ការរៀបចំទីក្រុងក្នុងសម័យទំនើបនៅចន្លោះឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៧៥

១.ចុងសម័យអាណានិគមបារាំង(១៩៥០-១៩៥៣) ........ ៩៦
១.១. ប្រវត្តិនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល ........ ៩៦
១.២. ការកសាងទីក្រុង ........ ៩៨
២.សម័យសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០) ........ ១០១
២.១. ប្រវត្តិនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល ........ ១០១
២.២. ការកសាងទីក្រុង ........ ១០៣
៣.សម័យសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥) ........ ១១១
៣.១. ប្រវត្តិនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល ........ ១១១
៣.២. ការកសាងទីក្រុង ........ ១១៣
សេចក្តីសន្និដ្ឋាន ........ ១១៦
ឯកសារយោង ........ ១១៧

## គន្លឹះទី៤

## ប្រវត្តិនៃការរៀបចំទីក្រុងចាប់ពីឆ្នាំ១៩៧៩ដល់បច្ចុប្បន្ន

ជំពូកទី១ ការរៀបចំក្រុងនៅសម័យប្រជាមានិតនិងសម័យរដ្ឋកម្ពុជា ........ ១១៩
១.ការរៀបចំទីក្រុងចាប់ពីឆ្នាំ( ១៩៧៩-១៩៨៩) ........ ១១៩
១.១.ស្ថានភាពទីក្រុងក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៨៩ ........ ១១៩
១.២.ស្ថានភាពសង្គមកិច្ច(បំរែបំរួល និងស្ថានភាពប្រជាជន) ........ ១២០
១.៣. ហេដ្ឋារចនាសម្ព័ន្ធនៅសម័យប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ........ ១២០
២. ស្ថានភាពសង្គមកិច្ចនៅសម័យសាធារណរដ្ឋប្រជាមានិក និងរដ្ឋកម្ពុជា ........ ១២៣
២.១. បំរែបំរួល និងស្ថានភាពប្រជាជន ........ ១២៣

២.២. ប្រព័ន្ធអប់រំ ............ ១២៤
២.៣. ប្រព័ន្ធសុខាភិបាល ............ ១២៥
ជំពូកទី ២ ការអភិវឌ្ឍន៍ និង ការកែលំអរទីក្រុងសោភ័ណ្ឌភាពទីក្រុង ............ ១២៥
១.ការរៀបចំក្រុងតាមបែបយុគសម័យទំនើប ............ ១២៥
២. ទិសដៅនៃការពង្រីកក្រុង ............ ១៣១
សេចក្តីសន្និដ្ឋាន ............ ១៤៤
ឯកសារយោង ............ ១៤៥

## **គន្លឹទី៥**

## **គុណសម្បត្តិនៃការផ្តល់សម្បទានដីសង្គមកិច្ច**

ជំពូកទី១ សញ្ញាណទូទៅ និង ការបង្កើតសម្បទានដីសង្គមកិច្ច ............ ១៤៧
១.សញ្ញាណទូទៅ ............ ១៤៧
១.១.ប្រវត្តិនៃសម្បទានដីសង្គមកិច្ច ............ ១៤៧
១.២.និយមន័យនៃសម្បទានដីសង្គមកិច្ច ............ ១៤៨
១.៣. មូលដ្ឋានច្បាប់នៃសម្បទានដីសង្គមកិច្ច ............ ១៤៩
១.៤. គោលដៅនៃសម្បទានដីសង្គមកិច្ច ............ ១៤៩
២. ការបង្កើតសម្បទានដីសង្គមកិច្ច ............ ១៤៩
២.១. ការធ្វើផែនការសម្បទានដីសង្គមកិច្ច ............ ១៤៩
២.២. នីតិវិធីនៃការធ្វើសម្បទានដីសង្គមកិច្ច ............ ១៥៣
២.៣. ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី ............ ១៥៥
២.៤. ការបែងចែកដីសម្បទានសង្គមកិច្ច និងការតាមដានវាយតំលៃលើដំណើរការអនុវត្តន៍ ............ ១៥៦
ជំពូកទី២ គុណសម្បត្តិនៃសម្បទានដីសង្គមកិច្ច ............ ១៥៨
១. គុណសម្បត្តិនៃការផ្តល់ដីសម្បទានដោយផ្ទាល់ ............ ១៥៨
១.១. ការផ្តល់ដីឲ្យប្រជាពលរដ្ឋកាន់កាប់ដីដោយស្របច្បាប់ ............ ១៥៨
១.២. ការលើកស្ទួយសេដ្ឋកិច្ចជាតិ និងគ្រួសារ ............ ១៦០
២. គុណសម្បត្តិនៃការផ្តល់ដីសម្បទានដោយប្រយោល ............ ១៦១
២.១. ការទប់ស្កាត់ក្នុងការទន្ទ្រានកាប់ព្រៃដោយខុសច្បាប់ ............ ១៦១
២.២. ការបញ្ចៀសកំណើនប្រជាជនតែមួយកន្លែង ............ ១៦១
សេចក្តីសន្និដ្ឋាន ............ ១៦២
ឯកសារយោង ............ ១៦២

## គន្លឹះទី៦

## គុណសម្បត្តិ និងគុណវិបត្តិសម្បទានដីសេដ្ឋកិច្ច


ជំពូកទី១ ទិដ្ឋភាពទូទៅនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ........ ១៦៥

១.និយមន័យ ........ ១៦៥

២.លក្ខខណ្ឌនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ........ ១៦៥

២.១.លក្ខខណ្ឌទូទៅ ........ ១៦៥

២.២.លក្ខខណ្ឌដី ........ ១៦៦

៣. លក្ខខណ្ឌក្នុងការទទួលដីសម្បទានសេដ្ឋកិច្ច ........ ១៦៧

ជំពូកទី២ គុណសម្បត្តិ និងគុណវិបត្តិនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច ........ ១៦៧

១.គុណសម្បត្តិ ........ ១៦៨

១.១.រដ្ឋទទួលបានចំនូលពីការបង់ពន្ធ ........ ១៦៨

១.២.កាត់បន្ថយអត្រាអ្នកអត់ការងារធ្វើ ........ ១៦៩

១.៣.កសាងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ នៅតាមមូលដ្ឋាននៃគម្រោង ........ ១៦៩

១.៤. នាំមកនូវបច្ចេកវិទ្យាថ្មីៗ ដល់កម្ពុជា ........ ១៧០

១.៥.សោភ័ណភាព និងសណ្តាប់ធ្នាប់ល្អ ........ ១៧១

១.៧.ជម្រុញកំណើនសេដ្ឋកិច្ចជាតិលើគ្រប់វិស័យ ........ ១៧១

២.គុណវិត្តិ ........ ១៧៣

២.១.ប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ........ ១៧៣

២.២. ប៉ះពាល់ដល់កម្មសិទ្ធិឯកជននៅក្នុងគម្រោងអភិវឌ្ឍ ........ ១៧៤

២.៣.ប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនដែលអាស្រ័យអនុផលព្រៃឈើ ........ ១៧៤

២.៤.ការប៉ះពាល់ដល់វប្បធម៌ និងជំនឿ ........ ១៧៥

៣. ដំណោះស្រាយលើបញ្ហាដីសម្បទានសេដ្ឋកិច្ច ........ ១៧៦

៣.១. ការត្រួតពិនិត្យពីសំណាក់រដ្ឋាភិបាលលើក្រុមហ៊ុនទទួលបានដីសម្បទានសេដ្ឋកិច្ច ........ ១៧៦

៣.២.ក្រសួងបរិស្ថានដកហូតដីសម្បទានពីក្រុមហ៊ុន ........ ១៧៧

៣.៣. ការចូលរួមពីសំណាក់សង្គមស៊ីវិល ........ ១៧៩

៣.៤.ដំណោះស្រាយរបស់សង្គមស៊ីវិលក្នុងបញ្ហាដីសម្បទានសេដ្ឋកិច្ច ........ ១៧៩

សេចក្តីសន្និដ្ឋាន ........ ១៨០

ឯកសារយោង ........ ១៨១


## គន្លឹះទី៧

## ប្រវត្តិនៃការរៀបចំទីក្រុងនៅក្នុងបណ្តាប្រទេសអាស៊ាន


ជំពូកទី១ ប្រវត្តិនៃការរៀបចំទីក្រុងនៃប្រទេសសិង្ហបុរី ........ ១៨២

១. ទិដ្ឋភាពទូទៅនៃប្រទេសសិង្ហបុរី ........ ១៨៣

២. ដំណើរការនៃការរៀបចំទីក្រុង ........ ១៨៣

២.១. ក្រោមការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស ........ ១៨៣

២.២. ក្រោយសម័យអាណានិគមអង់គ្លេស ........ ១៨៥

៣.កត្តាដែលជំរុញឲ្យមានការរៀបចំទីក្រុង ........ ១៨៨

៣.១. កត្តាភូមិសាស្ត្រ ........ ១៨៨

៣.២.កត្តាវិស័យទេសចរណ៍ ........ ១៨៩

៣.៣.ធនធានធម្មជាតិ(ធនធានទឹក) ........ ១៩០

៣.៤. កត្តាប្រជាសាស្ត្រ ........ ១៩០

៣.៥. កត្តាវិស័យគមនាគមន៍ និងដឹកជញ្ជូន ........ ១៩១

ជំពូកទី២ ប្រវត្តិនៃការរៀបចំទីក្រុងនៃប្រទេសម៉ាឡេស៊ី ........ ១៩១

១. ទិដ្ឋភាពទូទៅនៃការរៀបចំទីក្រុង ........ ១៩១

២.ដំណើរការនៃការរៀបចំទីក្រុង ........ ១៩២

២.១. ផែនការនៃទម្រង់ជាតិ ........ ១៩៣

២.២. ផែនការរចនាសម្ព័ន្ធ(SP) ........ ១៩៣

២.៣.ផែនការថ្នាក់តំបន់(LP) ........ ១៩៤

២.៤.ផែនការតំបន់ពិសេស(SP) ........ ១៩៥

៣. កត្តាដែលជំរុញឲ្យមានការរៀបចំទីក្រុង ........ ១៩៥

៣.១. ការរីកចម្រើននៃសេដ្ឋកិច្ច ........ ១៩៥

៣.២. កំនើនប្រជាជន ........ ១៩៥

សេចក្តីសន្និដ្ឋាន ........ ១៩៦

ឧបសម្ព័ន្ធ ........ ១៩៧

ឯកសារយោង ........ ១៩៨

# គន្លឹទី១

# ប្រវត្តិស្ថាបត្យកម្មខ្មែរ

## សេចក្ដីផ្ដើម

ប្រទេសកម្ពុជា គឺជាប្រទេសមួយ ដែលមានប្រវត្តិសាស្ត្រដ៏ចំណាស់មួយ ហើយមានប្រវត្តិសាស្ត្រជាច្រើនតាមវិស័យផ្សេងៗគ្នា ។ នៅក្នុងនោះដែរមានកាកត់សំគាល់មួយដែលគួរឲ្យចាប់អារម្មណ៍បំផុតក្នុងចំណោមវិស័យដែលគួរឲ្យចាប់អារម្មណ៍ទាំងនោះគឺ ប្រវត្តិស្ថាបត្យកម្មខ្មែរ។ ពីព្រោះថា ប្រទេសកម្ពុជាគឺជាប្រទេសដែលសម្បូរទៅដោយសម្បត្តិវប្បធម៌ ជាច្រើន ហើយពិសេសគឺខាងផ្នែកសំណង់ ឬស្ថាបត្យកម្មផ្សេងៗ ។ ឧទាហរណ៍ គឺប្រាសាទអង្គរវត្ត ដែលជាអច្ឆរិយវត្ថុ ដែលល្អឯកគ្មានពីរ ជាសំណង់ដែលពិភពលោកស្ងើចសរសើរ ពីស្នាដៃរបស់ស្ថាបត្យករខ្មែរបុរាណណថាជាអ្នកជំនាញគណិតសាស្ត្រ និងតារាសាស្ត្រ ដែលមានស្នាដៃសាងសង់ប្រាសាទ ដែលមិនគួរឲ្យជឿសោះ ថាអាចសាងសង់វាបាន ។ មួយវិញទៀតគឺប្រសាទបន្ទាយស្រី គឺជាប្រាសាទដែលមាន ក្បូរក្បាច់រចនា ល្អឯក គ្មានគូប្រៀប គឺការឆ្លាក់រូបនៅលើថ្មជញ្ជាំងប្រាសាទ ហើយមិនមែនមានតែប៉ុនហ្នឹងទេគឺ នូវមានជាច្រើនផ្សេងៗទៀត ។ ដូចក្នុងករណីនេះហើយ តើប្រវត្តិស្ថាបត្យកម្មខ្មែរមានអត្ថន័យខ្លឹមសារ និងការវិវត្តតាមសម័យកាលនីមួយៗ យ៉ាងដូចម្ដេចខ្លះ ?

ដូចនេះហើយដើម្បីឲ្យងាយយល់យើងគួរយល់នូវពាក្យគន្លឹះជាមុនសិន ។

ស្ថាបត្យកម្ម មានន័យថាជាសិល្បៈក្នុងការសាងសង់ប្រកបដោយការតុបតែងតាមក្បួនខ្នាត ។ ស្ថាបត្យកម្មនៅពេលនេះយើង សំដៅទៅលើស្ថាបត្យកម្មរបស់ខ្មែរទាំងសម័យបុរាណ និងសម័យទំនើបដែលល្បីល្បាញពាសពេញពិភពលោកសព្វថ្ងៃ ។ ប្រវត្តិ មានន័យថាគឺព្រឹត្តិការណ៍ ឬរឿងរ៉ាវ ពិតៗ ដែលបានកើតឡើងក្នុងអតីតកាល ។

តាមប្រវត្តិសាស្ត្របានបង្ហាញអោយយើងឃើញថា សិល្បៈខាងសំណង់ស្ថាបត្យកម្មខ្មែរ គឺមានកំណើតកកើតឡើងតាំងពីសម័យហ្វូណនមកម្លេះ ហើយបន្តវិវត្តន៍នាសម័យកាលបន្តបន្ទាប់ និងលូតលាស់ឡើងដល់ដំណាក់កាលកំពូលនាសម័យអង្គរ ដែលមានប្រាសាទអង្គរវត្តជាតឹកតាង ហើយបន្តរហូតដល់សម័យទំនើប គឺចាប់ពីសម័យអាណានិគមបារាំងមក ។

ស្ថាបត្យកម្មបុរាណ គឺសិក្សាលើសំណងប្រាសាទក៏ដូចជាសំណងនានាដែលកើតឡើងនៅសម័យមុនអង្គរ ពោលគឺសម័យនគរភ្នំ សម័យចេនឡា និងបន្តដល់សម័យអង្គរ ដែលជាសម័យកាលដ៏រុងរឿងបំផុតនៃប្រវត្តិសាស្ត្រខ្មែរលើគ្រប់វិស័យ ជាពិសេសវិស័យស្ថាបត្យកម្ម ដែលស្ដេចទាំងឡាយនាសម័យ

នោះបានខិតខំកសាងប្រាសាទជាច្រើន សាលាដំណាក់ សម្រាប់បំរើឲ្យវិស័យសាសនា នៅសម័យក្រោយអង្គរ សំណង់ប្រាសាទត្រូវបានធ្លាក់ចុះបន្តិចតែនៅតែសាងសង់តាមស្នាមព្រះហស្តរបស់ស្តេចមុនៗ ។ ស្ថាបត្យកម្មខ្មែរបុរាណ ដែលមានបង្ហាញក្នុងសម័យកាលខាងដើម ដែលបុរាណវិទូធ្វើការបែងចែកមានទាំងអស់ជា ១៣ រចនាបទ ដូចជា រចនាបថភ្នំដា (ពីស.វ ទី ១ ដល់ ស . វ ទី២) រចនាបថសម្បូរណ៌ (ពាក់កណ្តាលទី ១ នៃស. វ ទី ៧) រចនាបថបព្រៃក្មេង (ពាក់កណ្តាលទី២ នៃ ស វទី ៧ ) រចនាបថបកំពង់ព្រះ (ស.វទី ៨) រចនាបថគូលែន(ពាក់កណ្តាលទី ១ នៃ ស . វ ទី ៩ ) រចនាបថព្រះគោ(ដំណាក់កាលចុងក្រោយនៅ ស . វ ទី ៩ ) រចនាបថបាខែង ( ចុង ស . វ ទី ៩ ដើមស. វ ទី ១០) រចនាបថកោះកែរ (ស. វ ទី១០ ) រចនាបថបន្ទាយស្រី (ពាក់កណ្តាលទី២ នៃ ស. វ ទី១០ ) រចនាបថឃ្លាំង (ចុងស. វ ទី១០និងពាក់កណ្តាលទី១ នៃ ស. វ ទី១១ ) រចនាបថបាពួន (ពាក់កណ្តាលទី២ នៃ ស. វ ទី១១ ) រចនាបថអង្គរវត្ត (ពាក់កណ្តាលទី១ នៃ ស. វ ទី១២ ) រចនាបថបាយន័ (ពាក់កណ្តាលទី២ នៃ ស.វ ទី១២ និថដើម ស.វ ទី ១៣) ។

ស្ថាបត្យកម្មសម័យទំនើប គឺធ្វើការសិក្សាលើសំណង់អគារផ្សេងៗ ចាប់ពីសម័យអាណានិគមបារាំង(១៨៦៣-១៩៥៣) ដោយបារាំងបានសាងសង់សំណង់ដោយលាយបញ្ចូលនៅរចនាបទអឺរ៉ុប ដែលបង្ហាញពីវប្បធម៌អរិយធម៌របស់ខ្លួន បន្តមកក្រោយទទួលបានឯករាជ្យពីបារាំងនៅសម័យសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០) ក្រោមស្នាប្រហស្តដឹកនាំរបស់ព្រះបាទនរោត្តសីហនុវរ្ម័ន បានកសាងសំណង់អគារមហិមាជាច្រើនដែលបំរើឲ្យគ្រប់វិស័យ រួមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទ ដែលឆ្លុះបញ្ចាំងពីការរីកចំរើននាសម័យនោះ និងត្រឹមសម័យសាធារណ:រដ្ឋខ្មែរ(១៩៧០-១៩៧៥) ដែលដឹកនាំដោយលោកសេនាប្រមុខលន់ នល់។

ទន្ទឹមនឹងនេះដើម្បីឆ្លើយតបទៅ និងប្រធាបទស្រាវជ្រាវ " ប្រវត្តិស្ថាបត្យកម្មខ្មែរ" និងដើម្បីបង្ហាញពីអ្វីដែលបានលើកឡើងខាងលើ យើងធ្វើការបែងចែកនៅក្នុងសំណេរស្រាវជ្រាវជា ២ជំពូកគឺៈ

ជំពូកទី១. ស្ថាបត្យកម្មសម័យបុរាណ

១.១. ស្ថាបត្យកម្មសម័យ នគរភ្នំ ឬ ហ្វូណាន

១.២. ស្ថាបត្យកម្មសម័យចេនឡា

១.៣. ស្ថាបត្យកម្មសម័យអង្គរ

១.៤. ស្ថាបត្យកម្មនៅសម័យក្រោយអង្គរ

ជំពូកទី២. ស្ថាបត្យកម្មសម័យទំនើប

២.១. ស្ថាបត្យកម្មសម័យអាណានិគមបារាំង

២.២. ស្ថាបត្យកម្មសម័យសង្គមរាស្ត្រនិយម

២.៣. ស្ថាបត្យយកម្មសម័យសាធារណៈរដ្ឋខ្មែរ

## ជំពូកទី១ ស្ថាបត្យកម្មសម័យបុរាណ

### ១. ស្ថាបត្យកម្មសម័យនគរភ្នំ ឬ ហ្វូណាន

#### ១.១. ប្រវត្តិនៃការកកើតរដ្ឋសម័យនគរភ្នំ ឬហ្វូណាន

ការចាប់ផ្តើមបើកទំព័រសកវាជនៃប្រទេសកម្ពុជាហើយក៏ ជាការចាប់ផ្តើមកកើតរដ្ឋធានីរបស់ប្រទេសកម្ពុជាជាលើកដំបូង ដែលក្នុងនោះមានដំណាលរឿងប្រវត្តិសាស្ត្រខ្មែរដំណាលមកតៗ គ្នាថាមានការដឹកនាំប្រទេសដោយម្ចាស់ក្សត្រីមួយព្រះអង្គព្រះនាម សោមា ឬលាវយី បន្ទាប់មកទៀតទើបមានបុរសម្នាក់ដែលបានវាយឈ្នះលើទ័ពព្រះនាងលីវយី ហើយក្រោយមកបានរៀបអភិសេកជាមួយព្រះនាង ហើយថែមទាំងបានគ្រងរាជសម្បត្តិនៅនគរភ្នំ ឬហ្វូណាន[1] ។

គួរបញ្ជាក់ផងដែរថា សម័យនគរភ្នំ ឬហ្វូណាន ជាម័យកាលមួយដែលមានវ័យចំនាស់ជាងគេតាំងពីដើមសតវត្សទី១មកម្លេះ ។ សម័យកាលនោះមានការរីកចំរើនយ៉ាងខ្លាំងគឺ ចាប់តាំងពីទឹកដីនគរហ្វូណានធំទូលំទូលាយណាស់ លាតសន្ធឹងមានប្រទល់ដែនជាប់នឹងប្រទេសចាម នៅទិសខាងកើតជាប់នឹងទឹកដីចិន យេណាន នៅទិសខាងជើង និងខាងលិចជាប់នឹងប្រទេសភូមា[2] ។ ហើយគួរបន្ថែមទៀតថាទឹកដីនគរភ្នំបានលាតសន្ធឹងពីដីសន្តរនៃទន្លេមេគង្គ(កម្ពុជាក្រោម)រហូតដល់ភូមិភាគជលសីមានៃស្ទឹងស្រែមូល និងដីស្រែ ស្ថិតនៅទិសខាងជើងឈៀងខាងកើត និងភូមិភាគកណ្តាលនៃប្រទេសថៃ នាពេលបច្ចុប្បន្ន[3] ។ ឬ (មានទឹកដីលាតសន្ធឹងពីបឹងទន្លេសាបរហូតដល់ពាមទន្លេមេគង្គ ដែលជាប់ទៅនឹងសមុទ្រ)។

សន្ទុះនៃការរីកដុះដាលនាសម័យនគរភ្នំគឺចាប់តាំងពីស.វ ទី៣ ដល់ ស.វទី ៦ នៃគ.ស ដែលក្នុងនោះមានការចូលរួមពីសំណាក់ក្រុមអ្នកដឹកនាំ ឬប្រមុខរដ្ឋក្នុងកម្មវិធីសម្ពោធ បូជនីយដ្ឋាន ឬសំណង់សាសនាផ្សេងៗ និងព្រមទាំងបរិវេណនៃអតីតដែនដីខ្មែរទាំងមូល ទីក្រុងខ្មែរ ខេត្តនគរស្រីធម្មរាជជលបុរី, សិង្ហបុរី មហាសរខាម កាឡាស៊ីន ខនកែន រាជបុរី សុផានបុរី ដែលស្ថិតនៅប្រទេសថៃពេលបច្ចុប្បន្ន[4] ។

[1] ដកស្រង់ចេញពីសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា ចាប់តាំងពីសតវត្សទី១ ដល់ស.វទី ២១ ដោយលោក អាដេម៉ាឡឺក្លែរ

[2] ឯកសារ ចិនតាមរយៈឯកសារប្រវត្តិសាស្ត្រដែល អ្នកដំណើរចិនកត់ត្រា

[3] យោងតាមការស្រាវជ្រាវរបស់លោក វ៉ាន់ លីយ៉ែរ ដែលស្ថិតនៅទំព័រទី ៧៣ ក្នុង សៀវភៅលោក (បណ្ឌិត មី សែល ត្រាណេ)

[4] ពីសៀវភៅ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា (ការបង្កើតរដ្ឋខ្មែរ) បណ្ឌិត មីសែល ត្រាណេ ២០០២

ឧទាហរណ៍ជាក់ស្តែងគឺជាការបង្វិលទឹកនៃទន្លេមេគង្គ ដើម្បីបង្ហូរចូលទៅបរិវេណនៃទីក្រុងស្រេស្ធបរៈ ស្ថិតនៅក្បែរប្រាសាទវត្តភូ ពីសំណាក់ខ្មែរសម័យនគរភ្នំ ។

## ១. ២. ស្ថាបត្យកម្មសំខាន់ៗ ដែលបានស្ថាបនាឡើង

### ក. រាជធានីវ្យាធបុរៈ

មានទស្សនៈវិទូជាច្រើនបានធ្វើការស្រាជ្រាវក៏ដូចជាសន្មត់ផងដែរថា រាជធានីវ្យាធបុរៈ មានទីតាំងស្ថិតនៅបាភ្នំ ខេត្តព្រៃវែង ។ ប៉ុន្តែបើតាមការពិនិត្យឲ្យបានគ្រប់ជ្រុងជ្រោយទៅ តាមការពិតនោះគឺរាជធានីវ្យាធបុរៈនៃទីក្រុងនគរភ្នំស្ថិតនៅខេត្តតាកែវ ។ បន្ថែមពីនេះទៅទៀតគឺ រាជធានីមួយនេះមានអ្នកដំណើរ ចិន ក៏រៀបរាប់អធិប្បាយព័ណ៌នាក្បោះក្បាយអំពីព្រះមហាក្សត្រខ្មែរដែរ ។ ព្រះបរមរាជវាំងធ្វើអំពីឈើសង់លើគ្រឹះអំពីថ្ម ហើយភាគច្រើនធ្វើអំពីឥដ្ឋ ។

បើតាមសិលាចារឹកសម័យក្រោយៗ មកទៀតបានឲ្យដឹងថាក្រុងវ្យាធបុរៈ (បុរីនៃស្តេចទាក់ដំរី) ដែលអ្នកប្រវត្តិវិទូចាត់ទុកថាជារាជធានីមួយរបស់នគរភ្នំ ។ ចិនហៅរាជធានីនេះថា តូមូ ដែលលោកសឺដេសថាត្រូវនឹងពាក្យខ្មែរបុរាណថាទ្មាក់ ឬ ទល្មាក់ (អ្នកទាក់ដំរី) ។ លោកយល់ទៀតថា ក្រុងវ្យាធបុរៈនេះស្ថិតនៅម្តុំបាភ្នំនិងបាណាមក្នុងខេត្តព្រៃវែងសព្វថ្ងៃ ។ ព្រះភិក្ខុប៉ាងខាត់ក៏មានព្រះយោបល់ដូច្នេះដែរ ។ ព្រះអង្គបានសរសេរថារាជធានីវ្យាធបុរៈ តាំងនៅតំបន់បាភ្នំទំនងជានៅភ្នំខ្សាច់បច្ចុប្បនេះ ព្រោះគេបានរកឃើញបុរាណដ្ឋាននិងបុរាណទេវរូបជាច្រើននៅទីនោះ[5] ។

រាជធានីវ្យាធបុរៈជាទីក្រុងមួយ ដែលត្រូវបានគេដឹងមកថាជាទីក្រុងដែលកើតឡើងដោយសារកត្តាសាសនា ហើយដែលមានទីតាំងស្ថិតនៅក្បែរភ្នំលឹង្គ (លិង្គបរីវ៉ត) ដែលមានមនុស្សចាស់ទុំបុរាណចាត់ទុកជាកន្លែងដែលមានបុណ្យបារមីសក្តិសិទ្ធិផុតលេខ[6] ។

### ខ. ប្រាសាទភ្នំដា " ស.វ ទី ១ ដល់ ស . វ ទី២"

តាមកំណាយនៅអង្គបុរី និងនៅអូរកែវ " កម្ពុជាក្រោម " បានបង្ហាញអោយឃើញថា សិល្បៈសម័យហ្វូណាន ត្រូវ គេបញ្ចូលក្នុងរចនាបថភ្នំដា ដោយយកប្រាសាទភ្នំដាជាគោល ។ រចនាបថ ខ្មែរនាពេលនោះគឺគេបានចោះភ្នំធ្វើជាប្រាសាទដូចនៅប្រទេសឥណ្ឌាដែរហើយពេលខ្លះគេធ្វើ ប្រាសាទតូចៗដាច់ៗពីគ្នា[7]។

[5] ត្រឹង ងារ, ប្រវត្តិសាស្ត្រខ្មែរ ទំព័រ ៨៧,៨៨

[6] របាយការណ៍របស់លោក សេប៉ូ និងគេហុងនាសតវត្សទី៤ នៃគ.ស ទំព័រ ៦០ ក្នុង សៀវភៅលោក (បណ្ឌិត មី សែល ត្រាណេ)

[7] http://yimsamnang.wordpress.com

នៅសម័យភ្នំដាខ្មែរយើងបានលុងភ្នំធម្មជាតិ ធ្វើប្រាសាទគ្រាប់តាមឥណ្ឌាមែន ប៉ុន្តែក្រោយមកបុព្វបុរសយើងបានច្នៃគំនិតគោរពទៅលើទីខ្ពស់ឲ្យ ចេញជារូបរាងប្រាសាទ (ប្រាសាទភ្នំ) មានខឿនច្រើនជាន់ឲ្យខ្ពស់ដូចភ្នំធម្មជាតិ ។

បង្កាន់ដៃនាគអមសងខាងផ្លូវចូលទៅកាន់ប្រាសាទ និងគូដែលព័ទ្ធជុំវិញប្រាសាទជានិមិត្តរូបនៃការកូរសមុទ្រទឹកដោះ ក្នុងជំនឿសាសនាព្រាហ្មណ៍បានក្លាយមកជានិមិត្តរូបនៃនយោបាយទឹកដ៏ ប្រសើររបស់ខ្មែរនាសម័យអង្គរ ។ ដូចនេះ សិល្បៈស្ថាបត្យកម្មខ្មែរមិនត្រឹមតែបម្រើគំនិតនិមិត្តរូបនិយមនៅក្នុងជំនឿសាសនាប៉ុណ្ណោះទេ ថែមទាំងបម្រើគំនិតមនុស្សនិយមផង[8] ។

អាស្រ័យដោយស្នាដៃដ៏ប៉ិនប្រសប់ ដ៏ឆើតឆាយរបស់ដូនតាយើងបានធ្វើឲ្យសិល្បៈស្ថាបត្យកម្មខ្មែរមាន តម្លៃខ្ពង់ខ្ពស់ទាំងក្នុងប្រទេស និងក្រៅប្រទេស ដោយបានទទួលនូវការកោតសរសើរស្ងាប់ស្ងែងយ៉ាងក្រៃលែង ។

នៅក្នុងរចនាបថភ្នំដាមានរូបពុទ្ធបដិមា និងទេវៈបដិមាជាច្រើននៅអង្គរបូរី កំពង់ស្ពឺ ឧដុង្គ ។ ដោយខ្លាចរលំ គេធ្វើទម្រ ឬទំនប់ទប់រូបបដិមាមានរាងជាក្រចកសេះ រាងមូលទ្រវែង ជួនកាលរាង៤ជ្រុងទ្រវែង ហើយជួនកាលទៀត គេយកកេតនភណ្ឌ ឬជាយសំពត់ទល់រូបចម្លាក់នោះតែម្តង[9] ។

ជាទូទៅ រូបបដិមានៅសម័យនោះឈរមិនត្រង់ទេ គឺមានរាងកាច់ចង្កេះ ហើយមានសម្លៀកបំពាក់បែបឥណ្ឌា (ឧ.រូបគ្រិស្ណទ្រភ្នំ) ។

**គ. ប្រាសាទរូងភ្នំនៅអង្គរបុរី**

នៅជើងភ្នំដា ដែលមានទីក្រុងអង្គរបុរីដ៏ល្បីល្បាញនាសម័យហ្វូ-ណន គេឃើញមានរូង ឬល្អាងភ្នំសិប្បនិមិត្តចំនួន៥ ដែលបុព្វការីជនខ្មែរបានចោះ ឬលុងភ្នំ គឺ៣នៅខាងជើង ១នៅខាងលិច និង១ទៀតនៅខាងកើត ។ ទោះបីជាយើងអាចចាត់ទុកថា ល្អាងភ្នំទាំង៥នោះជាប្រាសាទរូងភ្នំក្តី ក៏ប៉ុន្តែមានតែល្អាងទី១ទេ ដែលមានទម្រង់ជាប្រាសាទយ៉ាងពិតប្រាកដ ។ ព្រោះថា ល្អាងទាំង៤ទៀត នៅរក្សានូវលក្ខណៈដើមរបស់វា ដោយគ្មានគ្រឿងតុបតែង ឬលំអអ្វីទាំងអស់ក្រៅពីចម្លាក់ទេវរូប ឬទម្រតម្កល់ព្រះសិវលិង្គដើម្បីជាទីគោរពសក្ការៈ ។ ដូច្នេះខុសពីប្រាសាទនៅខេត្តកំពត ដែលត្រូវបានកសាងឡើងអំពីឥដ្ឋ រៀបក្នុងរូងភ្នំធម្មជាតិផ្ទាល់ ប្រាសាទរូងភ្នំរបស់យើងដែលស្ថិតនៅក្រោមជើងភ្នំដា គឺជារូងភ្នំដែលគេបានលុងហើយតុបតែងឧបកិច្ចឡើងធ្វើជាប្រាសាទ ។ តាមការស្រាវជ្រាវបានបង្ហាញថា ប្រាសាទរូងភ្នំនាសម័យនគរភ្នំ

[8] តម្លៃនៃស្ថាបត្យកម្មខ្មែរ ប្រភេទប្រាសាទខ្មែរ Posted on 04/07/2008 by ឈូកខ្មែរ

[9] ដកស្រង់ចេញពីអត្ថបទ ឈូកខ្មែរ (វិវត្តន៍ចម្លាក់ខ្មែរ) Posted on 15/08/2008

នៅក្រោមជើងភ្នំជាត្រូវបានកសាងឡើងរវាងស.វទី៥ និងទី៦ នៃគ.ស តាមលំនាំនៃសំណង់ស្ថាបត្យកម្មផណ្តាជាពិសេសសិល្បៈគុហានៅជន្ត:។

តាមពិតទៅការលុងភ្នំ ដើម្បីធ្វើជាបូជនីយដ្ឋានប្រយោជន៍នឹងបូជាព្រះអាទិទេពនៃលទ្ធិព្រហ្មញ្ញសាសនា គឺជាការបន្តវេននៃជំនឿលើភាពស័ក្តិសិទ្ធិនៃរូងឬល្អាងភ្នំ ធម្មជាតិនាសម័យបុរេប្រវត្តិសាស្ត្រតែប៉ុណ្ណោះ។ព្រោះថា ជានិច្ចកាល រូង ឬល្អាងភ្នំធម្មជាតិត្រូវបានគេចាត់ទុកថាជាកន្លែងដែលប្រកបដោយបុណ្យបារមីភាពស័ក្តិសិទ្ធដ៏ខ្លាំងក្លាអស្ចារ្យមិនថានៅភូមិភាគអាស៊ីអាគ្នេយ៍ឬក៏នៅឧបទ្វីបអ៊ឺរ៉ុបទេ។

**គ.១.ប្រាសាទរូងភ្នំឬល្អាងភ្នំទី១**

ប្រាសាទរូងភ្នំទី១ ដែលបុព្វការីជនខ្មែរនាសម័យនគរភ្នំបានចោះ ដើម្បីធ្វើជាទីសក្ការ:បូជា គឺជាល្អាងមួយមានជម្រៅប្រមាណជា៥,៨០ម៉ែត្រ ស្ថិតនៅចំជណ្តើរទៅកាន់ប្រាសាទភ្នំដាហើយមានរាងជាចតុកោណ។ ប្រាសាទរូងភ្នំមានក្លោងទ្វារចេញចូលមួយដែលមានកំពស់ប្រមាណជា២,៨៥ ម៉ែត្រ ។ មេទ្វារដែលធ្វើអំពីឈើសព្វថ្ងៃនេះ ត្រូវបានបាត់បង់តាំងពីយូរទៅហើយ ដោយបានបន្សល់ទុកត្រឹមតែរន្ធមូលមួយលើធ្នឹមថ្មសម្រាប់សូកពន្លួញតែប៉ុណ្ណោះ។




ប្រាសាទរូងភ្នំទី១ចង្កេះភ្នំដា (ម.ត ២០០០)

ក្នុងល្អាងនៃប្រាសាទរូងភ្នំនេះ គេឃើញមានទម្រថ្ម២សម្រាប់តម្កល់ព្រះសិវ:លិង្គ ដែលត្រូវបានគេយករក្សាទុកក្នុងសារមន្ទីរស្រុកអង្គរបុរី ដែលទើបតែបានសាងសង់រួច ។ ប្រាសាទរូងភ្នំនេះមានប្រវែង៣ម៉ែត្រ,ទទឹង៥,៥០ម៉ែត្រនិងកំពស់៣ម៉ែត្រ៥០។

**គ.២. ប្រាសាទរូងភ្នំទី២**

ស្ថិតមិនឆ្ងាយប៉ុន្មានពីប្រាសាទរូងភ្នំទី១រូងភ្នំទី២នេះមិនមានលក្ខណ:ជាប្រាសាទដូចបូជនីយដ្ឋានទី១នោះទេ ។ ល្អាងនេះមានរាងកែង កោង ហើយគ្មានក្បាច់ក្បូរអ្វីទាំងអស់ ។ វត្តមានរបស់យោនីចំនួន២

តូចមួយ (ទំហំ១,៥០ម៉ែត្រ) ធំមួយ (១,៩០ម៉ែត្រ) ចង្អុលបង្ហាញថាប្រាសាទរូងភ្នំនេះត្រូវបានសាងសង់ឡើងដើម្បីឧទ្ទិសដល់លទ្ធិព្រហ្មញ្ញសាសនាសិវៈនិកាយ ។





ប្រាសាទរូបភ្នំទី២ (ម.ត ២០០០)

ល្អាងភ្នំទី២នេះ មានបណ្ដោយប្រមាណជា៥,៥០ម៉ែត្រ ទទឹង៤,៥០ម៉ែត្រ និងកំពស់ប្រមាណ៣,៥០ម៉ែត្រ។ សូមជម្រាបជាព័ត៌មានថា យោនីធំមាន៣ថ្នាក់ឬជាន់ជាន់ទី១មានប្រវែង១,៥៤៥ម៉ែត្រ ជាន់ទី២មានប្រវែង១,៤៣ម៉ែត្រ និងជាន់ទី៣ផ្នែកខាងក្នុងមានប្រវែង១០ស.ម ។

**គ.៣. ប្រាសាទរូងភ្នំទី៣**

ស្ថិតនៅខាងស្ដាំដៃនៃល្អាងទី២នៅប៉ែកខាងជើង មានប្រវែងប្រមាណ៥,៧០ម៉ែត្រ ហើយមានកំពស់ប្រមាណ២,៥០ម៉ែត្រ និងជម្រៅ៤,៩០ម៉ែត្រ ។ នៅក្នុងប្រាសាទរូងភ្នំនេះ យើងឃើញមានបំណែកស្ពានទ្រោណិបីបំណែកតែប៉ុណ្ណោះ ។







ប្រាសាទរូងភ្នំទី៣និងសមាសធាតុគុបតែង (ម.ត ២០០០)

នៅផ្នែកខាងឆ្វេងនៃផ្លូវចូលកាន់រូងភ្នំដ៏ពិសិដ្ឋនេះ យើងបានឃើញនូវសមាសធាតុថ្មគុបតែងប្រាសាទមួយចំនួន រាយប៉ាយដូចជាទម្រទេវរូបជាដើមគួរឲ្យចាប់អារម្មណ៍ជាអណោក ។ វត្តមានរបស់ស្លាកស្នាមទាំងនោះសបញ្ជាក់ឲ្យឃើញវិសាលភាពរបស់ទីតាំងនេះ ក្នុងអតីតកាលដ៏យូរលង់មួយដែលគប្បីគេត្រូវធ្វើការសិក្សាស្រាវជ្រាវជាបន្តទៀត ។

**គ.៤. រូងភ្នំទី៤**

ល្អាងភ្នំទី៤ដែលស្ថិតនៅខាងកើតក្បែរព្រះវិហារ ភ្នំដាបច្ចុប្បន្នមានជម្រៅ៥ម៉ែត្រ ទទឹង៤,១ម៉ែត្រ និង កំពស់២ម៉ែត្រ ។ ប្រភពព័ត៌មានបានឲ្យដឹងថា គេបានយកចេញពីល្អាងភ្នំនេះនូវចម្លាក់ព្រះវិស្ណុមួយធ្វើអំពីថ្មមានដៃ៨។

**គ.៥. រូងភ្នំទី៥**

ស្ថិតនៅទិសខាងលិចក្បែរវត្ត ហើយមានលក្ខណៈស្រដៀងទៅនិងល្អាងដទៃៗឯទៀត ដែលស្ថិតនៅចង្កេះភ្នំដា ។

ប្រាសាទល្អាងភ្នំនេះ មានជម្រៅប្រមាណ៣ម៉ែត្រ ទទឹង៥ម៉ែត្រ កំពស់៣,១០ម៉ែត្រ ។



វត្តតៃមិញ, បាដែងនិងកម្ពុជាក្រោម (ឯកសារ L′ Indochine de 1929)



(L. Gesick, "Reading the landscape" : Reflection on a Sacred Site in South Thailand, Art & Culture លេខ១២, តុលា ២៥២៨)

បូជនីយដ្ឋានបុរេអង្គរនេះបានបន្សល់ទុកតែស្ពានទ្រោណិថ្មមួយប៉ុណ្ណោះ ដែលមានរាង ៤ ជ្រុង ហើយមានទំហំប្រមាណ១,៩០ម៉ែត្រ[10] ។

## ២. ស្ថាបត្យកម្មសម័យចេនឡា

[10] (ម.ត្រាណេ) - See more at: http://www.cen.com.kh/culture/detail_cultureart/NWNjZjJhNDc1NmY#sthash.oByIOhhX.dpuf

### ២.១. ប្រាសាទសំបូរព្រៃគុក

ប្រាសាទសំបូរព្រៃគុក មានទីតាំងស្ថិតនៅក្នុងភូមិសំបូរ ស្រុកប្រាសាទសំបូរ ដែលមានចំងាយ ២៥គ.ម ពីទីរួមខេត្តកំពង់ធំ តាមផ្លូវជាតិលេខ៦៤ បត់ស្តាំតាមផ្លូវកូនត្នោត ។ សំបូរព្រៃគុកជារាជធានីចាស់បុរាណឈ្មោះឥសានបុរៈ ដែលកាលពីសម័យនោះជា មជ្ឈមណ្ឌលនៃសាសនាឧទ្ទិសថ្វាយដល់សិវនិយម ។ ក្រុមប្រាសាទនេះ សាងសង់អំពីឥដ្ឋតាន់ ថ្មបាយក្រៀម និងថ្មភក់ ដែលលំអរដោយចំលាក់ពីលើឥដ្ឋ ឬចាក់ពុម្ពដោយបាយអ ជាផ្ទាំងៗលើជញ្ជាំងឥដ្ឋ តែត្រូវរបេះអស់ ។ ក្បាច់ផ្តែរ និងសរសរពេជ្រ ប្រអប់ទ្វារធ្វើអំពី ថ្មភក់ ទាំងអស់។ប្រាសាទនេះកសាងឡើងនៅរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ ក្នុងសត-វត្សទី៧ ។

ក្រុមប្រាសាទសំបូរព្រៃគុក ត្រូវបានបោះបង់ចោលតាំងពីឆ្នាំ ១៩៧១ មកម្លេះ ហើយត្រូវបានរៀបចំសារជាថ្មី នៅឆ្នាំ១៩៨០។ ក្នុងការកាប់ឆ្ការព្រៃ គេរកឃើញប្រាសាទទាំងអស់ចំនួន១៥០ប្រាសាទ ។

រមណីដ្ឋានសំបូរព្រៃគុក ចែកចេញជា៤ក្រុមធំៗគឺៈ

-ក្រុមប្រាសាទខាងជើងៈ ហៅថាប្រាសាទសំបូរ នៅចំកណ្តាល និងព័ទ្ធជុំវិញដោយ ប្រាសាទតូចៗជាច្រើន ប្លែកៗគ្នា។

-ក្រុមប្រាសាទកណ្តាលៈ ហៅថាប្រាសាទតោ ប្រាង្គប្រាសាទកណ្តាលមានទ្វារចូល ពីខាងជើង ឯទ្វារបីទិសទៀតជាទ្វារបញ្ឆោត ។ នៅគ្រប់ក្បាលជណ្តើរទាំង៤ មានរូបតោអង្គុយបញ្ឈរជង្គង់ពីរក្នុងទិសនីមួយៗ ។ នៅភាគខាងលិចនៃប្រាសាទតោ មានក្រុមប្រាសាទតូចៗមួយចំនួនទៀត ។ ប្រាសាទទាំងនោះត្រូវបានកសាងឡើងនៅសតវត្សទី៩ ។

-ក្រុមប្រាសាទខាងត្បូងៈ ហៅថាប្រាសាទយាយព័ន្ធ ដែលស្ថិតនៅចំកណ្តាលហ៊ុំព័ទ្ធដោយប្រាសាទ ជាច្រើន មានកំពែងពីរជាន់ ដែលកំពែងខាងក្នុងមានគោបុរៈចូល ទាំង ៤ទិស ។ ក្រុមប្រាសាទនៅជាអតីតរាជធានី ។

-ក្រុមប្រាសាទក្រោរមាសៈ មានទីតាំងនៅខាងជើងចំងាយ ២គ.ម ពីប្រាសាទសំបូរ ព្រៃគុកមានតួប្រាសាទតូចៗធ្វើអំពីឥដ្ឋ និងខាងលិចមានប្រាសាទមួយធ្វើអំពី ថ្មបាយក្រៀម ។

ដើម្បីការពារតំបន់ប្រាសាទដ៏ច្រើនសន្ធឹកសន្ធាប់នេះគេបានកំណត់៣តំបន់សម្រាប់ការពារដូចជា

- តំបន់ទី១ ចំងាយ៣០ម ព័ទ្ធជុំវិញកំពែងខាងក្រៅ ឬក្រៅមាត់ស្រះ
- តំបន់ទី២ ចំងាយ៣០០ម ព័ទ្ធជុំវិញតំបន់ទី១
- តំបន់ទី៣ ចំងាយ១៥០០ម ព័ទ្ធជុំវិញតំបន់ទី២ ។




### ២.២. ប្រាសាទភ្នំជើងព្រៃ

ភ្នំជើងព្រៃដែលមានប្រវត្តិពីយូរលង់ណាស់មកហើយនោះ ឥឡូវនេះបានក្លាយទៅ ជារមណីដ្ឋានមួយដ៏សែនមនោរម្យសម្រាប់ បបោសអង្អែលអារម្មណ៍ភ្ញៀវទេសចរ។ អាស្រ័យដោយលក្ខណៈភូមិសាស្ត្រអំណោយផល ភ្នំជើងព្រៃស្ថិតនៅចម្ងាយប្រមាណ តែ ២គ.ម ប៉ុណ្ណោះពីផ្លូវជាតិលេខ៧ ជាប្រភេទផ្លូវគ្រួសក្រហម និង៥៦គ.ម ពីទីរួមខេត្តកំពង់ ចាមស្ថិតនៅក្នុងភូមិរវៀង ឃុំរវៀង ស្រុកជើងព្រៃ។

ប្រសិនបើគេចង់ទៅទីនោះ អ្នកទេសចរទាំងឡាយអាចធ្វើដំណើរ តាមរយៈ រថយន្តធុនតូច ដោយប្រើរយៈពេលតែមួយម៉ោងប៉ុណ្ណោះពីក្រុងកំពង់ចាម ។ ស្ទើរតែគ្រប់គ្នាអ្នក ដែលបានទៅដល់ ភ្នំជើងព្រៃគេមានជំនឿថាភ្នំនេះមានវត្ថុសក្តិសិទ្ធិ និងទេសភាពដ៏ត្រកាល ។ ប៉ុន្តែចំពោះអ្នកស្រុកនៅតំបន់នោះពួកគេមានជំនឿស៊ប់គោរព បូជាដោយការបន់ ស្រន់ ហើយនិងធ្វើពិធីលាបំណន់ជាញឹកញាប់ ។ ទោះបើមានការប្រកាន់ជាប់នូវជំនឿ ដូច្នេះដ៏ដោយក៏បច្ចុប្បន្នភ្នំជើងព្រៃនៅតែជារមណីដ្ឋានទេសចរណ៍មួយដែលប្រជាពលរដ្ឋគ្រប់ស្រទាប់តែងទៅកំសាន្តសប្បាយ ពេលមានពិធីបុណ្យទានធំៗ ដូចជាបុណ្យចូលឆ្នាំ ប្រពៃណីជាតិយើងជាដើម ។

តាមប្រសាសន៍ លោក អ៊ុច អ៊ីម ប្រធានការិយាល័យវប្បធម៌ស្រុកជើងព្រៃបាន ឲ្យដឹងថាសព្វថ្ងៃនេះ ភ្នំជើងព្រៃបានក្លាយទៅជារមណីដ្ឋានមួយដ៏សែនមនោរម្យ ព្រោះមានខ្យល់អាកាសល្អបរិសុទ្ធ ។ លោកបានបន្ថែមទៀតថា តាមការឲ្យដឹងពីចាស់ៗជំនាន់ មុនអ្នកដែលចង់ឡើងភ្នំជើងព្រៃ នេះពួកគេត្រូវសួរឡើងតាមវល្លិ៍ដែលដុះវារព័ទ្ធជុំវិញភ្នំ ។ លុះអំណេះតមក ពោលគឺនៅឆ្នាំ១៩៩៣ ភ្នំនេះក៏បានទទួលការរៀបចំកែលំអរជាថ្មីឡើង គិតរហូតមកដល់សព្វថ្ងៃអស់ទឹកប្រាក់ប្រមាណជា ១០០ លានរៀល ។

លោកមឿន មេត អាយុ ៨០ឆ្នាំ អ្នកមើលថែរក្សាភ្នំ និងជាគ្រូទស្សន៍ទាយ និងព្យាបាលជម្ងឺដែលល្បីថាឆុតឆាបនោះបានឲ្យដឹងថា តាមការកត់សម្គាល់អ្នកដែល មកដល់ភ្នំនេះ ភាគច្រើនពួកគេច្រើនមកពីភ្នំពេញ ហើយមានតែមួយចំនួនប៉ុណ្ណោះ ដែលមកពីទីរួមខេត្តកំពង់ចាម និងស្រុកក្បែរៗនេះ ។ ភាគ

ច្រើននៃអ្នកទាំងនេះមកដើម្បីស្វះស្វែងមើលជម្ងឺ ហើយនិងធ្វើការបន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិជាច្រើនដូចតាក្រហាមកជាដើម ។

តាមការស្រាវជ្រាវប្រវត្តិភ្នំជើងព្រៃនេះ អ្នកស្រុកមួយចំនួនបានតំណាលតៗគ្នាថា ភ្នំនេះចែកចេញជាពីរដាច់ពីគ្នា។ មួយស្ថិតនៅទិសខាងកើតហៅថាភ្នំស្រី ឬភ្នំធំ រីឯខាងលិចហៅថាភ្នំប្រុស ឬភ្នំព្រះបាទ ។

នៅលើភ្នំស្រីមានប្រាសាទបុរាណធ្វើអំពីថ្មបាយក្រៀម ដែលគេគ្រប់គ្នាដឹងថាជា ប្រាសាទភ្នំជើងព្រៃកសាងក្នុងស.វទី១២ ប៉ុន្តែបច្ចុប្បន្នត្រូវបានបំផ្លិចបំផ្លាញ បាក់បែកនៅសល់ប្រហែល៣០% ។ តាមរយៈចម្លាក់នៅលើផ្តែរ ប្រាសាទភ្នំជើងព្រៃនេះកសាងឡើង ដើម្បីឧទ្ទិសដល់ព្រហ្មញ្ញសាសនា ។ ប្រាសាទនេះមានទ្វាចូលចំនួនពីរ គឺខាងលិច និងខាងកើត ។ ប្រាសាទនេះពុំមានទ្វារបញ្ឆោតនោះទេ តែមានបង្អួច ពីរនៅសងខាងទ្វារចូលខាងកើត ។ នៅខាងមុខទ្វារចូលខាងកើតយើងឃើញមាន ជញ្ជាំងឥដ្ឋបែបជាសរសរអមសងខាង ទំនងជាសាងសង់សម័យក្រោយមកទេ ។ តាមការប៉ាន់ស្មានរបស់ខ្ញុំបាទគិតថា ប្រាសាទភ្នំជើងព្រៃនេះមានលក្ខណៈជាប្រាសាទមានរោងដូចដែលឃើញនាពេលបច្ចុប្បន្ននេះ តែរោងនោះទំនងជាសាងសង់ពីថ្មបាយក្រៀមដូចជាប្រាសាទ និងមានខ្លោងទ្វារ ប្រកបដោយដោយសរសរពេជ្រ និងផ្តែរចូលដ៏ស្រស់ស្អាត នេះបើតាមការសង្កេត ឃើញមានសរសរ និងផ្តែរនៅសេសសល់នៅលើនោះ ។ ទោះបីជាប្រាសាទនេះឧទ្ទិសដល់ ព្រហ្មញ្ញសាសនាក៏ពិតមែន ក៏ប៉ុន្តែបច្ចុប្បន្ននេះ ក្នុងប្រាសាទមានដំកល់នូវព្រះពុទ្ធរូបជាទីគោរពសក្ការៈរបស់ពុទ្ធបរិស័ទ្ធគ្រប់ទិសទី ដែលមកកាន់ទីដ្ឋានដ៏ពិសិទ្ធនេះ ។ នៅលើភ្នំស្រីនេះពីខាងមុខមានដានជើងមនុស្សលើផែនថ្ម អ្នកស្រុកហៅថា ដានជើងតាព្រេង ។ ចំណែកត្រង់ទិសឥសានមានដីរាបស្មើរធេង គេហៅថាកន្លែង យុនឆាង ។ ទិសបច្ចិមគុកគុហា មានរន្ធថ្មមួយប៉ុនប្រាក់រៀល គេហៅថារន្ធឡូតាព្រេង ។ ម៉្យាងវិញទៀត ជុំវិញបរិវេណភ្នំនោះមានកំពែងធ្វើដោយ ថ្មបាយក្រៀមដែលមួយដុំៗមានទំហំ ៤មx៦ម ។ តាមចាស់ បុរាណ កំពែងថ្មនេះ លោកថាមានដល់ទៅ៧ជាន់ ដែលជាស្នាដៃបុព្វបុរសយើងកសាង ។ សព្វថ្ងៃនេះ កំពែងបែកបាក់អស់នៅសល់តែដុំៗតែប៉ុណ្ណោះ ។

ភ្នំស្រី ឬភ្នំធំនេះមានជណ្តើរឡើង ៣ ពីទិសខាងជើង ខាងត្បូង និងខាងកើត ដែលមានកំពស់ប្រមាណ ៥០ម ។ ចំណែកខាងភ្នំប្រុស ឬភ្នំព្រះបាទមានកំពស់៣០ម រថយន្ត អាចឡើងដល់កំពូលភ្នំបានមូលហេតុដែលគេហៅថាភ្នំព្រះបាទគឺដោយសារមានពុទ្ធបាទ ដែលបានបន្សល់ដល់បច្ចុប្បន្ននេះ ។ គួរឲ្យឆ្ងល់ណាស់ថា នៅលើភ្នំស្រីមាន ប្រាសាទបុរាណដែលឧទ្ទិសដល់ព្រហ្មញ្ញសាសនា ប៉ុន្តែនៅលើភ្នំស្រីបែរជាមានពុទ្ធបាទ តាំងពីបុរាណបានបន្សល់នៅលើភ្នំប្រុសនោះទៅវិញ ម៉្យាងវិញទៀត គេសង្កេតឃើញថាមានផ្តែរ ប្រាសាទនៅលើភ្នំប្រុសនោះផងដែរ ដូច្នេះមានន័យថា នៅលើភ្នំប្រុស ក៏មានប្រាសាទមួយផង

ដែរ ។ តាមការសន្និដ្ឋានរបស់ខ្ញុំបាទគិតថា ប្រាសាទនៅលើ ភ្នំប្រុស នោះក៏ទំនង ជាសាងសង់ដើម្បីឧទ្ទិសដល់ព្រហ្មញ្ញសាសនាផងដែរ តែដោយសារការបាក់ បែកខ្ទេចខ្ទាំ ឬដោយសារវិវាទសាសនា ? ធ្វើឲ្យពុទ្ធបរិស័ទកសាង ព្រះវិហារនៅលើ ភ្នំនោះវិញ ហើយកសាងពុទ្ធបាទជាទីគោរពបូជា ។ យ៉ាងណាមិញ ពុទ្ធបាទនោះមិនមែន ទើបតែ កសាងនោះទេ តែប្រហែលជាកសាងនៅក្នុងសម័យ អង្គរ រឺក្រោយអង្គរមកម្លេះ(សម័យលង្វែក?) ។ ដោយសារការខ្វះខាតនូវចំណេះដឹង និងឯកសារធ្វើឲ្យការសន្និដ្ឋានរបស់ខ្ញុំបាទពុំប្រាកដថាត្រឹមត្រូវនោះឡើយ ប្រសិនមានឱកាស ឬមានអ្នកស្រាវជ្រាវណាបានស្វែងរកឫសគល់នៃប្រាសាទនេះ ប្រាកដជាល្អជាក់ជាពុំខានត្បិតសមត្ថភាពរបស់យើងខ្ញុំ នៅមានកម្រិតនៅឡើយ ។ ក្នុងនោះដែរ រវាងភ្នំទាំងពីរនេះ មានចម្ងាយពីគ្នា៥០០ម ។ ឧបាសក ឧបាសិកាដែលមានជំនឿមុតមាំលើផ្លូវព្រះពុទ្ធសាសនា តែងតែនាំយកទឹកទៅចាក់ ត្រង់ស្នាមព្រះបាទ នៅលើផ្ទាំងសិលាធំ លុះទឹកនោះហូរហៀរមកវិញ គេយកផ្តិល ឬចាន ត្រងយកទៅផ្ទះទុកផ្ញើរកូនចៅ គ្រាន់បានលុបមុខ និងទទួលទាន ។

គេបាននិយាយថា កាលដើមឡើយមនុស្សស្រីនិងប្រុសបានភ្នាល់គ្នាលើកភ្នំនេះ ដូចរឿងភ្នំប្រុសភ្នំស្រីនៅកំពង់សៀមដែរ ប្លែកតែខាងភ្នំជើងព្រៃនេះរណ្តៅដីនៅភ្នំស្រី ដែលស្រីៗជីកយកមកធ្វើភ្នំក្លាយទៅជាស្រះធំមួយ មានទឹកខួបប្រាំងខួបវស្សា ហៅថាស្រះទឹកព្រះ ។ រីឯរណ្តៅនៅជិតភ្នំប្រុស ដែលខាងប្រុសជីកយកដីមកធ្វើជា ភ្នំក្លាយទៅជាស្រះធំមួយដែរ ប៉ុន្តែគ្មានទឹកខួបប្រាំងខួបវស្សាឡើយ ហើយគេឲ្យឈ្មោះថាស្រះកំពែងស្ងួត ។

សព្វថ្ងៃនេះស្រះទឹកព្រះនៅល្អដូចដើម និងមានទឹកថ្លាឆ្វេងជាទីអាស្រ័យនៃពួកមច្ឆាជាតិ និងមានផ្កាឈូកដុះរីកស្គុះស្គាយដេរដាស ប្រៀបបាននឹងបឹងតូចមួយ គួរជាទីគយគន់ ក្រៃលែង។ រីឯរណ្តៅ ដីដែលប៉ែកខាងបុរស ជីកយកមកធ្វើភ្នំហើយក្លាយ ទៅជាស្រះមួយធំ ឈ្មោះកំពែងស្ងួតនោះមានទំហំប្រមាណ១០០ម បួនជ្រុងស្មើមិនដែលមាន ទឹកទេ ទោះបីខែវស្សាមានភ្លៀងធ្លាក់ខ្លាំងយ៉ាងណាក៏ដោយ ។ គួរឲ្យឆ្ងល់ណាស់ស្រះ ទាំងពីរនេះ ស្ថិតនៅឆ្ងាយពីគ្នាមិនដល់១០០មផង ម៉េចក៏ស្រះមួយមាន ទឹកមិនចេះរីង ឯស្រះមួយទៀតរីងមិនចេះមានទឹកដូច្នេះ ។ ប៉ុន្តែតាមការដំណាលរបស់លោកតាៗ បានឲ្យដឹងថាការដែលស្រះ ខាងប្រុសស្ងួតដូច្នេះ ព្រោះត្រូវបណ្តាសារបស់ពួកស្រីៗ ។ នៅខាងទិសពាយ័ព្យ ជិតស្រះទឹកព្រះមានកូនស្រះមួយតូចទំហំ៥០ម បួនជ្រុង ជម្រៅ៤ម គេហៅថាស្រះលាងជើង ព្រោះមុនពេលឡើងភ្នំគេតែងទៅលាងជើងនៅស្រះនោះ។



## ៣. ស្ថាបត្យកម្មសម័យអង្គរ

ជាទូទៅស្ថាបត្យកម្មនៅសម័យអង្គរប្រាសាទមួយចំនួនភាគច្រើនប្រើប្រាស់រចនាបទចំនួន៩ ដែលមានដូចជា រចនាបទអង្គរ រចនាបទព្រះគោ រចនាបទបាខែង រចនាបទកោះកេ រចនាបទបន្ទាយស្រី រចនាបទបាពួន រចនាបទឃ្លាំង និងរចនាបទបាយ័ន ។

នៅក្នុងចំនុចខាងក្រោមនេះ យើងនិងធ្វើការលើកឡើង ពីរចនាបទអង្គរ និងរចនាបទបាយ័ន ដែលនិងសិក្សាលម្អិត ហើយរចនាបទបន្តបន្ទាប់ទៀតដូចខាងក្រោម ៖

### ៣.១. រចនាបទអង្គរ

រចនាបថនេះ ស្ថិតនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ក្នុងនោះដែរយើងនិងលើកពីប្រាសាទអង្គរវត្ត មកបង្ហាញជូនជ្រាបជាលំដាប់។ ប្រាសាទអង្គរវត្ត ឬ អង្គរតូច ត្រូវបានកសាងឡើងនៅដើមសតវត្សទី១២(១១១៣-១១៥០)នៅយសោធរបុរៈ (បច្ចុប្បន្នស្ថិតក្នុងខេត្តសៀមរាប) ដោយព្រះបាទសូរ្យវរ្ម័នទី២ និងបញ្ចប់ដោយព្រះបាទជ័យវរ្ម័នទី៧ ។

#### ក. អំពីស្ថាបត្យកម្ម

ប្រាសាទនេះមានកម្ពស់៦៥ម៉ែត្រមានក្រឡាផ្ទៃប្រហែល ២០០ ហិចតារាងចតុកោណដែលកំណត់ដោយកំពែងព័ទ្ធជុំវិញ និងគូទឹកដែលមានទទឹង ២០០ ម៉ែត្រ ។ បរិវេណនៃកំពែង គឺ មានប្រវែងប្រហែល ៥,៥គ.ម ។ ផ្លូវចូលធ្វើអំពីថ្មភក់មានប្រវែងបណ្តោយ ២៥០ម៉ែត្រ និងទទឹង១២ម៉ែត្រ ។ ដោយសារតែទំហំដ៏ធំនិងស្ថាបត្យកម្មដ៏អស្ចារ្យនេះ មានមនុស្សមួយចំនួនគិត ថាប្រាសាទអង្គរវត្ត មិនមែនជាស្នាដៃរបស់មនុស្សទេ គឺជាស្នាដៃរបស់អាទិទេព ។




នៅខាងមុខផ្លូវចូលមានគោថ្មធំៗឈរយាមនៅអមសងខាងផ្លូវ ។ នៅខាងចុងនៃផ្លូវចូលនោះ មានគោបុរៈប្រាង្គបី ដែលមានកម្ពស់ខុសគ្នា ហើយប្រាង្គផ្នែកខាងលើត្រូវបានដួលរលំហើយ ។ នៅគោបុរៈនោះមានថែវដែលមានកំពូលជារូត ។

**ខ. ថែវខាងលើនៅអង្គរវត្ត**

បន្ទាប់ពីគោបុរៈមក គឺ មានផ្លូវមួយដែលមានប្រវែងបណ្ដោយ ៣៥០ម៉ែត្រនិងទទឹង ៩ ម៉ែត្រទទឹង ៩ម៉ែត្រធ្វើពីថ្មភក់ និង បង្កាន់ដៃនាគនៅអមសងខាង ។

ប្រាសាទនេះ គឺជាតំណាងនៃភ្នំព្រះសុមេរុលំនៅនៃពួកទេវៈជួរចតុរង្គចំកណ្ដាលនៃប្រាង្គជាសញ្ញាសំគាល់កំពូលទាំងប្រាំនៃភ្នំ ហើយជញ្ជាំង និងគូទឹកជាជួរភ្នំព័ទ្ធជុំវិញ និងមហាសមុទ្រ ។

អង្គរវត្ត គឺបែរមុខទៅទិសខាងលិចផ្ទុយពីប្រាសាទផ្សេងបែរទៅទិសខាងកើត ។ នេះបាននាំមកនូវហេតុជាច្រើនរួមមាន ហ្គ្លេសហ្ស៊ី និង ហ្សក-សឺដេស សន្និដ្ឋានថាព្រះបាទសូរ្យវរ្ម័ន បានបម្រុងទុកវាសម្រាប់ជាប្រាសាទបញ្ចុះព្រះសពរបស់ទ្រង់ ។ ភស្តុតាងបន្ថែមទៀតចំពោះការមើលឃើញដូចនេះត្រូវបានផ្ដល់ដោយចម្លាក់លៀនស្រាលៗដែលបានធ្វើតាមក្បួនទិសដៅ ប្រឆាំងនឹងទក្ខិណាវដ្ត-ប្រសវ្យៈជាយត្តសព្វវិជ្ជាហិណ្ឌូ- ដូចនេះគឺជាការបញ្ច្រាសនៃរបៀបធម្មតា។ ក្បួនវីត័ជា ច្រើនប្រារព្ធក្នុងរបៀបបញ្ច្រាស់កំឡុងសេវការបុណ្យសពព្រហ្មញ្ញ ។ បុរាណវិទូ ឆាលអឺស-ហាយអ៊ែម ក៏បានពិពណ៌នានូវអ្វីនៅខាងក្នុងដែល ប្រហែលជាក្រឡបញ្ចុះសពដែលត្រូវបានគេយក មកមកពីប្រាង្គប៉មកណ្ដាល ។ វាត្រូវបានគេហៅដោយអ្នកខ្លះ ថាជាការចំណាយ កម្លាំងច្រើន បំផុតលើសាកសពមួយដែលគេបោះបង់ចោល ។ ហ្វ្រីម៉ឺន និងចាខ យ៉ាងណាក៏ដោយកត់សម្គាល់ថា ប្រាសាទអង្គរផ្សេងៗ ជាច្រើន បែរមុខចេញពីទិសខាងកើតជាធម្មតា និងផ្ដល់យោបល់ថាការបង្វែរស់អង្គរវត្ត គឺដោយសារការឧទ្ទិសរបស់ប្រាសាទដល់ព្រះវិស្ណុដែលព្រះអង្គរាប់ អាននឹងទិសខាងលិច ។

**គ. បច្ចេកទេសស្ថាបត្យកម្ម**

ថ្មមួយចំនួនរលោងដូចជាថ្មពពាល ដែលបានប៉ូលាហើយត្រូវបានដាក់ដោយគ្មានបាយអជាមួយតំណយ៉ាងតឹងដែលជូនកាលពិបាករក ។ ដុំថ្មបូនជ្រុងៗជាច្រើន ត្រូវបានដាក់រួមគ្នាដោយតំណរប្រហោងដំណាប់និងពន្លួញក្នុងករណីខ្លះកាលណោះដែរ ក្នុងករណីផ្សេងៗទៀតបានប្រើកន្ទុយលលក និងទំនាញដី ។ ដុំថ្មខ្លះត្រូវបានដាក់នៅកន្លែងដោយក្តីសន្និដ្ឋានតាមការផ្សំគ្នានៃពួកដំរី ពូរ ស្រកីដក់រ៉ក និងការធ្វើរន្ធាឬស្សី ។ ប្រាង់រីមហ៊ិត បានកត់សម្គាល់ថាភាគច្រើននៃដុំថ្មមានរន្ធ២,៥សម ជាអង្កត់ ផ្ចិត និងជម្រៅ៣សមជាមួយរន្ធជាច្រើនទៀតលើដុំថ្មបូនជ្រុងធំៗ ។ ពួកអ្នកប្រាជ្ញ ខ្លះបានឲ្យយោបល់ថាទាំងនេះត្រូវបានប្រើចូលរួមគ្នាជាមួយដំបងដែកជាច្រើន ប៉ុន្តែអ្នកផ្សេង ទៀងអះអាងថារបស់នឹងត្រូវបានប្រើដើម្បីកាន់ស្នៀតជាបណ្តោះអាសន្នដើម្បីជួយហត្ថកិច្ចថ្មទាំងនោះចូលទៅកាន់កន្លែង ។

បូជនីយដ្ឋាននេះ ត្រូវបង្កើតចេញដោយចំនួនដ៏សម្បើមនៃថ្មភក់ច្រើនដូចគ្នា នឹងសាជីរបស់ខាបផ្រានៅអេហ្ស៊ីប(ជា៥ លានតោន) ។ ថ្មភក់នេះបានដឹកជញ្ជូនពីភ្នំគូលែនកន្លែងយកថ្មប្រហែល២៥ម៉ាយ (៤០ គ.ម) ទៅទិសឦសាន ។ ថ្មតាមសេចក្តីសន្និដ្ឋានត្រូវបានដឹកជញ្ជូនដោយក្បូនបណ្តោយស្ទឹងសៀមរាប ។ រឿងនេះនឹងត្រូវបានធ្វើឡើងជាមួយការប្រុងប្រយ័ត្នដើម្បីចៀសវាងការ ក្រឡាប់ក្បូនរួមជាមួយទម្ងន់មួយចំនួនធំ ។ វិស្វករទំនើបម្នាក់បានប៉ាន់ប្រមាណថាវានឹងចំណាយ ពេល៣០០ឆ្នាំដើម្បីបង្ហើយអង្គរវត្តសព្វថ្ងៃនេះ ។ ប៉ុន្តែបូជនីយដ្ឋាននេះត្រូវបានចាប់ផ្តើមភ្លាម បន្ទាប់ ពីវបានចាប់ផ្តើមភ្លាមបន្ទាប់ពីសូរ្យវរ្ម័នឡើងសោយរាជ្យ និងត្រូវបានបញ្ចប់រយៈពេលខ្លីក្រោយការសោយទីវង្គតរបស់ទ្រង់មិនច្រើនជាង៤០ឆ្នាំ ។

### ឃ.អំពីរចនាបថ

អង្គរវត្តជាគំរូដំបូងនៃរចនាបថបុរាណនៃស្ថាបត្យកម្មខ្មែរ —រចនាបថអង្គរវត្ត— ដែលវាបានដាក់ឈ្មោះតាមប្រាសាទនេះ។នៅសតវត្សទី១២ ពួកស្ថាបត្យករខ្មែរធ្លាប់មានជំនាញ និងទំនុកចិត្តក្នុងការប្រើប្រាស់ថ្មភក់ (ផ្ទុយពីឥដ្ឋ រឺ ថ្មបាយក្រៀម )សម្ភារៈសាងសង់សំខាន់ ។ ភាគច្រើនទី ដែលមើលឃើញ គឺជាដុំថ្មភក់ ដែលពេលនោះថ្មបាយក្រៀមត្រូវបានប្រើសម្រាប់កំពែងខាងក្រៅ និងសម្រាប់ផ្នែកខ្លះនៃរចនាសម្ព័ន្ធសំណង់ដែលបានលាក់កំបាំង ។ ភ្នាក់ងារដែលរុំភ្ជាប់បាន ប្រើប្រាស់ដើម្បីចូលរួមទៅជាដុំៗ តែមិនទាន់បានគេដឹងនៅឡើយថ្វីបើជ័រឈើធម្មជាតិ ឬកំបោរប្រេង ត្រូវបានគេលើកឡើងក៏ដោយ ។ តាមស្ថាបត្យកម្មចរិកលក្ខណៈធាតុជាច្រើននៃរចនាបថនេះ រួមមានប្រាង្គប៉មរាងក្បាលទូកបុនទន្ត ដែលមានរាងដូចជាត្របកឈូកច្រើន កន្លះ-ថែវពង្រីកផ្លូវរបៀងថែវអ័ក្សភ្ជាប់ទៅនឹង របងព័ទ្ធជុំវិញនិងលានរាងកាក បាទដែលលេចឡើងតាមបណ្តោយអ័ក្សធំនៃប្រាសាទ ។ ធាតុផ្សំតុបតែងជាធម្មតាគឺទេវតា(រឺអប្សរា) ចម្លាក់ លៀន

ស្រាលៗ និងនៅលើកម្រងផ្កាភ្ញីធំសន្ធឹងរបស់ហោជាង និង ឈុតឆាកនិទានកថា ។ រូបចម្លាក់បដិមានៃអង្គរវត្តត្រូវបានចាត់ចែងទុកអភិរក្សកំពុងនៅដដែល និងមិនសូវមាំមួនជាងស្នាដៃដើមដំបូងឡើយ ។ ធាតុសំខាន់ផ្សេងទៀតនៃការរចនាត្រូវបានគេបំផ្លិចបំផ្លាញដោយការលួចឆក់ប្លន់ និងការកន្លងទៅនៃពេលវេលារួមមានការបូកពាសស្រោបមាស លើប៉មប្រាង្គដោយការស្រោបមាសលើរូបចម្លាក់លើ ចម្លាក់លផនស្រាលៗ និងបន្ទះពិតានឈើ និងទ្វារនានា ។

<u>រូបភាពប្រសាទអង្គរវត្ត ដោយថតពីលើយន្តហោះ</u>



កំពែងខាងក្រៅ ១០២៤ គុណនឹង៨០២ម និងកំពស់ ៤,៥ម ព័ទ្ធជុំវិញដោយលាននៃវាលបើក ៣០ម និងគូទឹកមួយបណ្តោយ ១៩០ម ។

ច្រកចូលទៅប្រាសាទនេះ គឺនៅក្បែរច្រាំងដីនៅខាងកើត នឹងផ្លូវកាត់ទឹកធ្វើពីថ្មភក់ទៅខាងលិចនៅខាងចុងច្រកចូលធំ គឺជាការបន្ថែមចុងក្រោយ ប្រហែលជាជំនួសឲ្យស្ពានឈើ ។

ខាងក្រោយប្រាង្គខាងត្បូងមានរូបចម្លាក់ព្រះវិស្ណុមួយអង្គដែលគេស្គាល់ថា តារាជ ដែលប្រហែលដើមឡើយបានស្ថិតនៅកន្លែងសក្ការៈបូជាកណ្តាលនៃប្រាសាទ ។ ថែវជាច្រើនរត់នៅចន្លោះ ប្រាង្គនានា និងឆ្ងាយរហូតដល់ច្រកចូលពីរថែមទៀតនៅខាងណាមួយនៃគោបុរៈជារឿយៗ ចាត់ទុកថាជាច្រកដំរី តាមដែលច្រក នោះមានទំហំល្មមដើម្បីអោយសត្វទាំងនោះចូលបាន ។

ថែវទាំងនេះមានសសរបួនជ្រុងនៅខាងក្រៅ(ខាងលិច) និងជញ្ជាំងបិទជិតនៅខាងក្នុង (ខាងកើត) ។ ពិដានចន្លោះសសរទាំងនោះ តុបតែងដោយត្របកឈូក ផ្ទៃនៃជញ្ជាំងខាងលិចមានរូបចម្លាក់អេរាំ និងផ្ទៃជញ្ជាំងខាងកើតមានបង្អួចមានជើងទៀន រូបចម្លាក់ប្រុសកំពុងតែរាំលើសត្វ ដែលកំពុងលោតកញ្ឆោង

ហើយ និងអប្សរាដែលរួមមាន(ខាងត្បូងនៃច្រកចូល) តែមួយក្នុងប្រាសាទនេះកំពុងតែបង្ហាញធ្មេញរបស់នាង ។

កំពែងខាងក្រៅព័ទ្ធជុំវិញបរិវេណ ៨២០០០០មាត្រការ៉េ (២០៣ អេកឺរ) ដែលម្យ៉ាងទៀត ប្រាសាទកណ្តាលត្រូវបានកាន់កាប់ដោយទីក្រុងនេះតាំងពីដើមនិងនៅខាងជើងប្រាសាទនេះគឺ ព្រះបរមរាជវាំង ។ ដូចសំណង់មិនទាក់ទងសាសនាទាំងអស់នៃអង្គរដែលទាំងនោះ ត្រូវបានសាងសង់ឡើងដោយសម្ភារៈដែលអាចខូចបានខុសពីថ្ម ដូច្នោះគ្មានអ្វីសេសសល់ក្នុងចំណោមនោះទេ លើកលែងតែគ្រោងខ្សែក្រៅនៃផ្លូវខ្លះៗ ។ ភាគច្រើនបំផុតនៃតំបន់មួយនេះឥឡូវត្រូវបានគ្របដណ្តប់ដោយព្រៃឈើ ។ ផ្លូវឆ្លងកាត់ទឹក ៣៥០ម មួយភ្ជាប់ទៅគោបុរៈខាងលិចទៅកាន់ប្រាសាទកណ្តាលដែលមានបង្កាន់ដៃនាគ និងកាំជណ្តើរប្រាំមួយខ្សែនាំចុះទៅកាន់បុរីនៅខាងម្ខាងណាមួយ ។

ចំហៀងនីមួយៗ ក៏បង្ហាញឡើងនូវបណ្ណាល័យមួយដែលមានច្រកចូលមួយចំនួននៅក្នុងច្រកសំខាន់នីមួយៗ នៅចំពីមុខនៃកាំជណ្តើរខ្សែទីបីពីច្រកចូល និងស្រះមួយនៅចន្លោះបណ្ណាល័យ និងប្រាសាទនេះ ។ ស្រះជាច្រើនគឺជាការបន្ថែមក្រោយៗ ចំពោះការរចនាដូចជាលានរាងកាកបាទដែលបានយាមដោយតោភ្ជាប់ទៅនឹងច្រកឆ្លងកាត់ទឹកទៅរចនាសម្ព័ន្ធសំណង់កណ្តាល ។

គំរូតូចៗនៃរចនាសម្ព័ន្ធសំណង់កណ្តាលនៃអង្គរវត្ត ។ នៅផ្នែកខាងមុខលានរាងកាកបាទដែលសណ្តូកនៅខាងមុខនៃរចនាសម្ព័ន្ធសំណង់កណ្តាល ។ ប្រាសាទនេះតាំងនៅលើលានមួយដែលបានលើកខ្ពស់ជាងបុរីនេះ ។ វាត្រូវបានបង្កើតឡើងដោយថែវចតុកោណកែងបីដើបឡើងដល់ប្រាង្គ កណ្តាលកំពស់នីមួយៗខ្ពស់ជាងប្រាង្គមួយចុងក្រោយគេ ។ មែនិកាបកស្រាយថែវទាំងនេះថាជាការបូជាទៅដល់ព្រះមហាក្សត្រព្រះព្រហ្មព្រះចន្ទ និងព្រះវិស្ណុ ។ ថែវនីមួយៗមានគោបុរៈមួយនៅចំណុចនីមួយៗ ហើយនិងថែវខាងក្នុងពីរមានប្រាង្គនៅកាច់ជ្រុងរបស់ខ្លួន ដែលបង្កើតឡើងនូវជួរចតុរង្គដែលមានប្រាង្គនៅចំកណ្តាល ។ ពីព្រោះតែប្រាសាទបែរមុខទៅទិសខាងលិចលក្ខណៈពិសេសទាំងអស់បានកំណត់បែរឆ្ពោះទៅខាងកើតដែលបន្សល់ទុកទីលំហ បន្ថែមទៀតដែលត្រូវបានបំពេញនៅ ក្នុងវាំងចំណារនីមួយៗ និងថែវនៅចំហៀងខាងលិច ចំពោះហេតុផលដដែលកាំជណ្តើរបែរមុខទៅខាងលិចរាក់ជាងកន្លែងផ្សេងនៅខាងផ្សេងៗទៀត។

ថែវខាងក្រៅនេះ១៨៧គុណ២១៥ម ជាមួយសាលាសំណាក់ខុសពីប្រាង្គនានានៅកាច់ជ្រុង។ ថែវនេះចំហទៅខាងក្រៅនៃប្រាសាទដែលមានកន្លះថែវច្រើនមានសសរលាតសន្ធឹង និងជន្ទល់សំណង់នេះ ។ ភ្ជាប់ទៅនឹងថែវខាងក្រៅទៅកាន់វាំងចំណារទីពីរលើចំហៀងខាងលិច គឺជារបៀងរាងកាកបាទហៅថាព្រះ

ពាន់(សាល) ។ ពុទ្ធបដិមាធ្លាប់នៅខាងឆ្វេងនៅក្នុងរបៀងនោះដោយពួកអ្នកធម្មយា ត្រាអស់ជាងច្រើនសតវត្សទោះបីភាគច្រើនឥឡូវត្រូវបានដកចេញក៏ដោយ ។ ទីនេះមានអក្សរចារឹកច្រើនដែលទាក់ទងនឹងទង្វើល្អ នៃពួកអ្នកធម្មយាត្រាភាគច្រើនបានសរសេរភាសាខ្មែរប៉ុន្តែផ្សេងទៀតជាភាសាភូមា និងជប៉ុន។ ធ្លារបៀងតូចៗទាំងបួនគូសចេញដោយរបៀងនេះដើមឡើយត្រូវបានពេញប្រៀបដោយទឹក ។ ខាងជើងនិងខាងត្បូងនៃរបៀងនេះគឺជាបណ្ណាល័យ ។ ថែវទីពីរនិងខាងក្នុងត្រូវបានភ្ជាប់គ្នា និងទៅកាន់បណ្ណាល័យចំហៀងពីរក្បែរលានរាងកាកបាទមួយផ្សេងទៀតម្តងទៀតការបន្ថែមក្រោយមកទៀត ។ ចាប់ពីជាន់ទីពីរទៅលើ ពួកទេវតាមានច្រើនលើជញ្ជាំង ដោយច្រៀង ឬជាក្រុមរហូតដល់បួនអង្គ ។ វាំងចំណារជាន់ទីពីរគឺ ១០០គុណនឹង១៥ម ហើយដើមឡើយប្រហែលអាចត្រូវបានជោរជន់ដើម្បីតំណាងឱ្យមហាសមុទ្រព័ទ្ធជុំវិញភ្នំព្រះសុមេរុ ។ ជណ្តើរបីឈុតនៅម្ខាងៗនាំ ឡើងទៅដល់ប្រាង្គប៉ម និងគោបុរ:នៅកាច់ជ្រុងនៃថែវខាងក្នុងគេ ។ ផ្លូវជណ្តើរចោទណាស់តំណាង អោយភាពលំបាកនៃការឡើងទៅនគរពួកទេវ: ។ ថែវខាងក្នុងនេះហៅថាបាកានគឺ៦០ម.ការ៉េដែល មានថែវអ័ក្សជាច្រើនភ្ជាប់នឹងគោបុរ:នីមួយជាមួយទីសក្ការ:បូជានៅកណ្តាល ហើយនិងទីសក្ការ: បូជាបន្តបន្ទាប់នៅខាងក្រោមប្រាង្គប៉មនៅកាច់ជ្រុង។

ការប្រក់ដំបូលថែវត្រូវបាន តុបតែងជាមួយក្បាច់ក្បូរនៃខ្លួនពស់ដែលនៅចុងនៃក្បាលតោ ឬគ្រុឌ ។ ធ្នឹម និងហោជាងដែលបានឆ្លាក់តុបតែងច្រកចូលទៅថែវ និងទីសក្ការ:បូជា។ ប្រាង្គខាងលើទីសក្ការ:បូជាកណ្តាលងើបរះឡើង ៤៣ម.ដល់កម្ពស់៦៥ម.ពីលើដីមិនដូចប្រាសាទភ្នំទាំងប៉ុន្មានមុនៗ នោះឡើយប្រាង្គកណ្តាលគឺត្រូវបានផុសឡើងលើប្រាង្គបួនដែលព័ទ្ធជុំវិញ ។ ទីសក្ការ:បូជាខ្លួនឯង ដើមឡើយបានតម្កល់នៅរូបចម្លាក់ព្រះវិស្ណុនិងបើកទូលាយ នៅគ្រប់ខាងត្រូវបានព័ទ្ធជញ្ជាំងនៅខាង ក្នុងនៅពេលនោះប្រាសាទនេះ ត្រូវបានប្រែមកសម្រាប់ព្រះពុទ្ធសាសនាថេរវាទវិញជញ្ជាំងថ្មីរំលេច នូវព្រះពុទ្ធអង្គជាច្រើនកំពុងឈរ។

នៅឆ្នាំ១៩៣៤អ្នកអភិរក្សហ្សកហ្ស៊ី-ធូរ៉េ បានជីកលុងរណ្តៅនៅខាងក្រោមទីសក្ការ:កណ្តាល នេះបានពេញជាមួយខ្សាច់ និងទឹក បានត្រូវគេលួចឆក់ប្លន់រតនសម្បត្តិក្នុងនោះរួចអស់ទៅហើយ ប៉ុន្តែលោកខំស្វែងរកគ្រឹះពិសិដ្ឋិមួយទុកនូវសន្លឹកមាសពីរមាត្រលើជាន់ផ្ទាល់ដី ។

**ខ. ចម្លាក់ថែវនៅលើជញ្ជាំងប្រាសាទអង្គរវត្ត**

ចម្លាក់ថែវដែលព័ទ្ធជុំវិញប្រាសាទអង្គរវត្តនៅជាន់ទី១ ជាចម្លាក់លើថ្មភក់មានទំហំ ១,២០០ ម៉ែត្រការេ ។ ចម្លាក់នោះចែកជា ៨ផ្ទាំង និង ២ ផ្ទាំង នៅពន្លាជ្រុងនៃថែវខាងលិច។ សាច់រឿងនៃចម្លាក់នោះចាប់ផ្តើមតាមជួរដេកតាមជញ្ជាំងពីឆ្វេងទៅស្តាំ ។ នៅកន្លែងខ្លះមានព្រំផងដៃរសាច់រឿងនោះត្រូវបាន

រៀបចំតាមរបៀបគឺដាច់ពីគ្នាឬស្ថិតនៅពីលើគ្នា ។ ចម្លាក់នេះត្រូវមើលពីឆ្វេងទៅស្តាំ ។ អ្នកទស្សនាគួរដើរមើល ដោយចូលតាមច្រកកណ្តាលខាងលិច រួចបត់ស្តាំ និង ដើរជុំវិញ ។ ចម្លាក់ទាំងនោះរួមមានៈ

(១) ថែវខាងលិច(ត្បូង) : បង្ហាញពីចម្បាំងរបស់គូរុសាត្រា (មហាភារតៈ) ។

(២) ពន្លាជ្រុង(និរតី) : បង្ហាញពី ឆាកនៃរឿងរាមកេរ្តិ៍ ។

(៣) ថែវខាងត្បូង(លិច) : បង្ហាញពីព្យុហយាត្រារបស់ព្រះបាទសូរ្យវរ្ម័នទី២ ។

(៤) ថែវខាងត្បូង(កើត) : បង្ហាញពីរឿងឋានសួគ៌ និង ឋាននរក ។

(៥) ថែវខាងកើត(ត្បូង) : បង្ហាញពីរឿងកូរសមុទ្រទឹកដោះ ។

(៦) ថែវខាងកើត(ជិតផ្លូវចូល) : ជាសិលាចារិក ។

(៧) ថែវខាងកើត(ជើង) : បង្ហាញពីជ័យជំនះរបស់ព្រះវិស្ណុ លើពួកអសុរៈ ។

(៨) ថែវខាងជើង(កើត) : បង្ហាញពីជ័យជំនះរបស់ក្រឹស្ណៈ និង បាណ្ណៈ ។

(៩) ថែវខាងជើង(លិច) : បង្ហាញពីចម្បាំងរវាងទេវតា និងពួកអសុរៈ ។

(១០) ពន្លាជ្រុង(ពាយព្យ) : បង្ហាញពីឆាកនៃរឿងរាមកេរ្តិ៍ ។

(១១) ថែវខាងលិច(ជើង) : បង្ហាញពីចម្បាំងនៅក្រុងលង្កា(រឿងរាមកេរ្តិ៍) ។

### ៣.២. ស្រះស្រង់

ស្រះស្រង់មានទីតាំងស្ថិតនៅទល់មុខខាងកើតប្រាសាទបន្ទាយក្តី ។ ស្រះនេះកសាងឡើងនៅចុងសតវត្សរ៍ទី១២ ដោយព្រះបាទជ័យវរ្ម័នទី៧ ។ ស្រះនេះមានទំហំប្រវែង ៧០០x៣០០ ម៉ែត្រ ដែលមានរានហាលដ៏ស្រស់ស្អាត។ ស្រះនេះសាងសង់តែងតែមានទឹកជាប់ជានិច្ច និង មានទេសភា ពស្រស់បំព្រងព័ទ្ធជុំវិញ ។ ស្រះនេះបានសាងសង់ឡើងពីថ្មភក់និងថ្មបាយក្រៀម ។ រានហាលនៅ ស្រះស្រង់មានរាងកាកបាទដែលមានបង្កាន់ដៃនាគ និងមានតោឈយាមផ្លូវ ។

(SRAH SRANG Khmer: ស្រះស្រង់)



### ៣.៣. បារាយណ៍ទឹក

យ៉ាងណាមិញ ទីក្រុង ឬបុរៈ ក៏តម្រូវឲ្យមានតតាកៈ ឬបារាយណ៍ ដែលជាទំនប់ទឹក ផ្លូវគមនាគមន៍ សាលាឆទាន ឬអរោគ្យសាលា (មន្ទីរពេទ្យសម្រាប់ព្យាបាលជម្ងឺ) អ្វីមួយដែលជាសេចក្តីត្រូវការរបស់ប្រជានុរាស្ត្រខ្មែរគ្រប់មជ្ឈដ្ឋាន ក្នុងសង្គមជាតិ មានការគ្រប់គ្រង អភិបាលកិច្ចល្អ ។ ព្រះរាជកាតព្វកិច្ចសំខាន់ជាងគេបំផុតរបស់ព្រះមហាក្សត្រខ្មែរទាំងឡាយនាសម័យអង្គរ ក៏ដូចជាសម័យរប្បធមិមុនៗ គឺការជីកបារាយណ៍ ឬតតាកៈ នៅក្នុងទីក្រុងនានា ដែលទ្រង់គ្រប់គ្រង ។ ជាឧទាហរណ៍ជាក់ស្តែង ឥន្ទ្រតតាកៈ នៅទីក្រុងរលួស, យសោធរតតាកៈ នៅយសោធរបុរៈ បារាយណ៍ខាងលិច និងបារាយណ៍ខាងកើត ឬជយតតាកៈ ត្រូវបានស្ថាបនាឡើងនៅតំបន់សៀមរាបអង្គរដើម្បីផ្តល់នូវទឹកសម្រាប់វិស័យកសិកម្ម។

ក្នុងសម័យអង្គរ យើងឃើញតតាកៈ ឬបារាយណ៍ទាំងនោះ ត្រូវបានកសាងឡើងសម្រាប់ផ្តល់នូវទឹកធ្វើស្រែចំការ ប៉ុន្តែមានសញ្ញាជាវិជ្ជមានជាច្រើន ដែលអនុញ្ញាតិឲ្យយើងសន្និដ្ឋានថា ទំនប់ទឹកទាំងនោះក៏ទាក់ទិនទៅនិងវិស័យជំនឿសាសនាផងដែរ។

ក្នុងចំណោមបារាយណ៍ជាច្រើន គេរមែងតែសង្កេតឃើញវត្តមានរបស់ប្រាសាទមួយនៅចំកណ្តាល ដូចករណីប្រាសាទមេបុណ្យខាងកើត និងខាងលិច ជាឧទាហរណ៍ស្រាប់។ ព្រមជាមួយការផ្តល់នូវទឹកសម្រាប់ស្រោចស្រពស្រែចំការ បារាយណ៍ទាំងនោះក៏បំពេញសកម្មភាពយ៉ាងខ្លាំងក្លាក្នុងទិសដៅការពារសម្រេចនូវគោលបំណងរបស់សាសនិកជនផងដែរ។

មេបុណ្យ តំណាងឲ្យទឹកនៃទន្លេពិសិដ្ឋ គង្គានៅប្រទេសឥណ្ឌា បុណ្យ គឺបុណ្យបារមី កុសល ដូចនេះ បារាយណ៍ ឬមេបុណ្យ គឺជារូបភាពនៃសមុទ្រតំណាងឲ្យដំណើរការនៃការវិលវល់ក្នុងលោកីយ គឺការកើតស្លាប់-ស្លាប់កើត មិនឈប់ឈរនៃជីវិត។ ការប្រើពាក្យនេះ គឺដើម្បីជាអ្វីមួយដែលសមស្រប និងអត្ថន័យដើមនៃពាក្យបារាយណ៍ (សំស្ក្រឹត) ដែលមានន័យថា ចម្លងទៅត្រើយម្ខាងទៀតគឺព្រះនិពាន្វ។

ម្យ៉ាងវិញទៀត តាមតួលេខ ដែលបានផ្តល់ដោយនាយកដ្ឋានវិចិត្រសិល្បៈថៃ និងលាវ/ឡាវ រហូតមកដល់បច្ចុប្បន្ន នៅក្នុងសម័យអង្គរ មានបារាយណ៍ធំៗជាច្រើនចំនួនមិនតិចជាង ៣០ ដែលគេបានឃើញតាមរយៈរូបភាពថតពីលើអាកាស។ ទន្ទឹមនឹងនេះ ក៏មានវត្តមានរបស់បារាយណ៍មួយចំនួននៅកម្ពុជាក្រោម ដែលខ្លះនៅតែកំពុងប្រើប្រាស់ដោយសេរី នាសម័យទំនើបយើងនេះ។

ដូចនេះជារួម យើងអាចនិយាយបានថា ការបង្កើតទីក្រុងតូច ធំទាំងឡាយ ក្នុងអតីតចក្រភពកម្ពុជទេស ត្រូវបានផ្តើមចេញពីការស្ថាបនាបារាយណ៍ ដែលជាលក្ខណ្ឌមួយចម្បងខកខានពុំបានរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងសម័យបុរាណ ។ ភាពចាំបាច់នៃសិទ្ធិអំណាចនៃប្រមុខដឹកនាំខ្មែរនាជំនាន់នោះ គឺជា

កម្មវត្ថុទី១ ដែលត្រូវអនុវត្តន៍ គឺវឌ្ឍនភាព និងសុភមង្គលរបស់សហគមន៍មនុស្ស ហើយវាក៏ជាករណីកិច្ចនយោបាយជាតិផងដែរ ។

តាមរយៈការវិភាគខាងលើនេះ បានចង្អុលបង្ហាញថាការរៀបចំទីក្រុងខ្មែរបុរាណសុទ្ធសឹងតែស្ថិតនៅក្រោមឥទ្ធិពលនៃវិស័យជំនឿសាសនា ទោះជានៅទីណាក៏ដោយ ក្នុងចក្រភពកម្ពុជទេស ។ នេះមិនមែនមានន័យថា នគរូបនីយកម្ម ត្រូវផ្តាច់ចេញពីវិស័យសាសនាទេ ។ ផ្ទុយទៅវិញ នយោបាយទឹក ឬធារាសាស្ត្រ គឺជាប្រភពដ៏សំខាន់ចាំបាច់ជាទីបំផុត សម្រាប់ជាប្រយោជន៍ដល់សង្គមជាតិទាំងឡាយទៅវិញទេ។

សរុបសេចក្តីមក ខាងលើនេះ គឺជាហេតុផលបីយ៉ាងរក្សាទុក ដែលមានប្រយោជន៍ជាសាធារណៈក្នុងការបង្កបង្កើតទីក្រុង ឬបុរីខ្មែរឡើង ។

### ៣.៤.ប្រាសាទបាយ័ន

ព្រះបាទជ័យវរ្ម័នទី៧ បានរៀបចំកសាងកម្លាំងទ័ពជើងទឹកមួយយ៉ាងសំខាន់ទុកសម្រាប់ទប់ទល់និងវាយកម្ទេចកម្លាំងនាវាចររបស់ចាម ។ ព្រះអង្គយល់ច្បាស់ថាកម្លាំង និងចំណុចខ្សោយរបស់នគរចម្ប៉ាស្ថិតនៅលើកងនាវាចរ ។ ដូចនេះបើព្រះអង្គវាយកម្ទេចកម្លាំងនាវាចររបស់ចាមបានព្រះអង្គនឹងទទួលបានជោគជ័យរំដោះជាតិមាតុភូមិចេញពីកណ្តាប់ដៃរបស់ចាមបាន ។

ដូចព្រះអង្គបានត្រិះរិះពិចារណាមែន គឺកងទ័ពរបស់ព្រះអង្គបានវាយកម្ទេចកម្លាំងនាវាចររបស់ចាមខ្ទេចខ្ទី និងបរាជ័យទាំងស្រុង ។ ទិដ្ឋភាពចម្បាំងយ៉ាងសាហាវតាមទូក និងសំពៅលើទន្លេបានបង្ហាញយ៉ាងច្បាស់តាមរយៈចម្លាក់នៅលើជញ្ជាំងថែវប្រាសាទបាយ័ន ។ សិលាចារឹកនៅប្រាសាទបន្ទាយឆ្មារ ក៏បានបង្ហាញអំពីព្រឹត្តិការណ៍ច្បាំងប្រយុទ្ធគ្នា តាមដងទឹក លើទន្លេ និងជ័យជំនះយ៉ាងអស្ចារ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ទៅលើស្តេចចាមដែរ ។

កងសេនាយោធាចាមជាច្រើនបាក់ទ័ពរត់ប្រសាចគ្មានទិសតំបន់ ។ ខ្លះទៀតត្រូវកងទ័ពខ្មែរកាប់សម្លាប់ និងចាប់ជាឈ្លើយសឹក ។ នៅក្នុងឆ្នាំ ១១៨១ ព្រះអង្គបានរំដោះដណ្តើមយកមហានគរមកវិញ ហើយទឹកដីខ្មែរក៏រួចផុតពីការត្រួតត្រារបស់នគរចម្ប៉ាក្នុងគ្រានោះដែរ ។

ប្រាសាទបាយ័នដែលកសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៧ មានរូបព្រហ្មមុខបួនចំនួនទាំងអស់ ៥៤ ដែលតំណាងអោយចំនួនខេត្តខ្មែរទាំងអស់នាសម័យមហានគរ ។ រូបព្រហ្មមុខបួនដែល បញ្ចេញស្នាមញញឹម តំណាងអោយព្រហ្មវិហារធម៌ទាំងបួន គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ។ ប្រាង្គប្រាសាទបាយ័នសុទ្ធសឹងតែជារូបចម្លាក់។





## ៣.៥. ការរៀបចំមន្ទីពេទ្យ នាសម័យព្រះបាទជ័យវរ្ម័នទី ៧

មន្ទីរពេទ្យ ឬអរោគ្យសាលា ចំនួន ១០២ ត្រូវបានគេស្គាល់ដឹងចាប់ពីឆ្នាំ ១៩០២ តាមរយៈផ្ទាំងសិលាចារឹកនៅស្រុកសាយហ្វុង ប្រទេសឡាវ/លាវបច្ចុប្បន្ន។ សូមរំលឹកថា ដូចបានពោលខាងលើអរោគ្យសាលា និងធម្មសាលានៅក្នុងប្រទេសឡាវ/លាវ និងថៃបច្ចុប្បន្ន គឺជាភ័ស្តុតាងនៃវត្តមានខ្មែរក្នុងតំបន់នេះដែលធ្លាប់ជាភាគមួយនៃដែនដីខ្មែរបុរាណយ៉ាងប្រាកដ ។

យោងលើស្លោក XLV នៃសិលាចារឹកនេះ យើងឃើញថាក្នុងអរោគ្យសាលានីមួយៗ មានគ្រូពេទ្យ ២នាក់ អមដោយស្ត្រីពីរនាក់ និងមនុស្សប្រុសម្នាក់ គ្រូថ្នាំពីរនាក់នៅឃ្លាំងសម្រាប់ចែកចាយថ្នាំសង្កូវ, អ្នកដាំស្លពីរនាក់គឺជាអ្នកសំអាតផង ។ អ្នកមើលជម្ងឺ (គិលានុបដ្ឋាក) ចំនួន ១៤ នាក់,ស្ត្រីចំនួន៨នាក់សម្រាប់ដាំទឹក,កាន់ថ្នាំនិងបុកស្រូវ។

មានមនុស្សចំនួន ៦៦នាក់ទៀត ដែលជាអ្នកធ្វើការក្នុងមន្ទីរពេទ្យ ដែលមិនបានទទួលការឧបត្ថម្ភចំណាយដោយខ្លួនឯង។



សិលាចារឹកនៃអរោគ្យសាលា នៃប្រាសាទចោមព្រះ ខេត្តសុរិន្ទ្រ សារមន្ទីរខេត្តសុរិន្ទ្រ (ម.ត ១៩៩៦)

បន្ទាប់មកទៀត យើងឃើញមានអាចារ្យចំនួនពីរ ដើម្បីពិធីកម្ម ហើយហោរាសាស្ត្រម្នាក់ ដោយហេតុថា ប្រភេទជម្ងឺ, ការធ្វើវិភាគដើម្បីមើលការវិវត្តរបស់វា និងការថែទាំពឹងពាក់លើពេលវេលាដែលរោគបានផុសចេញ ។

អ្នកដែលទទួលការព្យាបាលរៀងរាល់ថ្ងៃ ឬក៏ក្នុងឱកាសណាមួយក្នុងឆ្នាំនូវឧបភោគបរិភោគធម្មតាដូចជា ឡាវហារ, វ៉ាន់ស៊ុយ, ក្រវាញ, ខ្ញី, បាយ, ប្រេង, ស្ក, ទឹកឃ្មុំ, ក្រមួន, ខ្ទឹម, អប់ទឹកខ្មេះ, ល្ង និងផ្លែពុទ្រា។ល។ និងឧបភោគ ដូចជាសម្លៀកបំពាក់, ថ្នាំ ដែលមានចំនួនត្រូវបានកំណត់ត្រឹមត្រូវ ។ វត្ថុទាំងនោះ ត្រូវវាស់ប្រគល់អោយអ្នកជម្ងឺដោយទៀងទាត់ណាស់។ ម្យ៉ាងវិញទៀត យើងក៏ដឹងផងដែរថា ថ្នាំសម្រាប់ព្យាបាលជម្ងឺមាន៣៦ប្រភេទទាំងអស់ដែលគេប្រើប្រចាំថ្ងៃក្នុងមន្ទីរពេទ្យនីមួយៗក្នុងចក្រភពកម្ពុជទេស។

ជាព័ត៌មានពិស្តារ យើងសូមរំឭកឡើងវិញនូវលទ្ធផលនៃការស្រាវជ្រាវរបស់លោកហ្សក ស៊ីដេស (Cf. អំពីមហាក្សត្រមួយអង្គក្នុងក្រុងកម្ពុជា ព្រះបាទជ័យវរ្ម័នទី ៧ ប្រែដោយជុំ ម៉ៅ ឆ្នាំ ១៩៣៥ ភ្នំពេញ)" មនុស្សទាំង៨ពួក អាចនឹងចូលមកឲ្យគេរក្សារោគក្នុងទីនេះបានគ្រប់គ្នា ។ មានគ្រូពេទ្យ ២នាក់ ក្នុងពេទ្យម្នាក់មានមនុស្សក្រោមបង្គាប់ជាច្រើន គឺប្រុសម្នាក់ ស្រីពីរនាក់ ដែលត្រូវបានតាំងទីលំនៅក្នុងទីនោះ មេឃ្លាំង ២នាក់ មានមុខក្រសួងត្រូវចែកថ្នាំ ចុងភៅ ២នាក់ ដែលមានអំណាច ត្រូវបានអុស និងទឹក ហើយត្រូវធ្វើការបោសសំអាតមន្ទីរព្យាបាលផង អ្នកបម្រើប្រុស ២នាក់ រៀបចំដង្វាយព្រះ ដែលត្រូវបានថ្នាំសង្កូវ និងអុស អ្នកព្យាបាលរោគ ១៤នាក់ចែកថ្នាំ ស្រី៦នាក់ មានមុខក្រសួងត្រូវដាំទឹកក្តៅ និងបុកថ្នាំ ស្រី ២នាក់ សម្រាប់បុកស្រូវទាំងអស់ ត្រូវប្រើអ្នកបម្រើស្រី ៨នាក់ ដែលត្រូវបានតាំងលំនៅក្នុងមន្ទីរ គឺ២នាក់ ១បន្ទប់ ។ ចំនួនមនុស្សទាំងអស់ ដែលត្រូវមានលំនៅក្នុងរោងព្យាបាល ត្រូវ៣២នាក់។ ម្យ៉ាងវិញទៀត នៅមាន

មនុស្សបំរើ៦៦នាក់ទៀត ដែលនៅ ដោយចេញសោហ៊ុយខ្លួនឯងៗរួមទាំងអស់ត្រូវ៩៨នាក់"ម្យ៉ាងវិញទៀត ប្រកាសនៃរោងព្យាបាល ដែលមានចំនួនទាំង ១០២ ទូទាំងចក្រភពខ្មែរ ក៏បានឲ្យដឹងថា ព្រះរាជហឫទ័យរបស់ព្រះបាទជ័យវរ្ម័នទី៧ "ពេញដោយសេចក្តីមេត្តា ដើមសេចក្តីសុខចំរើនដល់លោកទាំងមូល។ ព្រះមហាក្សត្រទ្រង់ធ្វើសេចក្តីឧទ្ទិស ដូច្នេះថា សត្វទាំងអស់ដែលលិចលង់ក្នុងសមុទ្រ គឺវដ្តសង្សារ សូមឲ្យខ្ញុំព្រះករុណាខ្ញុំ ស្រោចស្រង់បានដោយអំណាចអំពើដ៏ប្រសើរនេះ។ សូមឲ្យក្សត្រគ្រប់អង្គក្នុងកម្ពុជទេសដែលជាប់ដោយសេចក្តីល្អ ហើយដែលជាអ្នកជួយថែរក្សាការកសាងរបស់ខ្ញុំព្រះករុណាខ្ញុំបានដល់ទីដែលផុតចាកទុក្ខ ដែលគ្មានជម្ងឺមួយអន្លើ ដោយព្រះរាជវង្សានុវង្ស ព្រះអគ្គមហេសី សេនាមាត្យ និងមិត្រសម្លាញ់ទាំងអស់គ្នា" (Cf. ហ្សក សឺដេស អំពីមហាក្សត្រមួយអង្គក្នុងក្រុងកម្ពុជា ព្រះបាទជ័យវរ្ម័នទី៧ប្រែដោយជុំម៉ៅឆ្នាំ១៩៣៥ភ្នំពេញ)។

ម្យ៉ាងវិញទៀត សិលាចារឹកប្រកាសទាំងនោះ ដែលមានសេចក្តីដូចៗគ្នាបានឲ្យដឹងទៀតថា អរោគ្យសាលាទាំងនោះ ស្ថិតនៅក្រោមសេចក្តីប្រសិទ្ធិនៃព្រះពោធិសត្វ ដែលមានព្រះនាមថា ភៃសជ្យគុរុវៃទុរ្យប្រភាមានន័យថា"គ្រូថ្នាំដែលមានពន្លឺដូចជាកែវដ៏ប្រសើរ"។

ថ្មីៗនេះ ការធ្វើកំណាយខាងបុរាណវិទ្យាបានឲ្យដឹងថា មានការកប់សពនៅជុំវិញនៃរោងព្យាបាលនាសម័យនោះផងដែរ។

### ៣.៦.ប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារត្រូវបានស្ថាបនាឡើងពីថ្ម ចាប់តាំងពីរជ្ជកាលព្រះបាទសុរិយាវរ្ម័នទី១ ។ ព្រះបាទសុរិយាវរ្ម័នទី១ សោយរាជ្យនៅពាក់កណ្តាលទីមួយនៃសតវត្សទី ១១ ។ ទីតាំងធ្វើប្រាសាទ ដែលស្ថិតនៅលើទីខ្ពស់ជាងគេ មានកំពស់ ៦២៥ម៉ែត្រ ឬ ៦១៥ម៉ែត្រ ។

ប្រាសាទព្រះវិហារត្រូវបានស្ថាបនាឡើងដើម្បីធ្វើជាទីដែលគេរក្សាទុកលិង្គព្រះអាទិទេព ស្រីសិខៈរិស្វារៈ ។

តំណាក់កាលនៃការសាងសង់ មានបីដំណាក់កាលធំៗះ

១.ដែលក្រុមអ្នកប្រវត្តិវិទូគិតសង្ស័យថា កាលពីជំនាន់ព្រះអង្គម្ចាស់ ឥន្ទ្រាយុទ្ធ គឺអាស្រមប្រហែលធ្វើអំពីឈើ

២.តែមកដល់រជ្ជកាល ព្រះបាទសុរិយាវរ្ម័នទី១ គឺគេឈូសភ្នំយកថ្មភ្នំ ធ្វើជាកម្ពុជណ្តើរធ្វើជាផ្លូវឡើងទៅលើភ្នំនិងយកថ្មភ្នំ ទៅកសាងជាទីតាំងប្រាសាទផ្សេងៗនៅក្នុងដែនដីនៃប្រាសាទព្រះវិហារ ។

៣.បន្ទាប់មក គឺក្នុងរជ្ជកាលព្រះបាទ សុរិយាវរ្ម័នពេលនោះហើយដែលគេគិតថា ប្រាសាទភ្នំព្រះវិហារ គឺបានស្ថាបនាអោយកាន់តែល្អឡើង នៅពាក់កណ្តាលសត្សវត្សន៍ទី ១២ ។ ព្រះបាទសុរិយាវរ្ម័នទី២ នោះហើយដែលព្រះអង្គបានសាងប្រាង្គប្រាសាទអង្គរវត្ត ដែលស្ថិតនៅក្នុងខេត្តសៀម រាបសព្វថ្ងៃនេះ ។



## ៤. ស្ថាបត្យកម្មនៅសម័យក្រោយអង្គរ

### ៤.១. ស្ថាបត្យកម្មនៅសម័យចតុមុខ

#### ក. ការកសាងរាជធានីចតុមុខ

នៅ គ.ស. ១៤៣១ ព្រះបាទបរមរាជាចៅពញាយ៉ាត ទ្រង់បានលើករាជធានីទៅតាំងនៅទួលបាសានក្នុងខេត្ត ស្រីសឈរ តែគង់នៅទីនោះបានតែ ១ឆ្នាំ (ក្បួនខ្លះថាដល់៩ឆ្នាំ) ដោយមានទឹកជំនន់ធំខុសធម្មតា ព្រះអង្គក៏បញ្ជាអោយលើករាជធានីពីទួលបាសានទៅតាំងនៅក្រុងភ្នំពេញវិញ នៅលើត្រើយខាងលិចនៃទន្លេច្រាបឈាម។

ព្រះអង្គទ្រង់ត្រាស់បង្គាប់អោយ សម្តេចចៅពញាកៃ និង ឧកញ៉ាហោរាធិបតីខៀវ ព្រមដោយមន្ត្រីឯទៀតខ្លះផងឲ្យទៅពិនិត្យមើលទីដីដែលស្ថិតនៅជិតៗ ភ្នំដូនពេញ ។ លុះទៅធ្វើការពិនិត្យក្បួនតម្រាសព្វគ្រប់ហើយ មន្ត្រីទាំងនោះក៏ថ្វាយដំណឹងទៅព្រះរាជាវិញថា តំបន់ដែលស្ថិតនៅទិសអាគ្នេយ៍នៃភ្នំដូនពេញមានជ័យភូមិល្អល្មមស្ថាបនារាជធានីបាន។ ព្រះអង្គក៏ទ្រង់ត្រាស់អោយអស់ចៅហ្វាយស្រុកកែនរាស្ត្រ មកជួយកសាងព្រះរាជនិវេសន៍ លើកដីធ្វើកំពែង សង់ប្រាសាទ និងតំណាក់តូចធំក្នុងរយៈពេលដ៏ខ្លីបំផុត ។

លុះកិច្ចការបានបំពេញចប់សព្វគ្រប់ហើយ ព្រះអង្គក៏បានយាងមកគង់នៅរាជវាំងភ្នំដូនពេញតាមផ្លូវទឹកដោយមាននាម៉ឺនសព្វមុខមន្ត្រីដង្ហែមកផង ។ លុះយាងមកដល់ហើយ ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ចៅពញាតេជោ ចៅហ្វាយស្រុកខេត្តសំរោងទង អោយកែនរាស្ត្រលើកដីចាក់បំពេញតំបន់នៅជុំវិញវត្តភ្នំ

និងក្នុងរាជវាំង។ ដូច្នេះតំបន់នោះក៏បានរាបស្មើល្អ រហូតដល់មាត់ទន្លេដែលអ្នកផងនិយមហៅកំពង់រាប ចាប់តាំងពីពេលនោះមក។ ឯទីដែលចៅពញាតេជោអោយរាស្ត្រជីកយកអាចម៍ដីនោះ ក៏ក្លាយទៅជាបឹងមួយធំជ្រៅទូលាយទើបបានគេអោយឈ្មោះហៅ បឹងតេជោ តរៀងមក គឺទីដីត្រង់ផ្សារថ្មីសព្វថ្ងៃ។

តមកទៀតព្រះរាជាទ្រង់ត្រាស់បង្គាប់ ឧកញ៉ាវង្សាអនុជិតផ្លុង ចៅហ្វាយស្រុកខេត្តបាទីអោយជីកព្រែកបង្ហូរទឹកទន្លេចូលទៅក្នុងបារាយណ៍មួយ នៅក្នុងរាជធានីសម្រាប់យកទឹកប្រើប្រាស់ដល់ប្រជារាស្ត្រទាំងអស់គ្នា ព្រែកនោះគេហៅថា ព្រែកឧកញ៉ាផ្លុង។ បើតាមស្រាវជ្រាវទៅឃើញថាពីដើមព្រែកនេះស្ថិតនៅតាមបណ្តោយសួនច្បារនៅមុខស្ថានីយកណ្តាលនៃអយស្ម័យយាន គឺស្របនឹងវិថីឧកញ៉ាផ្លុងសព្វថ្ងៃនេះឯង។

ដើម្បីជាកិច្ចការពារ ព្រះរាជាទ្រង់បញ្ជាអោយជីកគូ និងលើកដីកំពែង តាំងជាសើន ជាបន្ទាយព័ទ្ធជុំវិញរាជធានី។ ដូច្នេះ នៅទិសខាងត្បូងគឺ ព្រែកតាកែវ ខាងលិច ព្រែកអូគរ ខាងជើង ព្រែកពោងពាយ ឬព្រែកចិនដំដែក ព្រោះនៅកន្លែងនោះមានជនជាតិចិនរកស៊ីរបរដំដែក ។ ក្រៅពីមុខងារការពារក្រុង ព្រែកទាំងនោះនៅមានមុខងារសំខាន់ម្យ៉ាងទៀត គឺយកទឹកសម្រាប់អោយរាស្ត្រធ្វើស្រែនៅទិសខាងលិច ។

ពួកនាម៉ឺនសព្វមុខមន្ត្រី និងពួកប្រជារាស្ត្របានសង់គេហដ្ឋានរៀងៗខ្លួនក្នុងបរិវេណនៃរាជធានី ។ លុះសម្រេចការកសាងហើយ ព្រះរាជាទ្រង់តាំងប្រទាននាមព្រះនគរថា ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរ បវរ ឥន្ទបត្តបុរី រដ្ឋរាជ សីមា មហានគរ[11] ។

ចំណែកឯទន្លេច្រាបឈាម ក៏ត្រូវបានប្រសិទ្ធិនាមថ្មីថា ទន្លេចតុមុខ វិញដែរ។ ក្រោយបន្តិចមកព្រះរាជបុត្រច្បងព្រះនាម នរាយណ៍រាជា ទ្រង់បានតែងតាំងជាឧបរាជ ហើយយាងទៅគង់ក្នុងព្រះតំណាក់នៅជ្រោយរលួស ។ ឯព្រះរាជបុត្រទីពីរព្រះនាម ស្រីរាជា យាងទៅគង់នៅខាងលិច ត្រង់ដីទួលមួយកន្លែងដែលតមកគេហៅថា ទួលព្រះស្រី (ម្តុំវត្តព្រះពុទ្ធមានបុណ្យសព្វថ្ងៃ) ។ នៅគ្រានោះ ព្រះវិហារកសាងឡើងដោយដូនពេញក៏បានទ្រុឌទ្រោមខ្លះទៅតាមកាលវេលា ។ ព្រះបាទបរមរាជាចៅពញាយ៉ាតទ្រង់បានកសាងវិហារនោះជាថ្មីឡើងវិញ ដោយពង្រីក និងពូនភ្នំដីអោយកាន់តែខ្ពស់ជាងដើម ហើយទ្រង់ចាត់ឲ្យក្រាលថ្មនៅកំពូលខាងលើ និងកសាងចេតិយមួយយ៉ាងធំពីខាងក្រោយព្រះវិហារ។

**ខ. ការកសាងវត្តអារាម**

[11] អាចមើលនៅទំព័រទី១៣០ និង ១៣១ ចំណុចខ នៃសៀវភៅប្រវត្តសាស្ត្រខ្មែរ និពន្ធដោយលោក ត្រឹង ងា បោះពុម្ពឆ្នាំ២០០១ ដោយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយនៃក្រសួងអប់រំយុវជន និងកីឡា ។

ព្រះរាជាទ្រង់បានចាត់ឲ្យកសាងវត្តអារាម នៅច្រើនកន្លែងក្នុងរាជធានី[12] : វត្តពីរនៅខាងកើតវត្តភ្នំ គឺ វត្តធម្មលង្កា និង វត្តកោះ វត្តមួយនៅខាងត្បូងអូរចិនដំដែកគឺ វត្តព្រះពុទ្ធឃោសា (សព្វថ្ងៃហៅ វត្តព្រះពុទ្ធឃោសារាម ឬវត្តចិនដំដែក នៅជាប់នឹងវត្តពិភទ្ធរង្សីមានវិថីឧកញ៉ាអ៊ុំខណ្ឌកណ្តាល។ នៅខាងមុខព្រះវិហារវត្តនេះ សព្វថ្ងៃគេឃើញមានរូបទ្វារបាលពីរនាក់ជារូបចិនដែលគេអាចមើលស្គាល់យ៉ាងងាយដោយសារលក្ខណៈមុខមាត់ សម្លៀកបំពាក់ និងគ្រឿងអាវុធ) វត្តមួយនៅត្រង់មាត់ទន្លេក្បែរពាកព្រែកឧកញ៉ាផ្លុងគឺ វត្តពាមផ្លុង វត្តមួយនៅត្រង់ចេតិយធំ វត្តឧណ្ណាលោមហើយវត្តមួយទៀតហៅ វត្តខ្ពបតាយ៉ង។ គួរគប្បីកត់សំគាល់ថាវត្តចុងក្រោយនេះ សព្វថ្ងៃស្ថិតនៅត្រង់វត្តបទុមវតី។ បើតាមអក្សរចារឹកតំកល់នៅទីនោះ ព្រះបាទបរមរាជាថៅពញាយ៉ាតបានសាងវត្តនេះនៅគ.ស.១៤៤២ លើកទីមួយមានទំហំ ២០២ មx២៦០ម ។ វត្តនេះគេហៅថា វត្តខ្ពបតាយ៉ង ព្រោះនៅខាងត្បូងមានខ្ពបរបស់តាយ៉ង ។ ព្រះវិហារវត្តនេះត្រូវបានកសាងថ្មីពីរលើកទៀត៖លើកទី១ នៅគ.ស. ១៨៦៥ ក្នុងរជ្ជកាលព្រះបាទសម្តេចនរោត្តម លើកទី២ នៅគ.ស.១៩៣៧ ក្នុងរជ្ជកាលរបស់ព្រះស៊ីសុវត្ថិមុនីវង្ស ។ គួរគប្បីជ្រាបម្យ៉ាងទៀតថាវត្តឧណ្ណាលោមនៅរក្សាឈ្មោះដដែលតាំងពីពេលកសាងរហូតមកដល់សព្វថ្ងៃ ហើយឈ្មោះនេះត្រូវបានប្រសិទ្ធឡើងដោយយកតាមឈ្មោះចេតិយដែលគេបញ្ចុះព្រះឧណ្ណាលោម គឺរៀមប្រជុំចិញ្ចើមនៃព្រះអស្សជិតត្ថេរ ។ នៅខាងមុខវត្តនេះ គឺនៅជិតមាត់ទន្លេ ព្រះរាជាទ្រង់អោយសាងឃ្លាំងមឿងមួយ (អ្នកតាចាំស្រុក) ឈ្មោះអ្នកតាប្រាជ្ញ[13] ។

រូបភាពតំបន់រាជធានីចតុមុខ[14]



[13] អាចមើលនៅទំព័រទី១៣២ នៃចំណុចខ នៃសៀវភៅប្រវត្តសាស្ត្រខ្មែរ និពន្ធដោយលោក ត្រឹង ងា បោះពុម្ពឆ្នាំ២០០១ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ នៃក្រសួងអប់រំយុវជន និងកីឡា ។

[14] អាចមើលនៅទំព័រទី១៣៣ នៃចំណុចខ នៃសៀវភៅប្រវត្តសាស្ត្រខ្មែរ និពន្ធដោយលោក ត្រឹង ងា បោះពុម្ពឆ្នាំ២០០១ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ នៃក្រសួងអប់រំយុវជន និងកីឡា ។

## ៤.២. ស្ថាបត្យកម្មសម័យលង្វែកការកសាងរាជធានីលង្វែក

បន្ទាយលង្វែកមានទទឹងប្រវែង ២ សហាតិមាត្រ( ២គីឡូម៉ែត) និងបណ្តោយប្រវែង ៣ សហាតិមាត្រ ( ជិត៣ គីឡូម៉ែត) ហើយចំណាយពេលសាងសង់ ៣ ឆ្នាំ (១៥២៧ - ១៥២៩) ។ ហើយតាមពាក្យដំណាលតៗគ្នាមកថា សូម្បីតែសេះខ្លាំងយ៉ាងណាក៏មិនអាច បោលអោយជុំវិញបន្ទាយនេះបានឡើយ[15] ។ បន្ទាយលង្វែកនេះ ជាទីតាំងប្រវិត្តសាស្ត្រខ្មែរដែលស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងជាកន្លែងយុទ្ធសាស្ត្រមួយមាន ទន្លេ បឹង ជាពិសេសព្រៃក ។ ក្រុមមេការឲ្យគេជីកបុកឫសរៀបថ្ម ៦ ហត្ថជុំវិញបន្ទាយជាបីជ្រុង ហើយលើកដីច្រុះក្តារធ្វើបន្ទាយនេះកម្ពស់ ១៤ហត្ថ កម្រាស់ខ្នងលើ ១០ហត្ថ ជើងទេរខាងក្រោម ២២ ហត្ថ ឯជ្រុងទី៤គឺទន្លេ[16]។

មូលហេតុនេះហើយ ទើបព្រះចន្ទរាជាបញ្ជាអោយមន្ត្រីឧកញ៉ាសេនាបតីអោយកេណ្ឌរាស្ត្រកាប់ឈើ ជញ្ជូនថ្ម រែកដី ដើម្បីសង់បន្ទាយនិងរាជវាំង ទ្រង់បានអោយគេធ្វើកំពែងការពារ ៥ ជាន់ព្រមទាំងដាំរបងឫស្សីយ៉ាងក្រាស់កម្រាស់ ២ សិន (១៦០ម) មានគូទឹក មានទ្វារ ៨ ខាងក្នុងបន្ទាយទាំង៥ជាន់ ដាក់សុទ្ធតែទាហានកាំភ្លើងវែង។ កំពែងទាំងប្រាំរួមមានោះ

-នៅក្នុងកំពែងជាន់ទីមួយ ដាក់សុទ្ធតែទាហានកាំភ្លើងធំ ហើយនៅមុខកំពែងនេះមានរោងដំរី ក្នុងកំពែងជាន់ទី១ ដាក់សុទ្ធតែទាហាកាំភ្លើងធំ ហើយ នៅមុខកំពែងនេះ មានរោងដំរី និងរោងសេះ។

-នៅក្នុងកំពែងទី២ ដាក់សុទ្ធតែទាហានកាំភ្លើងវែង សាលាជំនុំ សាលាដំបូង និង សាលាឧទ្ធរណ៍។

-នៅក្នុងកំពែងទី៣ ដាក់សុទ្ធតែទាហាអាវុធខ្លី មានដាក់ផ្គាក់ កាំបិត។

-នៅក្នុងកំពែងទី៤ ដាក់សុទ្ធ តែទាហានរក្សាព្រះអង្គ រោងល្ខោន និងព្រះពន្លាទតល្ខោន។

-និងក្នុងកំពែងទី៥ មានរោងបញ្ញក្សេត្រ និងដំណាក់សំរិទ្ធ វិមានកំសាន្ត ភិរម្យ ក្រុមបាគូ បុរោហិត និងក្រុមមហាតលិកនៅ។ ក្នុងកំពែងនេះដែរ មានរាជវាំង កំពូលប្រាំបិទមាស និង លាបម្រ័ក្សសម្រាប់ព្រះមហាក្សត្រាធិរាជផ្ទុំ ហើយមានតម្កល់វត្ថុសក្តិសិទ្ធិគឺ ព្រះកែវ ឬ ព្រះត្រឡែងកែង និងព្រះគោចំនួន ១២ ដែលនៅក្នុងពោះព្រះគោទាំងនោះមានរក្សានូវគម្ពីរក្បួនសាស្ត្រាដ៏មានតម្លៃលើសលប់។មានផ្ទះស្រីស្នំ ក្រមការ បុត្រាបុត្រី និងមានឃ្លាំងធំៗទុកស្រូវ អង្ករ អំបិល ប្រហុក ត្រីងៀត ត្រីឆ្អើរ និងឃ្លាំងសាស្ត្រាវុធ។ ម្យ៉ាងទៀតតាមជំនឿរបស់ខ្មែរ ព្រះគោ និងព្រះកែវជាបងប្អូនបង្កើតនិងគ្នា ដែលអ្នកស្រុកតែងតែគោរព

[15] អាចមើលនៅទំព័រទី១៨៤ នៃសៀវភៅប្រវត្តសាស្ត្រខ្មែរ និពន្ធដោយលោក ត្រឹង ងា បោះពុម្ពឆ្នាំ២០០១ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ នៃក្រសួងអប់រំយុវជន និងកីឡា ។

[16] អាចមើលនៅ http://reanputhi.wordpress.com/2012/05/04

បូជាទុកជាវត្ថុស័ក្តិសិទ្ធិ ដោយសារនៅក្នុងបន្ទាយលង្វែកមានរូបព្រះគោ ព្រះកែវ គេមានជំនឿថា នេះជាបន្ទាយ មួយយ៉ាងមាំសម្រាប់ការពារសត្រូវផង និងឃ្លាំងវប្បធម៌ជាតិបន្ទាប់ពីអង្គរ។

១.រូបភាពផែនទីបន្ទាយលង្វែក [17]




២. រូបភាពទីតាំងផែនទីបន្ទាយលង្វែក[18]




៣. រូបភាពនៃការចេញទ័ពពីបន្ទាយ

[17]អាចរកបានក្នុង http://fuckyeahcartography.tumblr.com/post/17765191888/ohmykhmer-1725-longvek-map-eauweck-capitale-de

[18] អាចមើលនៅទំព័រទី១៨៤ នៃសៀវភៅប្រវត្តសាស្ត្រខ្មែរ និពន្ធដោយលោក ត្រឹង ងា បោះពុម្ពឆ្នាំ២០០១ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ នៃក្រសួងអប់រំយុវជន និងកីឡា ។





### ៤.៣. ស្ថាបត្យកម្មនៅសម័យឧដុង្គ

សម័យឧដុង្គ ឆ្នាំ ១៦២០ ជាកាលកំណត់ដែលមហាក្សត្យខ្មែរ មួងអង្គនាមជ័យជដ្ឋាទី២ បានមកតាំងរាជធានី នៅក្នុងឧដុង្គ ។ ស្តេចសោយរាជ្យតៗគ្នាមកគង់នៅក្រុងនេះសឹងតែទាំអស់ រហូតដល់ឆ្នាំ ១៨៦៧[19] ។នៅក្នុងកំឡុងពេលឆ្នាំនេះគឺប្រទេសកម្ពុជាកំពុងតែមានវិបត្តិផ្ទៃក្នុង ព្រមទាំមានការឈ្លានពានពីប្រទេសថៃ និងវៀតណាត ដូចនេះហើយ គឺមិនសូវជាមានការសាងសង់អ្វីធំដំដូចសម័យអង្គរទេ គឺមានត្រឹមតែផ្ទះ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតិចតួចប៉ុណ្ណោះ ។

**ក .ការសាងសង់ទំនប់ និងផ្លូវ**

[19] អាចមើលនៅក្នុង ទំព័រទី ១៨៣ នៃសៀវភៅប្រវត្តសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា របស់លោកសាស្ត្រាចារ្យ ឥន្ទ ឱមសាម៉េង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ភឆ្នាំ ២០០៩។

នៅឆ្នាំ១៨៥០[20] ព្រះអង្គឌួងបានបញ្ជាឲ្យពួកមន្ត្រីកែនប្រជាជន ដើម្បីលើកទំនប់មួយសម្រាប់ការពាររាជធានីឧដុង្គពីខាងកើត ។ ព្រះអង្គបានកសាងផ្លូវមួយទៀតតភ្ជាប់ពីក្រុងឧដុង្គទៅកំពង់លួងមានប្រវែង ៦៨០០ម៉ែត ។ នៅលើចិញ្ចើមផ្លូវមានកសាងសាលាសំណាក់ជាច្រើន សម្រាប់ឲ្យប្រជាជនដែលធ្វើដំណើរឆ្លងកាត់ឈប់សម្រាកនៅពេលហត់នឿយ ។ ដើម្បីសម្រួលដល់ប្រជាជននៅម្តុំពោធិ៍ចិនតុងក្នុងការដឹកជញ្ជូនទំនិញមកលើកនៅកំពង់ផែក្រុងភ្នំពេញព្រះអង្គក៏បានបញ្ជាឲ្យគេកសាងផ្លូវមួយទៀត ។ ប្រទេសខ្មែរក្នុងសម័យអង្គរមានផ្លូវខ្វាត់ខ្វែង ប៉ុន្តែដោយសារចម្បាំងទើបផ្លូវអស់ទាំងនោះត្រូវគេបោះបង់ចោលមិនបានថែរក្សា ។ ចាប់ពី ឆ្នាំ ១៨៤៧ ពួកយួនបានគាបសង្កត់មកលើសេដ្ឋកិច្ចតាមផ្លូវទន្លេមេគង្គ ដោយយកពន្ធដារលើទំនិញឆ្លងកាត់ ទើបព្រះអង្គបាន សម្រេចព្រះទ័យសាងកំពង់ផែមួយនៅខេត្តកំពត ដើម្បីរំដោះសេដ្ឋកិច្ចប្រទេសជាតិឲ្យផុតពីការហ៊ុមព័ទ្ធរបស់សត្រូវ ។ ជាមួយគ្នានេះដែរ ព្រះអង្គក៏បានកសាងផ្លូវមួយខ្សែភ្ជាប់ពីឧដុង្គទៅកំពង់ផែកំពត ដើម្បីសម្រួលទំនាក់ទំនងជាមួយកំពង់ផែ និងសម្រាប់ប្រជារាស្ត្រខ្មែរធ្វើដំណើរទៅមក[21]។

**ខ. លំនៅឋានខ្មែរនាសម័យឧត្តុង្គ (ផ្ទះដំបូលប៉ិត)**

លំនៅឋានរចនាបថ«ផ្ទះដំបូលប៉ិត»នេះ គេធ្វើដំបូលបួនផ្ទាំង ពីរផ្ទាំងធំមានទំរង់ជាចតុកោណព្នាយសមបាត ដែលគ្របតាមបណ្តោយផ្ទះ និងពីរផ្ទាំងទៀតមានរាងជាត្រីកោណសមបាត(បីជ្រុង)ដែលគ្របផ្នែកទទឹងផ្ទះ ហើយមានជម្រាលស្មើគ្នា[22]។ ផ្ទះប៉ិតគ្មានហោជាងនៅដំបូលផ្នែកណាមួយនោះទេ ។ តាមប្រសាសន៍របស់ជាង មាស សុមន្ត រស់នៅភូមិ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ថា«រចនាបថផ្ទះដំបូលប៉ិតខ្មែរគេសម្គាល់បានទៅលើដំបូលដែលមានរាងប៉ិតនៅជ្រុងតូច ហើយនិងគេសាងសង់ផ្ទះបែបនេះដោយមិនឱ្យពិបាកធ្វើហោជាងពីមុខនិងពីក្រោយ»។

ក្នុងរជ្ជកាលព្រះបាទសម្តេចស៊ីសុវត្ថិ (រាជានុកោដ្ឋ) ប្រជារាស្ត្រខ្មែរទាំងក្រុងទាំងជនបទ ច្រើននិយមសាងសង់ផ្ទះដំបូលប៉ិតណាស់ ដោយផ្ទះនេះគ្មានហោជាងមុខក្រោយងាយធ្វើជាងផ្ទះរោងឌឿង ។ ដំបូលប៉ិតគេច្រើនសាងសង់ជាសាលាសំណាក់តូចៗនៅតាមស្រុកភូមិទីជនបទ ។

---

[20] អាចមើលនៅក្នុង ផ្នែក រជ្ជកាលព្រះបាទអង្គដួង ក្នុងកថាខណ្ឌទី៣ ចំណុចកាសាងសងទំនប់ផ្លូវ និងផ្លូវ នៃសៀវភៅលំនៅដ្ឋានខ្មែររបស់ លោកសាស្ត្រាចារ្យ ហ៊ឺ ចិន្តា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ បោះពុម្ពឆ្នាំ ២០១០។

[21] អាចមើលនៅក្នុង http://netstudy.orgfree.com/index.php/2012-08-01-05-19-10/2012-08-01-10-02-43

[22] អាចមើលនៅក្នុង ផ្នែក រជ្ជកាលព្រះបាទអង្គដួង ក្នុងកថាខណ្ឌទី៤ ចំណុចការសាងសងលំនៅដ្ឋានខ្មែររចានបថ ផ្ទះដំបូលពាន់ប៉ិត នៃសៀវភៅលំនៅដ្ឋានខ្មែររបស់ លោកសាស្ត្រាចារ្យ ហ៊ឺ ចិន្តា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ បោះពុម្ពឆ្នាំ ២០១០។

ក្នុងរជ្ជកាលព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស (ខត្តិយកោដ្ឋ) ប្រជារាស្ត្រខ្មែរច្រើនយកគំរូដំបូលបិតមកធ្វើជាលំនៅឋាន(ផ្ទះ)ស្នាក់នៅ ហើយធ្វើអោយធំទូលាយ ។

ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តមសីហានុវរ្ម័ន ប្រជារាស្ត្រខ្មែរច្រើននិយមធ្វើផ្ទះ ដំបូលបិតស្ទើរតែពេញព្រះរាជាណាចក្រ ឯផ្ទះរោងដោល រោងឌៀង គេមិនសូវនិយមធ្វើទេ ផ្ទះរោងដោល និងផ្ទះរោងឌៀងមានតែផ្ទះចាស់ៗដែលបានសង់ពីរជ្ជកាលមុនមក និងផ្ទះចាមជ្វា ។ រីឯសាសន៍ចាមជ្វាក៏និយមធ្វើ ផ្ទះដំបូលបិតនេះច្រើនដែរ តែផ្ទះដំបូលបិតគេច្រើនសង់ឱ្យមេដំបូលស្របបណ្តោយៗផ្លូវ ។ គេច្រើនសង់ផ្ទះដំបូលបិតធំៗដែលមានពីខ្នង ឬជាប់គ្នាផ្ទះធំមួយខ្នងនៅកណ្តាលផ្ទះបាយមួយខ្នងនៅខាងក្រោយ និងមានហោណាំងមួយ ខ្នងទៀតនៅខាងមុខ ។

**ខ.១.លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលរោងបិត» គំរូទី១**

អាគាររចនាបថដំបូលបិតនេះ គេអាចសង់ជាសាលាសំណាក់តូចៗ (សាលាឆទាន)នៅតាមផ្លូវឆ្ងាយ ឬនៅក្នុងភូមិ ស្រុកឯជនបទ ។ ចំពោះផ្ទះមានរចនាបថបែបនេះ ប្រជារាស្ត្រខ្មែរក៏និយមចូលចិត្តណាស់ដែរទាំងនៅទីក្រុង និង នៅជនបទ ព្រោះថាវាមានលក្ខណៈងាយស្រួលក្នុងការសាងសង់ ដោយគេគិតថាវាគ្មានហោជាងមុខក្រោយ។

អាគាររចនាបថដំបូលបិត គេអាចសង់ជាបួនជ្រុងការេ ឬចតុកោណកែង ទៅតាមតម្រូវការដោយសាងសង់មានសសរបួនជួរបណ្តោយ (មើលពីមុខ)និងបីជួរទទឹង(មើលពីចំហៀង) ។

រចនាបថផ្ទះដំបូលបែបនេះ គេច្រើនសាងសង់បន្ថែមសសរមួយជួរទៀត ដើម្បីឱ្យវាទូលាយ ។ អាគាររចនាបថដំបូលបិតគំរូទី២នេះ គេអាចសាងសង់ដោយមានសសរបួនជួរបណ្តោយ (មើលពីមុខ) និងបួនជួរទទឹង (មើលពីចំហៀង ) ។

រចនាបថផ្ទះដំបូលបិតប្រភេទទី២នេះ គេសាងសង់ឱ្យមានផ្ទះធំមួយខ្នងនៅខាងក្រោយ និង មួយខ្នងតូចនភពីខាងមុខសម្រាប់ទទួលភ្ញៀវ ឬ អង្គុយជជែកកំសាន្ត ។

<u>**ផ្ទះដំបូលរោងបិត» គំរូទី១**</u>



ខ.២. លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលរោងប៉ិត» គំរូទី២

រចនាបថផ្ទះដំបូលបែបនេះ គេច្រើនសាងសង់បន្ថែមសសរមួយជួរទៀត ដើម្បីឱ្យវាទូលាយ ។ អាគាររចនាបថដំបូលប៉ិតគំរូទី២នេះ គេអាចសាងសង់ដោយមានសសរបួនជួរ បណ្ដោយ (មើលពីមុខ) និង បួនជួរទទឹង (មើលពីចំហៀង ) ។

រចនាបថផ្ទះដំបូលប៉ិតប្រភេទទី២នេះ គេសាងសង់ឱ្យមានផ្ទះធំមួយខ្នងនៅខាងក្រោយ និង មួយខ្នងតូចនភពីខាងមុខសម្រាប់ទទួលភ្ញៀវ ឬ អង្គុយជជែកកំសាន្ត ។

<u>ផ្ទះដំបូលរោងប៉ិត» គំរូទី២</u>



**ខ.៣. លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលរោងប៉ិត» គំរូទី៣**

ប្រជាជនខ្មែរ គេច្រើនចូលចិត្តសាងសង់លំនៅឋានរចនាបថ«ផ្ទះដំបូលប៉ិត»ប្រភេទបែបនេះណាស់ ។ សូម្បីតែជនជាតិចាម ក៏និយមសាងសង់ផ្ទះដែលមានរចនាបថដំបូលប៉ិតនេះណាស់ដែរដោយសាងសង់ជាលក្ខណៈបណ្ដោយតាមដងផ្លូវ មិនថាទទឹង ឬបណ្ដោយថ្ងៃនោះទេ គឺសាងសង់ឱ្យមេដំបូលផ្ទះធំស្របនឹងផ្លូវ ។

រចនាបថផ្ទះដំបូលប៉ិតបែបនេះ គេច្រើនសាងសង់ផ្ទះធំមួយខ្នង ផ្ទះបាយមួយខ្នង និងហោណាំងមួយខ្នង នៅខាងមុខសម្រាប់អង្គុយកំសាន្ត និងទទួលភ្ញៀវ ។

**<u>ផ្ទះដំបូលរោងប៉ិត» គំរូទី៣</u>**



លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលប៉ិត» តាមតែអ្នកស្រុកបាត់ដំបង គេនិយមហៅថា «ផ្ទះជម» ឬ «ក្រជម» ។ ជាទូទៅផ្ទះដំបូលប៉ិតដែលមានមួយខ្នង ឃើញថាទ្វារមិនបិតនៅលើ ជ្រុងខ្លីទេ គឺបិតនៅលើជ្រុងដែលវែង ។

ផ្ទះដំបូលប៉ិត ជាធម្មតាគេអាចពង្រីកផែន(ប្លង់)បានច្រើនយ៉ាង ឬ បន្ថែម (បន្ត) ដំបូលឱ្យបានច្រើនខ្នងទៅតាមចិត្តប្រាថ្នារបស់អ្នកផង ។ ម្យ៉ាងទៀតនោះ ការពង្រីកបន្តខ្នងនោះ គេអាចថែមទៅខាងចំហៀងក៏មាន ដែលគេហៅថា «ភ្លោះ» ។ ជួនកាលយើងពិបាកឱ្យឈ្មោះលំនៅឋានដែលមានដំបូលស្រដៀងគ្នានឹងផ្ទះដំបូលប៉ិត ។ តែទោះជាយ៉ាងណាក៏បិតនៅក្នុងមូលដ្ឋាននៃរចនាបថលំនៅឋានផ្ទះដំបូលប៉ិតនេះដែរ ។

នៅសម័យអាណានិគមនិយមបារាំង ស្ថាបត្យការខ្មែរក៏បានច្នៃប្រឌិតឱ្យមាននូវហោរ «ទីលំហារ» សម្រាប់ទុកជាទីទទួលភ្ញៀវ ឬ អង្គុយកំសាន្ត ដែលមើទៅមានសោភ័ណភាពគួរគាប់ភ្នែក ។ រីឯការតុបតែងនៅលើព្រំដំបូលដូចជា កំពូលមិុតប៉ប្រកចុងចែង ឬ ក្បាច់ភ្ញីលម្អផ្សេងៗទៀតក៏មានច្រើនយ៉ាងណាស់ដែរទៅចំណង់ចំណូលចិត្តរបស់ម្ចាស់លំនៅឋាន ឬ ស្ថាបត្យករ (ជាងផ្ទះ) ។

**<u>លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលមិុត» តាមតែអ្នកស្រុកបាត់ដំបង</u>**





## ជំពូកទី២ ស្ថាបត្យកម្មសម័យទំនើប

### ១. ស្ថាបត្យកម្មសម័យអាណានិគមបារាំង( ១៨៦៣-១៩៥៣ )

បន្ទាប់ពីសម័យសង្វែកមក ប្រទេសខ្មែរត្រូវធ្លាក់ចូលទៅក្នុងសភាពអាប់ឱនស្ទើរជើបពុំរួចម្តងទៀត ចាប់តាំងពីចុងស.វទី១៦ រហូតដល់ពាក់កណ្តាលស.វទី១៩ ។ ក្នុងសម័យកាលនោះប្រទេសខ្មែរ បានក្លាយជាព្រ័ត្រសម្រាប់ប្រទេសជិតខាងគឺ សៀម និងយួន ដែលនាំគ្នាទាញដណ្តើមយកតែរៀងៗខ្លួន ។ ក្រោយថ្ងៃទី ១១ ខែ សីហា ១៨៦៣ សន្ធិសញ្ញាបារាំង-ខ្មែរ ដែលយល់ព្រមចុះហត្ថលេខាដោយហ្លួងនរោត្តម ត្រូវបង្ខំឲ្យខ្មែរស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង ។ នៅក្នុងសម័យនោះរាជធានីភ្នំពេញនៃប្រទេសកម្ពុជាបានផ្លាស់ប្តូរចេញពីឧត្តុង្គមកកាន់ភ្នំពេញវិញ ។ គេសង្កេតឃើញការស្ថាបនារាជធានីថ្មីនៅភ្នំពេញ ត្រូវតម្រូវឲ្យសាងសង់ឡើងវិញនូវព្រះបរមរាជវាំង ដែលស្ថិតនៅចំពីមុខទន្លេចតុមុខ ។ ព្រះបរមរាជវាំងនេះបានបន្សល់ទុកនូវស្ថាបត្យកម្ម តាមបែបខ្មែរយ៉ាងច្រើន និងដែលសំបូរបែបបំផុត ហើយសំណង់ធំៗដែលគួរឲ្យគយគន់នៅព្រះបរមរាជវាំងរួមមានប្រាសាទចន្ទច្ឆាយា ទីនាំងទេវាវិនិច្ឆ័យព្រមទាំងព្រះវិហារវត្តកែវមរកត... ។[23]

នៅសម័យអាណានិគមបារាំង ប្លង់រាជធានីភ្នំពេញ និងប្លង់ទីក្រុង តាមខេត្តនានា មានរាងជាក្រឡាចត្រង្គ ។ គេសង្កេតឃើញមាន សំណង់បុរាណត្រូវអភិរក្សមួយចំនួន ដែលនៅសេសសល់រហូតដល់សព្វថ្ងៃ និងមានតម្លៃជាប្រវត្តិសាស្ត្រ ដែលជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យឃើញពីជីវភាពរស់នៅពីអតីតកាលនៃសង្គមកម្ពុជានៅក្នុងសម័យអាណានិគម កំឡុងឆ្នាំ ១៨៦៣ ដល់ ១៩៥៣ ។ សំណង់ទាំងនោះភាគច្រើនជាអគាររដ្ឋបាលនានា ឬជាលំនៅដ្ឋានរបស់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជនជាតិបារាំងដែលមកធ្វើការនៅស្រុកខ្មែរ ។ ទម្រង់សំណង់អគារទាំងនោះគឺយកតាមលំនាំវប្បធម៌បែបអឺរ៉ុប នៅសម័យក្លាស៊ីកជាពិសេស គឺបារាំង ។[24] ឈ្មោះសំណង់សម័យបារាំងមួយចំនួនដែលនៅសល់រហូតដល់សព្វថ្ងៃ៖

**ក, ព្រះបរមរាជវាំង**(The Royal palace)



[23] ស្ថាបត្យកម្មសាកល រៀបរៀងដោយ វ៉ា សុវណ្ណរដ្ឋ បោះពុម្ពបណ្ណាគារអង្គរ ២០០៧ ទំព័រ ៤០ ។

[24] ប្រវត្តិនគររូបនីយកម្មនៅកម្ពុជា រៀបរៀងដោយ បណ្ឌិត អ៊ូ វ័ឌី គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ ២០១២ ទំព័រ ៨៨និង ៨៩ ។

(ROYAL PALACE: 1866-1870, LATE 19TH TO EARLY-MID 20TH CENTURY)

ព្រះបរមរាជវាំង ត្រូវបានគេចាត់ទុកជានិមិត្តរូបជាតិមួយនៃប្រទេសកម្ពុជា ។ ព្រះបរមរាជវាំង ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៨៦៦ នៅសម័យកាលព្រះបាទនរោត្តម។ ទីនេះ ជាទីប្រសព្វនៃទន្លេចតុមុខ នៅតាមបណ្តោយមហាវិថីសុធារស សព្វថ្ងៃ ។ ព្រះបរមរាជវាំង មានទទឹង ៤០២ម និងបណ្តោយ ៤៣៥ម ដែលពោពេញទៅដោយសំណង់អគារជាច្រើន មានរចនាបទវិហារ ។ គ្រប់សំណង់ទាំងអស់ សាងសង់តាមរចនាបទខ្មែរបុរាណ គឺមាន ដំបូល បូសស្បុក , រចនាបទដំបូលខ្មែរ ដែលមានកំពូលស្រួច ដូចវិហារ ឬប្រាសាទដែលតំណាងឲ្យអត្តសញ្ញាណសាសនា ក្នុងព្រះបរមរាជវាំងមានការលាបពិណលឿង(តំណាងព្រះពុទ្ធសាសនា) និងពិណស(តំណាងព្រហ្មណ៍សាសនា) ។

ប្រាសាទព្រះទីនាំងចន្ទច្ឆាយ៉ា ជាទីកន្លែងសំដែងសិល្បះរបាំ ជាកន្លែងគង់មើលរបស់ព្រះមហាក្សត្រនៅក្នុងពិធីផ្សេងៗ ។ សំណង់នេះសាងសង់ឡើងនៅឆ្នាំ ១៩១៣-១៤ ក្រោមរាជព្រះបាទស៊ីសុវត្ថិ ជំនួសឲ្យសំណង់ចាស់ដែលសង់អំពីឈើដែលសង់ដោយព្រះបាទនរោត្តម ១៨៦៦ ។

ប្រាសាទ ទេវាវិនិច្ឆ័យ ជាទីកន្លែងនៃរាជបល្ល័ង្គជាសំណង់ដែល ទាញចេញពីស្ថាបត្យកម្មនៃរចនាបទបាយ័នសម័យអង្គរ ។ ប្រាសាទមានកំពូលបី មានរាងជាព្រហ្មមុខបួន ដែលកំពូលកណ្តាលមានកំពស់ ៥៩ម ។នៅក្នុងប្រាសាទមានរៀបការ៉ូបាតយ៉ាងស្រស់ស្អាត ។

ប្រាសាទព្រះកែវមរកត ត្រូវបានកសាងឡើងរវាងឆ្នាំ ១៨៩២ និង ១៩០២ រជ្ជកាលព្រះបាទនរោត្តម ប៉ុន្តែនៅពេលនោះ សង់ឡើងដោយឈើ និងឥដ្ឋ ដែលត្រូវខូចទ្រុឌទ្រោម នៅឆ្នាំ ១៩៦២ សង់ឡើងវិញ ជាថ្មក្នុងទំហំដដែល តាមរចនាបទស្ថាបត្យកម្មប្រាសាទបុរាណខ្មែរ ។ នៅក្នុងប្រាសាទ បាតក្រាលដោយឥដ្ឋប្រាក់ ជាកន្លែងប្រារព្ធពិធីតាមបែបសាសនា ។[25]

**ខ,អគារទីស្នាក់ការ** UNESCO



[25] STHAPATYAKAM The Architecture of Cambodia (DMC) Royal University of phnom Penh,2012, pg 19 ,20

សំណង់សម័យបារាំង(ទីស្នាក់ការUNESCOប្រចាំភ្នំពេញ )

អគារ UNESCO ជាអតីតផ្ទះរបស់ប្រជាជនសាមញ្ញ ។ វីឡាមួយនេះត្រូវបានសាងសង់ឡើងដោយអ្នកជំនួញដែលមានទ្រព្យសម្បត្តិម្នាក់ ជាជនជាតិចិន ។ សំណង់នេះសាងសង់នៅរវាងឆ្នាំ ១៩១០ និង ១៩២០ យោងតាមផែនទីចាស់រាជធានីភ្នំពេញ សម័យអាណានិគមបារាំង ។ សំណង់អគារនេះមានពីរផ្នែក គឺ ផ្នែកខាងមុខ និងខាងក្រោយ ដោយភ្ជាប់គ្នាដោយជណ្តើរដើរឆ្លងនៅជាន់ទី១ ។ អគារនេះ សង់ដោយថ្ម បង្អួចឈើ និងកញ្ចក់ បាតក្រាលថ្ម និងពិដាន មានប្រភេទផ្សេងៗគ្នា ។

**គ,សារមន្ទីរជាតិ**( National maseum )



(Street 13 ,National Museum of Cambodia: 1920)

អគារដែលសាងសង់អំពីថ្មភក់មានពណ៌ក្រហមក្រមៅ ត្រូវបានគេស្គាល់ថាជា សារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជា។ សំណង់នេះយកតាមរចនាបទប្រាសាទអង្គរវត្ត ។ វាត្រូវបានសាងសង់ឡើងមានទម្រង់ជាប្រាសាទភ្នំសង់លើខឿនថ្មខ្ពស់ពីដី និងផ្នែកខ្លះមានកំពូលខ្ពស់រាងគ្នាដូចជាវិហារ ។ សារមន្ទីរនេះបានសាងសង់ដំណាលគ្នានិងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលមានទីតាំងនៅជាប់ខាងក្រោយនៃសារមន្ទីរនេះតែម្តង ។ សារមន្ទីរជាតិនេះត្រូវបានរចនានិងគូសប្លង់ដោយលោក George Groslier និងចាប់ផ្តើមសាងសង់នៅឆ្នាំ ១៩១៧ ហើយត្រូវបានសង់រួចរាល់និងបើកឲ្យដំនើរការនៅឆ្នាំ ១៩១៩ ដែលកាលនោះមានឈ្មោះថា Musée Albert Sarraut ។នៅឆ្នាំ ១៩៦១ សារមន្ទីរនេះបានប្តូរឈ្មោះជា សារមន្ទីរជាតិនៃព្រះរាជាណាចក្រកម្ពុជាវិញ ។ សំណង់នេះសង់រួចប្រើពេលអស់ពីរឆ្នាំកន្លះ ហើយត្រូវបានបើកសម្ពោធជាផ្លូវការដោយព្រះមហាក្សត្រ ព្រះបាទស៊ីសុវត្ថិ នៅថ្ងៃចូលឆ្នាំប្រពៃណីជាតិ នាថ្ងៃទី ១៤ មេសា ១៩២០ ។[26]

**ឃ,ផ្សារធំថ្មី ឬផ្សារថ្មី** ( Central Market )

[26] STHAPATYAKAM The Architecture of Cambodia (DMC) Royal University of phnom Penh,2012, pg ២០និង ២១



(Psah Thmei ('the New Market'): 1937)

ផ្សារថ្មី ត្រូវបានគេស្គាល់ថាជាមជ្ឈមណ្ឌលទីផ្សារដ៏ធំនៅកណ្តាលរាជធានីភ្នំពេញ ហើយជាអគារដ៏ល្បីមួយនៅសម័យអាណានិគមបារាំង។ ផ្សារថ្មីមានឈ្មោះពេញថា "ផ្សារធំថ្មី" ដែលបានកសាងឡើងនៅឆ្នាំ ១៩៣៥ និងសង់រួចជាស្ថាពរនៅឆ្នាំ១៩៣៧ ស្ថាបត្យករឈ្មោះ Jean Desbois វិស្វករឈ្មោះ Wladimir Kandarouoff និង Louis Chauchon ។ មុនមានសំណង់នេះ ទីតាំងនេះជាបឹង " បឹងតេជោ" ។ នៅឆ្នាំ ១៩៣៤ ពេលដែលព្រះបាទពញាយ៉ាតផ្លាស់ប្តូររាជធានីមកភ្នំពេញ ព្រះអង្គបានបញ្ជាឲ្យជីកបឹងនេះដើម្បីយកដីទៅសង់ទីទួលវត្តភ្នំ ហើយនិងប្រើដើម្បីរំដោះទឹកនៅរដូវវស្សា ។ កំឡុងសម័យបារាំងបឹងនេះបានចាក់លុបដើម្បីសាងសង់ផ្សារថ្មី ។ ផ្សារថ្មី មានលំនាំរចនាបទសិល្បៈឌីខូ(Art Deco ) ដែលមានកំពូលធំមួយនៅចំកណ្តាល និងមានស្លាបអគារបួនភ្ជាប់ជាមួយ។ កំពូល (ដោម)នៃផ្សារថ្មីមានទំហំ៣០ម និងកម្ពស់២៦ម។ចន្លោះពីស្លាបអគារមួយទៅមួយមានប្រវែង ៨៤ម និងកម្ពស់ ១២ម និងត្រូវបានជួសជុលឡើងវិញឆ្នាំ ២០១១ ។[27]

<u>**ខ,សណ្ឋាគាររ៉ាហ្វ៊ើលឡឺរ៉ូយ៉ាល់**( Raffles Hotel Le Royal )</u>



(Hotel Le Royal: 1929)

[27] : http://asialifeguide.com/Cover-Story/top-10-a-menu-of-phnom-penh-architecture.html

សណ្ឋាគារ Le Royal ត្រូវបានកសាងឡើងនៅឆ្នាំ ១៩២៩ នៅសម័យអាណានិគមបារាំង ដោយស្ថាបត្យករបារាំងឈ្មោះ Ernest Hebrard ។វាត្រូវបានស្ថាបនាឡើងតាមរចនាបទបារាំង តុបតែងឡើងយ៉ាងល្អប្រណិត រួមទាំងបំពាក់ដោយគ្រឿងសង្ហារឹមបែបខ្មែរ និងបារាំង។ សំណង់អគារនេះសង់តាមបែបបារាំង ប៉ុន្តែដំបូលសង់តាមរចនាបទខ្មែរ។ សណ្ឋាគារនេះមានការប្រែប្រួលឈ្មោះជាច្រើន ដូចជា នៅឆ្នាំ ១៩២៩ ឈ្មោះថា Le Royal ពីឆ្នាំ ១៩៧០ដល់១៩៧៥ មានឈ្មោះថា Le Phnom ដល់ក្រោយឆ្នាំ ១៩៧៩ ត្រូវគេដូរឈ្មោះថា សណ្ឋាគារសាមគ្គី និងរហូតដល់ឆ្នាំ ១៩៩៣ទើបបានប្តូរមកឈ្មោះដើមវិញរហូតដល់សព្វថ្ងៃ ។[28]

## ច,ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC )



ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) ត្រូវបានស្ថាបនាឡើងនៅរវាងឆ្នាំ ១៩៣៥ និង១៩៤៥ ដោយស្ថាបត្យករឈ្មោះថា Louis Chauchon ។ រាជការអាណាព្យាបាលបានប្រើអគារសំរាប់ធ្វើជាការិយាល័យរបស់ រេស៊ីដង់ប្រចាំប្រទេសកម្ពុជា(The Resident Superieur du Cambodge) ។ បន្ទាប់ពីUNTACT បានដកចេញពីប្រទេសកម្ពុជា អគារនេះបានចាប់ផ្តើមប្រើប្រាស់ឡើងវិញ ជាទីស្នាក់ការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) នៅឆ្នាំ ១៩៩៣ និង១៩៩៤ ។

## ឆ,បណ្ណាល័យជាតិ

[28] STHAPATYAKAM The Architecture of Cambodia (DMC) Royal University of phnom Penh,2012, pg ១៧



(National Library of Cambodia: 1924)

បណ្ណាល័យជាតិមានទីតាំងនៅខាងលិចវត្តភ្នំ។ វាត្រូវបានកសាងឡើងនៅឆ្នាំ ១៩២៤ ដោយ រដ្ឋាភិបាលអាណានិគមនៅឥណ្ឌូចិនក្នុងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ។ អគារនេះបានសង់ដោយស្ថាបត្យករជនជាតិបារាំង រលាយជាមួយរចនាបទបែបខ្មែរ ។ នៅខាងក្រៅអគារខាងស្តាំដៃមានរូបសំណាក់ព្រះវិស្ណុដែលតំណាងឲ្យប្រាជ្ញានិងចំណេះដឹង ។នៅលើជញ្ជាំងមានរចនាបទប្រាសាទខ្មែរ ដោយមានក្បាច់ផ្កាភ្ញីនិងក្បាច់ចំលាក់នៃជីវភាពរស់នៅនាសម័យអង្គរ ។ បណ្ណាល័យនេះបានបិទនៅសម័យខ្មែរក្រហម និងបានបើកឡើងវិញនៅឆ្នាំ ១៩៨០ ។

**ជ,បណ្ណសារជាតិកម្ពុជា**( National Archives of Cambodia )



មណ្ឌលឯកសារជាតិកម្ពុជា នៅខាងក្រោយ បណ្ណាល័យជាតិ មានលាបពណ៌លឿងខ្ចីមានបង្អួចជាច្រើនដែលអាចឲ្យខ្យល់អាចចេញចូលបានយ៉ាងល្អ ។ អគារនេះបានសាងសង់នៅឆ្នាំ ១៩២៦ ដោយរដ្ឋាភិបាលអាណានិគមបារាំង ។

**ឈ,ប្រៃសណីយ៍កម្ពុជា** ( Post Office )



(Post Office: 1894)

អគារប្រៃសណីយ៍ជាអគារមួយដែលមាននៅសម័យបារាំង ដែលមានទីតាំងនៅខាងលិចវត្តភ្នំ។ វាត្រូវបានសាងសង់នៅឆ្នាំ ១៨៩៥ដោយស្ថាបត្យករជនជាតិបារាំងឈ្មោះ Daniel Fabre ។ នៅជុំវិញនេះមានអគារមួយចំនួនបានសាងសង់ឡើងនៅសម័យបារាំង ដែលរួមទាំង អតីតទីស្នាក់ការប៉ូលីស(ស្ថាបនានៅឆ្នាំ១៩២៥និង១៩៣៥) អតីតធានាគារឥណ្ឌូចិន(សង់កំឡុងឆ្នាំ១៩០០) ជាដើម។ អគារនេះបានស្ថាបនាដោយលាយបញ្ចូលគ្នារវាងរចនាបទបែបបារាំង និងអាស៊ី ហើយអគារនេះត្រូវបានជួសជុល និងបើកឡើងវិញនៅឆ្នាំ ២០០៤ ។

**ញ,វិទ្យាល័យព្រះស៊ីសុវត្ថិ**( Preah Sisowath High School )



វិទ្យាល័យព្រះស៊ីសុវត្ថិ ជាអគារដ៏ចំណាស់មួយនៅក្នុងទីក្រុងភ្នំពេញ និងជាអគារមានភាពល្បីល្បាញ ។ វិទ្យាល័យនេះបានកសាងនៅឆ្នាំ ១៨៧៣ ជាសាលារបស់រដ្ឋបាលបារាំង ដោយស្ថាបត្យករ Francois –Fontaine ។ នៅឆ្នាំ១៨៩៣ សាលានេះបានក្លាយទៅជាមហាវិទ្យាល័យរដ្ឋបាលអាណានិគម។ នៅឆ្នាំ ១៩០៥ សាលានេះមានឈ្មោះថា លីសេស៊ីសុវត្ថិ (Lycee Sisowath) សាលានេះត្រូវបានបិទនៅសម័យប៉ុល ពត ហើយបើកឲ្យដំណើរការវិញនៅឆ្នាំ ១៩៨០ ។

**ដ,ស្ថានីយ៍រថភ្លើង**( Train station )




(Phnom Penh Railway Station: 1932)

ស្ថានីយ៍នេះមានទីតាំងស្ថិត បន្ទាប់ពីសាកលវិទ្យាល័យសុខាភិបាល និងសាកលវិទ្យាល័យជាតិគ្រប់គ្រង ។ អគារនេះសល់ពីសម័យអាណានិគមបារាំងសាងសង់ឡើងនៅឆ្នាំ ១៩៣២ ស្ថាបត្យករមិនស្គាល់ឈ្មោះ ។ សំណង់ស្ថានិយ៍នេះមានលក្ខណៈស្រដៀងនិងរចនាបទផ្សារថ្មី ។[29]

**ថ,រោងកុនលុច** ( Cine Lux )







សំណង់អគារនេះបានសង់ឡើងនៅឆ្នាំ ១៩៣៨ ជារោងកុនដែលមានវ័យចំណាស់នៅទីក្រុងភ្នំពេញ។ សំណង់នេះធ្វើតាមរចនាបទទំនើប (Art Deco Style) ដោយស្ថាបត្យករជនជាតិបារាំងឈ្មោះ Ronger Colne ។ រោងកុននេះដំណើរការរហូតដើមឆ្នាំ ១៩៩០ សំរាប់សកម្មភាពសិល្បៈផ្សេងៗមាន វិស័យភាពយន្ត មហោស្រពសំដែងសិល្បៈ មានកៅអីសរុប ៦៥០ ។ ហើយត្រូវបានបើកឡើងវិញ នៅឆ្នាំ ២០០១ បន្ទាប់ពីជួសជុលរួច ជារោងកុនខ្នាតធំទំហំ ៣៥មម ដែលនៅទសវត្សឆ្នាំ ១៩៦០ ដែលសម័យ

[29] http://www.antkh.com/project/visit_cambodia/image/Cambodian%20Architectural%20Heritages.pdf

នោះ មានរោងកុន ហេម៉ាក់ជាតិ(Hemakcheat) ប៉ូកគោ គីរីរម្យ ដែលបច្ចុប្បន្ន ប្រែក្លាយជា ផ្ទះល្វែង ភោជនីយដ្ឋាន ឬកន្លែងខារ៉ាអូខេ ។[30]

ក្រៅពីនេះនៅមានសំណង់អគារជាច្រើនទៀត ដែល បានសាងសង់នៅសម័យអាណានិគមបារាំង ដែលខ្លះក៏នៅរូបរាង និងខ្លះទៀតត្រូវបានគេវាយចោលនិងសង់សំណង់ផ្សេងជំនួសវិញ ។

## ២. ស្ថាបត្យកម្មសម័យសង្គមរាស្ត្រនិយម

នៅឆ្នាំ១៩៥៣ភ្នំពេញបានក្លាយជារាជធានី នៃកម្ពុជាឯករាជ្យ ។ ក្រោមព្រះរាជ្យកិច្ចដឹកនាំ របស់សម្តេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ការងារសាធារណៈការធំៗត្រូវចាប់ធ្វើ នៅកន្លុងរាជធានី និងនៅទាំងព្រះរាជាណាចក្រកម្ពុជា ។ពេលនៅមានតម្រូវការអោយសាងសង់អាគារជាច្រើន ដើម្បី ស្ថាប័នជាតិថ្មីៗជាច្រើន ដែលបង្កើតឡើង ជាកត្តាជំរុញបង្កើតថ្មីច្រើន ក្នុងវិស័យស្ថាបត្យកម្ម ។ការបង្កើត ថ្មីនោះតែងសង្កត់ធ្ងន់ទៅលើ អត្តសញ្ញាណជាតិថ្មីមួយដែលចូលប្រឡូកក្នុងឆាកអន្តរជាតិ ។អាគារសធារណៈព្រមទាំងហេដ្ឋារចនាសម្ព័ពទាំងពួង ក៏ផុសចេញពាសពេញជាការទាកទាញ ប្រជាជនពីជនបទ មករសនៅទីនេះ ហើយក្នុងរយៈពេលក្នុងមិនបាន១៥ឆ្នាំផង ផ្ទៃដីភ្នំពេញ រីកឡើង មួយជាពីរ។

វាក្យសព្ទដែលអ្នករៀបចំទីក្រុងនិងស្ថាបត្យករ ស្រុះស្រួលគ្នាយកមកប្រើសម្រាប់ អាគារថ្មីៗ នោះ សុទ្ធសឹងតែឆ្លុះបញ្ចាំងពីរចនាបថខ្មែរថ្មីសម្មួយឯករាជ្យ ។រចនាបថនេះ ជាលក្ខណៈអាគាររដ្ឋ សំខាន់ៗ ដូចជាសកលវិទ្យាល័យរដ្ឋនានា ក្រសួងផ្សេងៗ ពហុកីឡាដ្ឋានជាតិជាដើម ផ្ទៃដីដ៏ធំនៃរាជធានី ត្រូវរៀបចំអោយទៅជាឧទ្យានជាតិ ដែលព័ទ្ធទៅដោយអាងទឹក អ្វីដែឡមានប្រសិទ្ធ ភាពទប់ទល់ពន្លឺ និងកំដៅថ្ងៃខ្លាំង ដោយប្រពិតានបេតុង តើអ្វីដែលការពារទឹកបាន ប្រសើរជាជាងផ្ទះ លើកផុតពីដី នៃ le Coobusier (ពោលគឺការសាងសង់អាគារ ដោយស្រង់មូលដ្ឋានពីសំណង់ផ្ទះឈើ ដែលតែងតែមានសរសេរ លើកផ្ទះអោយផុតពីដី ដើម្បីចៀសផុត ពីទឹកជំនន់ ជោរមកក្នុងភូមិរាល់ថ្ងៃ ) នៅទៅទៀត ? ដងផ្លូវធំៗនៃរាជធានីក្រោយពីបាន ឯករាជ្យ នេះ បានបង្ហាញពីភាពពីសេសនៃរាជធានី ភ្នំពេញ ដែលពោរពេញទៅដោយសួនច្បារ។

### ២.១. ពហុកីឡាកដ្ឋានជាតិអូឡាំពិច

ពហុកីឡាក់ដ្ឋានជាតិ បានស្ថានឮបនាក្រោយ ភ្នំពេញបានទទួលនាទីរៀបចំការប្រកួតកីឡាលើកទីបីនៃអាស៊ីអាគ្នេយ៍នៅឆ្នាំ១៩៦៥ ។ពហុកីឡាដ្ឋាន នេះស្ថាបនាឡើងនៅលើវាលវង់ចាស់មួយ ។ទ្រង់

[30] STHAPATYAKAM The Architecture of Cambodia (DMC) Royal University of phnom Penh,2012, pg ១៩

ទ្រាយនៃពហុកីឡាដ្ឋានគឺយកតាមលំនាំនៃប្រាសាទ អង្គរវត្ត។ក្នុងបរិវេណនោះ មានលានកីឡាមួយ ដែលពាត់ដោយជម្រាលច្រាំង រួមនិងវេទិការមួយ ដែល ភ្ជាប់និងរោងលេងកីឡា(រោងកីឡាខាងក្នុង)។ អាងហែលទឹកនិងវាលលេងកីឡាផ្សេងៗ គ្រប់មុខ រៀបចំដោយមានឧទ្យានមួយពទ្ធ័ជុំវិញ ។ អាងហែលទឹកស្ថាបនាឡើង ប្រៀបប្រដូចនិងគូទឹកពទ្ធ័ជុំវិញ ប្រសាទបុរណ ហើយប្រើប្រាស់ ជាប្រព័ន្ធបង្ហូរទឹកចេញ ។

<u>រូបភាពពហុកីឡាក់ដ្ឋានជាតិអូឡាំពិច</u>



## ២.២. សំណង់ប៉ុលខិញ

សំណាងប៉ុលខិញ(Front du Bassac)កសាងនៅត្រើតខាងលិចទន្លេបាសាក់ ដដែលជាដំបូងស្ថាបនាឡើងសម្រាប អោយកីឡាកចូលរួមល្បែងអាស៊ីអាគ្នេយ៍លើកទីបីទាំងអស់ ស្នាក់នៅ។ អាគារផ្ទះល្វែងនេះ គឺជាការសាល្បងលើកដំបូង បង្កើតប្រភេទប្រភេទផ្ទះថ្មីនៅក្នុងក្រុង សម្រាប់ ខ្មែរដែលមានល្វែងនៅត្រួតលើគ្នារៀបចំឡើងជាពីជួរប្រសព្វគ្នា ព័ទ្ធជុំវិញដោយសួនច្បារ។ ផ្ទះនីមួយមានកន្លែងបើកទូលាយ ហើយផ្ទះបាយនៅក្រៅ ដាច់ពីបន្ទប់រស់នៅ ដែលរៀបចំឡើងតាម លំនាំ ផ្ទះខ្មែរដោយគិតគូអំពីទិសខ្យល់មកនៅតំបន់នោះ ហើយនិងកន្លែងខ្យល់ចេញចូល ដើម្បីចៀស វាងការប្រើម៉ាស៊ីនត្រជាក់ មហោស្រព្រះបាទសុរាម្រឹត ដែលបានស្ថាបនាឡើងនៅពៅមុខ"អាគារបុល ខិញ"ក៏មានបង្ហាញពីស្ថាបត្យកម្មខ្មែរដែរ ដោយយកលំនាំតាមជ្រោយចង្វារដែលលយនៅទីប្រសព្វមុខទន្លេ ។ កន្លែងទទួលភ្ញៀវនៃរោងមហោស្រព មានរាងត្រីកោណ ដែលរៀបចំលម្អដោយរៀបចំពន្លឺ និងទឹក នៅជុំវិញជណ្តើរច្រើនជាន់។

ទសវត្ស១០៥០និង១៩៦០ មិនត្រឹមជាសម័យបើកទ្វាទៅរកស្ថាបត្យកម្មថ្មី ហើយនិងស្ថាបនាសំណង់ផ្សេងៗ នៅកម្ពុជាតែប៉ុណ្ណោះទេ។ រយៈពេលពីរទសវត្សនេះ ក៏ជាសម័យបង្កើតហេដ្ឋារចនាសម្ព័ន្ធធំៗ ព្រមទាំងគម្រោងទូទៅនៃការរៀបចំលំអក្រុងស្របទៅតាមការផ្លាស់ប្តូរយ៉ាងខ្លាំងនៃក្រុងដែលមានមក ហើយផងដែរ ។ការពង្រីកផ្ទៃដីក្រុងអោយកាន់តែធំទៅៗ កកើតឡើងក្នុងរយៈពេល នេះដែរ ។

រូបភាពសំណង់ប៉ុលឌិញ



## ២.៣. ភ្នំពេញថ្មី

នៅឆ្នាំ១៩៦០ គម្រោងបង្កើត"ភ្នំពេញថ្មី "ត្រូវបានគិតគូរឡើង។ នេះជាផែនការពង្រីកក្រុងដែលមានស្រាប់ ទៅខាងពាយព្យ ទៅតាមគោលការណ៍នៃ Athens Charter ដោយរៀបចំអោយចរាចរណ៍យានយន្តនិងផ្លូវថ្មើរជើងដាច់ពីគ្នា តែដែលភ្ជាប់តំបន់ផ្សេងៗគ្នាដេលមានមុខងារ ច្បាស់លាស់(លំនៅស្ថាន,ពាណិជ្ជកម្ម,ឧស្សាហាកម្ម,មណ្ឌលក្រុង)។ ទោះបីយ៉ាងណា ក៏អត្រាកំនើនប្រជាជននៅ ពេលនោះមិនទាន់តម្រូវអោយមានផែនការដ៏ធំយ៉ាងនេះទេ ហើយថវិការក៏មិនមានគ្រប់គ្រាន់ សម្រាប់ សម្រេចគម្រោងនេះដែរ ។ដើម្បីជំនួសការអភិវឌ្ឍន៍ក្រុងក្នុងកម្មវិធី មួយធំធេងនោះមានគម្រោងតូចៗ ធម្មតា។គឺក្នុងគោលការណ៍នេះហើយដែលតំបន់ទួលគោករៀបចំកើតជា"ក្រុងសួនច្បារ "លេចរាង សាយ ចេញក្រៅជុំវិញបង្គោលស្ថានីយ៍ទូគមនាគមន៍ថ្មី ដែលស្ថាបនានៅជ្រុងពាយ័ព្យនៃក្រុង ហើយដែលចប់ស្រេចបាច់នៅឆ្នាំ១៩៦២-១៩៦៣។

ព្រមជាមួយគ្នានោះមណ្ឌលនៃរាជធានី ក៏ត្រូវបានរៀបចំស្ថាបនា និងកែលម្អអោយកាន់តែ ប្រសើរឡើងដែរ។នៅខាងត្បូងព្រះមរមរាជវាំង ត្រពាំងមួយដែលស្ថិតនៅពីមុខវត្តបទុមវតីក្លាយជាសួន ច្បារសធារណ:យ៉ាងធំ។ ព្រៃកជិករត់លិច-កើតជាប់នៅខាងត្បូងសួនច្បារនេះ កើតជាវិថីភ្លោះមួយ ដែលមានសួនច្បារមួយនៅកណ្តាល ហើយនិងមានអាងបាញ់ទឹក ជាច្រើននៅលើឧទ្យាននោះ។វិមាន ឯករាជ្យស្ថិតនៅចំកណ្តាល ឧទ្យានថ្មីនេះ។ ទ្រង់ទ្រាយនៃវិមាននេះស្រង់ពីរចនាបថអង្គរ ដែលសាង ឡើងបញ្ចូលក្នុងទស្សន:នៃ le Corbusier ក្នុងការកំណត់ខ្នាតសំណង់ផ្សេងៗ ដែលនៅក្នុងលំហាមួយ ជាមួយគ្នា។

## ២.៤. វាលយន្តហោះពោធិចិនតុង

ជាមួយពេលនិងសម្ពោធប្រើប្រាស់វាលយន្តហោះអន្តរជាតិពោធិចិនតុងនាឆ្នាំ ១៩៥៩ ផ្លូវដែលភ្ជាប់ពិវាលយន្តហោះ មកក្រុងត្រូវពង្រីកអោយទៅជារុក្ខវិថីធំមួយ ដោយមានសួនច្បារ មួយខ្សែវែង ចែកផ្លូវអោយដាច់ពីគ្នា រុក្ខវិថីនេះរត់មកជាប់និងរបងខាងត្បូងនៃសាកលវិទ្យាល៧យថ្មីមួយ និងវិទ្យា ស្ថានបច្ចេកទេស ហើយរត់នៅខាងជើងអាគារក្រសួងថ្មី និងទីស្តីការគណ:រដ្ឋមន្ត្រី។ មិនយូប៉ុន្មាន រុក្ខវិថីនេះក៏

ក្លាយទៅជាសសរទ្រូងសំខាន់មួយ ដែលនាំទេសចរណ៍ចូលមក ក្នុងរាជធានីនៃ ព្រះរាជាណាចក្រកម្ពុជា ដែលទើបតែបានឯករាជ្យថ្មីៗ ដូចគ្នានិងនេះដែរនៅក្បែរពុកីឡាដ្ឋាន សង្កាត់មួយ ដែលមានអាគារវប្បធម៌ និងពាណិជ្ជកម្មរីក ឡើងដោយមានវត្តព្រមទាំងផ្សារនៅជិតៗ នោះ។ដើម្បីបំពេញគម្រោងនគរពនីយកម្មធំដូចនេះ ព្រៃកនិងបឹងដែលមានតម្រូវដីបំពេញ ហើយលានដីធំៗ ត្រូវពាត់ដោយទំនប់ បន្ទាប់មកត្រូវបំពេញអោយមានផ្ទៃស្មើ ដោយបូមដីល្បាប់ ពីបាតទន្លេ មកចាក់ៗរោងមហោស្រពជាតិក៏ដូចជា អាគារ " ប៊ុលឌីង "ដែរគឺសុទ្ធតែស្ថាប់នាឡើងលើលានចាក់ដី បំពេញទាំងអស់ ។

<u>រូបភាព្រលានយន្តហោះពោចិនតុង</u>




## ២.៥. វិមានឯករាជ្យ

វិមានឯករាជ្យ ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៥៨ ក្នុងរាជ្យព្រះបាទនរោត្តម សុរាម្រិត (១៩៥៥-១៩៦០) ជានិមិត្តរូបបញ្ជាក់ថាកម្ពុជា បានទទួលឯករាជ្យពីបារាំងនៅឆ្នាំ ១៩៥៣ ។ វិមានឯករាជ្យមានទីតាំងស្ថិតនៅ ផ្លូវប្រសព្វគ្នា រវាងមហាវិថីព្រះនរោត្តម និងមហាវិថីព្រះសីហនុ ចំកណ្តាលក្រុងភ្នំពេញ[31]។

វិមានឯករាជ្យមានកំពស់ ២០ម៉ែត្រ មាន៥ជាន់ លំអដោយក្បាល ពស់នាគរាជចំនួន១០០ សង់តាមគំរូរចនាបរបស់អង្គរ រចនាប្លង់ដោយ ស្ថាបត្យករល្បីល្បាញគឺលោក វណ្ណ ម៉ូលីវណ្ណ ។

<u>រូបភាពវិមានឯករាជ្យ</u>

[31] សៀវភៅបុរីខ្មែរសម័យទំនើបអ្នកនិពន្ធឈ្មោះវណ្ណ ម៉ូលីវណ្ណទំព័រ១៦៧.១៦៨.១៧១-១៧៦




### ៣. ស្ថាបត្យកម្មសម័យសាធារណៈរដ្ឋខ្មែរ

តាំងពីដំណាក់កាលដំបូងនៃសង្គ្រាម វិស័យដែលប៉ះពាល់ខ្លាំងជាងគេ គឺគមនាគម៍។ នៅឆ្នាំ ១៩៧០ តាមផ្លូវគមនាគមន៍ធំៗនៅមានសន្តិសុខនៅឡើយ។ គមនាគមន៍មានសារៈសំខាន់សំរាប់បង្ហូរទំនិញគ្រប់ប្រភេទ ពីតំបន់មួយទៅតំបន់មួយទៀត ក៏ប៉ុន្តែសង្គ្រាមត្រូវបានកាត់ផ្តាច់ដង្ហើមសេដ្ឋកិច្ចទាំងនេះអោយធ្លាក់ដល់សូន្យ។ ដោយជួបនូវការលំបាកបែបនេះក្រសួងការពារជាតិបានបង្កើតអង្គភាពមួយដែលមានឈ្មោះថា សាធារណៈការនិង ទេពកោសល្យជនបទ ដើម្បីថែរក្សាប្រព័ន្ធគមនាគមន៍។ អង្គភាពនេះបានក្លាយទៅជាក្រសួងសាធារណៈការនិង ទេពកោសល្យជនបទ នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ១៩៧០ ដែលមានលោក អ៊ឹង ក្រពុំផ្កា ជារដ្ឋមន្ត្រី[32] ។

ក្រសួងទើបបង្កើតថ្មីនេះមានតួនាទីក្នុងការការពារសេដ្ឋកិច្ច ដែលចរាចរណ៍លើគមនាគមន៍គ្រប់ប្រភេទតាមរយះការពង្រឹង និង ការការពារសំណង់ ដែលបានសាងសង់រួចមកហើយ ដូចជាការជួសជុលស្ពាន ថ្នល់ កំពង់ចម្លង ផ្លូវដែក និង ជួសជុលកំពង់ផែ ។ ទាំងអស់នេះហើយគឺសំរាប់ការប្រកបអាជីវកម្មក្នុងពេលសង្គ្រាម។ ក្រសួងសាធារណៈការ និងទេពកោសល្យជនបទបើយើងប្រៀបធៀបមកដល់បច្ចុប្បន្ន មានតួនាទីប្រហាក់ប្រហែលនិង កងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទដូច្នោះដែរ ។

ចាប់ពីឆ្នាំ ១៩៧៣មក ខ្មែរក្រហមបានកាត់ផ្តាច់គមនាគមន៍សំខាន់ៗ ដែលជាដង្ហើមរបស់ក្រុងភ្នំពេញជាអន្លើៗលើ ផ្លូវជាតិលេខ ៤ ក្នុងតំបន់ខេត្ត កំពង់ស្ពឺ ផ្លូវជាតិលេខ៥ ផ្លូវជាតិសំខាន់ៗមួយចំនួនទៀត និងនៅតាមផ្លូវទឹកតាមទន្លេបាសាក់ និងទន្លេមេគង្គ ។ ឯផ្លូវជាតិ ដែលអាចធ្វើចរាចរណ៍បានយូរជាងគេគឺ ផ្លូវជាតិលេខ ២ ។ លុះក្រោយមកអសន្តិសុខតាមផ្លូវគមនាគមន៍រីករាលដាលខ្លាំងពេញផ្ទៃប្រទេស ជាពិសេស ផ្លូវរថភ្លើង ពីភ្នំពេញ ទៅ បាត់ដំបង និង ភ្នំពេញ ទៅ កំពង់សោម។ នៅឆ្នាំ ១៩៧៤ ប

[32] ដកស្រង់ពី សៀវភៅប្រវត្តសាស្ត្រខ្មែរ ដោយសាស្ត្រាចារ្យ ពៅ សារឿន នៃសាលកវីទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច

ណ្តាញគមនាគមន៍ទាំងអស់ត្រូវបានកាត់ផ្តាច់ជាស្ថាពរដោយកងទ័ព កំម្មុយនីស្ត ។ ដង្ហើមសេដ្ឋកិច្ចសាធារណៈខ្មែរនៅសល់តែផ្លូវទឹក និង ផ្លូវអាកាសប៉ុណ្ណោះ ប៉ុន្តែចាប់ពីឆ្នាំ ១៩៧៥ មក ផ្លូវទឹកក៏ត្រូវកាត់ផ្តាច់ចំណែកព្រលានយន្តហោះពោធិ៍ចិនតុង ក៏ត្រូវរងគ្រោះដោយសារគ្រាប់ផ្លោងស្ទើរតែរាល់ថ្ងៃដែរ។ ផ្លូវ និង ស្ពាន សំខាន់ៗត្រូវរងការវាយប្រហារដោយគ្រាប់បែក។ ដោយយុទ្ធសាស្ត្រ បំផ្លាញខ្លួនឯងបែបនេះហើយដែលធ្វើអោយហេដ្ឋារចនាសម្ព័ន្ធវស័យ គមនាគមន៍នៅប្រទេសកម្ពុជាធ្លាក់ចុះទៅក្នុងវិបត្តិមកដល់សព្វថ្ងៃនេះ ។

## សេចក្តីសន្និដ្ឋាន

ចាប់ពីរដ្ឋខ្មែរចាប់បដិសន្ធិចេញជារូបរាងជាលើកដំបូងងនៃប្រវត្តិសាស្ត្រខ្មែរ នាសម័យនគរភ្នំ ឬសម័យហ្វូណនដែលមានក្សត្រីជាអ្នកដឹកនាំនគរគឺព្រះនាង សោមា ឬលាវយី ។ ក្រោយមកព្រះនាងបានចម្បាំងចាញ់ព្រះអង្គកៅឌិញ្ញ ឬព្រះថោង បន្ទាប់មកអ្នកទាំងពីរក៏បានរៀបអភិសេកជាមួយព្រះនាងគ្រងរាជសម្បត្តិនៅនគរភ្នំតែម្តង។ក្នុងសម័យនគរភ្នំឬហ្វូណនមួយខ្មែរមានទឹកដីធំទូលំទូលាយ ដែលបានលាតសន្ធឹងពីព្រំប្រទល់ជាប់ប្រទេសចម្ប៉ានៅទិសខាងកើត រហូតទល់នឹងទឹកដីប្រទេសចិន នៅទិសខាងជើង ហើយខាងលិចជាប់នឹងប្រទេភូមា ។ ឃើញថានៅសម័យនគរភ្នំទឹកដីធំហើយសំបូរដីដែលមានជីវជាតិជាអំណោយផលពីធម្មជាតិនោះ ព្រះមហាខ្មែរក្នុងសម័យនោះក៏បានរៀបចំកសាងរាជធានីឈ្មោះថាវ្យាធបុរៈ ដែលមានទីតាំងនៅបាភ្នំ ខេត្តព្រៃវែងបច្ចុប្បន្ន ។ ការកសាងរាជធានីក្នុងសម័យនោះបានធ្វើឡើងអំពីឈើសង់លើគ្រឹះអំពីថ្មហើយមួយផ្នែកធំធ្វើអំពីឥដ្ឋ ។ ក្រោយមកបុព្វបុរសខ្មែលោកមានគំនិតសិល្បៈនៃការកសាងប្រាសាទជាច្រើន ហើយសិល្បៈនៃការកសាងប្រាសាទនៅសម័យនគរភ្នំនៃស.វទី១ ដល់ស.វទី ២ ភាគច្រើនប្រាសាទគេបានចោះ ឬលុងភ្នំធ្វើជាប្រាសាទមានដូចជាប្រាសាទភ្នំដាជាដើម នៅខេត្តតាកែវ ស្រុងអង្គរបុរីសព្វថ្ងៃ ហើយសិល្បៈនៃធ្វើប្រាសាទនេះមានលក្ខណៈស្រដៀងនឹងការធ្វើប្រាសាទនៅប្រទេសឥណ្ឌា ។ ហេតុនាំឲ្យលក្ខណៈប្រហាក់ប្រហែលគ្នារវាងប្រាសាទខ្មែរ និងឥណ្ឌាមកពីសម័យនគរភ្នំរងឥទ្ធិពលពីឥណ្ឌា ទាំងវប្បធម៌ ជំនឿសាសនា ។ ការកសាងប្រាសាទនៅសម័យនគរភ្នំដែលបានចោះលុងភ្នំធម្មជាតិធ្វើប្រាសាទហ្នឹង គឺបង្កើតបានជារចនាបថមួយឈ្មោះថារចនាបថភ្នំដា ។

បន្ទាប់ពីសម័យនគរភ្នំមកតាមប្រវត្តិសាស្ត្រឃើញថា មានការវិវត្តជាលំដាប់នៃសិល្បៈស្ថាបនាប្រាង្គប្រាសាទពីការចោះលុងភ្នំធ្វើប្រាសាទដោយយក ថ្មបាយក្រៀម ឥដ្ឋតាន់ និងថ្មភក់មកសាងសង់ជាប្រាសាទ គឺសម័យចេនឡា ។ ទឡ្ហីករណ៍ប្រាសាទសាងសងអំពី ថ្មបាយក្រៀម និងថ្មភក់មានជាអាទិ៍

ប្រាសាទសំបូរព្រៃគុក ប្រាសាទភ្នំជើងព្រៃជាដើម ហើយការកសាងប្រាសាទនៅសម័យចេនឡាជារចនាបថសំបូរព្រៃគុក ។

នៅសម័យអង្គរជាសម័យមួយ ដែលប្រទេសខ្មែរយើងឈានដល់អារ្យប្រទេសដែលមានការរីកចម្រើនយ៉ាងខ្លាំងគ្រប់វិស័យ ហើយជាសម័យដែលប្រទេសខ្មែរយើងប្រែក្លាយជាប្រទេសអាណាចក្រខ្មែរមានកិត្យានុភាពល្បីល្បាញសុះសាយទៅពិភពខាងក្រៅ និងជាប្រទេសចាស់ និងធំជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ក្នុងសម័យអង្គរ តាមផ្ទាំងប្រវត្តិសាស្ត្រខ្មែរយើងនឹងឃើញថាជាសម័យកាលដែលប្រទេសយើងសំបូរសប្បាយ មានការសាងសង់ប្រាង្គប្រាសាទច្រើនជាងគេក្នុងប្រវត្តិសាស្ត្រខ្មែរយើង ។ ការសាងសង់ប្រាសាទក្នុងសម័យអង្គរបុព្វបុរសយើង លោកមានប្រាជ្ញាខ្ពង់ខ្ពស់ ពោរពេញដោយទេពកោសល្យគំនិតច្នៃប្រឌិតអច្ឆរិយភាព ក្នុងការកសាងប្រាសាទមានជាអាទិ៍ ប្រាសាទអង្គរធំ ប្រាសាទអង្គរតូច ឬប្រាសាទអង្គរដែលបានចាប់បដិសន្ធិឡើងនៅសតវត្សទី១២ ចន្លោះឆ្នាំ(១១១៣ --១១៥០)ដោយព្រះបាទសូរ្យវរ្ម័នទី២ និងបញ្ចប់ដោយព្រះបាទជ័យវរ្ម័នទី៧ ដែលជាអង្គក្សត្របានស្ថាបនាប្រាសាទអង្គរជាស្ថាពរ ។ បើយើងក្រឡេកមើលប្រាសាទលើទឹកដីអង្គរដ៏ស្រស់បវរនៃយើងជាពិសេសប្រាសាទអង្គតែម្តង ដែលជាស្នាដៃល្អឯកគ្មានគូប្រៀបលើលោក មានក្រុមអ្នកស្រាវជ្រាវបរទេសល្បីៗបានសរសើរថាជាវណ្ណកម្មដ៏អស្ចារ្យដែលហួសពីនិស្ស័យមនុស្សពោលគឺមានតែព្រះអាទិទេពទេ ដែលអាចធ្វើប្រាសាទអង្គរនេះបាន ព្រោះអង្គរកសាងដោយថ្មទាំងផ្ទាំងៗយកមកតំរាប់គ្នាដែលមានទម្ងន់រាប់រយតោន និងយកមកពីភ្នំគូលែនឆ្ងាយពីអង្គរបាន ។ បើយើងនិយាយពីតំរិះប្រាជ្ញាវិញ បុព្វបុរសយើងនាសម័យពិតជាសំបូរអ្នកប្រាជ្ញមែន ទាំងផ្នែកអក្សរសាស្ត្រ គណិតសាស្ត្រ យុទ្ធសាស្ត្រទ័ព ទស្សនៈកសាងរាជធានីអង្គរដែលស្គាល់ពីភូមិសាស្ត្រច្បាស់លាស់មុននឹងសាងសង់ប្រាសាទ ។ និយាយពីស្ថាបត្យកម្មវិញទាំងបច្ចេកទេសរចនាបថ ការរៀបចំតំបន់អង្គរពិតមានលក្ខណៈល្អ មានសោភ័ណ្ឌភាព ក្បាច់ក្បូររចនាល្អវិចិត្រ មានរបៀបរាបរយ មានក្បួចខ្នាតច្បាស់លាស់ពោលគឺមានប្លង់មេ ។

ក្រោយពីសម័យអង្គរយើងឃើញថាប្រទេសយើងមានការធ្លាក់ចុះជាលំដាប់ទាំងនយោបាយ សេដ្ឋកិច្ច ទឹកដីចេះតែរួញទៅៗដោយច្បាំងចាញ់សត្រូវជិតខាងថៃ យួន ។ បើនិយាយពីការកសាងស្រុកទេសវិញ គឺមានការសាងសងរាជធានី ប្រាសាទខ្លះៗ ដែរ តែមិនមានលក្ខណៈជាដុំកំភួនអ្វីទេ ។ រហូតដល់សម័យអាណានិយគមនិយមបារាំងឆ្នាំ(១៨៦៣-១៩៥៣) ដែលយើងអាចចាត់ទុកថាជាស្ថាបត្យកម្មសម័យទំនើប ពីព្រោះមានការសាងសងអគ្គាសាលា ស្ថាប័នរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈទំនើបកម្មជាមុនគឺគេប្រើបច្ចេកទេសនៃកសាងតាមបែបអឺរ៉ុប ដោយប្រើប្រាស់ ស៊ីម៉ង ខ្សាច់ ដែក ថ្ម មកជំនួស បាយអ

ផ្ទាំងថ្មទាំងផ្ទាំងៗយកមករៀបជាប្រាសាទទៀតហើយ ជាក់ស្តែងព្រះបរមរាជវាំងបច្ចុប្បន្ន បណ្ណាល័យជាតិ សណ្ឋាគារ LE ROYAL សារមន្ទីជាតិ វិទ្យាល័យស៊ីសុវត្ថិ ។ នៅសម័យសង្គមរាស្ត្រនិយមសិល្ប:ស្ថាបត្យកម្មមានការរីកលូតលាស់គួរឲ្យកត់សម្គាល់ផងដែរ មានជាអាទ៏ ពហុកីឡាដ្ឋានអូឡាំពិច វិមានឯករាជ្យ សាលចតុមុខ ដែលជាស្នាដៃកូនខ្មែរជំនាន់ក្រោយគឺលោកតា វណ្ណ ម៉ូនលីវណ្ណ ។

និយាយជារួមស្ថាបត្យកម្មខ្មែរចាប់តាំងពីសម័យនគរភ្នំ ឬហ្វូណនរហូតមកដល់ស្ថាបត្យកម្មសម័យទំនើប ឃើញថាមានតែស្ថាបត្យកម្មសម័យអង្គរទេ ដែលមានការរីកចម្រើនខ្លាំងក្លាសំបូរប្រាង្គប្រាសាទជាច្រើន និងមានលក្ខណ:អស្ចារ្យនៃប្រាសាទគឺប្រាសាទអង្គរតែម្តង ។

## ឯកសារយោង

### ក, ឯកសារដក់ស្រង់ពីសៀវភៅ៖


១,សៀវភៅប្រវត្តិសាស្ត្រខ្មែរ និពន្ធដោយលោក ត្រឹង ងា បោះពុម្ពឆ្នាំ២០០១

២,សៀវភៅលំនៅដ្ឋានខ្មែររបស់លោកសាស្ត្រាចារ្យ ហ៊ឺ ចិន្តា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ បោះពុម្ភឆ្នាំ២០១០។

៣,សៀវភៅស្ថាបត្យកម្មសាកល រៀបរៀងដោយ វ៉ា សុវណ្ណរដ្ឋ បោះពុម្ពបណ្ណាគារអង្គរ ២០០៧

៤,សៀវភៅប្រវត្តិនគររូបនីយកម្មនៅកម្ពុជារៀបរៀងដោយ បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពផ្សាយឆ្នាំ ២០១២

៥,សៀវភៅ ប្រវត្តិសាស្ត្រ នៃប្រទេសកម្ពុជា (ការបង្កើតរដ្ឋខ្មែរ) និពន្ធដោយបណ្ឌិត មីសែល ត្រាណេរបោះពុម្ភឆ្នាំ ២០០២។

៦,សៀវភៅប្រវត្តសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា របស់លោកសាស្ត្រាចារ្យ ឥន្ទ ឱមសាម៉េង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ពឆ្នាំ ២០០៩។

៧,សៀវភៅប្រវត្តសាស្ត្រខ្មែរ និពន្ធដោយលោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ភផ្សាយឆ្នាំ ២០១០។

៨, សៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា ចាប់តាំងពីសតវត្សទី១ ដល់ស.វទី ២១ និពន្ធដោយលោក អាដេម៉ាឡឺក្លែរ

៩, សៀវភៅកំណត់ត្រារបស់លោកជីវ តាក្វាន់។

១០,សៀវភៅបុរីខ្មែរសម័យទំនើប អ្នកនិពន្ធឈ្មោះវណ្ណ ម៉ូលីវណ្ណ

១១, សៀវភៅ STHAPATYAKAM The Architecture of Cambodia (DMC) Royal University of Phnom Penh, ឆ្នាំ2012។

## ខ, ឯកសារដកស្រង់ពីគេហទំព័រ៖


១, http://asialifeguide.com/Cover-Story/top-10-a-menu-of-phnom-penh-architecture.html

២,http://www.antkh.com/project/visit_cambodia/image/Cambodian%20Architectural%20Heritages.pdf

៣,http://yimsamnang.wordpress.com

៤,តម្លៃនៃស្ថាបត្យកម្មខ្មែរ ប្រភេទប្រាសាទខ្មែរ Posted on 04/07/2008 by ឈូកខ្មែរ ៥,ដកស្រង់ចេញពីអត្ថបទ ឈូកខ្មែរ (វិវត្តន៍ចម្លាក់ខ្មែរ) Posted on 15/08/2008

៦,http://www.cen.com.kh/culture/detail_cultureart/NWNjZjJhNDc1NmY#sthash.oByIOhhX.dpuf

៧,http://km.wikipedia.org

៨,http://reanputhi.wordpress.com/2012/05/04

៩,http://fuckyeahcartography.tumblr.com/post/17765191888/ohmykhmer-1725-longvek-map-eauweck-capitale-de

១០, http://netstudy.orgfree.com/index.php/2012-08-01-05-19-10/2012-08-01-10-02-43

១១,http://asialifeguide.com/Cover-Story/top-10-a-menu-of-phnom-penh-architecture.html

១២,http://www.antkh.com/project/visit_cambodia/image/Cambodian%20Architectural%20Heritages.pdf

១៣,http://www.cen.com.kh/culture/detail_cultureart/NWNjZjJhNDc1NmY#sthash.oByIOhhX.dpuf


# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** **លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលរោងម៉ិត» គំរូទី១**


























**ឧបសម្ព័ន្ធទី២** **លំនៅឋានខ្មែរចេនាបថ «ផ្ទះដំបូលរោងប៉ិត» គំរូទី២**


រូបភាពផែនសសរ


រូបភាពផែន


រូបភាពមើលពីមុខ


រូបភាពមើលពីចំហៀងខាងស្តាំ


រូបភាពមើលពីក្រោយ


រូបភាពមើលពីខាងឆ្វេង


រូបភាពកាត់ទទឹង ក-ក


រូបភាពកាត់បណ្តោយ ខ-ខ





## ឧបសម្ព័ន្ធទី៣ លំនៅឋានខ្មែររចនាបថ «ផ្ទះដំបូលពេជមិត» គំរូទី៣






















# គន្លឹទី២

# ប្រវត្តិនៃការរៀបចំទីក្រុងសម័យអង្គរ

## សេចក្តីផ្តើម

ដោយសារតែមានការធ្វើសកលភាវូបនីយកម្ម សង្គមជាតិនានានៅលើពិភពលោកបានចាប់ផ្តើមស្គាល់អំពីវប្បធម៌ និង អរិយធម៌របស់គ្នាទៅវិញទៅមកកាន់តែច្បាស់ឡើងៗ ។ ជាក់ស្តែងបណ្តាសង្គមជាតិភាគច្រើនតែងតែធ្វើទំនាក់ទំនងជាមួយគ្នាលើ វិស័យផ្សេងៗដូចជា នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ជាដើម។ តាមរយៈទំនាក់ទំនងនេះ វាបានធ្វើឲ្យសង្គមជាតិទាំងនោះបង្កើតនូវចំណងមិត្តភាពកាន់តែជិតស្និត និង បង្កើតឲ្យមានកិច្ចសហប្រតិបត្តិការជាច្រើនរវាងគ្នា ទាំងផ្នែកសាធារណៈ និង ផ្នែកឯកជន ។

បច្ចុប្បន្នកំណើនប្រជាជនលើពិភពលោកមានការកើនឡើងគួរឲ្យកត់សម្គាល់ ។ កត្តានេះបានជំរុញឲ្យមានកំណើននៃតម្រូវការប្រើប្រាស់ផ្សេងៗជាចាំបាច់របស់ប្រជាជន ដូចជា ចំណីអាហារ សម្លៀកបំពាក់ និងជម្រកជាដើម ដែលនាំឲ្យមានការធ្វើវិនិយោគទុនយ៉ាងច្រើនលើគ្រប់វិស័យ ជាពិសេសលើវិស័យសំណង់ ។ ក្នុងរយៈពេលប៉ុន្មានទស្សវត្សចុងក្រោយនេះ វិស័យសំណង់ពិតជាមានការរីកលូតលាស់យ៉ាងខ្លាំងបំផុតពាសពេញពិភពលោក ។ សំណង់ដ៏ស្រស់ស្អាត និង មហិមារក្នុងសង្គមបច្ចុប្បន្ននេះ បានលេចរូបរាងឡើងដោយឆ្លងកាត់នូវបច្ចេកទេសបែបវិទ្យាសាស្ត្រ សម័យទំនើប ស្របតាមរបត់នៃសម័យកាល ។ គោលបំណងមួយផ្នែកក្នុងការសាងសង់សំណង់អគារល្បីៗលើពិភពលោកគឺដើម្បីបង្ហាញ និងបង្អួតអំពីបច្ចេកវិទ្យាដ៏អស្ចារ្យរបស់ក្រុមវិស្វករ និងស្ថាបត្យករក្នុងសង្គមនីមួយៗដល់ពិភពលោកឲ្យបានដឹងលឺ និង ទទួលស្គាល់ស្នាដៃទាំងនោះទុកជាអច្ឆរិយៈវត្ថុលើលោក ។

ទោះជាយ៉ាងណា ការសាងសង់សំណង់អគារនាសម័យបុរាណក៏មានលក្ខណៈ អច្ឆរិយៈផងដែរ ជាពិសេសប្រទេសដែលមានគ្រឹះអរិយធម៌តាំងពីយូរលង់ណាស់មកហើយទាំងបច្ចឹមប្រទេស និងបូព៌ាប្រទេស ។ ក្នុងនោះ កម្ពុជាក៏ជាប្រទេសមួយដែលមានអរិយធម៌ដ៏សំបូរបែបផងដែរ។ ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រតាំងពីមុនគ្រិស្តសករាជមកម្លេះ ។ ជានេះទៅទៀត ប្រទេសកម្ពុជាធ្លាប់មានអរិយធម៌ថ្កុំថ្កើនរុងរឿងល្បីរន្ទឺ រហូតដល់ក្លាយជាអាណាចក្រមួយក្នុងទ្វីបអាស៊ី ដែលត្រូវបានហៅថា អាណាចក្រអង្គរ ។ នាសម័យអង្គរ ដោយមានការយកចិត្តទុកដាក់ខ្ពស់ និងមានមនសិការស្នេហាជាតិយ៉ាងខ្លាំងរបស់អង្គព្រះមហាវីរៈក្សត្រគ្រប់ជំនាន់ រាជធានី និងក្រុងត្រូវបានកសាងឡើងជាបន្តបន្ទាប់ ។

ការរៀបចំក្រុងនាសម័យនោះ កើតចេញគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ព្រះមហាវីរៈក្សត្រគ្រប់អង្គ។ ការជ្រើសរើសទីតាំងភូមិសាស្ត្រ ធ្វើឡើងតាមការសិក្សាស្វែងយល់ និង វិភាគយ៉ាងល្អិតល្អន់ ដោយរិះរកនូវលក្ខណៈពិសេសនៃទីតាំង ដើម្បីទាញយកនូវអត្ថប្រយោជន៍ឲ្យអស់ពីលទ្ធភាព និងសំដៅធានាឲ្យមានការអភិវឌ្ឍនាពេលអនាគត។ ទាក់ទងនឹងការកសាងក្រុងសម័យអង្គរនេះទៀតសោត គឺមានរាជធានីចំនួន ៧ ដូចជា រាជធានី មហិន្ទ្របរិត រាជធានីហរិហរាល័យ រាជធានីយសោធបុរៈទី១ រាជធានីកោះកេរ្តិ៍ រាជធានីយសោធបុរៈទី២ រាជធានីយសោធបុរៈទី៣ និង រាជធានីយសោធបុរៈទី៤។ ចំណុចដែលគួរឲ្យស្ញប់ស្ញែងបំផុតរបស់អាណាចក្រអង្គរគឺ ការកសាងនូវសំណង់ប្រាសាទដ៏មហិមារគ្មានគូរប្រៀប ដែលប្រទេសនានាលើសកលលោកបច្ចុប្បន្នគិតថាជារឿងមិនគួរឲ្យជឿ។ ទាំងនេះគឺជាមោទនភាពរបស់កម្ពុជា។ រីឯកត្តាដែលជំរុញឲ្យមានការរីកចម្រើននាសម័យអង្គរគឺ កត្តាធនធានមនុស្ស កសិកម្ម សិប្បកម្ម គមនាគមន៍ ពាណិជ្ជកម្ម ការអប់រំ សង្គមកិច្ច។ ផ្ទុយទៅវិញ ទោះបីជាសម័យអង្គរមានភាពរុងរឿងយ៉ាងណាក៏ដោយ ក៏សម័យមួយនេះបានផុតរលត់ទៅវិញដែរ។ ការធ្លាក់ចុះនៃសម័យអង្គរ គឺដោយសារសង្គ្រាមឈ្លានពានពីប្រទេសជិតខាងជាច្រើនលើកច្រើនសារ ដោយកត្តាធម្មជាតិ និង ដោយតំហាយប្រជាជន។

ដើម្បីស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់អំពីស្ថាបត្យកម្មក្នុងសម័យអង្គរ។ តើប្រវត្តិនៃការកសាងក្រុងសម័យអង្គរដែលពិភពលោកតែងកោតសរសើរមានលក្ខណៈអស្ចារ្យដូចម្តេចខ្លះ?

## ជំពូកទី១ លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ និងប្រវត្តិសាស្ត្រនៃកសាងក្រុងនាសម័យអង្គរ

### ១. លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ

សណ្ឋានដីនៃតំបន់អង្គរកសាងឡើងពីចលនាតិចតួនិចនិងតាមរយៈដំណើរសំណឹក និងកំទេចកំនដែលបានកើតឡើងនៅគ្រប់សម័យកាលធរណីទាំងអស់ ។ តំបន់នេះទទួលរងនូវចលនាខ្លាំងក្លានៃពំនើងផ្ទត់ធំៗ ជាញឹកញាប់ គឺពំនើងផ្ទត់កាលេដូញាង និងអែស៊ីញាងនៅស័កទី១ តែផ្ទៃដីស័កទី២មានពំនើងផ្ទត់មួយទៀត គឺអាំងដូស៊ីញាងដែលបង្កអោយតំបន់នេះ មានដីប្រកបដោយទម្រង់ថ្មក្រៃ (ថ្មភក់) សឹងពាសពេញប្រទេសដូចជាតំបន់ជួរភ្នំក្រវ៉ាញ ជួរភ្នំដងរែក និងខ្ពង់រាបខាងកើត ។ ចលនាតិចតួចដែលមានកម្លាំងខ្លាំងក្លានេះបង្កើតបានជាភ្នំហិមាល័យ និងមានឥទ្ធិពលដល់ជួរភ្នំក្រវ៉ាញ បានឲ្យផ្ទៃផែនដីតំបន់នេះងើបឡើងបន្តិច និងបញ្ចប់ទៅវិញ នៅត្រង់ជួរភ្នំដំរីក្នុងខេត្តកំពតជាប់សមុទ្រ ។ ចលនានេះបានធ្វើឲ្យភូមិភាគ

តំបន់បឹងទន្លេសាបសព្វថ្ងៃស្រុតចុះ ហើយត្រូវគ្របបណ្តប់ដោយទឹកសមុទ្រនៅចុងស័កទី៣ ដែលធ្វើឲ្យផ្លូវទឹកនានាទទួលរងនូវការចាក់បង្ករកំទេចកំណរហូរពីតំបន់ខ្ពស់តាមទន្លេមេគង្គ ( នៅប្រទេសកម្ពុជា ) ទន្លេមេណាម( នៅប្រទេសថៃ ) ទន្លេសាលូអង់ ( នៅប្រទេសមីយ៉ាន់ម៉ា ) សុទ្ធតែមានប្រភពមកពីតំបន់ខ្ពស់ខាងជើងនៃខ្ពង់រាបខាងកើតទីបេ ។សណ្ឋានដីបានងើបបន្តិចម្តងៗដោយកម្លាំងចលនាតិចតូនិចគួបផ្សំនឹងចលនាថយចុះទៅនឹងទឹកសមុទ្រ បានធ្វើឲ្យគេមើលឃើញនូវទិដ្ឋភាពទំនាបកណ្តាលធំធេងនោះ គឺដីល្បាប់ថ្មីបិតនៅក្បែរផ្លូវទឹក (បឹងទន្លេសាប និងទន្លេមេគង្គ) ដីល្បាប់ចាស់បិតនៅក្បែរតំបន់ខ្ពស់ (ជួរក្រវ៉ាញ ជួរភ្នំដងរែក និងខ្ពង់រាបខាងកើត) ។ នៅតាមតំបន់ទំនាបកណ្តាលគេសង្កេតឃើញមានកូនភ្នំតូចៗ លេចចេញឡើងដែលជាទួលកសិណ ។ នៅស័កទី៣មានព្រឹត្តិការណ៍បន្ទុះភ្នំភ្លើង បានធ្វើឲ្យទឹកដីនៃតំបន់អង្គរទទួលរងនូវចលនាបំណាក់ស្រុត និងមានរំហៀរសិលាបាសាល់គ្របដណ្តប់តាមតំបន់ភូមិសាស្ត្របង្កើតបានជាខ្ពង់រាប ។ ក្រោមឥទ្ធិពលត្រូពិចមូសុងក្តៅហើយសើមបានបង្កលក្ខណៈអោយសិលាបាសាល់ពុកផុយក្លាយជាដីក្រហមមានជីជាតិ និងបម្រើអោយដល់ការដាំដុះ និងការលូតលាស់នៃរុក្ខជាតិនានា ។ កត្តាអាកាសធាតុសណ្ឋានដីភោគទ្រព្យព្រៃឈើ ផ្លូវទឹក ធនធានដី ធនធានសត្វ គួបផ្សំនឹងតំបន់អង្គរនេះមានធនធានមនុស្សខ្មែរប្រកបដោយឧត្តមគតិស្នេហាជាតិខ្ពស់ លក្ខណៈសម្បត្តិជាអ្នកអង់អាចឧស្សាហ៍ព្យាយាម មានទេពកោសល្យអាចស្ថាបនាប្រទេសបង្កើតក្រុងអង្គរពោរពេញដោយកិត្តិស័ព្ទល្បីរន្ទឺ និងក្លាយជាប្រទេសថ្កុំថ្កើងរុងរឿង និងសម្បូរណ៍សប្បាយ ។

ដែនដីនៃតំបន់អង្គរជាដែនដីដែលសម្បូរណ៍ដោយសិលាថ្មភក់ ( ថ្មក្រែ ) ថ្មបាសាល់ ថ្មបាយក្រៀម ថ្មក្រានីត ដែលសិលាទាំងនេះជាសារធាតុសំខាន់ ជាពិសេសសិលាក្រែ និងថ្មបាយក្រៀម និងថ្មក្រានីតដែលបុព្វបុរសខ្មែរបានយកថ្មទាំងនេះមកសាងសង់ប្រាសាទបន្សល់ទុករហូតដល់សព្វថ្ងៃ មានចំនួនជាងមួយពាន់ប្រាសាទបិតនៅរាយបាយពាសពេញ នៅលើដែនដីនៃតំបន់អង្គរសម័យនោះមានដូចជា ៖ ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទបន្ទាយស្រី ប្រាសាទបាពួន ប្រាសាទអង្គរធំ -ល-[33] ។

## ២. លក្ខណៈពិសេសនៃទីតាំងប្រវត្តិសាស្ត្រ

ទីតាំងភូមិសាស្ត្រនៅសម័យមហានគរ មានឥទ្ធិពលធំធេងដល់កំណរកំនើតការលូតលាស់ របាយធនធានធម្មជាតិ ប្រជាជន សេដ្ឋកិច្ច វប្បធម៌ ... ដែលទឹកដីនេះបានផ្សារភ្ជាប់យ៉ាងជិតស្និតជាមួយភូមិភាគអាស៊ីអាគ្នេយ៍ ទាំងដីគោក និងដីកោះលើលក្ខខណ្ឌធម្មជាតិ និងប្រវត្តិសាស្ត្រ ។ ដែនដីនេះបិតក្នុងតំបន់

[33] ភូ វ៉ែនី **ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា** ភ្នំពេញ ២០១២ ទំព័រ ៥

អាកាសធាតុត្រូពិចនៃអឌ្ឍគោលខាងជើងសំបូរដោយកំដៅ និងឋិតក្នុងតំបន់អាស៊ីមូសុងសំបូរដោយភ្លៀង ដែលជាតំបន់មានលក្ខណ:ប្រសើរដល់ការដុះលូតលាស់នៃរុក្ខជាតិមានដំណាំត្រូពិចគ្រប់ប្រទេស ។

នៅដើមសតវត្សទី១ នៃគ្រិស្តសករាជ តំបន់នេះជាដែនដីសុវណ្ណភូមិ មានមនុស្សខ្មែរតាំងទីរស់នៅតាំងពីយូរលង់ណាស់មកហើយ ដោយបង្កើតបានជាសង្គមមានរបៀបរៀបចំច្បាប់រដ្ឋច្បាស់លាស់ ដឹកនាំដោយស្ត្រីសោយរាជ្យឈ្មោះព្រះនាងសោមា តាមភាសាចិនហៅថាព្រះនាង លីវយីនៅនគរកោះគោកធ្លក ដែលមានអង្គរបុរីជារាជធានីទី១ នៃអាណាចក្រភ្នំ ឬនគរភ្នំ (ខេត្តតាកែវសព្វថ្ងៃ) ។ ព្រះនាងបានរៀបអភិសេកជាមួយព្រាហ្មណ៍ ដែលមកពីប្រទេសឥណ្ឌាឈ្មោះព្រះបាទកៅណ្ឌិន្យ តាមភាសាចិនហៅថាព្រះបាទហ៊ុនទៀន ហើយព្រះអង្គបាននាំមកជាមួយនូវសាសនាព្រាហ្មណ៍ ។

ឆ្លងកាត់ប្រវត្តិសាស្ត្រសម័យកាលនោះ អាណាចក្រខ្មែរមានឈ្មោះបោះសម្លេងលើដែនដីអាស៊ី និងអឺរ៉ុប និងមានទំនាក់ទំនងពាណិជ្ជកម្មរវាងបណ្តាប្រទេសក្នុងតំបន់អាស៊ីមានចិន ចម្ប៉ា ឥណ្ឌា និងអឺរ៉ុប ។ អាណាចក្រភ្នំ ឬនគរភ្នំ មានអាយុកាលចាប់ពីសតវត្សទី **១** ដល់សតវត្សទី **៦** តាមភាសាចិនហៅថា **ហ្វូណន** ។ តំណតមកសតវត្សទី **៦** ដល់សតវត្សទី **៨** ខ្មែរភាគខាងជើងបានបង្កើតរដ្ឋមួយឈ្មោះអាណាចក្រចេនឡា ដែលមានក្សត្រគ្រងរាជ្យនៅតាបុរីតូចៗ និងមានរាជធានីឈ្មោះ ***ភវបុរ:*** ។

តាមឯកសារចិនបានបញ្ជាក់ថា នៅដើមសតវត្សទី៧ ដោយសារតែជួបប្រទះនូវការបាត់បង់ឯកភាពជាតិ និងបែងបាក់សាមគ្គីភាពផ្ទៃក្នុងធ្វើឲ្យចេនឡាធំត្រូវបែងចែកជា**ពីរ**គឺះចេនឡាដីគោកនៅតំបន់ខាងជើងលើទឹកដីចេនឡាមុនមានរាជធានីឈ្មោះ ***ភវបុរ:*** និង ចេនឡាលិចទឹកនៅខាងត្បូងមានរាជធានីឈ្មោះ**សម្ភុបុរ:**(ស្រុកសំបូរ ខេត្តក្រចេះសព្វថ្ងៃ)[34] ។ ហេតុផលទាំងនេះហើយដែលធ្វើអោយស្ថានភាពនយោបាយមានការធ្លាក់ចុះដុនដាប រហូតដល់ទទួលការវាយលុកលុយពីសំណាក់ពួកជ្វានៅសតវត្សទី៧ ព្រមជាមួយគ្នានោះពួកជ្វាក៏បានចូលរាតត្បាតចេនឡាលិចទឹកដោយបានដុតសម្ភុបុរ: និងចាប់ស្តេចខ្មែរទៀតផង ។ តែនៅដើមសតវត្សទី៨ មានព្រះរាជាមួយអង្គ**ព្រះនាមជ័យវរ្ម័នទី ២** បានធ្វើការបង្រួបបង្រួមចេនឡាទាំងពីរឡើងវិញ និងកំចាត់ពួកជ្វាបានដោយជោគជ័យ[35] ។ ពេលនោះហើយការបង្កើតក្រុងនាសម័យអង្គរបានចាប់ផ្តើម ។

## ជំពូកទី២ ដំណើរការរៀបចំ និងការកសាងក្រុងសម័យអង្គរ

### ១. ការកសាងក្រុងនាសម័យអង្គរ

[34] ភូ វីឌី ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ភ្នំពេញ ២០១២ ទំព័រ ៦

[35] ពៅ សារឿន ប្រវត្តិសាស្ត្រនៃព្រះរាជណាចក្រកម្ពុជា ២០១០ ទំព័រ២២

### **១.១. រាជធានីមហេន្ទ្របវិត**

ក្រោយពីបានកំចាត់ពួកជ្វាប្រកបដោយជោគជ័យ និងរំដោះប្រទេសជាតិឲ្យមានឥស្សរភាពឡើងវិញមក **ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០)** បានយាងត្រឡប់មកពីប្រទេសជ្វាប្រហែលជា**គ.ស ៨០០** ហើយបានយាងទៅគង់នៅ**រាជធានីឥន្ទ្របុរ** ទំនងជាត្រង់បន្ទាយ **ព្រៃនគរ (ខេត្តត្បូងឃ្មុំ)**[36] ។ មុននឹងឡើងសោយរាជ្យ ដើម្បីធ្វើការបង្រួបបង្រួមជាតិនិងពង្រឹងសាមគ្គីភាពផ្ទៃក្នុង អោយមានឯកភាពជាតិឡើងវិញ ព្រះអង្គបានសម្រេចចិត្តផ្លាស់ប្តូររាជធានីជាច្រើន ព្រមទាំងបានកសាងប្រាសាទនៅគ្រប់រាជធានីនោះគឺ ៖

- រាជធានី **កុតិ (កន្លែងប្រាសាទបន្ទាយក្តីសព្វថ្ងៃ)**
- រាជធានី**ហរិហរាល័យ (នៅបណ្តោយដងស្ទឹងរលួសប្រមាណជា១៥ គ.ម ពីក្រុងសៀមរាប)**
- រាជធានី **អមរេន្ទ្របុរ (ទំនងជានៅត្រង់ទំនប់ទឹកខាងលិចនៃបារាយទឹកថ្លាសព្វថ្ងៃ)**[37]

ចុងក្រោយបង្អស់ ព្រះអង្គបានយោងទៅគង់នៅរាជធានី **មហេន្ទ្របិតវិត (លើសភ្នំគូលេនសព្វថ្ងៃកសាងនៅឆ្នាំ៨០២)** ។ ការជ្រើសរើសរាជធានីថ្មីនេះ ពោលគឺមានលក្ខណៈសំខាន់ ២ យ៉ាង ៖

- ✓ កន្លែងនៅចំកណ្តាល
- ✓ ព្រះអង្គចង់ក្លាយជាមហាក្សត្រភ្នំ និងជាព្រះមហាក្សត្រចក្រវាឡ

ហេតុដូចនេះ ព្រះអង្គបានជ្រើសរើសយក**ភ្នំមហេន្ទ្របពិត(បច្ចុប្បន្នភ្នំគូលែន)**[38] ដើម្បីតាំង**ព្រះសុមេរុ** ។ ព្រះអង្គបានអញ្ជើញព្រាហ្មណ៍យ៉ាងចំណានម្នាក់ហិរណ្យទាមអោយរៀបចំពិធីស្ថាបនាលិង្គព្រះឥសូរ ។ លិង្គនេះ តំណាងអោយប្រភពអំណាចទាំងអស់ ដែលមានព្រលឹងព្រះរាជានៅជាមួយផង ។ ពិធីនេះក៏មានបំណងអោយប្រទេសកម្ពុជាលែងរណបប្រទេសជ្វា ហើយមានតែព្រះអង្គមួយប៉ុណ្ណោះដែលជាស្តេចចក្រវាឡ ។ ព្រះបាទជ័យជ័រ្មនទី២ ទ្រង់បានកសាងប្រាសាទភ្នំមួយ នៅលើភ្នំគូលេនដែលជាចំនុចកណ្តាលនៃរាជធានីគឺ : **ប្រាសាទព្រះអារាមរោងចិន**[39] ។

### **១.២. ការវិលត្រឡប់មករាជធានីហរិហរាល័យ**

ដោយសារតែមានឧបសគ្គផ្សេងៗ ទើប**ព្រះបាទជ័យវរ្ម័នទី២** បានសម្រេចចិត្តយោងត្រឡប់ទៅគង់នៅរាជធានី**ហរិហរាល័យ**វិញ ។ នៅឆ្នាំ**៨៥០ ព្រះបាទជ័យវរ្ម័នទី២** បានសោយទីវង្គត បន្ទាប់មកព្រះរាជបុត្ររបស់ព្រះអង្គព្រះនាម**ជយវធ៌ន ឬជយវរ្ម័នទី៣ (៨៥០-៨៧៧)**បានសោយរាជ្យស្នងព្រះអង្គ ។

---

[36] ត្រឹង ងា **ប្រវត្តិសាស្ត្រខ្មែរ** ( ភាគ១ ) ភ្នំពេញ **១៩៧៣** ទំព័រ **៧៨**

[37] វណ្ណ មូលីវណ្ណ **បុរីខ្មែរសម័យទំនើប** វេយំ ភ្នំពេញ ២០០៤

[38] ម៉ាដឺឡែនហ្ស៊ីតូ ក្រែសំរួលដោយ ម៉ុញ សារី **ប្រវត្តិសាស្ត្រអង្គរ** ភ្នំពេញ ២០១១ ទំព័រ **២៥**

[39] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ (ភាគ ១ ) ភ្នំពេញ ១៩៧៣ ទំព័រ ៧៩

ព្រះបាទជ័យវរ្ម័នទី៣ ក៏បានបន្តគង់នៅរាជធានីហរិហរាល័យ និងបានកសាងប្រាសាទខ្លះនៅតំបន់អង្គរ រហូតដល់សោយទីវង្គតរបស់ព្រះអង្គនៅឆ្នាំ**៨៧៧** ។

ដោយពុំមានបុត្រស្នងរាជ្យនាពេល**ព្រះបាទជ័យវរ្ម័នទី៣** សោយទីវង្គត ជីដូនមួយរបស់ព្រះអង្គព្រះនាម**ឥន្ទ្រវរ្ម័នទី ១ (៨៧៧-៨៨៩)** ក៏បានបន្តស្នាក់នៅរាជធានី**ហរិហរាល័យ**ដដែល ហើយក៏ជាទីក្រុងសំខាន់ដំបូងក្នុងប្រវត្តិសាស្ត្រ ដែលមានមនុស្សរស់នៅតាំងពីយូរយារមកហើយតាមរយៈស្ថានីយបុរេប្រវត្តិសាស្ត្រ និងដំណែលប្រាសាទបុរាណនៅតំបន់នោះ ។ ដោយមានមរតកពីអតីតកាលក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ និងនគរូបនីយកម្មតាំងពីបុរាណ ទើបនៅសម័យអង្គរមានការច្នៃប្រឌិតក៏ចេះតែមានការរីកចម្រើនឡើង ដោយការកសាងបារាយណ៍ធំមួយនៅខាងជើង រាជធានីឈ្មោះ**ឥន្ទ្រតដាត** មានបណ្តោយ **៣០០០** ម៉ែត្រ និងទទឹង **៨០០** ម៉ែត្រ ដែលអាចផ្ទុកទឹកបាន **៦** លានម៉ែត្រត្រីគុណ [40] ។ ការកសាងនេះគឺធ្វើឡើងតាមតម្រូវការខាងសាសនា ប៉ុន្តែវាបានផ្តល់ផលប្រយោជន៍យ៉ាងធំធេងចំពោះវិស័យកសិកម្ម និងសម្រាប់ការប្រើប្រាស់ក្នុងទីក្រុង ។ តាមរយៈការច្បិចយកទ្រឹស្តីសាសនាមកអនុវត្តក្នុងការកសាងប្រទេស នៅឆ្នាំ**៨៨១ព្រះបាទឥន្ទ្រវរ្ម័នទី១** ទ្រង់បានកសាង**ប្រាសាទបាគង** ដែលជាប្រាសាទភ្នំមួយដែលសាងពីថ្មភក់មានទ្រង់ទ្រាយច្បាស់លាស់គឺមានឿន ៣ ជាន់សម្រាប់តំកល់លិង្គទេវរាជឈ្មោះ **ឥន្ទ្រេស្វរ (ឥន្ទ្រ=ព្រះរាជា+ ឥស្វរ =ព្រះឥវូរ)** ។

### ១.៣. រាជធានីយសោធរបុរៈទី១ (ក្រុងអង្គរទី១)

ក្រោយពី**ព្រះបាទឥន្ទ្រវរ្ម័នទី១** បានសោយទីវង្គតនៅឆ្នាំ**៨៨៩**បុត្ររបស់ព្រះអង្គបានឡើងសោយរាជ្យបន្តនៅរាជធានី**ហរិហរាល័យ** ។ នៅឆ្នាំ៨៩៣ **ព្រះបាទយសោវរ្ម័ទី១ (៨៨៩-៩១០)** ទ្រង់បានកសាងនៅកណ្តាលបារាយណ៍ **ឥន្ទ្រតាដាក** នូវប្រាសាទលលៃដែលមានប្រាង្គអិដ្ឋ**៤** តំរៀបជាពីរជួរមុខក្រោយដើម្បីឧទ្ទិសចំពោះព្រះមាតាបិតានិងជីដូនជីតា ខាងព្រះមាតារបស់ព្រះអង្គ ។ យោងតាមសិលាចារឹកស្តុកកក់ធំអាចអោយយើងដឹងបានថា ព្រះអង្គបានកសាងទីក្រុងថ្មីមួយទៀតឈ្មោះថា**យសោធបុរៈទី១**[41] ដែលមាន **ភ្នំបាខែង ឬប្រាសាទបាខែង** នៅកណ្តាលសម្រាប់តំកល់លិង្គ **យសោធរេស្វរ** ដែលមានកំពែងដី **៦** គីឡូម៉ែត្រព័ទ្ធជុំវិញ និងបានកសាងបារាយណ៍មួយឈ្មោះ **យសោធរតដាក**(Baray oriental) ដែលមាន

[40] សមាគម Promo-khmer **ប្រទេសខ្មែរពីបុព្វសម័យរហូតដល់ការបោះបង់រាជធានីអង្គរ** (ភាគទី១) ២០០០ ទំព័រ**១៨៥**

[41] ម៉ាដឺឡែនហ្សីតូ ក្រែសំរួលដោយ ម៉ុញ សារី **ប្រវត្តិសាស្ត្រអង្គរ** ភ្នំពេញ ២០១១ ទំព័រ ១

បណ្តោយ **៧** គីឡូម៉ែត្រ និងទទឹង **១.៨** គីឡូម៉ែត្រ ដែលអាចផ្ទុកទឹកបាន **៣០** លានម៉ែត្រគ្រីគុណ[42] គឺស្មើនឹងចំណុះទំនប់ **ឥន្ទ្រតដាក** ចំនួនពី **៤** ទៅ **៥** ដង ។

### ១.៤. រាជធានីកោះកេរ្តិ៍:

យោងតាមសិលាចារឹកស្តុកកក់ធំអាចអោយយើងដឹងថាចាប់ពីគ.ស **៩២១**ទៅ **ព្រះបាទជ័យវរ្ម័នទី**៤(៩២៨-៩៤០)ដែលជាប្អូនថ្លៃរបស់ **ព្រះបាទយសោវរ្ម័ទី១** បានងើបឡើងប្រឆាំងនឹងក្មួយខ្លួនឯងព្រះនាម**ហសិវរ្ម័នទី១** ដោយបានប្រមូលយកទ្រព្យសម្បត្តិក្នុងរាជធានី**យសោធរបុរៈទី១ (ក្រុងអង្គរទី១)** ទៅបង្កើតរាជធានីថ្មីនៅឯ**ឆោកគគ្យិរ {កោះកេរ្តិ៍(កោះជ័យជំនះ)}**ដែលមានចម្ងាយ**៧០**គីឡូម៉ែត្រ ខាងកើតអង្គរ[43] ។ ព្រះអង្គទ្រង់បានខិតខំកសាងសមិទ្ធិផលដែលសុទ្ធតែមានលក្ខណៈធំសំបើមហើយប្រកបដោយចលនាទៀតផង ។ ក្នុងរាជធានីនេះព្រះអង្គបានកសាងប្រាសាទធំមួយដែលមានយឿន **៧** ជាន់ កំពស់ **៣៥** ម៉ែត្រ សំរាប់តំកល់លង្គ **ត្រិភូវនេស្វរៈ** គឺ **ប្រាសាទធំ** ដែលបានកសាងឡើង នៅ**គ.ស៩៣១** ។ ក្រៅពីនេះព្រះអង្គបានកសាងប្រាសាទជាច្រើនទៀតព្រមទាំងបារាយមួយឈ្មោះ **បារាយណ៍រហាល់** ដែលមានទទឹង **៥៦០** ម៉ែត្រ និងបណ្តោយ **១២០០** ម៉ែត្រ[44] ។

### ១.៥. រាជធានីយសោធរបុរៈទី២ (ក្រុងអង្គរទី២)

ក្នុងរជ្ជកាលរបស់**ព្រះបាទសូរិយាវរ្ម័នទី១**(១០០២-១០៥០) **រាជធានីយសោធបុរីទី១ (ក្រុងអង្គរទី១)** ត្រូវទទួលការខូចខាតទាំងអស់ជាច្រើនដោយសារសង្គ្រាមស៊ីវិល ម្ល៉ោះហើយព្រះអង្គបានបញ្ជាឲ្យរៀបចំស្តាបនា និងជួសជុលនូវអ្វីដែលអាចជួសជុលបាន ។ ក្រោយមកព្រះអង្គក៏បានអោយគេគូសវាសប្លង់**រាជធានីយសោធរបុរីទី២ (ក្រុងអង្គរទី២)**ដែលមានប្រាសាទភ្នំមួយ ។ ប៉ុន្តែគ្រោងការនេះត្រូវបានសម្រេចដោយស្នាព្រះហស្ថរបស់ព្រះរាជបុត្រព្រះអង្គព្រះនាម**ព្រះឧទយាទិត្យវរ្ម័នទី ២(១០៥០-១០៦៦)** ដែលមាន**ប្រាសាទបាពួន** ជាចំនុចកណ្តាលនៃរាជធានី និងមានកំពែងដីព័ទ្ធជុំវិញ[45] ។ ព្រមជាមួយគ្នានេះព្រះអង្គទ្រង់បានបញ្ជាអោយជីកបារាយ**បារាយខាងលិច(បារាយទឹកថ្លា)** ដែលមានប្រវែង **៨** គីឡូម៉ែត្រ និងទទឹង **២.២** គីឡូម៉ែត្រ ហើយដាក់ទឹកបានប្រហែល **៧៥** លានម៉ែត្រគ្រីគុណ[46] សម្រាប់យកទឹកប្រើប្រាស់ និងផ្គត់ផ្គង់កសិកម្មក្នុងបំណាងចិញ្ចឹមទីក្រុងរបស់ព្រះអង្គនាពេលបច្ចុប្បន្ននិងអនាគត ។ នៅចំកណ្តាលបារាយ

---

[42] ម៉ាដឺឡែនហ្សិតូ ក្រែសំរួលដោយ ម៉ុញ សារី **ប្រវត្តិសាស្ត្រអង្គរ** ភ្នំពេញ ២០១១ ទំព័រ ១៤

[43] ត្រឹមងា **ប្រវត្តិសាស្ត្រខ្មែរ (ភាគ១)** ភ្នំពេញ ១៩៧៣ ទំព័រ៨៥

[44] ត្រឹមងា **ប្រវត្តិសាស្ត្រខ្មែរ(ភាគ១)** ភ្នំពេញ ១៩៧៣ ទំព័រ៨៦

[45] ឥន្ទ ឌីបសាម៉េត ប្រវត្តិសាស្ត្រនៃព្រះរាជាណាក្រកម្ពុជា ភ្នំពេញ ទំព័រ៦៦

[46] សមាគម Promo-khmer ប្រទេសខ្មែរពីបុព្វសម័យរហូតដល់ការបោះបង់រាជធានីអង្គរ (ភាគទី១) ២០០០ ទំព័រ១៨៥

នោះ ព្រះអង្គបានស្ថាបនាប្រាសាទមួយដែលមានឈ្មោះថា: **ប្រាសាទមេបុណ្យខាងលិច** សម្រាប់តំកល់បដិមាមួយដ៏ធំចម្បងធ្វើអំពីលង្ហិនដែលតំណាងអោយព្រះវិស្ណុកំពង់ផ្ទុំ ។

## ១.៦. រាជធានីយសោធបុរៈទី៣(ក្រុងអង្គរទី៣ ឬប្រាសាទអង្គរវត្ត)

ក្នុងរជ្ជកាលព្រះបាទ**សូរិយាវរ្ម័នទី២** (១១១៣-១១៥០) ជារជ្ជកាលមួយដែលមានកត្តិនាមល្បីល្បាញខ្ទរខ្ទារជាងគេក្នុងប្រវត្តិសាស្ត្រនៅប្រទេសកម្ពុជា ។ បន្ទាប់ពីរៀបចំប្រទេសអោយមានដំណើរការធម្មតារួចមក ការកសាងប្រទេសអោយបានរីកចម្រើនក៏បានចាប់ផ្តើម ។ ភាពសំបូរបែបនៃសំណង់ផ្សេងៗក្នុងរាជ្យ**ព្រះបាទសូរ្យវរ្ម័នទី២** បានឆ្លុះបញ្ចាំងអោយឃើញពីការរីកចម្រើននេះ ។ នៅតាមខេត្ត**ព្រះបាទសូរ្យវរ្ម័នទី២**ទ្រង់បានស្ថាបនា**ប្រាសាទភ្នំជីសូរ ប្រាសាទភ្នំសំណក ប្រាសាទវត្តភូ និងប្រាសាទព្រះវិហារ** ។ ជាមួយគ្នានេះព្រះអង្គបានចាប់ផ្តើមកសាង**ប្រាសាទបឹងមាលា ប្រាសាទ ព្រះខាន់(កំពង់ស្វាយ)** ។ នៅអង្គរព្រះអង្គបានកសាង**ប្រាសាទធម្មនន្ទ ប្រាសាទចៅសាយទេវតា ប្រាសាទព្រះពិធូរ បន្ទាយសំរៃ** ក្នុងនោះ**ប្រាសាទអង្គរវត្ត(ឈ្មោះដើម=បរមវិស្ណុលោក)**[47]ក៏បានកសាងឡើងដោយស្នាព្រះហស្តរបស់ព្រះអង្គផងដែរ ។ បញ្ជាក់ ៖ការវិវត្តនៃឈ្មោះ**អង្គរវត្ត** នេះអាចបានយកមកប្រើតាមប្រវត្តិសាស្ត្រ ។ ដោយយោងតាមសិលាចារឹកនៅសតវត្សទី១៦ បានបញ្ជាក់ថាឈ្មោះប្រាសាទអង្គរវត្តគឺ **ព្រះមហានគរឥន្ទ្រប្រ័ស្ថព្រះពិស្ណុលោក** មួយចំណែកទៀតនៅសតវត្សទី១៧ ឈ្មោះប្រាសាទអង្គរវត្តគឺត្រូវបានគេហៅថា **ឥន្ទ្របត្តម្ភានស្រីសុធរពិស្ណុលោក** ។ ប្រាសាទនេះបានសាង់សង់ឡើងមានលក្ខណៈវិចិត្រដើម្បីឧទ្ទិសថ្វាយ**ព្រះវិស្ណុ** ក្នុងព្រហ្មញ្ញសាសនា និងបង្ហាញនូវសិល្បៈខ្មែរដ៏អស្ចារ្យដល់កំពូល ។ ប្រាសាទអង្គរវត្តគឺតំណាងអោយពិភពលោក ហើយក៏តំណាងអោយប្រទេសខ្មែរផងដែរ[48] ។ ចំនែកប្រាង្គកណ្តាលតំណាងអោយភ្នំព្រះសុមេរុដែលស្ថិតនៅកណ្តាលពិភពលោក ។ ប្រាង្គទាំង ៥ តំណាងអោយកំពូលភ្នំព្រះសុមេរុ ដែលជាជាយដែនដី និងគូទឹកព័ទ្ធជុំវិញ គឺជាសមុទ្រដែលព័ទ្ធជុំវិញ ។ ប្រាសាទអង្គរវត្តមានកម្ពស់ **៦៥** ម៉ែត្រ មានក្រឡាផ្ទៃប្រហែល **២០០** ហិចតា រាងចតុកោណដែលកំណត់ដោយកំពែងជុំវិញប្រវែងប្រហែល **៥.៥** គីឡូម៉ែត្រ និងគូទឹក ឬកវិណាព័ទ្ធជុំវិញប្រហែល **១៦** គីឡូម៉ែត្រ[49] ចំណែកឯកសិណាពិតប្រាកដរបស់ប្រាសាទមានបណ្តោយប្រវែង **១៥០០** ម៉ែត្រ និងទទឹងប្រវែងជាង **២០០** ម៉ែត្រ[50]។

## ១.៧. រាជធានីយសោធបុរៈទី៤ (អង្គរធំ ឬក្រុងអង្គរទី៤)

[47] មីសែល ត្រាណេ **ព្រះបាទជ័យវរ្ម័នទី ៧** ភ្នំពេញ ១៩៩៨

[48] រស់ ចន្ទ្រាបុត្រ **ប្រវត្តិសាស្ត្រខ្មែរ (ភាគទី១)** បារាំង ១៩៩៧ ទំព័រ **២២**

[49] ម៉ាដឺឡែនហ្សិត្វ ក្រែសំរួលដោយ ម៉ុញ សារី **ប្រវត្តិសាស្ត្រអង្គរ** ភ្នំពេញ ២០១១ ទំព័រ **៧៤**

[50] រស់ ចន្ទ្រាបុត្រ **ប្រវត្តិសាស្ត្រខ្មែរ (ភាគទី១)** បារាំង ១៩៩៧ ទំព័រ **២២**

បន្ទាប់ពីរំដោះប្រទេសជាតិអោយរួចផុតពីការត្រួតត្រារបស់បរទេស និងដើម្បីសម្រេចគោលដៅក្នុងការប្រយុទ្ធប្រឆាំងយ៉ាងស្វិតស្វាញប្រឆាំងនឹងពួកឈ្លានពាន ទីបំផុតព្រះបាទជ័យវរ្ម័នទី៧បានទទួលជោគជ័យ ។ ដោយសារហេតុការណ៍នេះហើយ ទើបនៅគ.ស១១៨១ **ព្រះបាទជ័យវរ្ម័នទី៧** ទូលរាជាភិសេកឡើងសោយរាជ្យនៅ**យសោធរបុរៈទី៤**ក្នុងព្រះជន្មាយុ **៥៦** ព្រះវស្សា ។ កិច្ចការដំបូងដែលព្រះអង្គត្រូវបំពេញជាបន្ទាន់ គឺការរៀបចំរាជធានីឡើងវិញដោយស្ថាបនាកំពែងថ្មធ្វើពីបាយក្រៀមដែលមានរាងចតុកោណកែងស្មើ ទប់ទ្រដោយទំនប់អំពីដីដែលជ្រុងនីមួយៗប្រវែងប្រហែល **៣** គីឡូម៉ែត្រ ហើយមានទំហំប្រហែល **៩** គីឡូម៉ែត្រក្រឡា និងគូទឹក ឬកសិណព័ទ្ធទទឹង **១០០** ម៉ែត្រ និងជម្រៅ **៥** ឬ **៦** ម៉ែត្រព័ទ្ធជុំវិញដែលមានគោបុរៈចំនួន ៥ និងមានប្រាសាទភ្នំមួយឈ្មោះ **ប្រាសាទបាយ័ន**នៅចំកណ្តាល[51] ។ សព្វថ្ងៃត្រូវបានគេស្គាល់ថា**អង្គរធំ ឬក្រុងអង្គរទី៣** ។ ប្រាង្គប្រាសាទកណ្តាលនេះជាកន្លែងសំរាប់តម្កល់វត្ថុជាទីសក្ការៈ និងបដិមាពុទ្ធរាជអង្គរយ៉ាងធំសម្បើមដែលមានកំពស់ជិត ៤ ម៉ែត្រ ។

## ២. កត្តាជំរុញឲ្យមានការអភិវឌ្ឍន៍ និងការរីកចម្រើនក្រុងនាសម័យអង្គរ

### ២.១ កត្តាធនធានមនុស្ស

ជនជាតិខ្មែរនៅសម័យអង្គរ ជាជនជាតិដែលមានចិត្តឧស្សាហ៍ ព្យាយាម និងពូកែច្នៃប្រឌិតដែលមានមហិច្ឆិតាធំបំផុត គឺការធ្វើអោយមានភាពរីកចំរើនលើគ្រប់វិស័យ និងភាពសំបូរសប្បាយនៅគ្រប់ផ្នែក ។ ជាសក្ខីភាពនៃការតស៊ូព្យាយាមនេះ បុព្វបុរស់ខ្មែរបានឆ្លាក់រឿងកូរសមុទ្រទឹកដោះនៅលើជញ្ជាំងប្រាសាទអង្គរវត្ត និងនៅមុខច្រកទ្វារចូលនៃបុរីអង្គរធំជាដើម [52]។ ពីព្រោះទឹកសមុទ្រហូរចេញពីកូរសមុទ្រទឹកដោះ ជានិមិត្តរូបបញ្ជាក់យ៉ាងច្បាស់ពីថាមពលខាងការងារ និងការប្រណាំងប្រជែងបង្កើតផលិតផលយ៉ាងជាក់ច្បាស់ ។ ម្យ៉ាងទៀតការសិក្សាចិត្តវិទ្យាអំពីសិល្បៈខ្មែរបុរាណបានផ្តល់ពត៌មានជាច្រើនស្តីពីការតស៊ូចិត្តអំណត់ និងសេចក្តីប្រាថ្នាយ៉ាងមុតមាំរបស់ខ្មែរជំនាន់នោះចំពោះអ្វីដែលខ្លួនយល់ថាល្អប្រសើរ ។

មតិកដែលមានតាំងពីសម័យហ្វូណាននិងសម័យចេនឡា បានបន្សល់មកអោយខ្មែរនាសម័យអង្គរមានតំលៃពន់ពេក ចំនែកឯមរតកអរិយធម៌ខ្មែរដែលជឿលឿននាសម័យហ្វូណាន និងសម័យចេនឡាវិញ ក៏បានបន្សល់អោយអរិយធម៌នាសម័យអង្គរឈានដល់ចំណុចកំពូល និងផ្សាព្វផ្សាយល្បីល្បាញនៅអាស៊ីអាគ្នេយ៍ ។ ទេពកោសល្យរបស់មនុស្សខ្មែរបានធ្វើអោយអ្វីៗដែលមានពីមុនមក កាន់តែមានភាពល្អតលាស់ និងប្រសើរជាលំដាប់ មិនតែប៉ុណ្ណោះក៏បានបង្កើតនូវសមិទ្ធិផលថ្មីៗដ៏ អស្ចារ្យថែមទៀត

[51] សមាគម Promo-khmer **ប្រទេសខ្មែរពីបុព្វសម័យរហូតដល់ការបោះបង់រាជធានីអង្គរ** (ភាគទី១) ២០០០ ទំព័រ១៨៥

[52] ខាត់ធី **ប្រវត្តិសាស្ត្រប្រទេសកម្ពុជា** ភ្នំពេញ ២០០៩ ទំព័រ ៦១

ដែលក្នុងលោកសឹងរកអ្វីប្រៀបផ្ទឹមពុំបាន ។ ឧទាហរណ៍ ៖ ការសាងសង់បារាយណ៍ដែលតាមការប្រមាណមើលបរិមាណដី ដែលត្រូវយកចេញសម្រាប់ការជីកបារាយណ៍ខាងលិច(បារាយណ៍ទឹកថ្លា)មានប្រហែលជា ៥០០០០០ តោន ហើយនឹងត្រូវចំណាយពេលអស់ ២ ឆ្នាំសំរាប់ការធ្វើអោយសរេចនូវបាសាំងទឹកបែបនេះ ។ ការងារមួយនេះមិនត្រឹមតែចំណាយអស់ហាមពលច្រើនប៉ុណ្ណោះទេ ថែមទាំងត្រូវការវិស្វករដែលមានសមត្ថភាពទៀតផង[53] ។

យោងតាមកំណត់ហេតុរបស់លោក **ជីវ តាក្វាន់** និងសិលាចារឹកដែលបានរកឃើញ គេអាចប៉ាន់ប្រមាណបានថាប្រជាជនសរុបនៅតំបន់អង្គរមានចំនួនជិត ១ លាននាក់ នៅចុងសតវត្សទី១៣ ហើយប្រជាកសិករមានចំនួន ៧០% នៃប្រជាជនសរុប ។ ចំនួនអ្នកដាំដុះដ៏លើសលុបនេះក៏បានធ្វើអោយប្រទេសកម្ពុជានាសម័យនោះទទួលបាននូវគោគផលដ៏ច្រើនបរិបូរណ៍[54] ។

### ២.២. កសិកម្ម

យើងបានដឹងរួចមកហើយថា ខ្មែរបានជ្រើសរើសយកទីតាំងរាជធានីនៅតំបន់អង្គរ ព្រោះជាកន្លែងសម្បូរណ៍ដោយសម្បត្តិធម្មជាតិ ជាពិសេសគឺទឹក ។ លោក **ប៊ែលណាគ្រោលីយេ** បានពោលថានៅសម័យនោះទឹកនៅតំបន់អង្គរមិនជាខ្វះទេតែចំណោទស្ថិតនៅត្រង់ថា ការចែកចាយទឹកអោយបានទៅដល់គ្រប់កន្លែងប៉ុណ្ណោះ ។ លោកបានបន្ថែមទៀតថា ដោយខ្មែរមានដូនតាជាអ្នកជំនាញខាងនយោបាយទឹក គេក៏បានបន្តនយោបាយទឹកនេះតទៅទៀត ហើយក៏បានបោះជំហានយ៉ាងវែងក្នុងវិស័យនេះ ដោយបានធ្វើការផ្លាស់ប្តូរបច្ចេកទេសបញ្ចេញទឹកពីស្រែមកជាការបញ្ចូលទឹកក្នុងស្រុកវិញ ។ ឯនយោបាយសន្សំទឹកដើម្បីបង្ហូរទៅក្នុងស្រែ នៅពេលដែលគេត្រូវការនោះគឺត្រូវរៀបចំអោយម៉ត់ចត់ជំបូងដោយព្រះបាទឥន្ទ្រវរ្ម័នទី១ ។ ព្រះអង្គបានយកព្រះទ័យទុកដាក់នឹងកសិកម្មដែលធម្មតាពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង និងខ្យល់រដូវ ។ ការកើនចំនួនប្រជាពលរដ្ឋតម្រូវឲ្យគេប្រឹងប្រែងបង្កើតផលិតផលកសិកម្មថែមទៀត យ៉ាងណាមិញព្រះបាទឥន្ទ្រវរ្ម័នទី១បានរៀបចំតាមរបៀបដែលប្រទេសចេនឡាធ្លាប់បានធ្វើរួចមកហើយ គឺការទប់ទឹកបង្ខាំងទុកក្នុងតំបន់ធំៗរួចជីកប្រឡាយបង្ហូរទឹកនោះបញ្ចូលក្នុងស្រែផង បញ្ចូលទៅក្នុងស្រះធំៗ និងប្រឡាយឯទៀតនៅក្នុងទីក្រុងផងដើម្បីទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ ។ នយោបាយទឹករបៀបនេះត្រូវបានអនុវត្តនៅសម័យអង្គរជាបន្តទៅទៀតយ៉ាងម៉ត់ចត់ ជាហេតុនាំឲ្យកើតភាពសម្បូរណ៍សប្បាយដល់ប្រទេសអស់រយៈកាលជាច្រើនទសវត្ស ។

[53] Louis Frédéric, **La Vie Quotidienne dans la Péninsule Indochinoise à l'époque d'Angkor,** Paris, Hachette, 1981, P. **144**
[54] Louis Frédéric, La Vie Quotidienne dans la Péninsule Indochinoise à l'époque d'Angkor, Paris, Hachette, 1981, P. 144

ដោយសារតែកសិកម្មនៅប្រទេសកម្ពុជា ផ្តេកផ្តួលទាំងស្រុងទៅលើធម្មជាតិ ដែលអាចផ្តល់ផលស្រូវបានតែម្តងក្នុងមួយឆ្នាំបែបនេះ ជាហេតុធ្វើអោយដំណាំស្រូវអោយផលមិនគ្រប់គ្រាន់សំរាប់បំពេញសេចក្តីក្នុងស្រុកនោះទេ ម្ល៉ោះហើយនៅសម័យអង្គរ បុព្វបុរសបានស្ថាបនានៅជុំវិញរាជធានីនូវបឹងធំៗហៅថា បារាយណ៍សន្សំទឹកទឹកភ្លៀងនៅរដូវវស្សា និងជាមួយទឹកស្ទឹងសៀមរាបដែលហូរចុះពីលើភ្នំគូលេន ។ លុះផុតរដូវភ្លៀង គេអាចចែកចាយទឹកបារាយណ៍ទាំងនោះតាមប្រឡាយនានាបង្ហូរចូលទៅក្នុងស្រែ ។ តាមមធ្យាបាយបែបនេះ ទើបប្រជាកសិករខ្មែរអាចធ្វើស្រែបាន៣ ឬ៤ដងក្នុងមួយឆ្នាំ ហើយនៅរដូវប្រាំងគេអាចធ្វើដំណាំស្រូវម្តងទៀតនៅនឹងបាតបារាយណ៍ ដែលនៅទីនោះមានដីល្បាប់ដ៏មានជីជាតិ ហើយដែលមានសភាពសើមស្រាប់ ។ យោងតាមសិលាចារឹកនានានៅប្រទេសកម្ពុជា អាចអោយយើងធ្វើការវាយតំលៃបានថា ផលិតផលស្រូវនៅតំបន់អង្គរចុងសតវត្សទី១២មានចំនួនច្រើនលើសលប់ ។ ដោយការគណនាគេរកឃើញថានៅជុំវិញប្រាសាទតាព្រហ្មមាន ៨៣៨ ភូមិស្មើនឹងប្រជាជនចំនួន**៨១.៦៤០** គ្រួសារ បង្កបង្កើនផលស្រូវបានគ្រប់គ្រាន់សំរាប់ការផ្គត់ផ្គង់ផ្ទាល់ខ្លួន និងបង់ពន្ធថែមទៀតចំនួន **១១.១៩២** តោនសំរាប់ផ្គត់ផ្គង់ដល់មន្ទីរពេទ្យ មានន័យថាផលស្រូវទទួលបានសរុបមានចំនួនយ៉ាងតិច **៣៦.០០០** តោន ។ ដូចច្នេះ ភូមិនីមួយៗ អាចមានសមាជិកចំនួន **៥** នាក់ បរិមាណស្រូវផលិតបានក្នុងប្រជាជនម្នាក់ប្រហែល**៤០០**គីឡូក្រាម ដែលនេះជាបរិមាណមួយច្រើនបំផុត បើប្រៀបធៀបមកដល់បច្ចុប្បន្ននេះ ប្រហែលជាពិបាកនឹងផលិតបាន ទោះក្នុងលក្ខខណ្ឌសមប្រកបយ៉ាងណាក៏ដោយ ។ ជាសរុបផលិតផលប្រចាំឆ្នាំដែលទទួលបាននៅតំបន់អង្គរអាចឈាន់ដល់ **១៥.០០០០** តោននៅលើផ្ទៃដីត្រឹមតែជិត **១០០០** គីឡូម៉ែត្រក្រឡាប៉ុណ្ណោះ[55] ។

លោក Henristierlin អ្នកឯកទេសជនជាតិស្វីសម្នាក់បានគន់គូរឃើញថា នៅលើផ្ទៃដី ១០០០ គីឡូម៉ែត្រក្រឡានៅតំបន់អង្គរ គេអាចផលិតស្រូវបានក្នុង ១ឆ្នាំ ប្រហែល **១៥.០០០០** តោនដែលអាចចិញ្ចឹមប្រជាជនដល់ទៅ **៨០.០០០០** នាក់ ហើយនៅសល់ ៤០ % ទៀត អាចនាំយកទៅផ្តល់អោយតំបន់ផ្សេងៗទៀតបាន[56] ។ ខាងក្រោមនេះជាពេលវេលាប្រកបដោយដំណាំស្រូវ ដែលសឹងតែគ្មានពេលចន្លោះ និងបែងចែកក្នុងរយៈពេល ១ ឆ្នាំពេញតាមប្រក្រតិទិនលំអិត៖

- សាបគ្រាប់នៅខែឧសភា ដកស្ទូងនៅខែមិថុនា និងប្រមូលផលលើកទីមួយនៅចុងខែតុលា

[55] Louis Frédéric, **La Vie Quotidienne dans la Péninsule Indochinoise à l’époque d’Angkor**, Paris, Hachette, 1981, P. **142**

[56] សមាគម Promor-khmer **ប្រទេសខ្មែរពីបុព្វសម័យរហូតដល់ការបោះបង់ចោលសម័យអង្គរ** (ភាគទី១) បារាំង ២០០០ ទំព័រ៤៦

- ➢ សាបព្រោះលើកទីពីរនៅខែកញ្ញា(មួយខែកន្លះមុនចំរូតលើកទីមួយ) ដកស្ទូងនៅដើមខែ វិច្ឆិកា និង ច្រូតកាត់លើកទីពីរនៅខែ មករា
- ➢ សាបលើកទី៣ នៅចុងខែ ធ្នូ ហើយដកយកទៅស្ទូងនៅខែ កុម្ភៈ និងចុងបញ្ចប់ប្រមូលផលនៅខែ ឧសភារហូតដល់ភ្លៀងមូសុងលើកទីមួយមកដល់វិញ ។

មួយវិញទៀតការដាំដុះស្រូវនេះមិនធ្វើការនៅតាមវាលស្រែប៉ុណ្ណោះទេ ថែមទាំងនៅតាមអាងទឹកធំៗ ស្រះទឹក និងបឹងបួរទៀតផង ។ ប្រភេទពូជស្រូវខ្លះ អាចដុះលូតលាស់បានយ៉ាងលឿននៅក្នុងថ្នាលដែលមានទឹកច្រើន អាចដុះបានរហូតដល់ ១០ សង់ទីម៉ែត្រក្នុងមួយថ្ងៃ ហើយដើមរបស់វាអាចមានកំពស់ដល់រាប់ម៉ែត្រ និងដុះផុតពីទឹក ។

### ២.៣. សិប្បកម្ម

ប្រទេសមួយដែលប៉ិនប្រសប់យ៉ាងខ្លាំងខាងវិស័យសិល្បៈចម្លាក់ខាងផ្នែកសំណង់អំពីឈើ ឬអំពីថ្មប្រទេស នោះប្រាកដជាមានប្រជាជនដែលស្ទាត់ជំនាញខាងផ្នែកសិប្បកម្មជាមិនខាន ។ ម្យ៉ាងវិញទៀត លោក**ជីវ តាក្វាន់**ក្តី រូបចម្លាក់នៅលើជញ្ជាំងប្រាសាទក្តី បានប្រាប់អោយយើងដឹងថាខ្មែរជំនាន់សម័យអង្គរចូលចិត្តគ្រឿងឈើប្រដាប់ប្រណីតមានអលង្ការជាដើម ។

លោក**ជីវ តាក្វាន់**បានកត់សំគាល់ថា នៅសតវត្សទី១៣ ប្រជាជនសម័យអង្គរចេះត្បាញសំពត់សំលៀកបំពាក់ ហើយចេះដាំមន និងចិញ្ចឹមនាង ដើម្បីយកសូត្រដោយយកពូជពីស្រុកជិតខាង ។ លើសពីនេះប្រជាជនសម័យអង្គរក៏ចេះធ្វើទូធំតូច សង្ហារឹមគ្រប់យ៉ាងល្អវិចិត្រ ចេះឆ្លាក់វត្ថុធ្វើអំពីឈើ និងភ្លុកដើម្បីធ្វើជាគ្រឿងលំអ ធ្វើល្អី កញ្ច្រែង កន្ទេល សព្វសារពើ -ល- ។ ប្រដាប់ប្រដាទាំងឡាយនេះគេអាចដឹងបានដោយសាររូបចំលាក់លើជញ្ជាំងប្រាសាទនានា និងដោយសិលាចារឹកដែលរៀបរាប់នូវមុខសំភារៈជាច្រើនអនេកសំរាប់ប្រើប្រាស់នៅក្នុងប្រាសាទតាព្រហ្ម និងព្រះខាន់(អង្គរ) ។

នៅសម័យអង្គរគេឃើញមាននៅសល់ឥដ្ឋ ក្បឿង ព្រមទាំងគ្រឿងភាជន៍ គ្រឿងប្រដាប់ ផ្សេងៗ និងរូបសំណាកជាច្រើនពីលោហធាតុ ។ អត្ថបទសិលាចារឹកនៅបន្ទាយឆ្មារ និងបាយ័នបានបញ្ជាក់ថាមានប្រាសាទខ្លះសង់អំពីសំភារៈស្រាលៗ(ឈើ) ហើយប្រក់សំណ ឬក្បឿង ។ អគារដែលប្រក់សំណពុំឃើញនៅមានសេសសល់ទេ រីឯអគារប្រក់គ្រឿងសំបូរណាស់នៅសម័យអង្គរជាពិសេសគេហដ្ឋានរបស់អភិជន (តាមរយៈកំណាយដីនៅបរិវេណ ក្រុងអង្គរបានបង្ហាញអោយឃើញនូវសំណល់កំទេចក្បឿងជាច្រើន) ឯក្បឿងនេះមានគុណភាពប្លែកៗគ្នាទៅតាមមជ្ឈដ្ឋានដី ដីឥដ្ឋខ្លះពណ៌ផ្កាឈូកលឿងបន្តិចនៅតំបន់អង្គរ និងខ្លះទៀតដីឥដ្ឋមានពណ៌ស្ទើរតែស ។ ចំនែកឯគ្រឿងភាជន៍វិញ នៅសម័យអង្គរ ប្រជាជនតែងយក

គ្រឿងនេះដើម្បីដាក់ទឹកត្រី ទឹកសីអ៊ីវ បិទស្រា ដាក់គ្រាប់ធញ្ញជាតិ និងដាក់ជាតិជ័រផ្សេងៗ ។ អ្នកស្រុក (ប្រជាជនធម្មតា)តែងប្រើគ្រឿងភាសជន៍ធ្វើពីដី ឯពួកអភិជន និងស្តេចប្រើគ្រឿងប្រដាប់ដែលច្រើនតែធ្វើអំពីសំរិទ្ធ ស្ពាន់ ប្រាក់ មានសំរាប់ដាក់គ្រឿងក្រអូប ឬប្រើប្រាស់ក្នុងពិធីផ្សេងៗ ។

ម្យ៉ាងវិញទៀតគ្រឿងដែលធ្វើអំពីលោហធាតុ ដោយយោងតាមលោក **សុង ស៊ីង** ក្នុងសៀវភៅឈ្មោះ "**ចនលាអារ្យធម៌**" បានអះអាងថានៅសម័យអង្គរមានដុតរំលាយដែក ស្ពាន់ ប្រាក់ លង្ហិន សំរិទ្ធ មាសធ្វើគ្រឿងប្រដាប់ប្រើប្រាស់គ្រប់បែបយ៉ាង[57] ។ អ្នកស្រី **ម៉ា ដឺ ឡែនហ្សិតូ**ក៏បានសរសេរដែរថា ខ្មែរសម័យអង្គរប្រហែលជាចេះស្លដែក ស្លសំរិទ្ធ ព្រោះភស្តុតាង គឺគេរកឃើញរូបបដិមាព្រះវិស្ណុកំពុងផ្ទុំមួយយ៉ាងធំ សំបើមធ្វើអំពីសំរិទ្ធតែបាក់បែកអស់មួយភាគធំ រូបនេះត្រូវបានគេចាត់ទុកថាជាស្នាដៃយ៉ាងវិសេសមួយក្នុងលោកខាងផ្នែកគ្រឿងសំរិទ្ធ លោកស្រីបានសរសេរថា:"*De très beaux bronzes ont été coulés à l'époque du Bophoun. Nous avons signalé le gigantesque vishnu couché du Mébon Occidental*" [58] ។

### ២.៤ គមនាគមន៍

បណ្តាញផ្លូវថ្នល់បូករួមជាផ្លូវទឹកទាំងឡាយ ទោះផ្លូវទឹកនោះមានកំណើតពីធម្មជាតិក្តី ឬជីកដោយមនុស្សក្តីសុទ្ធសឹងតែមានសារៈសំខាន់ណាស់ចំពោះការដឹកជញ្ជូនផ្នែកពាណិជ្ជកម្ម ។ តាមធម្មតាទំនប់ដែលគេលើកព័ទ្ធជុំវិញបារាណ៍នីមួយៗ សុទ្ធសឹងតែផ្លូវថ្នល់សំរាប់ចរាចរណ៍ផងដែរ ។ ជាឧទាហរណ៍នៃការសង់ផ្លូវថ្នល់ក្នុងរជ្ជកាល ព្រះបាទយសោវរ្ម័នទី១ ព្រះអង្គបានអោយគេសង់ផ្លូវភូមិន្ទមួយក្រាលថ្មពីយសោធបុរៈទៅកាន់ហារិហរាល័យ ។ ក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី៧ គេដឹងថាព្រះអង្គបានអោយគេសង់ថ្នល់ជាច្រើនខ្វាត់ខ្វែងក្នុងព្រះរាជាណាចក្រ ជាអាទិ៍ផ្លូវថ្នល់ពីក្រុងអង្គរទៅកាន់ក្រុងវិជ័យនៅប្រទេសចម្ប៉ា និងផ្លូវថ្នល់ពីក្រុងអង្គរដដែលទៅកាន់ភិម៉ាយ(ប្រទេសសៀមសព្វថ្ងៃ) ។ លោកជីវ តាក្វាន់បានសង្កេតថានៅតាមដងផ្លូវទាំងនេះមានស្ថាបនាសាលាសំណាក់ជាច្រើនសម្រាប់អោយឈ្មួញចតទូក និងអ្នកដំណើរផ្លូវឆ្ងាយឈប់សំរាក ។ កម្ពុជាយើងនៅសម័យអាណាចក្រអង្គរ មានយ៉ាងតិចណាស់ផ្លូវថ្នល់ទំនាក់ទំនងគ្នាធំៗ ចំនួន ៧ ខ្សែ ដូចជា ៖

១. ផ្លូវទឹកក្រុងអង្គរទៅកំពង់ធំ

២. ពីក្រុងអង្គរទៅប្រាសាទព្រះខ័ននៃស្រុកកំពង់ស្វាយ

[57] ពៅ សារឿន ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ ២០១០ ទំព័រ៨៣

[58] M.Giteau, **Histoire du Cambodge**, op. cit.

៣. ផ្លូវប្រាសាទបឹងមាលាទៅវត្តភូ(បច្ចុប្បន្ននៅលាវ)ឆ្លងតាមកោះកែរ

៤. ផ្លូវពីប្រាសាទបឹងមាលាទៅបឹងធំ

៥. ផ្លូវពីក្រុងអង្គរទៅភិមាយ(បច្ចុប្បន្ននៅសៀម)ដោយកាត់លើខ្ពស់រាបកូរ៉ាត

៦.ផ្លូវពីក្រុងអង្គរទៅប្រាសាទបន្ទាយឆ្មារ

៧.ផ្លូវពីអង្គរទៅបឹងធំ[59]

ផ្លូវសំខាន់ទាំងនេះដែលមានទ្រូងទំហំ **១០** ទៅ **២៥** ម៉ែត្រ និងក្រាលដោយឥដ្ឋត្រូវបានធ្វើឡើងដោយលើកខ្ពស់ពីដីពី ២ ម៉ែត្រ ទៅ ៦ ម៉ែត្រ ដើម្បីការពារពេលមានទឹកជំនន់ និងទឹកហូរហៀរនៅរដូវភ្លៀង ។ ផ្លូវទាំងនោះសំរាប់ប្រើចំពោះការធ្វើដំណើរជាផ្លូវការរបស់មន្ត្រី និងព្រះមហាក្សត្រ តែរាស្ត្រសាមញ្ញទូទៅអាចប្រើបានដែរ ។ ដើម្បីទៅភូមិ ឬទៅកន្លែងដាច់ស្រយាលពិបាកនឹងទៅណាស់មន្ត្រី ឬអ្នករាជការជាន់ខ្ពស់ប្រើដំរីជាយាន ដើម្បីសំរួលការធ្វើដំណើរ ។ ចំពោះយុទ្ធនាការយោធាក្នុងសង្គ្រាមជាដើមក៏គេប្រើដំរី និងសេះជាយានដែរតែទ័ពភាគច្រើនដើរ ដោយថ្មើរជើងតាមពីក្រោយទ័ពដំរី ។ សំរាប់ដំណើរវែងឆ្ងាយ និងពិបាក គេចូលចិត្តតាមនាវាឡើងចុះតាមផ្លូវទឹកជាង ។

## ២.៥. ពាណិជ្ជកម្ម

យើងដឹងហើយថាតំបន់អង្គរឋិតនៅផ្លូវត្រឡែងកែង នៃចរន្តពាណិជ្ជកម្មទាំងឡាងទាំងខាងក្នុងប្រទេស និងខាងក្រៅប្រទេស ដោយសារតែបណ្តាញគមនាគមន៍ប្រទាក់ប្រទងគ្នាក្នុងព្រះរាជាណាចក្រ និងដោយសារតែការរីកចំរើនលូតលាស់នៃកសិកម្ម និងសិប្បកម្មនេះផង ។

សកម្មភាពជំនួញក្នុងស្រុកមានការមមាញឹកដូចសព្វមួយដង ព្រោះរូបចំលាក់នៅលើជញ្ជាំងប្រាសាទបាយ័ន បានបង្ហាញអំពីផ្សារប្រកបដោយមនុស្សអ៊ូអរ លើសពីនេះលោក ជីវ តាក្វាន់បានសរសើរថាមានការប៉ិនប្រសប់យ៉ាងខ្លាំងក្នុងរឿងជំនួញដូចជា ៖ លក់ស្រូវ អង្ករ ក្រណាត់ល្អៗមកពីស្រុកចិន ស្រុកសៀម ស្រុកចាម ព្រមទាំងថ្នាំសង្កូវគ្រប់មុខទៀតផង ។ លើសពីនេះខ្មែរសម័យអង្គរក៏បានធ្វើការទាក់ទងពាណិជ្ជកម្មជាមួយបរទេសផងដែរ តាមរយៈការនាំចេញទៅក្រៅដែលជារបស់បានមកពីធម្មជាតិដូចជា ៖ ក្រវ៉ាញ ភ្លុកដំរី កុយរមាស ជ័យរុក្ខជាតិផ្សេងៗ -ល- ។

ចំពោះជំនួញនាំចូលពីបរទេស(ប្រទេសចិន)វិញ គេអាចដឹងច្បាស់បានថាខ្មែរសម័យអង្គរត្រូវការមាស ក្រណាត់ សំណ ប៉ាន់តែ ថូផ្កាលាបពណ៌ទឹកប្រាក់ ស្ពាន់ធ័រ ថាសស្ពាន់ គុជ ...-ល- ។ ប្រទេសសៀម (នៅសតវត្សទី ១៣)ខ្មែរនាំចូលច្រើនតែក្រណាត់ និងសំពត់ ដូចជាប្រទេសចម្ប៉ាផងដែរ ។ ប៉ុន្តែសំពត់

[59] ពៅ សារឿន ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ ២០១០ ទំព័រ៨៣

ដែលមានសាច់ម៉ដ្ឋល្អ នោះច្រើនបានមកពីប្រទេសនៅភូមិភាគសមុទ្រខាងលិចហើយមានតែស្តេច ឬនាម៉ឺនធំៗទេដែលប្រើសំពត់បែបនេះ ។

ឯជំនួញផ្លូវទឹកនៅតែមានសកម្មភាពមមាញឹកដដែល តែគ្រាន់តែប្លែកពីសម័យហ្វូណនត្រង់ចំណុចដែលថាសម័យនោះគេចូលចិត្តធ្វើជំនួញជាមួយបរទេសតាមសមុទ្រ ។ ម្តងនេះសកម្មភាពជំនួញច្រើនធ្វើនៅតាមផ្លូវទឹកក្នុងប្រទេស តែកំពង់ផែអូកែវ ឬអូកែវដែរនៅតែដើរតួយ៉ាងសំខាន់នៅក្នុងវិស័យពាណិជ្ជកម្មដ៏រស់រវើកជាមួយបរទេស ពិសេសជាមួយឥណ្ឌា ព្រោះកំពង់ធំនេះគឺជាចំណុចជួបគ្នារវាងអ្នកដំណើរ ឬអ្នករកស៊ីមកពីប្រទេសខាងកើត និងមកពីប្រទេសចិន[60] ។

ជាការពិតណាស់នៅសម័យអង្គរ មានកប៉ាល់ចិនមួយចំនួនទោះតិច ឬច្រើនតែជាទៀងទាត់បានមកដល់ប្រទេសចម្ប៉ា និងកម្ពុជា ហើយក៏ប្រហែលទៅប្រទេសជ្វា ស៊ូម៉ាត្រា និងឆ្នេរសមុទ្រម៉ាឡេស៊ីដែរ ដើម្បីស្វែងរកទិញផលិតផលនៅតាមតំបន់នេះ ឬក៏ដើម្បីបញ្ជូនអ្នករាជទូតជាដើម ។

ក្រៅពីទន្លេ បឹងបួ និងស្ទឹងជាច្រើននេះ ខ្មែរយើងបានជីកព្រែក ប្រឡាយជាច្រើនទៀត ដែលទូកជំនួញតូចធំអាចធ្វើដំណើរឆ្លងកាត់ចុះឡើងរហូតដល់កំពែងបូរីអង្គរធំ ។ លោកប៉ែរណា គ្រោលីយេបានសរសេរថានាវាសមុទ្រធំៗអាចឡើង តាមទន្លេមេគង្គឆ្លងចូលបឹងទន្លេសាប ហើយឡើងរហូតដល់មាត់ច្រាំងនៅក្បែរតំបន់អង្គរ(នៅរដូវវស្សា) ។

ដូចនេះក្រុងអង្គរឋិតនៅទីប្រជុំនៃចរន្តពាណិជ្ជកម្មក្រៅស្រុក និងក្នុងស្រុកដោយសារតែបណ្តាញផ្លូវគោក និងផ្លូវទឹកទាំងឡាយនេះឯង ។

### ២.៦ អប់រំសិក្សា

របៀបកត់ត្រានៅសម័យអង្គរគឺគេសរសេរនៅលើថ្ម ឬនៅលើស្បែកសត្វ តែការសរសេរលើស្បែកសត្វ គ្មានឯកសារសេសសល់ដល់សព្វថ្ងៃនេះទេ ។ ក្នុងការកត់ត្រាលើផ្ទាំងថ្ម "សិលាចារឹក" គេនិយមប្រើភាសាសំស្ក្រឹត ភាសាខ្មែរបុរាណ និងភាសាបាលី ។ គេបានរកឃើញសិលាចារឹកសម័យនគរភ្នំមួយនៅវ៉ូកាញ់ ក្នុងភូមិភាគ ញ៉ាត្រាង (យួនខាងត្បូង) ជាសិលាចារឹកខ្មែរដំបូងបង្អស់ប៉ុន្តែសេចក្តីក្នុងសិលាចារឹកនោះជាភាសាសំស្ក្រឹត[61] ។ ការសិក្សាប្រៀបធៀបបានឲ្យដឹងថាអក្សរខ្មែរបុរាណនឹងអក្សរឥណ្ឌាខាងត្បូងមានទ្រង់ទ្រាយដូចគ្នា ។

[60] Louis Frédéric, **La Vie Quotidienne dans la Péninsule Indochinoise à l'époque d'Angkor**, Paris, Hachette, 1981, P. 115

[61] ខាត់ ធី **ប្រវត្តិសាស្ត្រប្រទេសកម្ពុជា** ភ្នំពេញ ២០០៩ ទំព័៦ **៥៩**

ភាសាសំស្ក្រឹតជាភាសាដែលអ្នកប្រាជ្ញសំរាប់ប្រើកត់ត្រាធ្វើបញ្ជីព្រះរាជវង្សនុវង្ស ឬមហាក្សត្រ និងតែងសេចក្តីសរសើរដល់ក្សត្រដែលសាងប្រាសាទ ឬអស់លោកដែលមានសទ្ធាជ្រះថ្លាធ្វើអំណោយទាន ។ តាមសិលាចារឹកភាសាខ្មែរបុរាណសម្រាប់កត់ត្រា រាយរឿងការកសាង និងសេចក្តីរៀបរាប់ពួកមនុស្សបំរើ និងគ្រឿងប្រដាប់ប្រដាដែលវេរថ្វាយព្រះវិហារ ។ ភាសាសំស្ក្រឹត និងភាសាខ្មែរបុរាណនិយមទាក់ទងនឹងប្រវត្តិក្សត្រ ព្រមទាំងការគ្រប់គ្រងអាណាចក្រខ្មែរ ដែលមានប្រើច្បាប់សម្រាប់ស្រុកទេសសម្រាប់តុលាការព្រមទាំងកត់ត្រាវិជ្ជាដោយមុខផ្សេងៗទៀត ។ ភាសាសំស្ក្រឹតត្រូវបានគេធ្វើដោយប្រពៃនាពេលនោះ ។ សិលាចារឹកបានប្រាប់ពីមុខងារសំខាន់ៗដែលក្សត្រីពីររូបបានបំពេញជាប្រយោជន៍ដល់បញ្ញា និងការចេះដឹងគឺព្រះនាងឥន្ទ្រទេវី និងព្រះនាងជ័យរាជទេវី (ជាបងប្អូនបង្កើតនឹងគ្នា និងជាអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ ) ។ ព្រះនាងឥន្ទ្រទេវីចេះវិជ្ជាអក្សរសិល្ប៍ ចេះភាសាសំស្ក្រឹតច្បាស់លាស់ ចេះវិទ្យាសាស្ត្រផ្សេងៗ ហើយមានប្រាជ្ញាឈ្លាវៃផង ។ ព្រះនាងឥន្ទ្រទេវីត្រូវបានព្រះរាជាតែងតាំងជាសាកលវិទ្យាធិការនីនៅសាកលវិទ្យាល័យមួយឈ្មោះថាទិលកុត្តរ ហើយព្រះនាងបង្ហាត់បង្រៀនស្រីខ្មែរអំពីមុខវិជ្ជាសាសនានៅក្នុងវត្តមួយឈ្មោះ នរេន្ទ្រាស្រម គឺព្រះនាងឥន្ទ្រទេវីនេះហើយ ដែលបានណែនាំបញ្ចុះបញ្ចូលព្រះស្វាមីអោយងៃកមកកាន់ព្រះពុទ្ធសាសនាមុតមាំ ។ ចំណែកព្រះនាងជ័យរាជទេវី ជាព្រះរាជកនិដ្ឋភគីនីវិញ ព្រះនាងតែងមានព្រះទ័យសន្តោសប្រោសប្រណីដល់ពួកក្មេងស្រីកំព្រា ហើយបានណែនាំពួកទាំងនេះ ឲ្យសាងផ្នួសជាដូនជីនៅក្នុងភូមិមួយឈ្មោះ **ធម៌កេរ្តិ៍** ។ ព្រះនាងថែមទាំងធ្លាប់បានឲ្យគេលេងល្ខោនជាតកទៀតផង ។

ក្រៅពីរៀបរាប់ខាងលើនៅសម័យអង្គរមានមហាវិទ្យាល័យ និងសាកលវិទ្យាល័យដែលជាថ្នាលសម្រាប់បណ្តុះបណ្តាលការចេះដឹងសព្វសារពើ ។ យោងតាមចំនួន និងទំហំនៃប្រាង្គប្រាសាទ និងក្បាច់ចំលាក់ទាំងឡាយឃើញថា សំបូរស្ថាបត្យករ វិស្វករ ជាង និងសិប្បករណាស់ ។ ជាមួយគ្នានេះប្រាកដជាមានអ្នកចេះដឹងមុខវិជ្ជាបន្ទាប់បន្សំជាចាំបាច់ដទៃទៀតជាច្រើន នៅក្នុងមជ្ឈដ្ឋានប្រជារាស្ត្រដូចជា៖ គណិតវិទ្យា និងតារាវិទ្យាជាដើម ។ដូចច្នេះដើម្បីផ្ទេរចំនេះវិជ្ជាពីជំនាន់មនុស្សមួយទៅជំនាន់មនុស្សមួយទៀត លុះត្រាតែមានការអប់រំ បង្ហាត់បង្រៀនគ្នា បានន័យថា គោងតែមានរោងជាងនិងសាលាតាមបែបណាមួយមិនខាន។ ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី ១ វត្តយសោធរាស្រមជាទីប្រជុំនៃនិស្សិតបរទេសដែលរមែងស្វះស្វែងមករៀនចំនេះវិជ្ជាផ្សេងៗអំពីប្រទេសខ្មែរ ។ តួយ៉ាងនៅក្នុងសម័យបាយ័ន មានបដិមាជាច្រើនបង្ហាញលក្ខណៈប្រហាក់ប្រហែលគ្នា ជាហេតុនាំអោយគេសន្មតថា ចេញពីរោងជាងតែមួយ ឬសាលាតែមួយ ។ ម្យ៉ាងទៀតគួរចាប់អារម្មណ៍ដល់សិលាចារឹកទាំងឡាយនៅសម័យនោះ ដែលរមែងតែង

តែអួតសរសើរគុណសម្បត្តិខាងផ្លូវបញ្ញា និងផ្លូវសីលធម៌របស់តួអង្គនានា មិនថាប្រុស ឬស្រី មិនថាស្តេច ឬរាស្ត្រឡើយ ហើយទាំងនេះសអោយឃើញច្បាស់ថាគេចេះអោយតម្លៃទៅលើចិត្តគំនិតច្រើនជាងទៅលើបុណ្យសក្តិ និងសំភារៈ ដែលទាំងអស់នេះជាការអប់រំនៅសម័យអង្គរ ។

### ២.៧ សង្គមកិច្ច "វេជ្ជសាស្ត្រ"

ដោយមានឧត្តមគតិស្នេហាជាតិស្រឡាញ់ប្រជារាស្ត្រ នៅចុងសតវត្សទី ១២ **ព្រះបាទជ័យវរ្ម័នទី៧** បានកសាងមន្ទីរពេទ្យគ្រប់ទីកន្លែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាមាន ១០២ កន្លែងនិងធម្មសាលា ឬសាលាសំណាក់**១២១** ហើយមានប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈអាចចូលទៅព្យាបាលដោយគ្មានរើសអើង ។ នៅតាមមន្ទីរពេទ្យទាំងនោះមានចារឹកពាក្យស្លោកថា:..."**ជំងឺរបស់ប្រជារាស្ត្រធ្វើឲ្យព្រះអង្គឈឺចាប់ជាងជំងឺផ្ទាល់ព្រះអង្គទៅទៀត ពីព្រោះថាសេចក្តីឈឺចាប់របស់ប្រជារាស្ត្រនេះហើយ ដែលជាសេចក្តីឈឺចាប់របស់ព្រះរាជាទាំងឡាយ ពុំមែនជាសេចក្តីឈឺចាប់ផ្ទាល់ទេ ដែលធ្វើឲ្យព្រះអង្គឈឺចាប់**[62] " ។ ចំណេះដឹងនិងបទពិសោធន៍ក្នុងវិស័យសង្គមកិច្ចទាំងនេះ ប្រជារាស្ត្រខ្មែរមានការយល់ដឹងជាយូរមកហើយ ។ គ្រូព្យាបាលជំងឺស្គាល់ច្បាស់លាស់ពីលក្ខណៈរោគជាសារវន្ត និងជំងឺមួយចំនួនធំ ហើយអាចព្យាបាលជំងឺទាំងនេះបានជាសះស្បើយ តាមរយៈថ្នាំផ្សំពីរុក្ខជាតិដែលមាននៅក្នុងស្រុក ។ មន្ទីរពេទ្យជាច្រើនបានសង់រាយពាសពេញប្រទេស និងមានតួនាទីព្យាបាលប្រជារាស្ត្រដោយពុំគិតពីឋានៈ ឬវណ្ណៈអ្វីឡើយ ។ ព្រះរាជបន្ទូលរបស់**ព្រះបាទជ័យវរ្ម័ន ទី ៧** ចារទុកនៅតាមមន្ទីរពេទ្យបានអោយយើងដឹងថា បុព្វបុរសយើងចេះផ្សំថ្នាំនានាអំពីរុក្ខជាតិ និងរូបធាតុក្រអូបទាំងឡាយដែលជារូបធាតុក្នុងស្រុកមានដូចជា ៖ ម្រេចម៉ត់ ដើមប្រេងខ្យល់ស្អុរ ទេពភារូ វ៉ាន់ស៊ុយ ក្រវាញ ខ្ញី ទឹកឃ្មុំ...-ល- ។ ទាំងអស់នេះ ជាការដកបទពិសោធន៍ដែលមានបទពិសោធន៍ដ៏មានប្រសិទ្ធភាពខ្ពស់បំផុតក្នុងវិស័យវេជ្ជសាស្ត្រប្រពៃណី ជាមត៌កបុព្វបុរសដែលបានបន្សល់ទុកអោយ ហើយដែលយើងត្រូវតែប្រើប្រាស់ និងសិក្សាពង្រីកបន្ថែមទៀតដើម្បីបំពេញតម្រូវការរបស់ប្រជាជន ។

## ៣. ការធ្លាក់ចុះនៃសម័យអង្គរ

### ៣.១. ដោយសារសង្គ្រាមឈ្លានពាន

សង្គ្រាមរវាងសៀម-កម្ពុជាបានចាប់ផ្តើមពីឆ្នាំ **១២៩៦** ។ កាលពីពេលនោះសៀមប្រយុទ្ធដើម្បីការពារដែនដីរបស់ខ្លួនដែលបណ្តើមបានពីកម្ពុជា ក្រោយកំណាកំណើតរដ្ឋសុខោទ័យ ។ មកដល់សតវត្ស

[62] ខាត់ ធី **ប្រវត្តិសាស្ត្រប្រទេសកម្ពុជា** ភ្នំពេញ ២០០៩ ទំព័រ ៦២

ទី ១៤ គឺក្រោយពេលដែលសៀមបង្កើតបានរដ្ឋអាយុធ្យា និងដោយឃើញសក្តានុពលយោធារបស់កម្ពុជាស្រុតចុះ សៀមចាប់ផ្តើមពង្វាតទឹកដីរបស់ខ្លួនមកលើរាជាណាចក្រកម្ពុជា ។

### ៣.១.១. សង្គ្រាមឈ្លានពានរបស់សៀមលើកទីមួយ (១៣៥១-១៣៥៥)

ឆ្នាំ១៣៥១ បន្ទាប់ពីបានធ្វើអោយព្រះរាជាណាចក្រសៀមមានឯកភាព និងបង្កើតបានជារដ្ឋអាយុធ្យាមកស្តេចសៀមព្រះនាមរាមាធិបតីទី ១ បានលើកទ័ពយ៉ាងធំចូលមកវាយព្រះរាជណាចក្រកម្ពុជា ។ នៅពេលនោះខ្មែរពុំបានដឹងខ្លួនជាមុនទេ ព្រះរាជាខ្មែរព្រះនាមព្រះបាទស្រីលំពង្សរាជាបានចាត់តាំងអោយការពាររាជធានីយ៉ាងរឹងមាំ ។ កងទ័ពខ្មែរថ្វីបើពុំបានត្រៀមខ្លួនជាមុនក៏បានតស៊ូការពាររាជធានីយ៉ាងខ្លាំងក្លាធ្វើអោយកងទ័ពសៀមទទួលបរាជ័យដកថយទៅវិញ ។

មួយឆ្នាំក្រោយមកគឺក្នុងឆ្នាំ ១៣៥២ សៀមបានលើកទ័ពមកឈ្លានពានកម្ពុជាម្តងទៀត (បញ្ជាក់ៈលើកនេះលកងទ័ពសៀមច្រើនលើសមុនដប់ដង) ។ ឯខាងខ្មែរវិញដោយនឹកស្មានថាសៀមខ្លាចពុំហ៊ានត្រឡប់មកវិញ ក៏ពុំបានត្រៀមសំភារៈសឹក ស្បៀង ថែមទាំងបានរំសាយកងពលអោយទៅធ្វើស្រែចំការអស់មួយចំនួនធំ ។ នៅពេលដែលកងទ័ពសៀរមវាយលុកមកដល់ក្រុងអង្គរ ព្រះបាទស្រីលំពង្សរាជា និងព្រះអនុជដែលឧបរាជ ព្រះនាមសុរិយោទ័យ បានខិតខំប្រមូលប្រជាជនតំបន់អង្គរអោយចូលរួមប្រយុទ្ធការពាររាជធានី ។

ក្រោយពីបានធ្វើការតស៊ូទប់ទល់អស់រយៈ **៦-៧** ខែមក ព្រះបាទស្រីលំពង្សរាជាទ្រង់ប្រឈួនហើយសុគតទៅ ។ ចំណែកព្រះអនុជព្រះនាមសុរិយោទ័យ នាំទ័ពការពាររាជធានីរហូតក្ស័យព្រះជន្មទៅដែរ ។ កងទ័ពខ្មែរអស់មេដឹកនាំក៏បែកខ្ញែកគ្នា ហើយក្រុងអង្គរក៏ធ្លាក់ទៅក្នុងកណ្តាប់ដៃសៀម ។

### ៣.១.២. សង្គ្រាមឈ្លានពានរបស់សៀមលើកទី ២ (១៣៩៣-១៤១០)

៤០ឆ្នាំក្រោយមកគឺនៅចុងឆ្នាំ១៣៩៣ ក្នុងរជ្ជកាលព្រះបាទធម្មាសោក សៀមបានលើកទ័ពចូលមកលុកលុយកម្ពុជាថ្មីទៀត ។ កាលនោះព្រះរាជាខ្មែរបានចាត់ទ័ពចំនួន **៤** កងពលអោយយាមការពារព្រំដែនព្រះនគរ ប៉ុន្តែ **២** កងពលដឹកនាំដោយអង្គម្ចាស់កែវ និងទ័ពពុំព្រមក្រាញប្រយុទ្ធទប់ទល់ទេ ពួកគេចេះតែដកទ័ពថយធ្វើអោយទ័ពសៀមវាយលុកចូលរហូតហ៊ុមព័ទ្ធរាជធានីអង្គរបាន ។

ជាថ្មីម្តងទៀតអ្នកក្រុងអង្គរ និងកងទ័ពក្រោមការដឹកនាំរបស់ព្រះរាជាបានប្រើគ្រប់មធ្យោបាយការពាររាជធានី ។ ក្រោយពីការធ្វើការហ៊ុមព័ទ្ធអស់រយៈពេល **៧** ខែ សៀមបានធ្វើការទាក់ទងជាសំងាត់ជាមួយអ្នកអង្គម្ចាស់កែវ និងទ័យ ហើយអោយជនក្បត់ជាតិទាំងពីរលបចូលបើកទ្វារបន្ទាយ

ក្រុងអង្គរអោយកងទ័ពសៀមចូល ។ ទីក្រុងអង្គរក៏ត្រូវទ័ពសៀមចូលលុកពាសពេញ ការប្រយុទ្ធខ្លួនទល់ខ្លួនកើតមានយ៉ាងកាលាហល ពេលនោះ**ព្រះបាទធម្មាសោក(១៣៧៣-៣៩៣)** ជាព្រះមហាក្សត្រខ្មែរ ក៏បានសោយទីវង្គតក្នុងសង្គ្រាមនោះទៅ ។ ជាលទ្ធផលទៅក្រុងអង្គរត្រូវសៀមចូលកាន់កាប់ម្តងទៀតនៅឆ្នាំ១៣៩៤[63] ។

### ៣.១.៣. សង្គ្រាមឈ្លានពានរបស់សៀមលើកទី ៣ (១៤២០)

មកដល់ឆ្នាំ១៤២០ គឺក្នុងរជ្ជកាលព្រះបាទបរមសុខា ជារាជបុត្រព្រះបាទសុរិយោវង្សទី២ សៀមបានលើកកងទ័ពយ៉ាងធំម្តងទៀតក្នុងបំណងសងសឹក និងឈ្លានពានកម្ពុជា ដោយសារតែកងកម្លាំងសៀមខ្លាំងពេក កងទ័ពខ្មែរបានដកថយមកតាំងទីប្រយុទ្ធការពាររាជធានី ។ កងទ័ពសៀមបានវាយគ្នាឡោមព័ទ្ធក្រុងអង្គរ ក៏ប៉ុន្តែមិនអាចឆ្លងកំពែងដ៏រឹងមាំរបស់ក្រុងអង្គរបានឡើយ ។

ទ័ពសៀមឡោមព័ទ្ធក្រុងអង្គរអស់រយៈពេល ៧ ខែ ។ ស្បៀង និងកងទ័ពក៏កាន់តែគ្មានសល់ម្យ៉ាងវិញទៀតកងជំនួយរបស់ខ្មែរក៏បានធ្វើដំណើរជិតមកដល់ក្រុងអង្គរ ។ សភាពការណ៍នេះធ្វើឲ្យសៀមភ័យខ្លាច ពេលនោះសៀមបានប្រើល្បិចចាប់យកទាហានខ្លួនចំនួន ៦ នាក់ ចងវ៉ាយវាយ ៥០ រំពាត់ និងលាក់ថ្វាសជាសញ្ញាជើងក្អែក ។ ទាហានសៀមទាំង ៦ នាក់ក៏រត់មកជ្រកកោនមកសុំជ្រកកោនខាងខ្មែរ ។ ដោយសារតែព្រះរាជាខ្មែរពុំយល់ល្បិចលកសៀម ក៏បានយល់ព្រមទទួលជនទាំង ៦ នាក់នោះ ។ ទាហាន ២ នាក់ស្លាប់ដោយបែកខ្នងកាលត្រូវគេចងវ៉ាយវាយ ចំនែក ៤ នាក់ទៀតបានខំធ្វើការហូតស្តេចខ្មែរទុកព្រះទ័យ ហើយតំលើងបុណ្យសក្តិ ។ លុះបានឱកាសល្អក្លាហាន ទាហាន ៤ នាក់នោះបានអោយការណ៍ទៅព្រះចៅសៀម ។ កងទ័ពសៀមក៏បានបើកការវាយលុកចូលក្រុងអង្គរ ។ ទីបំផុតសៀមបានវាយយកទីក្រុងអង្គរបានដោយជោគជ័យ ហើយស្តេចសៀមក៏បានតែងតាំងរាជបុត្ររបស់ខ្លួនឈ្មោះ ឥន្ទរាជា ឲ្យធ្វើជាស្តេចសោយរាជ្យនៅអង្គរ ។

### ៣.២. ដោយសារធម្មជាតិ

លោក B.Groslier បានបង្ហាញថាអាកាសធាតុ និងធរណីនៅតំបន់អង្គរបានជំរុញអោយមានប្រតិកម្មយ៉ាងសាហាវធ្វើអោយប្រព័ន្ធជនសាស្ត្រខ្មែរមិនអាចជួសជុលបាន ហើយដែលគ្មានអ្នកណាម្នាក់ស្មានទុកជាមុន[64] ។ លោកបានពន្យល់ថាការបង្ហូរទឹកលើដងស្ទឹងទាំងឡាយដែល ពោរពេញទៅដោយភក់ល្បាប់ និងមានជំរាលយ៉ាងទាបបែបនេះពុំអាចគេចផុតពីការគំរាមកំហែងជានិច្ចកាលដែលបណ្តាល

---

[63] តន ឌីម សាម៉េង **វប្បធម៌ទូទៅ** ភ្នំពេញ ២០០៨

[64] ៧ សារឿន **ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា** ភ្នំពេញ ២០១០ ទំព័រ ៥១

មកពីគាំងដោយល្បាប់នោះទេ ។ ជាច្រើនឆ្នាំដរាបមកស្ទឹងទាំងឡាយត្រូវចាលគាំងដោយល្បាប់នាំឲ្យទឹកហូរខុសផ្លូវ ដែលជាហេតុនាំអោយប្រឡាយបង្ហូរទឹកសំរាប់ប្រើប្រាស់ក្នុងក្រុង និងប្រឡាយបង្ហូរទឹកផ្សេងៗទៀតក្តី ដែលភ្ជាប់ទៅនឹងស្ទឹងត្រូវបានគាំងដំនើរ ។ លោកយកឧទាហរណ៍នៅសម្បូរព្រៃគុក ខ្មែរយើងរស់នៅទីនោះយ៉ាងហោចណាស់ក៏រហូតដល់សតវត្សទី ១៣ ក៏ត្រូវសាបសូន្យព្រោះថាស្ទឹងដែលផ្តល់ទឹកអោយទីក្រុងនេះត្រូវចាល ហើយបែរក្បាលបង្វែងទឹកប្រហែល ៣ គីឡូម៉ែត្រទៅខាងកើត ដូចយើងឃើញសព្វថ្ងៃដោយសារដីល្បាប់នេះឯង ។

ពិសេសទៅទៀតនៅក្នុងរាជធានីយើងពុំអាចផ្លាស់ប្តូរគូទឹក ដែលព័ទ្ធប្រាសាទទាំងឡាយឬស្រះទឹកបានទេ បារាយណ៍ថ្មីៗគេអាចលើកបានតែនៅខាងក្រៅ ហើយឆ្ងាយពីរាជធានីប៉ុណ្ណោះ ។ ដូចច្នេះនៅទីបំផុត ធម្មជាតិបានបង្ខំអោយយើងបោះបងរាជធានីចាស់ ហើយសាងរាជធានីថ្មីនៅទីផ្សេងតែម្តង ។

### ៣.៣ ការធ្លាក់ចុះនៃផលិតផលកសិកម្ម

នៅពាក់កណ្តាលសតវត្សទី ១៣ ការវិវត្តន៍នៃបាតុភូតសង្គម និងធម្មជាតិ បានកើតឡើងធ្វើឲ្យកំពស់ទឹកនៅតាមស្ទឹងដ៏សំខាន់ គឺស្ទឹងសៀមរាបបានថយចុះ ។ ដីហិលអស់ជីជាតិ បានបណ្តាលឲ្យផលដំណាំកសិកម្មថយចុះ ។ ម្ល៉ោះហើយបណ្តាលកសិករក៏ចាប់ផ្តើមចាកចេញពីរាជធានីអង្គរជាបណ្តើរ[65] ។

ដូចយើងដឹងហើយថាសេដ្ឋកិច្ចខ្មែរសម័យអង្គរជាសេដ្ឋកិច្ច ដែលពឹងផ្អែកទៅលើកសិកម្មអតិផលទាំងស្រុង ហើយខ្មែរអាចធ្វើស្រែបានយ៉ាងហោចណាស់ពីរ ឬ បីដងដោយការបញ្ចូលទឹកក្នុងស្រែតាមបណ្តាញជលគតិ ។ ប៉ុន្តែដោយបារាយណ៍ខ្ទេចខ្ទាំដោយសង្គ្រាម និងខូចខាតដោយបាតុភូតធម្មជាតិព្រមទាំងដីស្ទើរក្លាយទៅជាថ្មបាយក្រៀមបែបនេះ ទើបធ្វើអោយយើងមិនអាចប្រកបកសិកម្មអតិផលបានទៀតទេ ពោលគឺយើងធ្វើស្រែបានតែម្តងដោយសារទឹកភ្លៀងក្នុងមួយឆ្នាំហើយទិន្នផលក៏ធ្លាក់ចុះ ដែលអាចឲ្យយើងប៉ាន់ប្រមាណបានថាផលិតកម្មស្រូវប្រចាំឆ្នាំត្រូវថយពី បី ទៅ បួន ភាគរយ ។

### ៣.៤. គំហាយប្រជាជន

ការធ្លាក់ចុះនៃផលិតផលមានវិបាកធ្ងន់ធ្ងរណាស់ចំពោះប្រជាគណាន៍ ។ កង្វះស្រូវអង្ករបង្កើតបានជាទុរ្ភិក្ស ធ្វើអោយមនុស្សជាច្រើនរងទុក្ខវេទនា ។ មនុស្សដែលទទួលអាហារពុំគ្រប់គ្រាន់ពុំអាចទប់ទល់នឹងជំងឺដង្កាត់ផ្សេងៗ ដែលយាយីបានទេ ។ ដូចច្នេះបន្ថែមពីលើការអត់អាហារ ប្រជាជនសម័យអង្គរ (ក្រោយសតវត្សទី១៣) ស្លាប់ដោយជំងឺថែមទៀត ។

[65] ឡុងសៀម ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ម៉ូស្គូ ១៩៨៥ ទំព័១១៦

លោក Pierre Gourou មានប្រសាសន៍ថា ជំងឺគ្រុនចាញ់រាតត្បាតយ៉ាងខ្លាំងនៅតំបន់អង្គរ ។ លោក B.P Groslier ក៏ស្របយោបល់ចំពោះរឿងមូសដែកគោលរាតត្បាតនេះដែរ ប៉ុន្តែលោកបានមានប្រសាសន៍បន្ថែមថាមតិដែលថា ជំងឺគ្រុនចាញ់ជាកត្តាមួយដែលធ្វើអោយធ្ងន់ធ្ងរដល់ការធ្លាក់ចុះនៃអរិយធម៌នោះជាការសមសម្បណាស់ ព្រោះគេសង្កេតឃើញថាមកដល់បច្ចុប្បន្នជំងឺចង្រៃនេះនៅតែរាតត្បាតយ៉ាងខ្លាំងនៅឡើយនៅតំបន់អង្គរ[66] ។

កត្តាមួយទៀតដែលនាំអោយថយចំនួនប្រជាជាគឺដោយសារសង្គ្រាម ។ ប្រវត្តិវិទូខ្លះមានលោក P.Devillers ជាដើមបានមានប្រសាសន៍ថា នៅសម័យអង្គរប្រជាជនរស់នៅប្រមូលផ្តុំគ្នាកុះករខាងជើងបឹងទន្លេសាប ។ សង្គ្រាមដែលនាំអោយអរិយធម៌អង្គរដួលរលំភាគច្រើនកើតមាននៅតំបន់នោះ ដូចច្នេះច្បាស់ណាស់ថាប្រជាជនមួយចំនួនត្រូវស្លាប់ដោយសង្គ្រាម ។ ម៉្យាងវិញទៀតពួកសត្រូវពុំគ្រាន់តែសំលាប់អ្នកស្រុកប៉ុននោះទេ ពួកគេថែមទាំងបានចាប់នឹងកៀរប្រជារាស្ត្រយកជាឈ្លើយផងដែរ ។ តាមតួលេខរបស់ប្រវត្តិវិទូខ្លះថាអ្នកស្រុកដែលសៀមកៀរទៅស្រុកវាម្តងៗមានចំនួន ៩០ ០០០នាក់ ខ្លះថា ៧០ ០០០នាក់ ។ដូចនេះចំនួនប្រជាជនកាន់តែចុះថយជាលំដាប់នៅតំបន់អង្គរ ។

ក្នុងបុព្វហេតុផ្សេងទៀតដែលនាំអោយតំហាយប្រជាជននេះ ពោលគឺប្រជាជនត្រូវស្លាប់ដោយសារការកសាងប្រាសាទសន្ធឹកសន្ធាប់នៅមុនសតវត្សទី ១៣ ។ លោក Pierre Gourou បានគន់គូរឃើញថាប្រាសាទអង្គរវត្ត និងប្រាសាទជាច្រើនទៀតជាងពីរពាន់ប្រាសាទ តើគេត្រូវប្រើមនុស្សប៉ុន្មាននាក់ដើម្បីដឹកជញ្ជូនថ្ម និងកសាងប្រាសាទទាំងនោះ ។ ដូចច្នេះលោកអាចសន្និដ្ឋានបានថា មនុស្សស្លាប់ដោយការកសាងប្រាសាទក្នុងរយៈពេលបួនទសវត្សនេះមិនតិចជាងមនុស្សដែលស្លាប់ដោយសារចំបាំងនោះឡើយ ។

កត្តាទាំងអស់នេះហើយ ដែលនាំអោយមានតំហាយប្រជាជននៅតំបន់អង្គរដែលដើមឡើយមានមនុស្សកុះករ ។ ការស្រុតចុះនៃចំនួនប្រជាជនកាន់តែច្បាស់ទៅទៀត បើយើងលើកយកស្ថិតិនៃប្រវត្តិវិទូខ្លះមកពិនិត្យមើល ។ លោក Louis Cheminais ក្នុងសៀវភៅ"ប្រទេសកម្ពុជា" ទំព័រ ១៩៨ លោកបានដាក់ថា នៅឆ្នាំ **១២០០** គ.ស គឺនៅរជ្ជកាល**ព្រះបាទជ័យវរ្ម័នទី ៧** ប្រទេសកម្ពុជាមានចំនួនប្រជាជន **១០** លាននាក់ ហើយនៅឆ្នាំ **១៨៦៣** គឺនៅពេលដែលប្រទេសកម្ពុជាយើងធ្លាក់ទៅក្នុងអាណាព្យាបាលបារាំងប្រទេសកម្ពុជាយើងមានចំនួនប្រជាជនតែ ៨ សែននាក់ ប៉ុណ្ណោះ ។ ដូចច្នេះយើងអាចប្រមាណបានថាមុនពេលដែលខ្មែរយើងបោះបង់សម័យអង្គរ គឺពីរទសវត្សកន្លះក្រោយពីការចូលទីវង្គត់នៃព្រះបាទជ័យវរ្ម័នទី ៧ ប្រទេសកម្ពុជាយើងត្រូវបាត់បង់ប្រជាជនយ៉ាងហោចណាស់ក៏សែសិបប្រាំភាគរយដែរ ។

---

[66] ពៅ សារឿន **ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា** ភ្នំពេញ ២០១០ ទំព័រ **៥៣**

## សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមរយៈការរៀបរាប់នៃដំណើរកសាងក្រុងអង្គរ គួរឲ្យកត់សំគាល់ឃើញថា ការកសាងអង្គរ គឺមានលក្ខណៈពិសេសចាច្រើន តួយ៉ាងលក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ ដែលជាទីតាំងមួយសមប្រកបមានលំនឹងធម្មជាតិ ដែលមានទឹកដី ព្រៃព្រឹក្សា ខ្យល់អាកាស និងបរិវេណមួយប្រកបដោយភាពអំណោយផល ដល់គ្រប់វិស័យនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍នៅក្នុងតំបន់នេះ ។ ម្យ៉ាងវិញទៀតនោះ គឺជាទីតាំងប្រវត្តិសាស្ត្រ ដែលទីតាំងមហានគរនេះ មានឥទ្ធិពលធំធេងដ៏កំណាកំណើតការលូតលាស់របាយធនធានធម្មជាតិ ប្រជាជន សេដ្ឋកិច្ច វប្បធម៌ ដែលទឹកដីនេះបានផ្សាភ្ជាប់យ៉ាងជិតស្និតជាមួយភូមិភាគអាស៊ីអាគ្នេយ៍ ទាំងដីគោក និងដីកោះលើលក្ខណៈធម្មជាតិ និងប្រវត្តិសាស្ត្រ ។ ទន្ទឹមនឹងការមើលឃើញអំពីលក្ខណៈពិសេសនៅក្នុងការកសាងក្រុងអង្គរ ងាកក្រឡេកមកមើល ដំណើរការរៀបចំ និងការកសាងក្រុងសម័យអង្គរវិញម្តង ដែលការកសាងក្រុងសម័យអង្គរ គឺបានឆ្លងកាត់ហេតុការណ៍ដែលកើតមាន ជាច្រើនដែលកើតមាន ដូចជាការផ្លាស់ប្តូររាជធានីពីកន្លែងមួយទៅកន្លែងផ្សេងទៀតក្នុងបរិវេណក្រុងសម័យអង្គរ រួមមានជាអាទ៍ រាជធានីមហេន្ទ្របរិត រាជធានីហរិហរាល័យ រាជធានីសោធបុរៈទី១ (ក្រុងអង្គរទី១) រាជធានីកោះកេរ្តិ៍ រាជធានីសោធបុរៈទី២ (ក្រុងអង្គរទី២) រាជធានីសោធបុរៈទី៣ (ក្រុងអង្គរទី៣ ឬប្រាសាទអង្គរវត្ត) និងរាជធានីសោធបុរៈទី៤ (អង្គរធំ ឬក្រុងអង្គរទី៤) ។

ឆ្លើយតបនៅក្នុងការកសាងក្រុងអង្គរ គឺមានការចូលរួមចំណែកយ៉ាងច្រើនពីកត្តាមួយចំនួនដែលជំរុញឲ្យមានការអភិវឌ្ឍន៍ និងការរីកចំរើនក្រុងនាសម័យអង្គរ គឺរួមមានកត្តាធនធានមនុស្ស ដែលជនជាតិខ្មែរនៅសម័យអង្គរ ជាជនជាតិដែលមានចិត្តឧស្សាហ៍ព្យាយាម និងពូកែច្នៃប្រឌិត ដែលមានមហិច្ឆតាធំបំផុត គឺការធ្វើឲ្យមានភាពរីកចំរើនលើគ្រប់វិស័យ និងភាពសំបូរសប្បាយនៅគ្រប់ផ្នែក ។ កសិកម្ម ដែលខ្មែរបានជ្រើសរើសទីតាំងនៅតំបន់អង្គរ ព្រោះជាកន្លែងសម្បូរណ៍ដោយសម្បត្តិធម្មជាតិ និងជាពិសេសនោះគឺទឹក ។ សិប្បកម្ម ជនជាតិខ្មែរស្ទាត់ជំនាញ និងប៉ិនប្រសប់យ៉ាងខ្លាំងខាងសិល្បៈចម្លាក់ខាងផ្នែកសំណង់អំពីឈើ និងអំពីថ្មប្រទេស ។ គមនាគមន៍ បណ្តាញផ្លូវថ្នល់បូករួមជាមួយផ្លូវទឹកទាំងឡាយ ទោះផ្លូវទឹកមានកំណើតពីធម្មជាតិក្តី ឬជីកដោយមនុស្សក្តី សុទ្ធសឹងតែមានសារៈសំខាន់ណាស់ចំពោះការដឹកជញ្ជូនផ្នែកពាណិជ្ជកម្ម ។ ពាណិជ្ជកម្ម ដោយតំបន់អង្គរស្ថិតនៅផ្លូវត្រឡែងកែង នៃចរន្តពាណិជ្ជកម្មទាំងឡាយ ទាក់ទងគ្នាក្នុងព្រះរាជាណាចក្រ និងដោយសារតែការីកចំរើនលូតលាស់នៃកសិកម្ម និងសិប្បកម្មនេះផង ។ អប់រំសិក្សា ដោយរបៀបកត់ត្រានៅសម័យអង្គរគឺគេសរសេរនៅលើថ្ម ឬនៅលើស្បែកសត្វ តែការសសេរនៅលើស្បែកសត្វ គ្មានឯកសារសេសសល់ដល់សព្វថ្ងៃទេ ។ សង្គមកិច្ច "វេជ្ជសាស្ត្រ" ដោយ

ឧត្តមគតិស្នេហាជាតិ ស្រឡាញ់ប្រជារាស្ត្រនៅក្នុងសតវត្សទី១២ ព្រះបាទជ័យវរ្ម័នទី៧ បានកសាងមន្ទីពេទ្យគ្រប់ទីកន្លែងនៅក្នុងព្រះរាជាណាចក្រ ១០២កន្លែង និងធម្មសាលា ឬសាលាសំណាក់ ១២១កន្លែង ហើយមានប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈអាចចូលទៅព្យាបាលដោយគ្មានរើសអើង ។

ទន្ទឹមនឹងការរីកចំរើនរបស់ក្រុងសម័យអង្គរ ក៏មានហេតុផលមួយចំនួនបណ្តាលឲ្យមានការធ្លាក់ចុះនៃសម័យអង្គរ ដូចជាសង្គ្រាមឈ្លានពានពីបណ្តាប្រទេសជិតខាងជាច្រើនលើកច្រើនសារ កត្តាធម្មជាតិ គំហាយប្រជាជន និងការធ្លាក់ចុះនៃផលិតផលកសិកម្ម ។

សរុបជារួមមកការកសាងនៅក្នុងសម័យមួយ ទៅសម័យមួយតែងតែមានបញ្ហាប្រឈមមិនថាតិចឬច្រើនឡើយ ប៉ុន្តែអ្វីដែលសំខាន់សួរថា តើថ្នាក់ដឹកនាំ ក៏ដូចជាអ្នកគ្រប់គ្រងមានសមត្ថភាព និងលទ្ធភាពប៉ុនណា ក្នុងការដោះស្រាយ និងបញ្ចៀសរាល់បញ្ហាទាំងអស់នោះ និងធានាយ៉ាងណាស្វែងរកផ្លូវដោះស្រាយប្រកបប្រសិទ្ធភាពខ្ពស់ ។

# ឯកសារយោង


១.សៀវភៅប្រវត្តិសាស្ត្រខ្មែរ របស់បណ្ឌិត **រស់ ចន្ទ្រាបុត្រ** បោះពុម្ពបារាំង ឆ្នាំ ១៩៩៧

២.សៀវភៅប្រវត្តិសាស្ត្រខ្មែរ របស់**ត្រឹង ងា** ភាគ ១ បោះពុម្ពភ្នំពេញ ឆ្នាំ ១៩៧៣

៣.សៀវភៅប្រវត្តិសាស្ត្រនៃព្រះរាជណាចក្រកម្ពុជា របស់សាស្ត្រចារ្យ **ពៅ សារឿន** បោះពុម្ពភ្នំពេញ ឆ្នាំ ២០១០

៤.សៀវភៅប្រវត្តិសាស្ត្រនៃព្រះរាជាណាក្រកម្ពុជា របស់សាស្ត្រចារ្យ**ឥន្ទឪបសាម៉េត** បោះពុម្ពភ្នំពេញ ឆ្នាំ ២០១០

៥.សៀវភៅ**ប្រវត្តិស្ថាប័នខ្មែរ** របស់សាស្ត្រចារ្យពៅ សារឿន បោះពុម្ពភ្នំពេញ ឆ្នាំ២០១១

៦.សៀវភៅប្រវត្តិសាស្ត្រអង្គរ របស់**ម៉ាដឺឡែនហ្ស៊ីតូ ក្រែសំរួលដោយ ម៉ុញ សារី** បោះពុម្ព ភ្នំពេញ ឆ្នាំ២០១១

៧.សៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា របស់សាស្ត្រចារ្យ **ខាត់ធី** បោះពុម្ពភ្នំពេញ ឆ្នាំ២០០៩

៨.សៀវភៅ**ប្រទេសខ្មែរពីបុព្វសម័យរហូតដល់ការបោះបង់រាជធានីអង្គរ** របស់សមាគម Promo-khmer (ភាគទី១) បោះពុម្ពបារាំង ឆ្នាំ២០០០

៩.សៀវភៅ**ព្រះបាទជ័យវរ្ម័នទី ៧** របស់មីសែល ត្រាណេ បោះពុម្ពភ្នំពេញ ឆ្នាំ១៩៩៨

១០.សៀវភៅ**ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា** របស់អ៊ូ វ៉ីឌី បោះពុម្ពភ្នំពេញ ឆ្នាំ២០១២

១១.សៀវភៅ**បុរីខ្មែរសម័យទំនើប** របស់វណ្ណ មូលីវណ្ណ បោះពុម្ពភ្នំពេញ ឆ្នាំ២០០៤

១២.សៀវភៅHistoire du Cambodge របស់ M.Giteau ឆ្នាំ១៩៩៧

១៣.សៀវភៅLa Vie Quotidienne dans la Péninsule Indochinoise à l´époque d´Angkor របស់Louis Frédéric បោះពុម្ពបារាំង ឆ្នាំ1981

# ឧបសម្ព័ន្ធ

រាជធានីយសោធបុរៈទី១(ក្រុងអង្គរទី១) {ភ្នំបាខែង ឬប្រាសាទបាខែង)



រាជធានីកោះកេរ្តិ៍ (ប្រាសាទធំ)





រាជធានីយសោធរបុរៈទី២ (ក្រុងអង្គរទី២) {ប្រាសាទបាពួន)



រាជធានីយសោធបុរៈទី៣( ក្រុងអង្គរទី៣ ឬប្រាសាទអង្គរវត្ត) {ប្រាសាទអង្គរវត្ត}



រាជធានីយសោធបុរៈទី៤ (អង្គរធំ ឬក្រុងអង្គរទី៤) {ប្រាសាទបាយ័ន}



# គន្លឹះទី៣
# ការរៀបចំទីក្រុងក្នុងសម័យទំនើបនៅចន្លោះឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៧៥
## សេចក្តីផ្តើម

នៅលើពិភពលោកយើងនេះ ប្រទេសណាក៏ដូចប្រទេសណាដែរ គឺតែងតែមាននៅបំលាស់ប្តូរក្នុងប្រទេសរបស់ខ្លួន ដូចជាការដោះស្រាយបញ្ហាដែលកើតមានការធ្វើកំណែទម្រង់ និងការអភិវឌ្ឍន៍ជាដើម ។ សកម្មភាពទាំងនេះនាំទៅរកការរៀបចំពីក្រុង និងតំបន់ផ្សេងៗទៀត ដើម្បីសំរួលដល់ការរស់នៅ និងការធ្វើដំណើររបស់អ្នករស់នៅក្នុងតំបន់ទាំងនោះ ជាតិសេសគឺតំបន់ជាយក្រុង ដែលជាកន្លែងដែលត្រូវសម្លឹងមើលឃើញមុនគេកាលណាទីក្រុងមានការរីកចម្រើនខ្លាំង ។ មានកត្តាច្រើនណាស់ដែលនាំឲ្យមានការរៀបចំទីក្រុង ដែលក្នុងនោះរួមមាន ការរីកចម្រើនផ្នែកសេដ្ឋកិច្ច កំណើនប្រជាជន ការបំពុលបរិស្ថាន ការអភិរក្សបេតិកភណ្ឌ សោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់និងទំនៀមទំលាប់សង្គម ។ យ៉ាងហោចណាស់មានកត្តាមួយក្នុងចំណោមកត្តាដែលបានរៀបរាប់ខាងលើជំរុញឲ្យមានការរៀបចំទីក្រុងដែរ ។ ជាក់ស្តែងប្រទេសកម្ពុជាយើងបានអភិវឌ្ឍខ្លួនពីសម័យកាលមួយទៅសម័យកាលមួយទៀតដែលក្នុងនោះ ការរៀបចំក្រុងត្រូវបានរៀបចំឡើងយ៉ាងល្អិតល្អន់ ក្នុងន័យអភិវឌ្ឍឲ្យមានការរៀបចំសណ្តាប់ធ្នាប់ល្អ សោភ័ណភាព និងអនាម័យ និងគ្មានការបំពុលជាដើម ។ ដូចបានដឹងឮគ្រប់គ្នាថា ទីក្រុងភ្នំពេញបច្ចុប្បន្ន យើងមានប្លង់គោលត្រឹមត្រូវ និងច្បាស់លាស់ ដែលក្នុងនោះគឺតំបន់ចតុមុខជាតំបន់ពិសេស ហើយហាមឃាត់មិនឲ្យមានការសាងសង់អគារខ្ពស់ៗ ទៅតាមចិត្តចង់នោះទេ ព្រោះវាអាចនាំឲ្យតំបន់ទេសចរណ៍រងនូវផលប៉ះពាល់ ជាពិសេសគឺអគារបេតិកភណ្ឌចាស់ៗ និងបាត់បង់សោភណ្ឌភាពបេតិកភណ្ឌទាំងនោះ និងអាចរាំងស្ទះខ្យល់អាកាសជាដើម ។ ការរៀបចំបែបនេះមិនមែនចេះតែធ្វើៗទៅតាមតែការនឹកឃើញនោះទេ តែគេមានផែនការសម្រាប់រយៈពេលវែងក្នុងការរៀបចំ តែប្រសិនបើប្រទេសមានការអភិវឌ្ឍន៍លឿន នោះការរៀបចំទីក្រុងនឹងមានការផ្លាស់ប្តូររៀបចំទីក្រុងលឿនទៅតាមនោះដែរ ។ ដូច្នេះយើងសង្កេតឃើញថា កត្តាទាំងឡាយខាងលើ គឺមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការរៀបចំទីក្រុង ដែលយើងគួរតែដឹង និងស្វែងយល់បន្ថែម ។ ទោះជាយ៉ាងណាក៏ដោយការសិក្សាអំពីអ្វីមួយឲ្យស៊ីជំរៅ យើងមិនត្រូវមើលរំលងទេ អំពីប្រវត្តិនៃអ្វីដែលត្រូវសិក្សានោះ ព្រោះវាជាស្ពានមួយសម្រាប់អ្នកសិក្សាទាំងឡាយក្នុងការធ្វើដំណើរទៅរកការអភិវឌ្ឍមួយប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់នូវបទពិសោធន៍ ដែលមានស្រាប់ក្នុងអតីតកាល ។ ហេតុនេះហើយដើម្បីឲ្យការរៀបចំទីក្រុងរបស់យើងប្រព្រឹត្តទៅប្រកបដោយភាពរលូន មិនប៉ះពាល់ដល់ការរស់នៅរបស់ពលរដ្ឋ ក៏ដូចជាបរិស្ថា

នទីក្រុង និងឲ្យការរៀបចំទីក្រុងរបស់យើង ប្រព្រឹត្តទៅប្រកបដោយភាពរលូន មិនប៉ះពាល់ដល់ការស់នៅរបស់ពលរដ្ឋ ក៏ដូចជាបរិស្ថានទីក្រុង និងបន្តយូរអង្វែងបាននោះ យើងមិនត្រូវមើលរំលងជាដាច់ខាតនូវមេរៀនសំខាន់ៗ ពីអតីតកាលក្នុងការរៀបចំទីក្រុងរបស់យើង ។ ក្នុងកិច្ចការស្រាវជ្រាវមួយនេះដែរ យើងនឹងសិក្សាអំពីការរៀបចំទីក្រុងក្នុងសម័យទំនើបនៅចន្លោះឆ្នាំ ១៩៥០ ដល់ឆ្នាំ ១៩៧៥ ដោយវែកញែកនូវការរៀបចំទីក្រុងទៅតាមសម័យកាល ដោយធ្វើការបែងចែកជាបីសម័យកាលដូចខាងក្រោមៈ

- ចុងសម័យអាណានិគមបារាំង(ឆ្នាំ ១៩៥០-១៩៥៣)
- សម័យសង្គមរាស្រ្តនិយម(ឆ្នាំ ១៩៥៣- ១៩៧០ )
- សម័យសាធារណរដ្ឋខ្មែរ(ឆ្នាំ ១៩៧០- ១៩៧៥ )

ការបែងចែកនេះធ្វើឡើង ក្នុងគោលបំណងបង្កឲ្យមានភាពងាយស្រួលដល់ការសិក្សាយល់ដឹងអំពីស្ថានភាពនៃការរៀបចំទីក្រុង ដោយហេតុថាសម័យកាលនីមួយៗ ប្រទេសកម្ពុជាមានបំលាស់ប្តូររបបនយោបាយយ៉ាងខ្លាំង ដែលបណ្តាលឲ្យការរៀបចំមានលក្ខណៈខុសគ្នាទៅតាមនោះដែរ ។ ខ្លឹមសារទាំងស្រុងមានដូចខាងក្រោមៈ

## ១.ចុងសម័យអាណានិគមបារាំង( ១៩៥០-១៩៥៣ )

### ១.១. ប្រវត្តិនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល

**ក. ប្រវត្តិនយោបាយ**[67]

ព្រះរាជាដែលមានទំនាក់ទំនងជាមួយបារាំងមុនគេ គឺព្រះបាទអង្គឌួង ឆ្នាំ ១៨៥៤ ប៉ុន្តែទំនាក់ទំនងនេះត្រូវទទួលការបរាជ័យ ពីព្រោះមានការរារាំងពីសំណាក់ព្រះចៅសៀម ។ នៅដើមរជ្ជកាលព្រះបាទនរោត្តម គេឃើញមានការប៉ះបោរជាច្រើនកើតឡើង ដើម្បីប្រឆាំងជាមួយអំពើឈ្លានពាន របស់សៀម និងយួន ។ ដូច្នេះហើយដើម្បីរំដោះខ្លួនចេញពីអំណាចនៃការឈ្លានពានរបស់សៀម និងយួន ព្រះបាទនរោត្តម បានសម្រេចព្រះទ័យធ្វើទំនាក់ទំនងជាមួយបារាំង តាមរយៈសន្ធិសញ្ញាមួយនៅឆ្នាំ ១៨៦៣ ។

សន្ធិសញ្ញានេះ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថាភាគីខ្មែរ ចាញ់ប្រៀបភាគីបារាំងខ្លះៗយ៉ាងណាក៏ដោយ ក៏ភាគីខ្មែរអាចទទួលយកបានដែរ ពីព្រោះសន្ធិសញ្ញានេះមានលក្ខណៈស្រាលជាងសកម្មភាពរបស់សៀម និងយួន ហើយម្យ៉ាងទៀត បារាំងនៅមិនទាន់ដកហូតអំណាចពីព្រះរាជាខ្មែរនៅឡើយទេ ។

[67] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្រ្តាចារ្យ ពៅ សាវឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ៩៧ ។

ចំណែកស្ថាប័ននយោបាយខ្មែរ នៅក្រោមអំណាចអាណានិគមបារាំង មានការវិវត្តទាក់ទងជាមួយនឹងសន្ធិសញ្ញា និងកំណែទម្រង់មួយចំនួនដែលគេឃើញមានដូចជា ស្ថាប័នព្រះមហាក្សត្រ (ព្រះរាជា) ព្រះរាជវង្សានុវង្ស រាជរដ្ឋាភិបាល ក្រុមប្រឹក្សារាជបល្ល័ង្ក និងមន្ត្រីជាន់ខ្ពស់ ។

**ខ.រចនាសម្ព័ន្ធរដ្ឋបាល**

មានការប្រែប្រួល និងផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងផ្នែករដ្ឋបាលខ្មែរនាពេលនោះទាំងស្ថាប័នរដ្ឋបាលកណ្តាល និងរដ្ឋបាលដែនដី[68] ។

**ខ.១. រដ្ឋបាលកណ្តាល**

រាជរដ្ឋាភិបាល គឺជាស្ថាប័នដែលដឹកនាំរដ្ឋបាលកណ្តាល ។ ស្ថាប័នរដ្ឋបាលកណ្តាលខ្មែរ នៅសម័យអាណានិគមបារាំងបានកំណត់តាមរយៈកំណែទម្រង់ និងសន្ធិសញ្ញាដូចខាងក្រោមៈ

- សន្ធិសញ្ញាបារាំងខ្មែរ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៨៦៣ បានចែងថាៈ

ព្រះចៅអធិរាជបារាំង មានសិទ្ធិតែងតាំងរេស៊ីដង់បារាំងម្នាក់អមព្រះរាជាខ្មែរ ឯចំណែកព្រះរាជាខ្មែរ ក៏មានសិទ្ធិតែងតាំងមន្ត្រីខ្មែរម្នាក់អមទេសាភិបាលបារាំងប្រចាំនៅកូសាំងស៊ីនដែរ ។ ម៉្យាងទៀត រាល់ការធ្វើទំនាក់ទំនងជាមួយកុងស៊ុលខ្មែរផ្សេងៗ ត្រូវសុំការអនុញ្ញាតពីបារាំងសិន ។

- អនុសញ្ញា បារាំងខ្មែរ នៅថ្ងៃ ១៧ ខែមិថុនា ឆ្នាំ ១៩៨៤ បានចែងថាៈ

ព្រះរាជាខ្មែរ ត្រូវទទួលស្គាល់ជាមុន នូវរាល់ការកែទម្រង់ទាំងឡាយខាងរដ្ឋបាល ហិរញ្ញវត្ថុនិងខាងពាណិជ្ជកម្ម ដែលបារាំងយល់ថាគួរធ្វើនៅពេលអនាគត ។

ក្នុងការគ្រប់គ្រងក្រសួងនានា ដោយមន្ត្រីខ្មែរត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបារាំង ។ ចំណែកក្រសួងគយ ក្រសួងពន្ធដារ ក្រសួងសាធារណការ និងក្រសួងឯទៀតដែលប្រើវិស្វករ ត្រូវបានបារាំងកាន់កាប់ផ្ទាល់តែម្តង ។

ប៉ុន្តែក្រោយមកដោយមានការប៉ះបោរពីសំណាក់ព្រះរាជា មន្ត្រី អ្នកស្នេហាជាតិ និងប្រជារាស្ត្របារាំងបានយល់ព្រមប្រគល់អំណាចឲ្យមកខ្មែរវិញ ដូចជា កិច្ចការរដ្ឋខ្មែរ រាល់ការកែទម្រង់ទាំងឡាយ និងមិនឲ្យអាជ្ញាធរបារាំងជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់អាជ្ញាធរខ្មែរឡើយ ។

**ខ.២ រដ្ឋបាលដែនដី**

នៅក្នុងបញ្ញត្តិទាក់ទងនឹងរដ្ឋបាល បានចែងថា ទឹកដីខ្មែរទាំងមូលត្រូវបែងចែកជាមណ្ឌលរដ្ឋបាលធំៗប្រាំ (ហៅថាកំណាន់ខេត្ត) ស្របតាមចំនួននៃរដ្ឋមន្ត្រីទាំងប្រាំ ដែលគ្រប់គ្រងមណ្ឌលនីមួយៗ ។

---

[68] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១០៩ ។

ចំនួនខេត្ត ត្រូវបង្រួមពី ៥៧ខេត្ត មកត្រឹមតែ ៥០ខេត្តវិញ ។ ពួកមន្ត្រី ត្រូវទទួលប្រាក់បៀវត្សន៍ដែលមានកម្រិតជាក់លាក់ ហើយត្រូវហាមឃាត់ការធ្វើជំនួញ ។

ពួកឧកញ៉ាលួង ដែលមានភារៈទៅត្រួតពិនិត្យខេត្តនានា ត្រូវលុបចោលព្រោះពួកនេះបានទាញយកប្រយោជន៍ ពីព្រះរាជាផង និងប្រជារាស្ត្រផង ។ ម្យ៉ាងទៀត ប្រជារាស្ត្រ មានសិទ្ធិជ្រើសរើស មេស្រុក មេឃុំ និងជំទប់របស់ខ្លួនដោយខ្លួនឯង ។

យោងតាមអនុសញ្ញាបារាំងខ្មែរ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៨៨៤ បានចែងថា ៖

ក្នុងការគ្រប់គ្រងខេត្ត ដែលគ្រប់គ្រងដោយមន្ត្រីខ្មែរ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរបារាំង ។ ក៏ប៉ុន្តែក្រោយមកដោយការតស៊ូបះបោរ ពីសំណាក់ព្រះរាជា ពួកមន្ត្រី អ្នកស្នេហាជាតិ និងប្រជាពលរដ្ឋខ្មែរ អាជ្ញាធរបារាំងបានយល់ព្រមប្រគល់បណ្តាខេត្តនានាមកឲ្យខ្មែរវិញ លើកលែងតែខេត្ត៥ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរបារាំងដដែល គឺខេត្តកំពត កំពង់ធំ ក្រចេះ ពោធិសាត់ ។

### ១.២. ការកសាងទីក្រុង

**ក. ការកសាងផ្នែកសេដ្ឋកិច្ច**[69]

ចំពោះវិស័យនេះ រដ្ឋាភិបាលបារាំង បានបង្រៀនឲ្យខ្មែរចេះច្រើនដូចជា:

- បង្កើតពន្ធដារ
- ឲ្យចេះដាំដំណាំកៅស៊ូ
- ស្ថាបនាផ្លូវថ្នល់ខ្វាត់ខ្វែងពីតំបន់មួយ ទៅតំបន់មួយទៀត
- ផ្សារធំថ្មី កសាងឆ្នាំ ១៩៣៧
- កសាងស្ពានក្បាលថ្នល់ ១៩៣២ (រជ្ជកាលព្រះបាទស៊ីសុវត្ថិមុន្នីវង្ស)
- ធនាគារ ក៏បានមានកំណើនដែរសម្រាប់ផ្តល់ឥណទានដល់ប្រជាកសិករ ។

**ខ. ការកសាងផ្នែកសង្គមកិច្ច**

វិស័យអប់រំ:[70]

- បង្កើតសាលារៀនតាមភូមិស្រុក ។
- បឋមសិក្សាជាន់ខ្ពស់នៅតាមខេត្តដែលមានកម្មវិធីសិក្សាបែបបារាំង ។

[69] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១១៦។

[70] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១១៥ ។

- បានកសាងអនុវិទ្យាល័យនៅភ្នំពេញមួយ នៅឆ្នាំ ១៩០៤ ( ឯកសារខ្លះថា ១៩១១ ) ដែលមានឈ្មោះថា អនុវិទ្យាល័យព្រះស៊ីសុវត្ថិ រហូតដល់ ១៩៣៥ អនុវិទ្យាល័យនេះបានក្លាយជាវិទ្យាល័យព្រះស៊ី សុវត្ថិ ។

- ១៩០៧ បង្កើតគណកម្មការពីរ ដើម្បីរៀបចំតាក់តែង រាជពង្សាវតាខ្មែរ ដែលដឹកនាំដោយលោកឧកញ៉ា វាំងជួន និងលោកឧកញ៉ាវង្សាអក្ខរាជ ឧុច ។

- ១៩១៥ បង្កើតក្រុម បង្កើតវចនានុក្រមខ្មែរជាលើកដំបូង ។

- ១៩២១ កសាងសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ ។

**គ. ការកសាងផ្នែកវប្បធម៌**

សំណង់ស្ថាបត្យកម្ម: បារាំងបានជួយស្រាវជ្រាវ ផ្សព្វផ្សាយវប្បធម៌ និងអរិយធម៌ខ្មែរដែលបានបាត់បង់រាប់រយឆ្នាំមកហើយ ។ នៅឆ្នាំ ១៩១៨ បារាំងបានបង្កើតសារមន្ទីរមួយនៅទីក្រុងភ្នំពេញ ដើម្បីប្រមូលនូវស្នាដៃ ដែលជាវត្ថុបុរាណ យកមករក្សាទុកឲ្យបានគង់វង្សតទៅ ។ ចំណែកនៅឆ្នាំ ១៩៣២ បង្កើតអាជ្ញាធរជួសជុលប្រាង្គប្រាសាទនៅតំបន់អង្គរ[71] ។

នៅចន្លោះឆ្នាំ ១៩២៤ ដល់១៩៣០ មានគម្រោងពង្រីកក្រុងជាច្រើន លើកឡើងដោយនាយកដ្ឋានស្ថាបត្យកម្ម និងនគរូបនីយកម្មដែលបង្កើតឡើងដោយបារាំង ។ ក្រុងដែលមានស្រាប់ព្រមទាំងតំបន់ជនបទនៅជុំវិញ ត្រូវដាក់បញ្ចូលក្នុងផែនការរៀបចំក្រុងតែមួយ ។ ការពង្រីកក្រុងបានរៀបចំធ្វើឡើងនៅត្រើយខាងលិចទន្លេសាប ។ គេបែងចែកដីនៅឫស្សីកែវជាក្បាលតូចៗសម្រាប់រៀបចំជាតំបន់ជាយក្រុង ។ ការពង្រីកក្រុងនៅទិសខាងលិច ត្រូវបានគូសវាសឡើងតាមផែនការលើកទំនប់ជាក្រវ៉ាត់ច្រើនជាន់ រំកិលតាមខ្សែក្រវ៉ាត់ក្រៅឆ្ពោះទៅខាងលិច ។

នៅសម័យអាណានិគមបារាំង ប្លង់រាជធានីភ្នំពេញ និងប្លង់ទីក្រុងតាមខេត្តនានាមានរាងជាក្រឡាចត្រង្គ ។ គេសង្កេតឃើញមានសំណង់បុរាណត្រូវអភិរក្សមួយចំនួន ដែលនៅសេសសល់រហូតដល់សព្វថ្ងៃ និងមានតម្លៃជាប្រវត្តិសាស្ត្រចាំបាច់ត្រូវរក្សា ។ សំណង់ទាំងនោះច្រើនជាអគាររដ្ឋបាលនានា ឬជាលំនៅស្ថានរបស់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជាជនជាតិបារាំងដែលមកធ្វើការនៅក្នុងស្រុកខ្មែរ និងច្រើនមានទម្រង់ជាអគារ ឬសំណង់យកតាមលំនាំវប្បធម៌បែបអឺរ៉ុបនៅសម័យក្លាស៊ីក ដូចជានៅតាមតំបន់រដ្ឋបាលមានសាលាខេត្ត សាលាក្រុងភ្នំពេញ និងនៅរាជធានីភ្នំពេញគេសង្កេតឃើញមាននៅតាមតំបន់រដ្ឋបាល និងនៅសង្កាត់វត្តភ្នំដែលជាតំបន់លំនៅស្ថានរបស់មន្ត្រីជាន់ខ្ពស់បារាំង ។

[71] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ទំព័រ ១១៥ ។

ជាទូទៅអគារសាធារណៈថ្មីៗ ចម្លងតាមគំរូស្ថាបត្យកម្មនៅក្រុងប៉ារីសដោយតម្រូវបត់បែនតាមស្ថានភាពតំបន់ត្រូពិច ។ លើកលែងតែកន្លែងនៅក្នុងក្រុង ផ្លូវថ្នល់ស្ថាបនាតាមគំរូតែមួយ ដែលច្បាប់កំណត់ថាទទឹងត្រូវមានទំហំ ២០ម៉ែត្រ ។

លំនៅស្ថានរបស់ប្រជាជនដែលនៅសេសសល់រហូតមកដល់សព្វថ្ងៃ ច្រើនស្ថិតនៅជុំវិញទីផ្សារជាតំបន់ពាណិជ្ជកម្ម ហើយសំណង់នេះកំពុងទទួលរងនូវការបាត់បង់ជាបណ្តើរៗ បើគ្មានវិធានការទប់ស្កាត់អភិរក្សទេនោះ ។ ប្រជាជនចេះតែបន្តការកែប្រែតាមបែបសម័យថ្មី ដែលធ្វើឲ្យបាត់បង់ទម្រង់ដើមបាត់បង់តម្លៃប្រវត្តិសាស្ត្រ ព្រោះសំណង់ទាំងនេះជាអគារដែលមានអាយុចំណាស់ និងជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យឃើញពីជីវភាពរស់នៅពីអតីតកាលរបស់សង្គមកម្ពុជា ក្នុងសម័យអាណានិគមបារាំងអំឡុងឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៣ ។

ក្រៅពីនេះ គេសង្កេតឃើញមានសំណង់ស្ថាបត្យកម្ម ធ្វើអំពីឈើជាផ្ទះរោងឌឿង ស្ថិតនៅភូមិតាព្រូច គឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ខ្មែរ ។ សព្វថ្ងៃសំណង់នេះនៅគង់វង្សល្អនៅឡើយនិងបានបង្ហាញពីភាពប្រសប់ពីការងារឈើ ដែលជាផ្នែកលម្អិតនៃសំណង់ និងត្រូវបានអាជ្ញាធរមូលដ្ឋានថែរក្សាសម្រាប់ទាក់ទាញភ្ញៀវទេសចរ ព្រោះជាសំណង់ដែលមានអាយុចំណាស់ និងជាផ្ទះខ្មែរដែលត្រូវអភិរក្សនៅក្នុងខេត្តបាត់ដំបង ។ បច្ចុប្បន្នសំណង់លំនៅស្ថានជាគ្រឿងឈើរបស់ប្រជាជនខ្មែរ ដែលមានអាយុចំណាស់បែបនេះមានសេសសល់តិចតួច នៅតាមបណ្តាខេត្តនានា ដូចជាខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ដែលជាខេត្តសម្បូរណ៍ដោយផ្ទះធំៗធ្វើអំពីគ្រឿងឈើ។ ចំពោះខេត្តបន្ទាយមានជ័យក៏មានផ្ទះឈើធំៗដែរ តែក្នុងរបប ប៉ុល ពត ផ្ទះឈើដែលមានទំហំធំៗទាំងនោះ ត្រូវបានបន ប៉ុល ពត រុះរើបំផ្លាញ និងយកមកបំបែកធ្វើជាផ្ទះខ្ទមតូចៗ ។

សង្កាត់នីមួយៗ ឬតំបន់ក្នុងក្រុងដែលបង្កើតបានមកត្រឹមនេះ មិនថាជាសំណង់សាធារណៈឬឯកជនឡើយ គឺសុទ្ធតែស្ថិតនក្នុងផែនការដែលមានមក ។ ឧទាហរណ៍ នៅពេលសង្កាត់ពង្រីក បណ្តាញផ្លូវថ្នល់ដែលអមដោយប្រព័ន្ធបង្ហូរទឹក ប្រព័ន្ធផ្គត់ផ្គង់ទឹក ហើយនឹងបណ្តាញអគ្គីសនី ត្រូវបានបង្កើតឡើងក្នុងពេលព្រមគ្នា និងការស្ថាបនាផ្សារដោយមានកសាងផ្ទះល្វែងព័ទ្ធជុំវិញ ។ រុក្ខវិថីដូនពេញ និងសួនច្បារសារធារណៈ សណ្ឋាគារ ឡឺរ៉ូយ៉ាល់ ក្លឹបកីឡា និងបណ្ណាល័យជាតិ ទាំងអស់នេះសុទ្ធតែស្ថាបនាឡើងក្នុងពេលតែមួយ ដោយមានទីធ្លាមួយទុកបម្រុងសម្រាប់រៀបចំការសម្តែងសិល្បៈ និងល្បែងកំសាន្តផ្សេងៗ ។ ក្រៅពីនេះគេស្ថាបនាសារមន្ទីរជាតិ និងរៀបចំវាលព្រះមេរុឡើងវិញ ដើម្បីបង្កើតមណ្ឌលនៃរាជ្យអំណាចមួយប្រកបដោយសំណង់ជានិមិត្តរូបជាតិ ។

ហេដ្ឋារចនាសម្ព័ន្ធ: អគាររដ្ឋបាល និងកម្មសិទ្ធិឯកជនរបស់បារាំង តាំងនៅខាងត្បូងនិងខាងកើតភ្នំដូនពេញ គឺ គេរៀបចំតំបន់នេះឲ្យជៀសផុតពីទឹកជំនន់ ដោយទំនប់ការពារ និងប្រើប្រាស់ដីដែលជីកយកពីប្រឡាយបង្ហូរទឹកមកលើកទំនប់ឲ្យខ្ពស់ ។ ផ្លូវ និងថ្នល់តូចៗដែលមានមកពីដើមក្លាយមកជាវិថីថ្មីៗរបស់រាជធានី ។ ព្រែកមួយត្រូវបានជីកព័ទ្ធជុំវិញក្រុង កំណត់ព្រំប្រទល់នៃការពង្រីករាជធានីភាគខាងជើង ។ មើលទៅទំនងជាព្រែកព័ទ្ធក្រុងនេះ ដែលលើកឡើងដើម្បីកម្រិតព្រំប្រទល់ខាងលិចនៃរាជធានីជីកទៅតាមល្បាក់ធម្មជាតិ ឬជីកពីលើសំណង់គូទឹកព័ទ្ធជុំវិញក្រុងចាស់ ។ ដូចគ្នានេះដែរ មហាវិថីដែលជាប់នឹងជាយក្រុង(មហាវិថីមុន្នីវង្សសព្វថ្ងៃ)លើកជាថ្នល់ឡើងលើទំនប់ដែលមានមកហើយ ដែលប្រហែលជាសំណង់នៃកំពែងព័ទ្ធក្រុង ស្ថាបនាឡើងនៅជំនាន់ព្រះបាទពញាយ៉ាត ។ នៅខាងត្បូងទំនប់មួយពេលនោះហៅថា កំពែងយួន ក្លាយជាព្រំប្រទល់នៃរាជធានី (សព្វថ្ងៃជាមហាវិថីព្រះសីហនុ) ។

ចាប់ពីឆ្នាំ ១៨៩០មក ផែនការពាក់ព័ន្ធគ្នាជាច្រើន និងផែនការថែទាំរាជធានី ចាប់ដំណើរការដោយមានកម្មវិធីរៀបចំប្រព័ន្ធបង្ហូរទឹក រួមជាមួយនឹងការផ្តួចផ្តើមកែលម្អសម្រស់រាជធានី ។

## ២.សម័យសង្គមរាស្ត្រនិយម(១៩៥៣-១៩៧០)

### ២.១. ប្រវត្តិនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល

#### ក. ប្រវត្តិនយោបាយ[72]

កាលណាគេនិយាយអំពីសង្គមរាស្ត្រនិយម គេតែងនឹកឃើញដល់ស្ថាបនិកម្នាក់ដែលពុំអាចបំភ្លេចបាន នោះគឺ ព្រះបាទនរោត្តមសីហនុវរ្ម័ន ។ ទ្រង់ជាព្រះមហាក្សត្រ មានសិទ្ធិដាច់ខាតលើការសម្រេចចិត្តផ្សេងៗ ហើយព្រះអង្គក៏ជាព្រះមហាក្សត្រ ដែលយករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងយកច្បាប់ជាធំក្នុងការគ្រប់គ្រងប្រទេសជាតិ ។

នៅឆ្នាំ ១៩៤៩ ទ្រង់បានទាមទារឲ្យបារាំងលុបចោលសន្ធិសញ្ញាអាណាព្យាបាល លើប្រទេសកម្ពុជាដែលបានចុះហត្ថលេខា នាឆ្នាំ ១៨៦៣ និងឆ្នាំ ១៨៨៤ ហើយព្រះអង្គបានឡាយព្រះហត្ថលេខាលើសន្ធិសញ្ញាឯករាជ្យដែលប្រទេសបារាំង យល់ព្រមទទួលស្គាល់តាមផ្លូវច្បាប់នូវឯករាជ្យរបស់ប្រទេសកម្ពុជា និងការលុបចោលសន្ធិសញ្ញាអាណាព្យាបាលលើប្រទេសកម្ពុជាជាផ្លូវការ ។ ពីឆ្នាំ ១៩៥២ ដល់ឆ្នាំ១៩៥៣ ព្រះបាទនរោត្តមសីហនុ បានយាងបំពេញព្រះបូជនីយកិច្ចទាមទារកេតនភណ្ឌឯករាជ្យមួយរយភាគរយជូនមាតុភូមិ ហើយនៅថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ ព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យ

[72] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ញ៉ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១១៧ ។

ទាំងស្រុងពីសាធារណរដ្ឋបារាំង ។ ក្រោយទទួលបានឯករាជ្យភាព និងអធិបតេយ្យពេញបរិបូរណ៍នៃព្រះរាជាណាចក្រកម្ពុជាឡើងវិញមានការផ្លាស់ប្តូរដ៏សំខាន់នូវនយោបាយផ្ទៃក្នុងប្រទេសគឺការបង្រួបបង្រួម ។

ចំពោះស្ថាប័ននយោបាយវិញ នៅសម័យនោះមានការបែងចែកអំណាចដាច់ដោយឡែកពីគ្នា ប៉ុន្តែ តាមស្ថានភាពជាក់ស្តែង នៃសង្គម-សេដ្ឋកិច្ច និងនយោបាយក្នុងប្រទេស ពុំអនុញ្ញាតឲ្យមានការបែងចែកអំណាចដាច់ដោយឡែកនោះទេ ។ ព្រះមហាក្សត្រ រដ្ឋសភា ជាពិសេសរាជរដ្ឋាភិបាល មានការផ្លាស់ប្តូរជារឿយៗ ។

**ខ.រចនាសម្ព័ន្ធរដ្ឋបាល**

នៅសម័យនោះការបែងចែក និងការគ្រប់គ្រងរដ្ឋ ត្រូវបែងចែកដូចខាងក្រោម[73]៖

**ខ.១. ការបែងចែកដែនដី**

ព្រះរាជាណាចក្រកម្ពុជា ទាំងមូលត្រូវបែងចែកជា:

- ភូមិភាគ មានចំនួន ៨ភូមិភាគ ។
- ភូមិភាគនីមួយៗ មានខេត្តមួយ ឬច្រើន អាស្រ័យតាមស្ថានភាពជាក់ស្តែង ។
- ខេត្ត ត្រូវបែងចែកជា ស្រុក ។
- ស្រុក ត្រូវបែងចែកជា ឃុំ ។

**ខ.២. ការគ្រប់គ្រងដែនដី**

នៅប្រទេសកម្ពុជាសម័យនោះ យើងយកគំរូ ចាត់តាំងដែនដី តាមប្រទេសបារាំង គឺវិ មជ្ឈការនៅថ្នាក់ខេត្ត និងឃុំ និងវិសហមជ្ឈការពីថ្នាក់កណ្តាលទៅថ្នាក់តំបន់ ។

ចំពោះរាជធានី គឺក្រុងភ្នំពេញជារាជធានីនៃព្រះរាជណាចក្រកម្ពុជា ដែលត្រូវគ្រប់គ្រងដោយប្រតិភូក្រុង ត្រូវបែងចែកជា ៧សង្កាត់ ដែលគ្រប់គ្រងដោយប្រធានសង្កាត់ ឬចៅសង្កាត់ម្នាក់ តែងតាំងដោយប្រកាសរបស់ប្រតិភូក្រុងភ្នំពេញ ។

ចំពោះខេត្ត បង្កើតជាសមូហភាពដែនដីដែលគ្រប់គ្រងដោយទេសាភិបាលខេត្ត ឬចៅហ្វាយខេត្ត និងមានប្រឈួយខេត្តជាជំនួយការ ហើយត្រូវចែកជាស្រុក ដែលគ្រប់គ្រងដោយប្រធានស្រុក ឬចៅហ្វាយស្រុក និងបាលាត់ស្រុកជាជំនួយការ ។ ចំណែកឯឃុំ មានលក្ខណៈជានីតិបុគ្គល ក្នុងន័យនេះ ឃុំមានកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ឃុំទាំងអស់ និងស្វ័យភាពសម្រេចក្នុងដែនដីរបស់ខ្លួនតាមអំណាចច្បាប់ជា

[73] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១៣៦ ។

ធរមាន ។ ចំណែកឯការគ្រប់គ្រងឃុំវិញ គឺបានរៀបចំអង្គការសមូហភាពមួយសម្រាប់សម្រេចកិច្ចការនានាក្នុងដែនដីឃុំ ដែលគេហៅថា ក្រុមប្រឹក្សាឃុំ ។

### ២.២. ការកសាងទីក្រុង

#### ក.ការកសាងផ្នែកសេដ្ឋកិច្ច[74]

#### ក.១ វិស័យកសិកម្ម

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ លើគោលការណ៍នយោបាយពង្រីកដីស្រែថ្មីការជ្រើសរើសពូជស្រូវការប្រើ ជីធម្មជាតិគួបផ្សំជីគីមីនិង ការធ្វើនយោបាយទឹក ។ ផលស្រូវនៅឆ្នាំ១៩៥៥ទទួលបាន ១ ៥៨៥ ០០០ តោន ហើយចំនួននេះកើនដល់ ៣ ២៥០ ០០០ តោនក្នុងឆ្នាំ ១៩៦៨ ។ ផលកៅស៊ូនៅឆ្នាំ ១៩៥៥ទទួលបាន ២៥ ០០០ តោនហើយចំនួននេះកើនដល់ ៥១ ០០០ តោនក្នុងឆ្នាំ១៩៦៨ ។ ផលកប្បាសនៅឆ្នាំ១៩៦៤ ទទួលបាន ៥ ០០០ តោននៅក្នុងចំនួននេះ ២០០០ តោនសម្រាប់រោចក្រវាយនភ័ណ្ឌក្នុងប្រទេស និង ៣ ០០០ តោនសម្រាប់នាំចេញ។ ផលចិញ្ចឹមសត្វ សត្វស្លាបនៅឆ្នាំ ១៩៥៧ ទទួលបាន ៣ ៧៣០ ០០០ ក្បាលហើយចំនួននេះកើនដល់ ៤ ១៩០ ០០០ក្បាលនៅឆ្នាំ ១៩៦៥ ។ សត្វគោនៅឆ្នាំ ១៩៥៥ ទទួលបាន ៣០០ ០០០ ក្បាលហើយចំនួននេះកើនដល់ ៦២០ ០០០ ក្បាលនៅឆ្នាំ១៩៦៥។ ជ្រូកនៅឆ្នាំ ១៩៥៥ ទទួលបាន ៣៩០ ០០០ ក្បាល កើនឡើងដល់ ៩៨០ ០០០ក្បាល នៅឆ្នាំ១៩៦៥ ។

ដើម្បីរក្សាកម្លាំងអូសទាញឲ្យបានល្អ រាជរដ្ឋាភិបាលចាត់ក្រុមបសុពេទ្យ ឲ្យចាក់ថ្នាំបង្ការរោគរាតត្បាតដល់ សត្វពាហនៈគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។ ព្រៃឈើជាធនធានធម្មជាតិ មានសារៈសំខាន់ ដែលបំរើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។ ដោយមានការព្រួយបារម្ភពីភាពរាំងស្ងួត ទើបរាជរដ្ឋាភិបាលបង្កើតឲ្យមានរុក្ខទិវានៅគ្រប់ខេត្ត ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា ។ រីឯវិស័យនេសាទមានការរីកចំរើនជាលំដាប់អាចធានាលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងបាននាំចេញទៅក្រៅប្រទេសទៀតផង ។

#### ក.២ វិស័យគមនាគមន៍

សម្តេចនរោត្តម សីហនុ ទ្រង់ដឹងនាំប្រជាពលរដ្ឋដោយផ្ទាល់ឲ្យធ្វើការហត្ថកម្មរួមទាំងការកសាងផ្លូវថ្នល់ ផ្លូវរថភ្លើង ។ នៅឆ្នាំ១៩៥៤ មានការពង្រីកកំពង់ផែភ្នំពេញ នឹងការកសាងកំពង់ផែ សមុទ្រនៅក្រុងព្រះសីហនុ ដើម្បីធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ហើយកំពង់ផែនេះបានត្រូវពង្រីកថែមទៀតនៅឆ្នាំ ១៩៦៤ ។ នៅឆ្នាំ១៩៥៦ មានការកសាងផ្លូវជាតិលេខ ៤ ដែលតភ្ជាប់ពីទីក្រុងភ្នំពេញទៅក្រុងព្រះសីហនុ

[74] សៀវភៅសិក្សាសង្គមថ្នាក់ទី១២ បោះពុម្ពផ្សាយ ឆ្នាំ២០០៣ ទំព័រ ២១១។

ប្រវែង ២២៦ គ.ម ហើយអាកាសយានដ្ឋានពោធិចិនតុង បានពង្រីកឲ្យក្លាយទៅជាអាកាសយានដ្ឋានខ្នាតអន្តរជាតិ ដែលមានផ្លូវប្រវែង ២៨០០ ម៉ែតនិងទីលានសំរាប់យន្តហោះចុះចតទំហំ ១២០ម x ១១០ម ។ អាកាសយានដ្ឋាននេះបានបើកឲ្យប្រើប្រាស់នៅឆ្នាំ ១៩៥៨ ។ នៅឆ្នាំ១៩៥៩ មានការកសាងអាកាសយានដ្ឋានខ្នាតអន្តរជាតិមួយទៀតសម្រាប់ពង្រីកវិស័យទេសចរណ៍ នៅខេត្តសៀមរាប។ នៅឆ្នាំ ១៩៦០ មានការស្ថាបនាផ្លូវរថភ្លើងមួយខ្សែភ្ជាប់ពីទីក្រុងភ្នំពេញ ទៅក្រុងព្រះសីហនុប្រវែង ២៧០គ.ម ហើយនៅឆ្នាំនោះដែរក៏មានការកសាងស្ពានដ៏ទំនើបមួយ កាត់ដងទន្លេសាប គឺស្ពានជ្រោយចង្វា ។ នៅឆ្នាំ ១៩៦០ ព្រះរាជាណាចក្រកម្ពុជា បានពង្រីកទំនាក់ទំនងជាអន្តរជាតិដោយភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូក្យូ សង់ប្រង់ស៊ីស្កូ អូសាកា ។

### ក.៣ ផ្នែកពាណិជ្ជកម្ម និង ឧស្សាហកម្ម

នៅឆ្នាំ ១៩៥៥ ក្រៅពីក្រុងពាណិជ្ជកម្មធំៗរបស់បារាំង គេសង្កេតឃើញមានសាខានៃក្រុមហ៊ុនពាណិជ្ជកម្ម និងក្រុងហ៊ុនធានារ៉ាប់រងអាមេរិចផងដែរ ដែលបានដំនើរការនៅទីក្រុងភ្នំពេញ ក្នុងនោះមានក្រុងហ៊ុនអាមេរិច អាំងទែណាស្យូណាល់ និងញូហែមព្យូរ ឈ្មោះ អេសូ និងកាល់តិចដែលទទួលបានសិទ្ធិនាំចូលប្រេងឥន្ធន ៣៥% ក្នុងនោះក៏មានក្រុមហ៊ុនជាគូប្រជែង គឺក្រុមហ៊ុនប្រេងកាតអង់គ្លេស ហូឡង់ឈ្មោះសែលដែលទទួលបន្ទុកក្នុងការនាំចូលប្រេង ៦០%ដែរ ។ បន្ទាប់ពីការកកើតក្រុមហ៊ុពាណិជ្ជកម្មអង់គ្លេស ក៏មានការកកើតក្រុមហ៊ុនពាណិជ្ជកម្មជប៉ុនដែលធ្វើការនាំចូលគ្រឿងតំបាញ ។ សកម្មភាពរបស់ក្រុមហ៊ុនអង់គ្លេស និងជប៉ុន បានរីកសាយទៅលើបំរើបំរាល់ឥណទាន សំរាប់ពាណិជ្ជកម្មដោយមានការបង្កើតធនាគារអង់គ្លេសពីរគឺ ធនាគារឆាទែរិចបង់ ហុងកុងសាងហៃបង់ និងធនាគារជប៉ុនមួយឈ្មោះបង់អូហ្វតូក្យូ ។ ការនាំចូលទុនឯកជនរបស់សហរដ្ឋអាមេរិច អង់គ្លេស និងជប៉ុនមកក្នុងវិស័យឧស្សាហកម្មកម្ពុជា មានតិចតួចស្តួចស្តើងបំផុតរហូតដល់ឆ្នាំ ១៩៦៤ ។ ចាប់ពីឆ្នាំ១៩៥៦ រង្វង់នៃបំរើបំរាស់ឥណទានខាងពាណិជ្ជកម្មក្រៅប្រទេស នៅព្រះរាជាណាចក្រកម្ពុជាបានទៅជាមូលដ្ឋាន នៃការប្រកួតប្រជែងរវាងមូលធនបារាំង និងមូលធនអាមេរិច អង់គ្លេស និងជប៉ុន ។ ប្រាក់រៀល ជារូបិយប័ណ្ណក្នុងស្រុក និងប្រើប្រាស់តាមរយៈមូលនិធិការប្តូរប្រាក់ ដែលយកប្រាក់រៀលទៅធ្វើការចំណាច នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ តាមស្ថិតិឆ្នាំ ១៩៦២ មូលធនបារាំងបានកាន់កាប់សកម្មភាពផ្នែកពាណិជ្ជកម្ម ១/៣ នៃក្រុមហ៊ុនទាំងនោះមានក្រុមហ៊ុនពាណិជ្ជ (ឌុយម៉ារ៉េស )(ដឺនីសប្រែន ) និង( ឡាអារវ៉េស) បានប្រើប្រាស់មូលធននេះក្នុងការនាំចេញ កៅស៊ូ អង្ករ ម្រេច និងអីវ៉ាន់ ដទៃទៀតមួយចំនួនធំ ។ នៅខែវិច្ឆិកា ឆ្នាំ ១៩៦៣ រាជរដ្ឋាភិបាលបានសំរេចសេចក្តី និងអនុវត្តការប្រែប្រព័ន្ធធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដោយហាមឃាត់

សកម្មភាពក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេស និងធនាគារឯកជនខាង ពាណិជ្ជកម្មនៅក្នុងស្រុក ។ ក្រុមហ៊ុនពាណិជ្ជកម្មទើបបង្កើតថ្មីមានឈ្មោះថា(ក្រុមហ៊ុនអាហារ័ណនីហារ័ណជាតិ ឬហៅកាត់ថា(សូណិចស៊ីម) ។ ក្រុមហ៊ុននេះមានមូលនិធិ ២៤០លានរៀលដែលក្នុងនោះមូលនិធិ ៦០%ជាដើមទុនរបស់រដ្ឋ និង៤០% ជាដើមទុនរបស់ពាណិជ្ជករកម្ពុជា ហើយចំពោះការផ្ដល់ឥណទាន ដែលបានបំពេញដោយធនាគារនានានៃបរទេសនោះត្រូវបានផ្ដល់ដល់ធនាគារពាណិជ្ជកម្មរដ្ឋ ឈ្មោះ ឥណទានជាតិ ។ ការបង្កើតក្រុមហ៊ុនសូណិចសុិម និងធនាគារឥណទានជាតិពុំបង្កឧបសគ្គដល់បំរើបំរាស់មូលធនអន្តរជាតិ នៅក្នុងរង្វង់នៃកិច្ចការពាណិជ្ជកម្មឡើយ ។ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យក្រុមហ៊ុនបរទេសខ្លះនៅបន្តសកម្មភាពរបស់ខ្លួន ដូចជា ក្រុមហ៊ុនធំជាងគេក្នុងការនាំប្រេងកាតចូលរបស់អង់គ្លេស និងហូឡង់ឈ្មោះ (សែល) និងក្រុមហ៊ុនអាមេរិច ឈ្មោះ អេសូ និង កាល់តិច ជាដើម ។ នៅឆ្នាំ១៩៦៤ រាជរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ និងឯកជនពីរ គឺក្រុមហ៊ុនខ្មែរ ឬហៅកាត់ថាសូរ៉ាប៉ា និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល ឬហៅកាត់ថា ណាព្រីម ។ មុខងារនៃក្រុមហ៊ុនទាំងពីរ គឺការជួយឧបត្ថម្ភដល់ក្រុមហ៊ុនសូណិចស៊ីម ក្នុងការរៀបចំទំនិញសំរាប់ការនាំចេញផ្ទាល់ ពីសំណាក់អ្នកបង្កបង្កើតផល ព្រមទាំងជួយធ្វើការចែករំលែកទំនិញនាំចូលតាមរយៈសហករណ៍ពាណិជ្ជកម្ម និងអង្គការរដ្ឋនានា ។ ក្រុមហ៊ុនរដ្ឋ និងឯកជននៃប្រទេសកម្ពុជា បានដំនើរការហូតមកដល់ប្រទេសជាតិ ផ្ទុះសង្គ្រាមស៊ីវិលឡើង ។រាជរដ្ឋាភិបាល បានជំរុញការសាងសង់រោងចក្រមួយចំនួន ដូចជារោងចក្រវាយនភ័ណ្ឌនៅកំពង់ចាម រោងចក្រក្ដារបន្ទះនៅដីឥដ្ឋ និងរោងក្រកែវចំការដូងក្នុងខេត្តកណ្ដាល រោងចក្រក្រដាស់នៅ ឆ្លូងក្នុងខេត្តក្រចេះ រោងចក្រស៊ីម៉ង់ចក្រីទីងក្នុងខេត្តកំពត រោងចក្រតំលើងត្រាក់ទ័រ រោងចក្រចំរាញ់ប្រេងកាត និង រោងចក្រស្រាបៀរនៅក្រុងព្រះសីហានុ ។ ទន្ទឹមនឹងការកសាងរោចក្រ រាជរដ្ឋាភិបាលបានកសាងទំនប់វារីអគ្គីសនីនៅស្ទឹងច្រាលគិរីរម្យ និងនៅព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ ។

**ខ.វិស័យវប្បធម៌**[75]

ដើម្បីពង្រីកវិស័យវប្បធម៌ រាជរដ្ឋាភិបាលបានកសាងអគារសិក្សា និងបណ្ដុះបណ្ដាលបុគ្គលិកសិក្សាសម្រាប់គ្រប់ភូមិសិក្សាឲ្យមានសន្ទុះខ្លាំងក្លាឡើង ។

នៅឆ្នាំ ១៩៥៣ ភ្នំពេញក្លាយទៅជារាជធានី នៃកម្ពុជាឯករាជ្យ ។ ក្រោមព្រះរាជកិច្ចដឹកនាំនៃសម្ដេច សីហានុ ព្រះប្រមុខរដ្ឋ ការងារសាធារណៈធំៗ ត្រូវចាប់ធ្វើក្នុងរាជធានី និងនៅទូទាំងព្រះរាជាណាចក្រ ។ ពេលនោះ មានតម្រូវការឲ្យកសាងអគារជាច្រើន ដើម្បីស្ថាប័នជាតិថ្មីៗ ដែលបង្កើតឡើងជាកត្តា

[75] សៀវភៅសិក្សាសង្គមថ្នាក់ទី១២ បោះពុម្ពផ្សាយ ឆ្នាំ២០០៣ ទំព័រ ២១៥ ។

ជំរុញឲ្យមានការបង្កើតថ្មីច្រើន ក្នុងវិស័យស្ថាបត្យកម្ម ។ ការបង្កើតថ្មីនោះ តែងសង្កត់ធ្ងន់លើអត្តសញ្ញាណជាតិថ្មីមួយ ដែលចូលប្រឡូក លើឆាកអន្តរជាតិ ។ អគារសាធារណៈ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធទាំងពួងក៏ផុសចេញពាសពេញ ជាការទាក់ទាញប្រជាជនពីជនបទ មករស់នៅទីនេះ ហើយក្នុងរយៈពេលមិនបាន ១៥ឆ្នាំផង ផ្ទៃដីភ្នំពេញរីកឡើងមួយជាពីរ ។

វាក្យស័ព្ទដែលអ្នករៀបចំទីក្រុង និងស្ថាបត្យករស្រុះស្រួលគ្នាយកមកប្រើ សម្រាប់អគារថ្មីនោះ សុទ្ធសឹងឆ្លុះបញ្ចាំង ពីរចនាបទខ្មែរសម័យថ្មីសម័យឯករាជ្យ ។ រចនាបទនេះ ជាលក្ខណៈនៃអគាររដ្ឋសំខាន់ៗ ដូចជាសាកលវិទ្យាល័យនានា ក្រសួងផ្សេងៗ ពហុកីឡាដ្ឋានជាតិជាដើម ។ ផ្ទៃដីដ៏ធំនៃរាជធានី ត្រូវបានរៀបចំឲ្យទៅជាសួនឧទ្យាន ដែលព័ទ្ធទៅដោយអាងទឹក ។ អ្វីដែលមានប្រសិទ្ធភាពទប់ទល់ពន្លឺ និងកំដៅថ្ងៃខ្លាំង ដោយប្រើពិដានបេតុង ។ ដងផ្លូវធំៗនៃរាជធានី ក្រោយបានឯករាជ្យនេះបង្ហាញពីភាពពិសេស ដែលពោរពេញទៅដោយសួនច្បារ ។

ពហុកីឡាដ្ឋានជាតិស្ថាបនាឡើងក្រោយពីភ្នំពេញ បានទទួលនាទីរៀបចំការប្រកួតកីឡាលើកទី៣ នៅអាស៊ីអាគ្នេយ៍ នៅឆ្នាំ១៩៦៥ ។ ពហុកីឡាដ្ឋាននេះ ស្ថាបនាឡើងនៅលើវាលវង់ចាស់មួយ ។ ទ្រង់ទ្រាយនៃពហុកីឡាដ្ឋាន យកតាមលំនាំប្រាសាទអង្គរវត្ត ។ ក្នុងបរិវេណនោះ មានលានកីឡាមួយដែលព័ទ្ធដោយជម្រាលច្រាំងរួមនឹងវេទិកាមួយដែលភ្ជាប់ទៅនឹងរោងលេងកីឡា (រោងកីឡានៅខាងក្នុង) ។ អាងហែលទឹក និងវាលលេងកីឡាផ្សេងៗគ្រប់មុខ រៀបចំដោយមានឧទ្យានមួយព័ទ្ធជុំវិញ ។ អាងទឹកជាជួរៗ ស្ថាបនាឡើង ប្រៀបប្រដូចនឹងគូរទឹកព័ទ្ធជុំវិញប្រាសាទបុរាណ ហើយប្រើប្រាស់ជាប្រព័ន្ធបង្ហូរទឹកចេញ ។ ឧទាហរណ៍មួយទៀតនៃរចនាបទសម័យក្រោយឯករាជ្យនោះ គឺសំណង់ ប៊ុលឌិញ កសាងនៅត្រើយខាងលិចនៃទន្លេបាសាក់ ដែលជាដំបូងស្ថាបនាឡើងសម្រាប់ឲ្យកីឡាករចូលរួមលេងល្បែងអាស៊ីអាគ្នេយ៍ លើកទី៣ទាំងអស់ស្នាក់អាស្រ័យ ។ អគារផ្ទះល្វែងនេះ ជាការសាកល្បងមុនដំបូងក្នុងការបង្កើតប្រភេទផ្ទះថ្មី នៅក្នុងក្រុងសម្រាប់ខ្មែរដែលមានល្វែងនៅត្រួតលើគ្នា ដែលរៀបឡើងជាពីជួរស្របគ្នាព័ទ្ធជុំវិញដោយសួនច្បារ ។ ផ្ទះនីមួយៗមានកន្លែងបើកទូលាយ ហើយផ្ទះបាយនៅក្រៅដាច់ពីបន្ទប់រស់នៅ ដែលរៀបចំឡើងតាមលំនាំផ្ទះខ្មែរ ដោយគិតគូរអំពីទិសខ្យល់បក់នៅតំបន់នោះហើយនឹងកន្លែងខ្យល់ចេញចូល ។ មហោស្រពព្រះបាទសុរាម្រឹត ដែលស្ថាបនាឡើងពីមុខអគារប៊ុលឌិញ ក៏បានបង្ហាញពីស្ថាបត្យកម្មខ្មែរដែរ ដោយយកលំនាំតាមជ្រោយចង្វារដែលលយនៅទីប្រសព្វមុខទន្លេ ។ កន្លែងទទួលភ្ញៀវនៃរោងមហោស្រពមានរាងត្រីកោណដែលមានរៀបចំលំអដោយប្រើពន្លឺនិងទឹកនៅជុំវិញជណ្តើរច្រើនជាន់ ។

ព្រមជាមួយគ្នានោះ ក៏មានវិធានការជាប់ជានិច្ច ក្នុងការថែរក្សាការពារសម្បត្តិវប្បធម៌បេតិកភណ្ឌជាតិ ក្នុងការជំរុញផ្នែកសិល្បៈជាតិឲ្យបានរុងរឿង ដោយបង្កើតឲ្យមានសាលាវិចិត្រសិល្បៈ និងរោមហោស្រព ។ ចាប់ពីឆ្នាំ ១៩៦១ មករាជរដ្ឋាភិបាលបានលើកស្ទួយវិស័យកីឡា ដោយរៀបចំមានស្នងការដ្ឋានកីឡាមួយ ស្ថិតនៅក្រោមឪវាទទីស្តីការរដ្ឋមន្ត្រីក្រសួងការពារជាតិ ។ ដើម្បីផ្សព្វផ្សាយ និងពង្រីកវិស័យនេះ រាជរដ្ឋាភិបាលបានអញ្ជើញគ្រូបង្ហាត់កីឡាអន្តរជាតិមកពីឆេកូស្លូវាគី សម្រាប់កីឡាបាល់ទាត់ មកពីសាធារណៈរដ្ឋប្រជាមានិតចិន សម្រាប់កីឡាបាលបោះមកពីសហរដ្ឋអាមេរិចសំរាប់អត្តពលកម្ម និងមកពីអូស្ត្រាលីសម្រាប់កីឡាវាយសី ។ ព្រមជាមួយគ្នានោះនាយកដ្ឋានកីឡាបានបង្កើតកីឡាគ្រប់ប្រភេទនៅតាមក្រសួងមន្ទីរ សាលារៀន សហគ្រាសរដ្ឋ និងឯកជន ។ នៅតាមទីរួមខេត្ត និងទីរួមស្រុក ក៏មានការបង្កើតទីលានកីឡាផ្សេងៗយ៉ាងសកម្មដែរ ។ ដូចនេះនៅសម័យសង្គមរាស្ត្រនិយម វិស័យកីឡាមានការលូតលាស់យ៉ាងខ្លាំង រហូតដល់មានលទ្ធភាពចូលរួមប្រកួតជាអន្តរជាតិ ជាពិសេសសមិទ្ធផលដ៏សំខាន់ក្នុងវិស័យនេះ គឺការស្ថាបនា ពហុកីឡាដ្ឋានជាតិ ដែលអាចទទួលទស្សនិកជនបានចំនួន ៥០ ០០០នាក់ ។ ព្រះរាជាណាចក្រកម្ពុជា ចាត់ទុកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។ សម្តេចនរោត្តសីហនុ ទ្រង់បានជួយឧបត្ថម្ភយ៉ាងពេញទំហឹង ព្រមទាំងបានខិតខំផ្សព្វផ្សាយលទ្ធិពុទ្ធិរហូតដល់ពុទ្ធិកមហាវិទ្យាល័យ ។

ទស្សវត្ស ១៩៥០ និង១៩៦០ មិនត្រឹមតែជាសម័យបើកទ្វារទៅរកស្ថាបត្យកម្មថ្មី ហើយនឹងស្ថាបនាសំណង់ផ្សេងៗនៅកម្ពុជាតែប៉ុណ្ណោះទេ រយៈពេលពីរទសវត្សនេះ ក៏ជាសម័យបង្កើតហេដ្ឋារចនាសម្ព័ន្ធធំៗ ព្រមទាំងគម្រោងទូទៅនៃការរៀបចំលំអរក្រុង ស្របទៅតាមការផ្លាស់ប្តូរយ៉ាងខ្លាំង នៃក្រុងដែលមានមកផងដែរ ។ ការពង្រីកផ្ទៃដីក្រុងឲ្យកាន់តែធំទៅៗ ក៏កើតឡើងក្នុងរយៈពេលនេះដែរ ។ ចន្លោះទសវត្សឆ្នាំទី ៥០ និងឆ្នាំ៦០ ទីក្រុងភ្នំពេញបានក្លាយជារាជធានី និងជាទីក្រុងតូចមួយ ប្រកបដោយសោភ័ណភាពល្អជាទីក្រុងដែលមានការកោតសរសើរពីបណ្តាប្រទេសជិតខាងក្នុងតំបន់ ។ នៅភាគខាងត្បូងទីក្រុង មានការសាងសង់ជារោងចក្រ និងសិប្បកម្មនានា ដែលធ្វើឲ្យតំបន់នោះក្លាយជាសង្កាត់ឧស្សាហកម្មរបស់ក្រុងតែជាតំបន់ឧស្សាហកម្មធុនស្រាល និងសិប្បកម្ម ។

នៅឆ្នាំ ១៩៦០ គម្រោងបង្កើត ភ្នំពេញថ្មី ត្រូវបានគិតគូរឡើង ។ នេះជាផែនការពង្រីកក្រុងដែលមានស្រាប់នៅខាងពាយ័ព្យ ទៅតាមគោលការណ៍នៃ Atherns Charter ដោយរៀបចំឲ្យចរាចរណ៍យានយន្ត និងផ្លូវថ្មើរជើងដាច់ពីគ្នា តែដែលភ្ជាប់តំបន់ផ្សេងៗគ្នា ដែលមានមុខងារច្បាស់លាស់ ( លំនៅស្ថាន ពាណិជ្ជកម្ម ឧស្សាហកម្ម មណ្ឌលក្រុង) ។ ទោះបីជាយ៉ាងណា ក៏អត្រាកំណើនប្រជាជន នៅពេលនោះ

មិនទាន់តម្រូវឲ្យមានផែនការដ៏ធំយ៉ាងនេះទេ ហើយថវិកាក៏មានមិនគ្រប់គ្រាន់សម្រាប់សម្រេចគម្រោងនេះដែរ ។ ដើម្បីជំនួសការអភិវឌ្ឍក្រុង ក្នុងកម្មវិធីមួយដ៏ធំធេងនោះ គេលើកទឹកចិត្តឲ្យធ្វើការចំណាយជាទ្រង់ទ្រាយតូចជាងវិញ ដោយអនុវត្តផែនការ ភ្នំពេញថ្មី ដែលក្នុងនោះមានគម្រោងតូចៗធម្មតា ។ គឺក្នុងគោលការណ៍នេះហើយ ដែលតំបន់ទួលគោករៀបចំកើតជាសួនច្បារ លេចរាងសាយចេញក្រៅជុំវិញបង្គោលស្ថានីយ៍ទូរគមនាគមន៍ថ្មី ដែលស្ថាបនានៅជ្រុងពាយ័ព្យនៃក្រុង ហើយដែលចប់ស្រេចបាច់នៅ ឆ្នាំ ១៩៦២-១៩៦៣ ។

ព្រមជាមួយគ្នានោះ មណ្ឌលនៃរាជធានីក៏ត្រូវបានរៀបចំស្ថាបនា និងកែលំអរឲ្យកាន់តែប្រសើរឡើងដែរ។ នៅខាងត្បូងព្រះបរមរាជវាំង ត្រពាំងមួយដែលស្ថិតនៅពីមុខវត្តបទុមវតីក្លាយទៅជាសួនច្បារសាធារណៈយ៉ាងធំ ។ ព្រែកជីកដែលរត់ពីលិចទៅកើត ជាប់ខាងត្បូងសួនច្បារនេះ កើតជាវិថីភ្លោះមួយដែលមានសួនច្បារនៅពាក់កណ្តាល ហើយនិងមានអាងបាញ់ទឹកជាច្រើននៅលើឧទ្យាននោះ ។ វិមានឯករាជ្យស្ថិតនៅចំកណ្តាលឧទ្យានថ្មីនេះ ។ ទ្រង់ទ្រាយនៃវិមាននេះ ស្រង់ពីរចនាបទអង្គរ ដែលសាងឡើងបញ្ចូលទៅក្នុងទស្សនៈ Le Corbusier ក្នុងការកំណត់ខ្នាតសំណង់ផ្សេងៗដែលនៅក្នុងលំហាជាមួយគ្នា ។

ជាមួយពេលនឹងសម្ពោធប្រើប្រាស់វាលយន្តហោះអន្តរជាតិពោធិចិនតុង នាឆ្នាំ ១៩៥៩ ផ្លូវដែលភ្ជាប់ពីវាលយន្តហោះមកក្រុង ត្រូវពង្រីកឲ្យទៅជារុក្ខវិថីធំមួយ ដោយមានសួនច្បារមួយខ្សែវែង ចែកផ្លូវឲ្យដាច់ពីគ្នា ។ រុក្ខវិថីនេះរត់មកជាប់នឹងរបងខាងត្បូងនៃសាកលវិទ្យាល័យ ថ្មីមួយ និងវិទ្យាស្ថានបច្ចេកទេស ហើយរត់ទៅខាងជើងអគារក្រសួងថ្មី និងទីស្តីការគណៈរដ្ឋ មន្ត្រី ។ មិនយូរប៉ុន្មាន រុក្ខវិថីនេះក៏ក្លាយទៅជាសសរទ្រូងសំខាន់មួយ ដែលនាំទេសចរណ៍ចូលមករាជធានីនៃព្រះរាជាណាចក្រកម្ពុជា ដែលទើបតែបានឯករាជ្យថ្មីៗ ។ ដូចគ្នានេះដែរ នៅក្បែរពហុកីឡាដ្ឋាន សង្កាត់មួយដែលមានអគារវប្បធម៌ និងពាណិជ្ជកម្ម រីកឡើងដោយមានវត្ត ព្រមទាំងផ្សារនៅជិតនោះ ។ ដើម្បីបំពេញគម្រោងនគរូបនីយកម្មធំដូចនេះ ព្រែក និងបឹងដែលមានមកត្រូវលុបដីបំពេញ ហើយលានដីធំៗត្រូវព័ទ្ធដោយទំនប់ បន្ទាប់មកត្រូវបំពេញឲ្យមានផ្ទៃស្មើ ដោយបូមដីល្បាប់ពីបាតទន្លេមកចាក់ ។ រោងមហោស្រពជាតិ ក៏ដូចជាអគារប៊ុលឌិញដែរគឺសុទ្ធតែស្ថាបនាឡើងលើលានដីចាក់បំពេញទាំងអស់ ។

នៅទសវត្សទី ៦០ រាជធានីភ្នំពេញមានការអភិវឌ្ឍទៅមុខយ៉ាងលឿន ដែលធ្វើឲ្យមុខមាត់ទីក្រុងមានឈ្មោះបោះសម្លេងថា ជាទីក្រុងដែលតូច តែស្អាតជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ។ ទោះបីជាទសវត្សឆ្នាំទី៦០ រាជធានីភ្នំពេញមានទំហំតូចក៏ដោយតែការអភិវឌ្ឍបានបោះជំហានទៅមុខយ៉ាងលឿន មុខមាត់

ទីក្រុងមានការផ្លាស់ប្តូរ ធ្វើឲ្យទីក្រុងភ្នំពេញមានឈ្មោះបោះសម្លេងក្លាយជាទីក្រុងគុជ និងជាប្រទេសដែលមានឈ្មោះថា កោះសន្តិភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍[76] ។

បើធ្វើការប្រៀបធៀបពីផ្ទៃដីក្រុងភ្នំពេញ នៅចន្លោះសម័យសង្គមរាស្ត្រនិយមឆ្នាំ ១៩៦២(ផ្ទៃដីមាន ៩៦គ.ម²) និងសម័យបច្ចុប្បន្នឆ្នាំ២០១០ (ផ្ទៃដី ៦៧៨.៧គ.ម²) នោះបានអះអាងថាក្នុងរយៈពេល ៤៩ឆ្នាំ ទីក្រុងភ្នំពេញមានផ្ទៃដីរីកធំឡើងទៅដល់ជិត ១៥ដង ។

នៅចុងទសវត្ស ១៩៦០ អគារចាំបាច់ទាំងអម្បាលមាណសម្រាប់ឲ្យភ្នំពេញក្លាយជារាជធានីមានភាពថ្កុំថ្កើននោះ ឃើញថាបានសាងឡើងគ្រប់សព្វហើយ ព្រឹត្តិការណ៍នយោបាយនៅឆ្នាំ ១៩៧០ បានបញ្ឈប់ការអភិវឌ្ឍនេះយ៉ាងទាន់ហន់ ។

**គ.វិស័យសង្គមកិច្ច**[77]

វិស័យសង្គមកិច្ច ក៏ជាបុព្វហេតុមួយដែលជំរុញខឿនអភិវឌ្ឍសង្គមជាតិឆ្ពោះទៅកាន់ភាពសំបូររុងរឿង ។ បញ្ហាសុខភាពរបស់ប្រជាពលរដ្ឋ និងការអប់រំ ជាកត្តាចំបងចំពោះមុខ ដែលត្រូវតែដោះស្រាយដើម្បីភាពខ្លាំងពលកម្ម និងស្មារតីនៃមូលដ្ឋានសង្គម ។

ការអប់រំៈ តាមស្ថិតិសម័យនោះ ចំនួនសាលារៀនបឋមសិក្សាបានកើនពី ២៧៣១ ក្នុងឆ្នាំ ១៩៥៥ ដល់ ៥៨៥៧ ក្នុងឆ្នាំ១៩៦៨ ឯចំនួនអនុវិទ្យា និងវិទ្យាល័យកើនពី ១២ក្នុងឆ្នាំ ១៩៥៥ ដល់ ១៥០ ក្នុងឆ្នាំ ១៩៦៨ ។ ផ្នែកសិក្សាបច្ចេកទេសក៏មានការរីកចំរើនយ៉ាងរហ័ស ហើយបានរួមចំណែកយ៉ាងសកម្មក្នុងការធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាមានវឌ្ឍនភាព ។ ផ្នែកឧត្តមសិក្សាបានត្រូវពង្រឹង និងពង្រីកជាលំដាប់ ។ នៅឆ្នាំ ១៩៦០ មានការបង្កើតឡើងនូវសាកលវិទ្យាល័យនានា ដែលមានមហាវិទ្យាល័យជាច្រើនដូចជា មហាវិទ្យាល័យនីតិសាស្ត្រ មហាវិទ្យាល័យវេជ្ជសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រ និងមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រ ។ ព្រមជាមួយគ្នានោះក៏មានទំនាក់ទំនងវប្បធម៌ជា មួយប្រទេសនានាលើសកលលោកដោយបានបញ្ជូននិស្សិតឲ្យទៅសិក្សានៅបរទេស និងទទួលនិស្សិតក្រៅប្រទេសមករៀននៅប្រទេស ក៏មានសន្ទុះរីកចំរើនដែរ ។ នៅឆ្នាំ ១៩៥៧ រាជរដ្ឋាភិបាលបានស្ថាបនាអគារសម្រាប់និស្សិត និងកម្មសិក្សាការីខ្មែរស្នាក់ នៅបូរីសាកលវិទ្យាល័យក្នុងទីក្រុងប៉ារីសអស់ទឹកប្រាក់ ៤៥លានរៀល ។ ការរីកដុះដាលនៃអគារសិក្សាទូទាំងប្រទេសក្នុងសម័យសង្គមរាស្ត្រនិយមធ្វើឲ្យការបណ្តុះបណ្តាលបុគ្គលិកសិក្សា ក្លាយទៅជាទិសដៅមួយយ៉ាងសំខាន់របស់រាជរដ្ឋាភិបាល ។ ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៦៩

[76] សៀវភៅសិក្សាសង្គមថ្នាក់ទី១២របស់ក្រសួងអប់រំ យុវជន និង កីឡា ទំព័រ ២១៩ បោះពុម្ពផ្សាយឆ្នាំ ២០០៣ ។

[77] សៀវភៅសិក្សាសង្គមថ្នាក់ទី១២ បោះពុម្ពផ្សាយ ឆ្នាំ២០០៣ ទំព័រ ២១៧ ។

ចំនួនគ្រូ បឋមសិក្សាកើនពី ៤ ៣២៨នាក់ដល់ ២២ ៧៥២នាក់ សាស្ត្រាចារ្យមធ្យមសិក្សាបានកើនពី៣៧ នាក់ដល់ ៥០០៩នាក់ ឯសាស្ត្រាចារ្យឧត្តមសិក្សា បានកើនពី ៧ នាក់ដល់ ១៩៣៥នាក់ ។ ផែនការ៥ឆ្នាំ របស់រាជរដ្ឋាភិបាល១៩៦០-១៩៦៥ គោលការណ៍ពង្រឹងសមត្ថភាពបុគ្គលិកសិក្សាឲ្យបានល្អប្រសើរ ព្រម ទាំងពង្រីកផ្នែកមធ្យមសិក្សា ឧត្តមសិក្សា ជាពិសេសសិក្សាបច្ចេកទេស ឲ្យបានរីកចំរើនឆាប់រហ័ស ។

ដើម្បីលើកស្ទួយប្រទេសឲ្យមានវឌ្ឍនភាព រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នយោបាយមិត្តភាពដ៏ ប៉ិនប្រសប់ជាមួយបណ្តាលប្រទេសលើសកលលោកដើម្បី ទាក់ទាញជំនួយសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច បច្ចេកទេស ។ ក្នុងក្របខ័ណ្ឌជំនួយ រាជរដ្ឋាភិបាលបានយកមួយភាគធំ សម្រាប់វិស័យសិក្សាធិការ ជាក់ ស្តែងក្នុងជំនួយពីសហរដ្ឋអាមេរិចនៅឆ្នាំ ១៩៦០ ចំនួន៣៦៣៤ លានរៀល ចំណាយសម្រាប់សិក្សាធិការ មានដល់ទៅ ៥០២ លានរៀល ចំណែកក្នុងជំនួយពីប្រទេសបារាំង ចំនួន ៧៥លានរៀល ចំណាយ សម្រាប់សិក្សាធិការមានចំនួន ១៦លានរៀល ។ ក្នុងពេលជាមួយគ្នានេះ សហភាពសូវៀតបានជួយស្ថាប នាវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មួយដែលមានមហាវិទ្យាល័យចំនួន ៥ ។ ក្នុងក្របខ័ណ្ឌជំនួយរបស់ សាធារណរដ្ឋប្រជាមានិតចិននៅឆ្នាំ ១៩៥៧ ចំនួន៧៧៥ លានរៀល ក៏មានចំណាយសម្រាប់សាលារៀន និងសាលមហោស្រពដែរ ។ ក្នុងការលើកកំពស់កំរិតវប្បធម៌របស់ប្រជាពលរដ្ឋខ្មែរ រាជរដ្ឋាភិបាលបានធ្វើ យុទ្ធនាការទូទាំងប្រទេស ដើម្បីបំបាត់អនក្ខរភាព ។

សុខាភិបាលៈ ក្រោយមាគ៌ាសង្គមរាស្ត្រនិយម ប្រជាជាតិទាំងមូលបានចូលរួមយ៉ាងសកម្មក្នុងការ ថែរក្សាសុខភាព ហើយកិច្ចការនេះចាំបាច់អនុវត្តព្រមគ្នាទូទាំងប្រទេស។ ដើម្បីរួមចំនែកជំរុញកិច្ចការ បន្ទាន់នេះស្ថាប័នពាក់ព័ន្ធទាំងឡាយបានចាប់ដំណើរការ ដែលក្នុងនោះមានយុទ្ធនាការដំបូង គឺការចាក់ ថ្នាំបង្ការរោគរាតត្បាត ការអនុវត្តក្បួនអនាម័យ ការសិក្សាពីវិធានការការពារ និងព្យាបាលជំងឺ ។ តាមការ ដកស្រង់ពីសកម្មភាពជាក់ស្តែង ដែលធ្វើបានក្នុងអំលុងផែនការ ៥ឆ្នាំ នៃការងារសុខាភិបាលនាឆ្នាំ ១៩៦១ មកធ្វើជាតឹកតាង ។ ការចាត់ថ្នាំការពារជំងឺអុតសម្រេចបាន ១៧៤ ០៤៣ នាក់ ជំងឺអាសន្នរោគ សំរេចបាន ១ ៣៤០ ០០០នាក់ ជំងឺគ្រុនចាញ់សម្រេចបាន ៦៣៦ ៤០៨នាក់ ។ ការឃោសនាអប់រំ ការ ចូលរួមសំអាតភូមិស្ថាន បានចំនួន ១៤ភូមិ ការចាត់ធ្វើបាឋកថាស្តីពី អនាម័យបាន ១៨៧ លើក ។

ក្នុងតួនាទីទ្រទ្រង់វិស័យសង្គមឲ្យកាន់តែរឹងមាំឡើង វិធានការទាំងឡាយបានផ្តោតទៅលើការ សាងសង់មន្ទីរពេទ្យ សាលារៀន វិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រ សមិទ្ធិផលផ្នែកសុខាភិបាល រីកដុះដាល ស្ទើរគ្រប់ទិសទី តាំងពីក្រុងដល់ជនបទ ។ កេរដំណែលដែលនៅសេសសល់ ហើយបាន និងកំពុងបន្តប្រើ ប្រាស់បំរើសង្គមជាតិរៀងមក នៅទីក្រុងភ្នំពេញមានៈ មន្ទីរពេទ្យកុមារគន្ធបុប្ផា ឳសថល័យព្រះសុរាម្រឹត

មហាវិទ្យាល័យភូមិន្ទវិជ្ជាពេទ្យ មន្ទីរសម្ភពផះង៉ាង៉ា មន្ទីពេទ្យព្រះសង្ឃព្រះកុសុមៈ មន្ទីពេទ្យរូស៊ី (ព្រះសីហានុ) ព្រមទាំងមន្ទីពេទ្យ និងឪសថល័យជាច្រើនទៀតនៅតាមបណ្តាលខេត្តនានា ។

ក្នុងគោលការណ៍ ប្រែក្លាយទឹកដីកម្ពុជាឲ្យទំនើបឡើង កិច្ចការសង្គម ដូចជាការងារហត្ថកម្មដោយស្ម័គ្រចិត្ត ការស្ថាបនាទីក្រុង និងអភិវឌ្ឍន៍ជនបទ មានសកម្មភាពយ៉ាងសស្រោកសស្រាំ ។ ស្នាដៃនៃហត្ថករស្ម័គ្រចិត្ត និងសមិទ្ធិដែលប្រសូតចេញពីស្មារតីសង្គម មានការរៀបចំទីក្រុង ការឈូសឆាយបង្កើតភូមិនិង សង់លំនៅឋានជូនប្រជារាស្ត្រក្រីក្រ ការសាងសង់អគាសាធារណៈ ការជីកអណ្តូង ស្រះ ប្រឡាយ ដើម្បីឆ្លើយតបតាមតំរូវការរបស់ប្រជាពលរដ្ឋ -ល-។

លើកិច្ចការច្បាប់ និងអនុវត្តន៍ច្បាប់ ក្នុងសម័យសង្គមរាស្ត្រនិយម មានការរៀបចំព្រះរាជក្រមជាច្រើនដើម្បីបំរើឲ្យសុវត្ថិភាពសង្គមបានល្អ ។ ព្រះរាជក្រម និងព្រះរាជក្រឹត្យសម្រាប់ការពារសិទ្ធិនៃសង្គមមានជាអាទិ៍ ការពារព្រៃឈើ និងមច្ឆជាតិ ហាមឃាត់មិនឲ្យលក់ទ្រព្យសម្បត្តិរដ្ឋ ដល់ជនបរទេស ។ ដើម្បីពង្រឹកសមត្ថភាពកំលាំងស្រួចលើកិច្ចការពារសន្តិសុខ និងសុវត្ថិភាពសង្គម យុវជនរាជសង្គមនិយមខ្មែរបាន ទទួលការរឹកហាត់ចំនេះដឹងខាងវិជ្ជាយោធា ។ ដើម្បីការពារវប្បធម៌ប្រពៃណីខ្មែរច្បាប់បំបាត់ពេស្យាចារ បានត្រូវអនុវត្តព្រមទាំងបានបង្កើតមជ្ឈមណ្ឌលសម្រាប់អប់រំស្ត្រីពេស្យានៅទួលគោក (ឆ្នាំ១៩៦១) ។ លើកិច្ចការអនុវត្តន៍ច្បាប់ មានគោលការណ៍ដាក់ពិន័យ ដាក់ទណ្ឌកម្ម ហើយក៏មានគោលការណ៍អប់រំតំរង់ទិស វិជ្ជាជីវៈ ដល់ពិរុទ្ធជនដែរ ។ គោលការណ៍ច្បាប់សម័យសង្គមរាស្ត្រនិយមបានផ្តល់សិទ្ធិបោះឆ្នោតជូនស្ត្រី និងឈរឈ្មោះឲ្យគេបោះឆ្នោត ។ សិទ្ធិជ្រើសរើអ្នកតំណាង អនុវត្តន៍រហូតដល់ថ្នាក់ឃុំផងដែរ ។ នេះជាគោលការណ៍ដែលបានលើឡើងក្នុងឆ្នាំ១៩៥៩ ដែលជាសិទ្ធិបែបប្រជាធិបតេយ្យក្នុងសង្គម ។

ប្រជាពលរដ្ឋមានការងារធ្វើតាមលទ្ធភាពរៀងៗខ្លួន ហើយបានទទួលការគាំទ្រពីរាជរដ្ឋាភិបាលដែលជាបន្ទុករបស់ក្រសួងសង្គមកិច្ច និងការងារ ។ ការអនុវត្តស្មារតីមហាសាមគ្គីជាតិ និងនយោបាយអព្យាក្រឹតបានបង្កលក្ខខណ្ឌ ល្អប្រពៃឲ្យប្រជាពលរដ្ឋខ្មែរ រស់នៅក្នុងជីវភាពរុងរឿង (សុខក្សេមក្សាន្ត ) សន្តិភាពប្រជាធិបតេយ្យលើកោះសន្តិភាព ក្នុងតំបន់អាស៊ីអាគ្នេយ៍[78] ។

## ៣.សម័យសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)

### ៣.១. ប្រវត្តិនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល

[78] សិក្សាសង្គមថ្នាក់ទី ១២ ភូមិវិទ្យា និង ប្រវត្តិវិទ្យា បោះពុម្ពឆ្នាំ ២០០៣ ទំព័រ ២១៩ ។

**ក. ប្រវត្តិនយោបាយ**[79]

រដ្ឋប្រហាររបស់ឧត្តមសេនីយ៍ លន់ នល់ បានចាប់ផ្ដើមឡើងនៅថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៧០ ហើយនៅពេលនោះ សម្ដេចនរោត្តម សីហនុ ត្រូវបានក្រុមប្រឹក្សាព្រះរាជាណាចក្រ និងសភាជាតិទាំងពីរធ្វើការដកសេចក្ដីទុកចិត្ត ។ នៅក្រោយរដ្ឋប្រហារមួយថ្ងៃ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានធ្វើសេចក្ដីថ្លែងការណ៍ស្ដីពីការទទួលស្គាល់អំណាចរបស់ឧត្តមសេនីយ៍ លន់ នល់ និងសិរិមតៈ ជាអ្នកដឹកនាំ ។

ចាប់តាំងពីរដ្ឋាភិបាលត្រូវថ្មីបង្កើតឡើង របបគ្រប់គ្រងរដ្ឋត្រូវបានផ្លាស់ប្ដូរពីរបបរាជានិយម មករបបសាធារណរដ្ឋខ្មែរ[80] ដែលធ្វើឲ្យប្រជារាស្ត្រមួយចំនួនមានក្ដីសង្ឃឹម ។ របបសាធារណរដ្ឋខ្មែរត្រូវបានបង្កើតឡើងនេះ ត្រូវបានបង្កើតឡើងស្របច្បាប់ព្រោះមានការបោះឆ្នោតជាសម្ងាត់នៅថ្ងៃទី ៥ ខែតុលា ឆ្នាំ ១៩៧០ យោងតាមច្បាប់ស្ដីពីការបោះឆ្នោត ដែលជាច្បាប់មួយអាស្រ័យរដ្ឋធម្មនុញ្ញ ដោយបញ្ញត្តិថា ការប្រកាសនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧០ ។

ចំពោះស្ថាប័ននយោបាយវិញ បញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញត្រង់ជំពូកទី៥ បានចែងអំពី ព្រឹទ្ធសភា និងរដ្ឋសភា ក្រៅពីនេះមានតុលាការធម្មនុញ្ញ ប្រធានាធិបតី និងរដ្ឋាភិបាល ដែលនៅសម័យនោះ គេមិនប្រើប្រាស់តំណែងនាយករដ្ឋមន្ត្រីទេ តែគេប្រើរដ្ឋមន្ត្រីទី១វិញ ។

**ខ. រចនាសម្ព័ន្ធរដ្ឋបាល**[81]

**ខ.១. ស្ថាប័នរដ្ឋបាលកណ្ដាល**

នៅក្នុងសម័យសាធារណរដ្ឋខ្មែរ មានការជ្រើសរើសថ្នាក់ដឹកនាំប្រទេសដោយការបោះឆ្នោត ព្រមទាំងមានការបង្កើតរដ្ឋធម្មនុញ្ញថ្មី របស់សាធារណរដ្ឋនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៧២ ។ ក្រោយពីលទ្ធផលនៃការបោះឆ្នោត ការគ្រប់គ្រងរដ្ឋត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឧត្តមសេនីយ៍ លន់ នល់ ជាប្រធានាធិបតី ដូចប្រធានាធិបតីសហរដ្ឋអាមេរិកដែរ ។

**ខ.១. ស្ថាប័នរដ្ឋបាលដែនដី**

ដោយសារប្រទេសមានសង្គ្រាមស៊ីវិលពាសពេញផ្ទៃប្រទេស ជាហេតុនាំឲ្យមានការបែងចែកស្ទើរតែគ្រប់ផ្នែកនៃការគ្រប់គ្រងរដ្ឋ តាមលក្ខណៈបែបយោធានិយមដូចជាៈ

ផ្នែកយោធាបានចែកចេញជាបីគឺ ទ័ពអាកាស ទ័ពជើងទឹក និងទ័ពជើងគោក ។

[79] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ៣៧ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១៤២ ។

[80] មាត្រា ១ នៃរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ឆ្នាំ ១៩៧២ ។

[81] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ៣៧ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១៥១ ។

ចំពោះការគ្រប់គ្រងនៅតាមមូលដ្ឋាន នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧០ លន់ នល់បានចេញក្រឹត្យប្រកាសធ្វើកំណែនទូទៅ ដើម្បីរៀបចំស្វ័យការពារពីសំណាក់ប្រជាពលរដ្ឋស៊ីវិល ។

### ៣.២. ការកសាងទីក្រុង

#### ក. ការកសាងផ្នែកសេដ្ឋកិច្ច

ពីមួយថ្ងៃទៅមួយថ្ងៃនៅគ្រប់សមរភូមិខេត្តក្រុងស្នូរគ្រាប់កាំភ្លើងដៃ គ្រាប់ផ្លោងឮនៅជិតបង្កើយខ្សែក្រវ៉ាត់ក្រុងភ្នំពេញមួយថ្ងៃទៅមួយថ្ងៃកាន់តែរួញទៅៗ ។ តំបន់សេដ្ឋកិច្ចសំខាន់ដែលជាដង្ហើមរស់សម្រាប់អ្នកក្រុងភ្នំពេញត្រូវបានកាត់ផ្ដាច់ ។ អ្នកក្រុងភ្នំពេញរស់ដោយសារជំនួយដឹកតាមយន្តហោះ ដែលដឹកដោយកង លន់ នុល ផ្តល់ដោយសហរដ្ឋអាមេរិក ជាពិសេស អង្ករ ។ នៅទូទាំងប្រទេសក្រៅ ពីក្រុងភ្នំពេញ តំបន់ក្បែរៗក្រុង និងទីរួមខេត្តនានាត្រូវបានធ្លាក់ក្នុងតំបន់រំដោះ ដូចនេះដង្ហើមសេដ្ឋកិច្ច ដែលជាក្តីសង្ឃឹមរបស់ទីក្រុងមានតិចណាស់ ។ ចាប់ពីថ្ងៃ ១៨ មីនា ១៩៧០ មកទល់ថ្ងៃ ១៧ មេសា ១៩៧៥ ដែលមានរយៈពេល ៥ឆ្នាំ ប្រជាជនកម្ពុជាត្រូវរស់នៅក្រោមការរត់គេចពីគ្រាប់រំសេវ គ្រប់យ៉ាង ដែលពួកអាមេរិក និង លន់ នល់ យកមកទម្លាក់លើ ប្រជាជនខ្មែរដែលជាជនស្លូតត្រង់គ្មានកំហុស ស្លាប់អស់ជាច្រើន និង ព្រាត់ប្រាស់កូនចៅ ។ សង្គ្រាមបានកាត់ផ្តាច់ ការផលិត ផលិតផល កសិកម្ម ជាពិសេស ដំណាំស្បៀង ដូចជាស្រូវ ពោត ........ ។

ភាពវឹកវរនេះបានធ្វើឲ្យប្រជាជនដែលមិនធ្លាប់ស្គាល់សង្គ្រាម មិនធ្លាប់ឮស្នូរគ្រាប់កាំភ្លើង ភ័យតក់ស្លុតនាំគ្នាភៀសខ្លួន រត់ចូលក្រុងរកសេចក្ដីសុខ គេចចេញពីតំបន់ប្រយុទ្ធ គេចពីការស្លាប់និងបាន ធ្វើឲ្យរាជធានីភ្នំពេញ ក៏ដូចជាតំបនជុំវិញមានទីរួមខេត្តកណ្តាល ( ទីប្រជុំជនតាខ្មៅ ) ជាដើម ចំនួនប្រជាជនបានកើនឡើងយ៉ាងលឿនប្រមាណ ជាពី ២០០០០០០ នាក់ទៅ ៣០០០០០០នាក់ ។ តែបើ តាមឯកសារបោះពុម្ពផ្សាយរបស់លោក Jacques Migozzi ( ១៩៧៣ ) វិញលោកបានបង្ហាញថាភ្នំពេញ នៅឆ្នាំ ១៩៦៨ មានប្រជាជនប្រមាណ ៦០០០០០ នាក់ ប៉ុណ្ណោះ តែចាប់ពីថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ រហូតដល់ឆ្នាំ ១៩៧២ ចំនួនប្រជាជនបានកើនឡើងប្រមាណជា ១៥០០០០០នាក់ ។ ការកើនឡើងនៃ ចំនួនប្រជាជននាពេលនោះគឺ ជាការកើនឡើងនៃចំនួនប្រជាជន ដែលកើតបានពីការធ្វើចលនាផ្លាស់ទី ពីទីជនបទ ចូលមករស់នៅក្នុងទីក្រុង ។

#### ខ. ការកសាងផ្នែកសង្គមកិច្ច

ចន្លោះឆ្នាំ ១៩៧០ ដល់ ១៩៧៥ គេបានធ្វើការងារសាធារណៈតែមួយគត់ គឺទំនប់ធំមួយដែលកសាងឡើងនៅឆ្ងាយពីក្រុង សម្រាប់ប្រើប្រាស់ជាខ្សែក្រវ៉ាត់កងទ័ព ។ ក្នុងពេលជាមួយគ្នានោះភ្នំពេញ បាន

ទទួលជនភៀសខ្លួនយ៉ាងច្រើនដែលរត់គេចខ្លួនពីចម្បាំងនៅតាមជនបទ។ នៅឆ្នាំ ១៩៧៥ ប្រជាជននៅក្នុងរាជធានី បានកើនឡើងដល់ជាង ១លាននាក់ ដោយមានអ្នករស់នៅគ្មានច្បាប់ទម្លាប់នៅលើផ្ទៃដីដ៏ធំនៃក្រុង ។

ចំពោះវិស័យអប់រំ:[82] ទោះបីជាប្រទេសជួបប្រទះនូវសង្គ្រាមក៏ដោយ ក៏រដ្ឋាភិបាលបានជំរុញឲ្យប្រជាជនចូលរួមក្នុងកសាងសាលារៀនដោយកំណត់ ១ភូមិ សង់មួយកន្លែង ។

វិស័យសុខាភិបាល:[83] ចាប់តាំងពីឆ្នាំ ១៩៦៩មក ថវិកាសាធារណ:លើវិស័យសុខាភិបាលដែលរដ្ឋបានអនុម័តមានចំនួនតែ ៤.៨%នៃថវិកាជាតិប៉ុណ្ណោះ ។ ជាមួយថវិកាដ៏តិចតួចនេះ ធ្វើឲ្យក្រុមគ្រូពេទ្យមានត្រឹមតែ ៤៥០នាក់ប៉ុណ្ណោះ ដែលជាការលំបាកមួយក្នុងការបំពាក់គ្រឿងបរិក្ខារ និងធ្វើឲ្យមណ្ឌលសុខភាពមានសកម្មភាព ។

**គ. ការកសាងផ្នែកវប្បធម៌**

ចាប់ពីពេលដែលកម្ពុជាមានរដ្ឋប្រហារ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមស៊ីវុលពេលនេះហើយដែលដំណើរនគរូបនីយកម្មនៅកម្ពុជាមានការប្រែប្រួល ជាពិសេសនៅដើមឆ្នាំ ១៩៧២ នគរូបនីយកម្មមានអត្រាពី ២០ ភាគរយទៅ ២៥ ភាគរយ នៃប្រជាជនកម្ពុជាទូទាំងប្រទេស ។ ទោះបីជាប្រទេសកម្ពុជាមាននគរូបនីយកម្មកើនឡើងយ៉ាងឆាប់បំផុត និងមានល្បឿនលឿនបែបនេះ ក៏ដោយតែបើប្រៀបធៀបទៅនិងនគរូបនីយកម្មទៅនិងសាធារណ:រដ្ឋវៀតណាមវិញនោះ អត្រានគរូបនីយកម្មនៅកម្ពុជានៅតែទាបជាង ព្រោះនៅវៀតណាមខាងត្បូងមានចលនារំដោះប្រទេស ដើម្បីផ្តួលរលំរបបធីវគីកំពុងមានសន្ទុះខ្លាំងក្លា ដែលបណ្តាលឲ្យមានចលនាជនភៀសខ្លួនយ៉ាងច្រើនចូលមករស់នៅក្នុងទីក្រុងព្រៃនគរ ឬ ទីក្រុងសាយហ្គន ..... ។

នៅតាមទីប្រជុំជននៃទីរួមខេត្តធំៗ មានខេត្តបាត់ដំបង ខេត្តកំពង់ចាម ក្រុងព្រះសីហនុ (ខេត្ត ព្រះសីហនុ) .....ចលនាជនភៀសខ្លួនប្រមូលផ្តុំរស់នៅយ៉ាងកុះករ ។ ចំពោះទីរួមខេត្តកណ្តាល មានក្រុងតាខ្មៅបានពង្រីកខ្លួនមកភ្ជាប់នៅក្រុងភ្នំពេញ ។ នគរូបនីយកម្មមានល្បឿនលឿន ទន្ទឹងនឹងចលនាបម្លាស់ទីជនបទចូលក្រុង និងតំបន់ជុំវិញហើយរីករាលដាលដល់តំបន់ជាយក្រុង ក្នុងរយ:ពេលដ៏ខ្លី ដោយបានបង្ករនូវបញ្ហាសង្គមយ៉ាងធ្ងន់ធ្ងរដូចជាបញ្ហាសន្តិសុខ ខ្វះជម្រក ទឹក ភ្លើង ស្បៀង ..... ។

[82] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១៦០ ។

[83] សៀវភៅ ប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ទំព័រ ១៦១ ។

តាមរយៈការសិក្សាបានបង្ហាញឲ្យឃើញពីដំណើរនគរូបនីយកម្ម បានផ្សារភ្ជាប់ទៅនឹងស្ថានភាពនយោបាយរបស់ប្រទេស ។ ពាក់ព័ន្ធនិងបញ្ហាសន្តិសុខប្រទេស បញ្ហាសង្គមក៏បានកើតឡើងដែរ ដោយរួមជាមួយនឹងបញ្ហាសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាបញ្ហាសេដ្ឋកិច្ចជាតិ ដែលមិនអាចស្រោចស្រង់បានរហូតដល់ថ្ងៃដែលរបបសាធារណរដ្ឋខ្មែរ ត្រូវបានដួលរលំ និងធ្លាក់ទៅក្នុងកណ្តាប់ដៃចលនារំដោះជាតិ ដែលមាននិន្នាការទៅរកលោកខាងកើត គឺរបបកុំម្មុយនីស្ត ។

ទោះបីជីវភាពនៅទីក្រុងមិនមានលក្ខណៈល្អក្តី តែដើម្បីជីវិតគេចឲ្យផុតពីគ្រោះថ្នាក់ ប្រជាជនត្រូវតែចូលមកជ្រកកោននៅក្នុងតំបន់ដែលមានសុវត្ថិភាពនេះសិន ដោយរង់ចាំពេលវេលាណាប្រទេស មានសន្តិភាព ពួកគេនិងវិលត្រលប់ទៅស្រុកវិញ ។ វត្តអារាមដែលជាទីសក្ការៈ បានក្លាយជាជម្រកសម្រាប់ជនភៀសខ្លួន និងជាទីតាំងកងទ័ពលន់ នល់ ផងដែល ។ ជនភៀសខ្លួនប្រមូលផ្តុំនៅតាមដង ផ្លូវ និងតំបន់នានាដូចជា វត្តអារាម ក្រោមស្ពាន ជាពិសេសទីណាដែលមានដីទំនេរលើដីរដ្ឋ និងដីឯកជន មានជនភៀសខ្លួនស្នាក់នៅពាសពេញ ។ តាមលំនៅឋាននីមួយៗ សមាជិកគ្រួសារបានកើន ឡើង ដោយមានការចែករំលែកទីកន្លែងស្នាក់នៅ ព្រោះពួកគេជាសាច់ញាតិសន្តានមកពីខេត្តនានា ។

ក្នុងពេលប្រទេសកំពុងឋិតក្នុងសង្គ្រាម សាលាក្រុងគ្មានផែនការដើម្បីអភិវឌ្ឍក្រុងឡើយ ។ សោភ័ណភាពទីក្រុងត្រូវបានធ្លាក់ចុះ ពិសេសពាក់ព័ន្ធនិងបញ្ហាបរិស្ថាន ។ ក្បាលម៉ាស៊ីនរដ្ឋដឹកនាំ ដោយពួកសាធារណរដ្ឋខ្មែរ មិនបានគិតគូរអ្វីក្រៅពីធ្វើយ៉ាងណាដើម្បីទប់ទល់និងសង្គ្រាម ។

ប្រជាពលរដ្ឋក្នុងទីក្រុងក៏ដូចជាតំបន់ជាយក្រុង ខ្វល់ខ្វាយនិងជីវភាពរស់នៅប្រចាំថ្ងៃ ។ ឋិតក្នុងស្ថានភាពរឹករបែបនេះ ទំនិញឡើងថ្លៃ រដ្ឋមិនអាចគ្រប់គ្រងតម្លៃបាន ព្រោះសមរភូមិក្រោយ ត្រូវកាត់ផ្តាច់សមរភូមិមុខ ដែលសង្គ្រាមនេះធ្វើឲ្យរបបសាធារណៈរដ្ឋខ្មែរដឹកនាំដោយលោកលន់ នុលរង់ចាំតែថ្ងៃបរាជ័យ ។

ដូចនេះប្រជាជនកម្ពុជាជាអ្នករងគ្រោះពិតប្រាកដ ព្រោះមួយថ្ងៃៗ គ្រាប់បែករបស់សហរដ្ឋ អាមេរិក បានទម្លាក់ស្រោចស្រពមកលើតំបន់នានា ក្នុងប្រទេសកម្ពុជា និងបានសម្លាប់ប្រជាជនស្លូត ត្រង់ ដែលគ្មានកំហុសទាល់តែសោះ បំផ្លាញទាំងធនធានធម្មជាតិ មានសត្វរុក្ខជាតិ ដូចជា ចំការកៅស៊ូ ព្រៃឈើ ត្រូវឆេះខ្លោចបំផ្លាញទាំងដំណាំដាំដុះនានា ធ្វើឲ្យវិស័យកសិកម្មធ្លាក់ដល់កម្រិតសូន្យ ។ ចំណែករោងចក្រឧស្សាហកម្ម ៤ភាគ៥ ត្រូវបានបំផ្លិចបំផ្លាញ ចំការដំណាំកៅស៊ូ២ភាគ៣បានបាត់បង់ ផ្លូវថ្នល់ និងផ្លូវដែកពី៧០ ទៅ៨០ភាគរយបានខូចខាត ហើយកំពង់ផែ កំពង់ចំលងបានខ្ទេចខ្ទាំ សំណង់សាធារណៈ ទីប្រជុំជន និងគ្រឹះស្ថានសិក្សាពី ៨០ ទៅ៩០ភាគរយ បានរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ។

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាយ៉ាងល្អិតល្អន់អំពីការរៀបចំទីក្រុងពីឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៧៥ រួចមក យើងសង្កេតឃើញថាការរៀបំទីក្រុងមិនមែនធ្វើតែចំពោះទីក្រុងនោះទេ ហើយក៏មិនមែនរៀបចំតែក្នុងទីក្រុងនោះដែរ គឺគេអាចធ្វើឡើងនៅទីកន្លែងណាដែលស្ថានភាព(ភូមិសាស្ត្រ ឬសេដ្ឋកិច្ច) តម្រូវឲ្យធ្វើដើម្បីជាប្រយោជន៍ដល់ការរស់នៅប្រកបដោយភាពសុខសប្បាយរបស់ប្រជាពលរដ្ឋ ។ មួយវិញទៀតការរៀបចំនេះត្រូវធ្វើឡើងព្រមគ្នាទាំងផ្នែកដែនដីរដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រោះវិស័យទាំងនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធក្នុងការរុញច្រានប្រទេសមួយឲ្យឈានទៅដល់ការអភិវឌ្ឍពិតប្រាកដ ។ តាមរយៈការសិក្សារបស់យើង តាំងពីសម័យអាណានិគមរហូតដល់ឆ្នាំ១៩៧៥នេះ គឺយើងកត់សម្គាល់ឃើញថា វត្តមាននៃ ការរៀបចំផ្នែករដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងទីតាំងភូមិសាស្ត្រ សុទ្ធតែត្រូវបានធ្វើឡើងក្នុងសម័យកាលនីមួយៗ ដោយពុំអាចខ្វះខាតបានដើម្បីធានាតុល្យភាព នៃការអភិវឌ្ឍន៍ ។

មួយវិញទៀត ភ្ជាប់ទៅនឹងមូលហេតុនានាដែលនាំឲ្យមានការរៀបចំទីក្រុង របត់នយោបាយ និងការដឹកនាំ ក៏ជាធាតុផ្សំដ៏សំខាន់ផងដែរ គឺវាបានកំណត់អំពីទីតាំងដែល ត្រូវរៀបចំ ហើយបើកាលណាការដឹកនាំមានភាពស្ទាក់ស្ទើរ ឬធ្វើសេចក្តីសម្រេចចិត្តខុស ក្នុងកំណត់ទីតាំងដែលត្រូវរៀបចំ និងអភិវឌ្ឍន៍ វាអាចបណ្តាលឲ្យមានមានផលវិបាកដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ និងបញ្ហាកើតមានឡើងដែលបង្កើនបន្ទុកដល់រដ្ឋទៅវិញ ។

ដោយយល់ឃើញថា ការរៀបចំទីក្រុងគឺជាកិច្ចការលំបាក និងជាកិច្ចដែលត្រូវធ្វើឡើងដើម្បីផលប្រយោជន៍សម្រាប់រយៈពេលយូរទៅថ្ងៃខាងមុខនោះ ការរៀបចំទីក្រុងត្រូវតែបានល្អប្រសើរ ត្រូវតែមានប្លង់គោល (Master Plan) ច្បាស់លាស់និងស្របទៅតាមទីតាំងភូមិសាស្ត្រ ដើម្បីរៀបចំឲ្យបាននូវតំបន់អភិវឌ្ឍន៍មួយប្រកបដោយគុណភាព សោភណ្ឌភាព និងមិនបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថានជុំវិញ ។

ដោយយល់ដឹងអំពីសារៈសំខាន់នៃការរៀបចំនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជាយើងបានបង្កើតនូវស្ថាប័នរដ្ឋសំខាន់ៗ មួយចំនួនដើម្បីរៀបចំកែលម្អទីក្រុង ដោយធានាបាននូវសណ្តាប់ធ្នាប់សាធារណៈល្អ ប្រកបដោយផាសុខភាព ដែលក្នុងនោះ រួមមាន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរអប្សរា និងអាជ្ញាធរព្រះវិហារជាដើម ។ ស្ថាប័នទាំងនេះ មានភារៈកិច្ចយ៉ាងសំខាន់ក្នុងការរៀបចំទីក្រុងក្នុងសម័យទំនើប ។

## ឯកសារយោង


១. រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៤៧ ដល់១៩៧០ ។

២. រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋខ្មែរ ឆ្នាំ ១៩៧២ ។

៣. ការកសាងបូរីរបស់លោក វណ្ណ មូលីវណ្ណ ។

៤. ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពផ្សាយ ឆ្នាំ ២០១២ ។

៥. សៀវភៅប្រវត្តិស្ថាប័នខ្មែរ របស់លោកសាស្ត្រាចារ្យ ពៅ សារឿន បោះពុម្ពលើកទី១ ឆ្នាំ២០១១ ។

៦. សៀវភៅសិក្សាសង្គមថ្នាក់ទី១២ បោះពុម្ពផ្សាយ ឆ្នាំ២០០៣ ។

# គន្លឹទី៤

# ប្រវត្តិនៃការរៀបចំទីក្រុងសម័យទំនើបឆ្នាំ១៩៧៩ដល់បច្ចុប្បន្ន

## សេចក្តីផ្តើម

ភ្នំពេញធ្លាប់ជារាជធានីថ្នាក់ជាតិចាប់តាំងពីអាណានិគមនិយមបារាំង នៅកម្ពុជាមកម្ល៉េះក៏ជាទីរាជធានី និងជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ជាកន្លែងដែលមានមនុស្សរស់នៅច្រើន ជាងគេក្នុងប្រទេសកម្ពុជា ។ លើសពីនេះទៅទៀតរាជធានីភ្នំពេញបានធំធាត់ រីកលូតលាស់ឡើងក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ច និងឧស្សាហកម្មរបស់ជាតិជាមជ្ឈមណ្ឌលសន្តិសុខនយោបាយកេរ្តិ៍ដំណែល វប្បធម៌ការទូតនៃកម្ពុជា ។ ហើយក៏ជាកន្លែងសម្រាប់ប្រកួតប្រជែង ទីផ្សារពាណិជ្ជកម្មសេដ្ឋកិច្ច ទំនាក់ទំនងការបរទេស នយោបាយ ការអភិវឌ្ឍន៍ និងជាកន្លែងដែលបន្សល់ទុកនូវសំណង់ចាស់ៗ ជាច្រើនផងដែរ ដូចជាព្រះបរមរាជវាំងវត្តភ្នំនិង អគារផ្សេងៗទៀតជាដើម។ល។ សព្វថ្ងៃនេះភ្នំពេញបានប្តូររូបរាងថ្មីទាំងការអភិវឌ្ឍន៍ និង សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និង សំណង់ជាដើម។ លើសពីនេះទៅទៀតភ្នំពេញក៏បានក្លាយទៅជាទីក្រុងមួយដែលមានការប្រកួតប្រជែងផ្នែកទីផ្សារ និងសេដ្ឋកិច្ចជាមួយនិងទីក្រុងធំៗនានានៅលើសកលលោក ។

ម្តងនោះកម្ពុជាក៏ត្រូវធ្លាប់បានគេស្គាល់ថាជា*គុជអាស៊ី* ដែលត្រូវបានគេចាត់ទុកថាជាទីក្រុងមួយក្នុងចំណោមទីក្រុងជាទីស្រលាញ់បំផុត ដែលសាងសង់ដោយបារាំង នៅឥណ្ឌូចិននៅក្នុងទសវត្សឆ្នាំ១៩២០ ។ ភ្នំពេញរួមជាមួយសៀមរាបនិងព្រះសីហនុគឺជាគោលដៅទេសចរណ៍ពិភពលោក និងក្នុងស្រុកគួរឲ្យកត់សំគាល់សម្រាប់ប្រទេសកម្ពុជា ។ បានស្ថាបនានៅឆ្នាំ១៤៣៤ទីក្រុងនេះត្រូវបានគេកត់សំគាល់ដោយសារតែស្ថាបត្យកម្ម និងការទាក់ទាញខាងសោភ័ណភាព និងប្រវត្តិសាស្ត្រជាច្រើន ។ មានអគារសម័យអាណានិគមបារាំងនៅសេសសល់ដែលនៅរាយប៉ាយតាមបណ្តាមហាវិថីធំៗ ។ ដោយបានស្ថិតនៅលើច្រាំងនៃទន្លេសាបមេគង្គ និងទន្លេបាសាក់ផ្ទៃទីក្រុងមេភ្នំពេញ គឺជាផ្ទះសម្បែងនៃប្រជាជនកម្ពុជាប្រហែល២,២លាននាក់ក្នុងចំណោមប្រជាជន១៤,៨លាននាក់ ដែលកើនឡើងរហូតចាប់ពីប្រហែល១,៩លាននាក់នៅឆ្នាំ២០០៨ ។ ទីក្រុងនេះគឺជាទីក្រុងស្តុកស្តម្ភ និង សម្បូរប្រជាជនបំផុតនៅកម្ពុជា និងក៏ជាមជ្ឈមណ្ឌលនយោបាយរបស់ប្រទេសនេះ ។

ពីមួយឆ្នាំទៅមួយឆ្នាំទីក្រុងភ្នំពេញបានកំពុងបន្តការរីកចំរើន និងអភិវឌ្ឍន៍ឥតឈប់ឈរតែជាមួយនិងការអភិវឌ្ឍន៍ វាក៏ជួបប្រទះនូវបញ្ហាតូចធំជាច្រើនដែរ ដូចជាបញ្ហាការគ្រប់គ្រងសំរាមចរាចរណ៍ និងបញ្ហាលំនៅឋានផងដែរ ។ នាពេលថ្មីៗនេះបញ្ហាទឹកជំនន់ គឺជាបញ្ហាចោទយ៉ាងខ្លាំងនៅ

ក្នុងរាជធានីភ្នំពេញនារដូវវស្សាចំពោះប្រជាពលរដ្ឋ ដែលរស់នៅភ្នំពេញបានដឹងយ៉ាងច្បាស់ ថាពួកគេនិងត្រូវជិះកាត់ទឹកលិចផ្លូវជាមិនខានប្រសិនបើមានភ្លៀងធ្លាក់នោះ។ និស្សិតមួយរូបមកពី សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច បានឲ្យដឹងថា វាពិតជាបង្ករជាបញ្ហានិងការរំខាននៅពេលភ្លៀងម្តងៗព្រោះវាធ្វើឲ្យទឹកលិចផ្លូវ ស្ទះចរាចរណ៍ថែមទៀតផង[84] ។ ដើម្បីដោះស្រាយបញ្ហានេះ សាលាក្រុងភ្នំពេញបានសហការជាមួយ ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដើម្បីធ្វើគម្រោងការពារទឹកជំនន់ និងអភិវឌ្ឍន៍ប្រព័ន្ធលូបង្ហូរទឹក ដែលវាជាដំណាក់កាលទីបីនៃកិច្ចប្រតិបត្តិការណ៍នេះ ។ ដំណាក់កាលទី I និងទី II បានអនុវត្តន៍ក្នុងឆ្នាំ២០០២ និង២០០៧ បានចំណាយទឹកប្រាក់សរុបចំនួន 59 លានដុល្លារអាមេរិក ។ តើគម្រោង ការពារទឹកជំនន់ និងការអភិវឌ្ឍន៍ប្រព័ន្ធលូបង្ហូរទឹក នៅក្នុងដំណាក់កាលទី III មានអ្វីខ្លះ? កិច្ចប្រតិបត្តិការគម្រោងអភិវឌ្ឍន៍ដំណាក់កាលទី III នេះ គឺបានចាប់ផ្តើមនៅថ្ងៃទី១៦ ខែ មករា ឆ្នាំ ២០១២ ហើយនឹងបញ្ចប់ នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៥ខាងមុខនេះ ។ គម្រោងនេះអនុវត្តន៍ ផ្តោតទៅលើតំបន់សំខាន់ៗចំនួនបួន គឺ តំបន់ទួលស្លែង (៦០៧៨៩ ម៉ែត) តំបន់ឬស្សីកែវ (១៩០៥៨ម៉ែត) តំបន់បឹងកេងកង ( ១២៦៨៧១ម៉ែត) និងតំបន់ទួលទំពូង ( ១២៦៧២៧ម៉ែត) ។ គម្រោងនេះ គឺត្រូវបានផ្តល់ថវិការដោយ JICA ក៏ដូចជារដ្ឋាភិបាលជប៉ុន ដែលមានទំហំទឹកប្រាក់ប្រមាណជា៤៦ លានដុល្លារអាមេរិក ។

## ជំពូកទី១ ការរៀបចំក្រុងនៅសម័យប្រជាមានិត និងសម័យរដ្ឋកម្ពុជា

### ១.ការរៀបចំទីក្រុងចាប់ពីឆ្នាំ( ១៩៧៩-១៩៨៩)

#### ១.១.ស្ថានភាពទីក្រុងក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៨៩

យើងឃើញថា ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ រដ្ឋធានីភ្នំពេញ ជាទីក្រុងរហោស្ថាន ហើយមានព្រៃដុះស៊ុបទ្រុប និងមានភាពស្មុកស្មាញ ។ ក្នុងទីក្រុងគ្មាន ស្រមោលមនុស្ស គ្មានភាពអ៊ូអរ មានតែសម្លេងសត្វមូសខ្លាហើរចេញពីផ្ទះសំបែងបែកបាក់ ដោយសារសង្រ្គាម ហ៊ុំព័ទ្ធដោយព្រៃស្មៅ ហើយគេហដ្ឋានខ្លះទៀតនៅល្អស្អាតគ្មានអ្នកណា ប៉ះពាល់ ហើយពោពេញទៅដោយសម្លៀកបំពាក់នារីដែលនៅរៀបជាជួរយ៉ាងស្អាត មានស្បែកជើងសង្រែក និងស្បែកជើងល្អៗ របស់ប្រទេសអ៊ឺរ៉ុប ។ តែត្រូវរើសចោលរប៉ាត់ របាយនៅក្រោយឆ្នាំ១៩៧៩ នៅពេលដែលប្រជាជនត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ ។

[84]ការលើកឡើងរបស់និស្សិត ឈ្មោះ សុន ដារ៉ាតាមទិដ្ឋភាពជាក់ស្តែងក្នុងឆ្នាំ២០១៤

ហើយភ្នំពេញជំនាន់នោះ មានទឹក មានភ្លើងដោយកន្លែង តែគ្មានកន្លែងកំសាន្ត គ្មានសួនច្បារ ទេ គឺមានតែសួនបន្លែនៅកន្លែងណាដែលពួកគេរស់នៅតែប៉ុណ្ណោះ ។

**១.២.ស្ថានភាពសង្គមកិច្ច**(បំរែបំរួល និងស្ថានភាពប្រជាជន)

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រជាជនដែលសេសសល់ពីរបបប៉ុលពត បានត្រលប់ចូលមកស្នាក់នៅ គិតទាំងប្រជាជនដែលធ្លាប់រស់នៅទីក្រុងភ្នំពេញ និងខេត្តនានា ។ ប្រជាជនមកពីគ្រប់ទិសទាំង ៤ ដែលពីមួយថ្ងៃទៅមួយថ្ងៃបានកើនឡើងយ៉ាងឆាប់រហ័ស ហើយមានគ្រប់ប្រភេទជនជាតិ ។ អាស្រ័យហេតុនេះបំរែបំរួល និងចលនាចេញចូលរបស់ប្រជាជននៅរដ្ឋធានីភ្នំពេញមានការវិវត្តខ្ពស់ និងមានភាពស្មុកស្មាញ ដែលនៅក្នុងនោះមានតែ អ្នកធ្វើការរដ្ឋរស់នៅតាមផ្ទះនានាដែលស្ថិតនៅក្បែរផ្លូវធំៗ ។ ប្រហែលមួយឆ្នាំក្រោយមក ទើប មានប្រជាជនដែលជាប្រពន្ធ កូនរបស់អ្នកធ្វើការរដ្ឋចូលមករស់នៅក្នុងទីក្រុង ដែលនៅមិន ទាន់មានផ្សារត្រឹមត្រូវនោះឡើយ ។ របស់របរហូបចុក និងរបស់ប្រើប្រាស់ប្រចាំថ្ងៃត្រូវបានគេ ទិញដូរគ្នាដោយប្រើអង្ករ ឬមាសជំនួសក្រដាស់ប្រាក់រៀល ដែលមិនទានមានសម្រាប់ចាយ វាយ។ នៅពេលនោះអ្នកធ្វើការរដ្ឋគ្មានប្រាក់ខែទេ គឺមានតែរបបឧបត្ថម្ភជាអង្ករ ស្រូវសឡី ឬ គ្រាប់ពោត និងរបស់របរខ្លះទៀត ដូចជាម្ហូបកំប៉ុង សាប៊ូ ប្រេងកាត ក្រណាត់ ជាដើម ។ ជីវភាពអ្នកទីក្រុងចាប់ផ្តើមមានសកម្មភាពជាបណ្តើរៗឡើងវិញចាប់ពីដើមឆ្នាំ ១៩៨០ រហូតមក ។ ហើយក្រដាស់ប្រាក់រៀលថ្មីត្រូវបានដាក់ឲ្យធ្វើចរាចរណ៍នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដោយមានប្រភេទជាកាក់ និងជាក្រដាស់រៀលនៅលើទីផ្សារក្នុងក្រុងភ្នំពេញ ។

**១.៣. ហេដ្ឋារចនាសម្ព័ន្ធនៅសម័យប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា**

**ក.ហេដ្ឋារចនាសម្ព័ន្ធនៅសម័យប្រជាមានិតកម្ពុជា**

យើងឃើញថា ក្រោពីឆ្នាំ១៩៧៩ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទីក្រុងភ្នំពេញ ជាពិសេសគឺផ្លូវថ្នល់ គឺមិនមានការកសាងអ្វីជាដុំកំភួននោះទេ ក្រៅពីផ្លូវថ្នល់ដែលមានស្រាប់ ដែលបានកសាងនៅមុនសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ លើសពីនេះទៅទៀត ផ្លូវថ្នល់ ទាំងអស់នោះទៀតសោធក៏ត្រូវបានខូចខ្ទាំអស់ទៅទៀត ដោយសារតែសង្គ្រាមនៅក្នុងរបប នោះ ។ មួយឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៨០ ទើបយើងឃើញថា ផ្លូវថ្នល់នៅក្នុងទីក្រុងភ្នំពេញ ត្រូវបានជួសជុល នឹងកសាងបន្ថែម ដោយហេតុថា នៅពេលចប់សង្គ្រាមនៅក្នុងឆ្នាំ ១៩៧៩ ប្រជាជនដែលត្រូវបានជំលៀសពីទីក្រុងភ្នំពេញទៅតាមបណ្តាលខេត្តនានានៅក្នុងសម័យ កម្ពុជាប្រជាធិបតេយ្យ បានធ្វើដំណើរចូលមកកាន់ទីក្រុងភ្នំពេញវិញក្រោយថ្ងៃរំដោះ ០៧ មករា ឆ្នាំ១៩៧៩ ដោយឥតឈប់ឈរ ហើយមធ្យោបាយដែលប្រជាជនធ្វើដំណើរនៅពេល នោះគឺមានតែ

រទេះសេះ កង់ឌុប រ៉ឺម៉ក់ប៉ុណ្ណោះ ដែលធ្វើចរាចរណ៍នៅតាមវិថីនានា ដែលត្រូវ ខូចខាតដោយអន្លើ ក្រោយមកទៀត ពីមួយឆ្នាំទៅមួយឆ្នាំ ទើបទីក្រុងភ្នំពេញមានការ អភិវឌ្ឍន៍បន្តិចម្តងៗ ដោយប្រែក្លាយ មធ្យោបាយធ្វើដំណើរដោយរ៉ឺម៉ក់ម៉ូតូ ស៊ីក្លូ រថយន្ត រត់ ខ្វាត់ខ្វែងលើទ្រូវផ្លូវដែលគ្មានគំនូសចរាចរណ៍ គ្មានភ្លើងស្តុប តែមានប៉ូលីសចរាចរណ៍នៅ តាមផ្លូវកន្លែងកែង ដែលពេលនោះមានកាកក់ស្ទះម្តងម្កាល ។ លើសពីនេះទៅទៀត បើតាមលទ្ធផលនៃការអង្កេត ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ១៩៨៩ របស់មន្ទីរ គមនាគមន៍ បានបង្ហាញឲ្យដឹងថា ផ្លូវនៅក្នុងរដ្ឋធានីភ្នំពេញនៅសម័យនោះមានប្រវែង ៤៧០ គ.ម ដោយ ក្នុងនោះត្រូវបានចែកចេញជា ផ្លូវក្រាលថ្ម និងចាក់កៅស៊ូ និងផ្លូវក្រាលគ្រួសក្រហម ។ ដោយ ផ្លូវក្រាលថ្ម នឹងចាក់កៅស៊ូមានប្រវែង ១៧០ គ.ម ដែលក្នុងនោះមានមហាវិថីសហភាពសូវៀត ដែលផ្លូវនេះមាន ចំណុចខ្វះខាត នឹងបាក់ស្រុត ហើយរបើកកៅស៊ូ ដែរតំរូវឲ្យមានការជួសជុល នឹងថែទាំ ។ ចំណែកផ្លូវទូ សាមុត, ផ្លូវស៊ីងម៉ុកម៉ីង , ផ្លូវស៊ីរុត្តា , ផ្លូវហ្សីជីមិញ និងផ្លូវលេនីន ដែលផ្លូវទាំងនេះពិនិត្យសភាពក្រៅឃើញ គ្រាន់បើ តែងាប់ជាតិកៅស៊ូច្រើន នឹងខូចប្រេះស្រាំ ច្រើន ដែលទៀមទារឲ្យមានការថែទាំ ហើយផ្លូវក្រៅពី នេះ គឺខូចខាតប្រេះស្រាំ ច្រើនមានទឹក ដក់ នឹងស្រុត[85]។ រីឯផ្លូវក្រាលគ្រួសក្រហមមានប្រវែង ៣០០ គ.ម គឺជាប្រភេទផ្លូវតូចៗ ហើយផ្លូវនេះត្រូវទទួលរងការខូចខាតជាច្រើនកន្លែង នឹងមានព្រៃដុះ ស្មៅ ថែមទាំង មានរណ្តៅ ក្រហូង ហើយជាពិសេសគឺផ្លូវនេះត្រូវទទួលរងការខូចខាតខ្លាំងនៅរដូវវស្សា ។

**គ.១.ប្រព័ន្ធប្រឡាយបង្ហូរទឹក**

នៅសម័យនោះប្រព័ន្ធប្រឡាយបង្ហូរទឹក ទៅស្ថានីយបូមទឹកមានទាំងអស់ប្រវែង ៣១៨ គ.ម ដែល នៅក្នុងនោះមានដូចជា:

-ប្រឡាយបឹងត្របែក

-ប្រឡាយទួលសាន

-ប្រឡាយបឹងសាឡាង

-ប្រឡាយទឹកល្អក់ ព្រមទាំងមានប្រឡាយតូចៗ ជាច្រើនទៀត ដូចជា ប្រឡាយផ្សារ ដើមថ្កូវ , ប្រឡាយទួលស្វាយព្រៃ នឹងទួលគោកជាដើម ។ ហើយចំពោះប្រឡាយបឹងត្របែក , ប្រឡាយទួលសាន , ប្រឡាយទឹកល្អក់ ដែលជាប្រភពបង្ហូរទឹកដ៏សំខាន់ ត្រូវបានគោកដោយ សារតែបរិមាណភក់មានកំរាស់ រហូតទៅដល់ ២.០០០ម$^{3}$ ដែលត្រូវកាយយកភក់នោះចេញ ជាបន្ទាន់ ដើម្បីឲ្យប្រឡាយទាំងនោះមាន

[85] របាយការណ៍របស់សាលាក្រុងចំពោះលទ្ធផលនៃការអង្កេត ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ១៩៨៩ របស់មន្ទីគមនាគមន៍

ដំណើរការបាន ។ ចំពោះប្រឡាយតូចៗ វិញត្រូវគោកស្ទើរតែទាំងអស់ ដូចជា ប្រឡាយម៉ុទូលគោក ជាដើមក្រោយពីបានកាប់ព្រៃភ្លារ នៅឆ្នាំ១៩៨០ រហូតដល់ឆ្នាំ ១៩៨៣ ត្រូវបានគោកទាំងអស់។

**ក.២. អណ្តូងលូ**

ចំណែកឯអណ្តូងលូក្រោយថ្ងៃរំដោះមានចំនួន ៤៧០០ អណ្តូង ហើយអណ្តូងលូងប្រមាណ ៣០០០ អណ្តូងត្រូវបានស្ទះ ដោយសារតែមានកាក់សំណល់ជាច្រើនដែលជាហេតុ បណ្តាលឲ្យទឹកហូរចូលលូរមិនទាន់ ដូច្នេះហើយទើមានការរៀបចំជួសជុល នឹងកសាងនូវ គំរបលូបានចំនួន ១ភាគ ៣ នឹងនៅសល់ ២ ភាគ ៣ ទៀតដែលគ្មានគំរបលូ ។

**ក.៣. ទំនប់នៅក្នុងរាជធានីភ្នំពេញ**

ទំនប់នៅក្នុងរាជធានីនាសម័យនោះ មានប្រវែង៩៦ គ.ម ដែលកសាងឡើងដើម្បីការពារទីក្រុងភ្នំពេញកុំឲ្យមានទឹកជំនន់ហូរចូលមកក្នុងក្រុង ហើយដែលទំនប់ទាំងអស់នោះ ក៏សាងឡើងចែកចេញជាទំនប់នៅក្នុងក្រុង នឹងទំនប់នៅក្រៅក្រុង ចំពោះទំនប់នៅក្នុងក្រុងមាន ប្រវែង៣២ គ.ម នឹងទំនប់នៅក្រៅក្រុងមានប្រវែង ៦៤ គ.ម ។

**ក.៤. ស្ថានីយ៍បូមទឹក**

ស្ថានីយបូមទឹកនៅសម័យនោះមាន ៤ស្ថានីយ និងមានម៉ាស៊ីន និងម៉ូទ័រអគ្គីសនីចំនួន ១៨ គ្រឿងសម្រាប់ធ្វើការបូមទឹកចេញពីក្នុងក្រុង ហើយស្ថានីយទាំង ០៤ នោះមានដូចជា:

-ស្ថានីយបូមទឹកបឹងត្របែក: មានម៉ូទ័រប្រើអគ្គីសនី ចំនួន ០៨ គ្រឿង ដែលមានកំលាំង ៨០ គ.វ/ ១ គ្រឿង ដែលអាចបូមទឹកចេញបាន ២.៣៤០ ម៣/ ១ម៉ោង /១គ្រឿង ។

-ស្ថានីយបូមទឹកបឹងទំពុន: មានម៉ូទ័រប្រើអគ្គីសនីចំនួន ០៤ គ្រឿង មានកំលាំង ៩២ គ.វ/១ គ្រឿង ដែលអាចបូមទឹកចេញបាន ២.៥០០ ម៣/ ១ ម៉ោង/១ គ្រឿង នឹងម៉ាស៊ីនប្រើ ប្រេងម៉ាស៊ូតចំនួន ០៤ គ្រឿង មានកំលាំង ១០៤ សេះ/ ១គ្រឿង អាចប៉ូមទឹកចេញបាន ២.៥០០ម៣/១ម៉ោង/១គ្រឿង ។

-ស្ថានីយបូមទឹកទួលគោកទី ១៖ មានម៉ាស៊ីនប្រើប្រេងម៉ាស៊ូតចំនួន ០១ គ្រឿង មាន កំលាំង ១០៤ សេះ/ ១គ្រឿង អាចប៉ូមទឹកចេញបាន ២.៥០០ម៣/១ម៉ោង/១គ្រឿង ។

-ស្ថានីយបូមទឹកទួលគោកទី ២៖ មានម៉ាស៊ីនប្រើប្រេងម៉ាស៊ូតចំនួន ០១ គ្រឿង មាន កំលាំង ១០៤ សេះ/ ១គ្រឿង អាចប៉ូមទឹកចេញបាន ២.៥០០ម៣/១ម៉ោង/១គ្រឿង ។

**ក.៥. សួនច្បារក្នុងរដ្ឋធានីភ្នំពេញ**

សួនច្បារក្នុងរដ្ឋធានីភ្នំពេញដែលបានកសាងឡើង មុនឆ្នាំ១៩៧៥ មានទំហំផ្ទៃដី ៩៦.៥ ហិចតា ដែលមានសួនច្បារអតីតបូរីទាហ៊ាន, សួនច្បារបរិវេណមហាវិទ្យាល័យមិត្តភាពកម្ពុជា សូវៀត , សួនច្បារ បុរីកីឡា,សួនច្បារស្តាតអូឡាំពិក, សួនច្បារចេនឡា, សួនច្បារក្រុង, សួន ច្បារវិមានឯករាជ្យ, សួនច្បារមុខ វត្តបុទុម, សួនច្បារមាត់ទន្លេចតុមុខ, សួនច្បារមុខវាំង, សួនច្បារមហោស្រពទន្លេបាសាក់, សួនច្បារសន្និ សិទ្ធចតុមុខ, សួនច្បារសណ្ឋាគារសាមគ្គី, សួនច្បារវត្តភ្នំ, សួនច្បារមុខសត្យមនុចេតិយ, សួនច្បារវិមានរ ដ្ឋាភិបាល, សួនច្បារក្បាល ជ្រោយចង្វារ ។ ហើយបន្ទាប់មកទៀតនៅឆ្នាំ១៩៨៣ យើងបានធ្វើការស្តារ និងកែលំអរសួនទាំង នោះបាន ២២ ហិចតា ដែលក្នុងនោះមានសួនជើងគោ, សួនបណ្តោយមហាវិថីសហ ព័ន្ធរុស្ស៊ី,សួនច្បារវិមានឯករាជ្យ, សួនច្បារមុខវត្តបុទុម, សួនច្បារមុខវាំង,សួនច្បារមុខសត្យមនុចេតិយ, សួនច្បារក្បាលជ្រោយចង្វារ ។ ហើយនៅក្នុងឆ្នាំបន្ទាប់មកទៀតយើងបានបន្តកែលំអសួន មុខវាំង, សួន មាត់ទន្លេ, និងសួនវិមានឯករាជ្យ.។

## ២. ស្ថានភាពសង្គមកិច្ចនៅសម័យសាធារណរដ្ឋប្រជាមានិត និងរដ្ឋកម្ពុជា

### ២.១. បំរែបំរួល និងស្ថានភាពប្រជាជន

ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រជាជនដែលត្រូវសេសសល់ពីរបបប៉ុល ពត បានត្រឡប់ ចូលមកស្នាក់នៅ គិតទាំងប្រជាជនដែលធ្លាប់រស់នៅទីក្រុងភ្នំពេញ និងខេត្ត នានា ។ ប្រជាជនគ្រប់ទិស ទាំង ៤ ដែលពីមួយថ្ងៃទៅមួយថ្ងៃបានកើនឡើងយ៉ាងឆាប់រហ័យ ហើយមានគ្រប់ជនជាតិ។ អាស្រ័យ ហេតុនេះបំរែបំរួល និងចលនាចេញចូលរបស់ប្រជាជននៅ រាជធានីភ្នំពេញមានការវិវត្តខ្ពស់ និងមានភាព ស្មុកស្មាញបង្គួរ ។

បុគ្គលិកកម្មករ និងកម្មាភិបាល បានប្រមូលផ្តុំរស់នៅទីក្រុងស្រូបបានប្រមាណ ៥០% នៃចំនួន បរិមាណ បុគ្គលិកកម្មករ និងកម្មាភិបាលសរុបទូទាំងប្រទេស ។ បើសិនជារាប់ អ្នកដែលអ្នកដែលនៅក្នុង បន្ទុក គ្រួសារ គឺកំណើននេះមានខ្ពស់ប្រហែល ៦០% នៃចំនួនប្រជា ជនសរុបនៅភ្នំពេញ ក្នុងនោះបើ និយាយតែក្នុងក្រុង មានរហូតដល់ ៨០% ។

គិតក្រោយជំហ៊ានរៀបចំស្ថិតិ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ១៩៨០ រហូតមកដល់ឆ្នាំ ១៩៨៩ សន្ទុះរីកចំ រើនក្នុងរយ:ពេល ០៣ ឆ្នាំ គឺ ១២២,៩៩% គិតជាមធ្យមភាគឃើញថា កើន ឡើង ៧.១០% ជារៀងរាល់ ឆ្នាំ។ ចំនួនមនុស្សដែលកើនឡើងបន្ថែមមានច្រើនប្រភពផ្សេង ៗ ពីគ្នា ក្នុងនោះមានជនខ្លះត្រឡប់មកពី ទឹកដី នៃអាណាខេត្តនៅវៀតណាមភាគខាងត្បូង , ខេត្ត នានា និងខ្លះទៀតមកពីទឹកដីថៃ ដែលក្នុងសម័យ កាលនៃរបបមុន ។ បានធ្វើឲ្យគេរត់គេច ដោយការភ័យខ្លាច ហើយបច្ចុប្បន្ននេះបានវិលត្រឡប់មកវិញ ។

ជនខ្លះនៅតាមខេត្តនានា បានចូលមករស់នៅរកស៊ីតាមបណ្តាលសង្កាត់ ក្នុងក្រុងនិងជាយក្រុងដែលមិនទាន់មានគ្រប់ គ្រាន់នូវសំណុំរឿងស្ថិតិគ្រួសារ និងមិនទាន់ស្រប់ច្បាប់ ។

ផុសចេញពីសភាពការណ៍ប្រែប្រួលប្រជាជនដែលបានពោលខាងលើបានកើតឡើងនូវច្រើបញ្ហាស្មុកស្មាញដោយមានការលំបាក់ច្រើនយ៉ាង ជះឥទ្ធិ ពលដល់ការគ្រប់គ្រង, ចាត់តាំង, សន្តិសុខរបៀបរាបរយផលិតកម្ម អាជីវកម្ម និងការកែប្រែ ជីវភាពរស់នៅរបស់ប្រជាជនក្នុងទូទាំងរដ្ឋធានីភ្នំពេញ ។

អនុវត្តតាមសេចក្តីសម្រេចរបស់ក្រមប្រឹក្សារដ្ឋមន្ត្រី, រដ្ឋធានីភ្នំពេញបានធ្វើ អង្កេតធំ ០២ លើក គឺលើកទី ០១ អង្កេតគ្រប់សមាសភាពប្រជាជន ចាប់ផ្តើមពីខែ ០៨ ឆ្នាំ ១៩៨០ និង អង្កេតលើកទី ០២ ធ្វើនៅក្នុងសង្កាត់ ០៤ គឺប្រជាសាស្ត្រ ដើម្បីអាត្រាកំណើន, ស្លាប់, អត្រាកំណើនយន្តសាស្ត្រ, អត្រាកំណើនទូទៅ និងផ្សេងទៀត គឺ ក្នុងឆ្នាំ ១៩៨៣ ។

## ២.២. ប្រព័ន្ធអប់រំ

យើងឃើញថា ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាស្ទើតែគ្មាន ទាំងអស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយមេដឹកនាំនៅសម័យនោះ បានយកអ្នក ដែលចេះដឹងទាំងអស់ទៅសម្លាប់ចោល ដើម្បីកុំឲ្យមានការរើបំរាស់ ។ ម្យ៉ាងទៀត នៅសម័យនោះក្មេងៗមិនត្រូវឲ្យបានសិក្សា និងអប់រំនោះទេ បែជាឲ្យក្មេងៗទៅធ្វើពលកម្ម ដោយហេតុនេះទើបនៅសម័យនោះ សាលារៀនគឺមិនត្រូវបានកសាងអ្វីឡើយសាលារៀនដែលបានកសាងនៅមុនសម័យនេះទៀតសោត បែរជាយកទៅជាកន្លែងធ្វើទារុណ កម្ម និង សំលាប់មនុស្សទៅវិញ ។ ប៉ុន្តែក្រោយពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ រហូតមក មួយឆ្នាំបន្ទាប់មកទៀត យើងសង្កេតឃើញថា ប្រព័ន្ធអប់រំនៅកម្ពុជាបានចចាប់ផ្តើមសាជាថ្មី មានសិស្សជាច្រើនបានចូលសិក្សានៅតាមសាលានៅក្នុងរាជធានីភ្នំពេញ ជាច្រើនយ៉ាងកំហុក ហើយចំណែកឯសាលារៀនវិញក៏ត្រូវបានរីកដុះដាល់ចាប់ពីពេលនោះមក។ បើយោង ទៅតាមការអង្កេតរបស់មន្ទីអប់រំ បានបង្ហាញទិន្ន័យចំនួនសិស្ស ហើយថ្នាក់រៀនឲ្យយើងដឹងថា នៅសម័យនោះចំនួនសាលាសរុបនៅក្នុងរាជធានីទាំងអស់មានចំនួន ៦៥ នៅក្នុងនោះមានចំនួនថ្នាក់រៀនសរុប ២១១៧ ថ្នាក់ ហើយចំនួនគ្រូបង្រៀនសរុបមាន ២៩៩៣ នាក់ និងមានសិស្សសរុបស្មើនឹង ៧៨១៨៣ នាក់ ។ ចំណែកឯសាលាមត្តេយ្យវិញយើងឃើញថា ក៏មានការកើនឡើយដូចគ្នាផងដែរ ដោយនៅសម័យនោះ ចំនួនសាលាមត្តេយ្យសរុបមានចំ នួន ២៤ និងមានថ្នាក់រៀនចំនួន ៨៧ ថ្នាក់ និងមានចំនួនសិស្សរសុប ៣០៧០ នាក់ នឹងមាន ចំនួនបុគ្គលិកសរុបស្មើនឹង ១៤៣ នាក់ ។ ដែលតួរលេខនេះបង្ហាញឲ្យឃើញឃើញថា ប្រព័នអប់រំនៅកម្ពុជាចាប់ពីសម័យនោះមកមានការកើនឡើងដោយយើងមិនទាន់បានរាប់នូវសាលារៀននៅតាមបណ្តាលខេត្តនានាទៀតផង ។

### ២.៣. ប្រព័ន្ធសុខាភិបាល

យើងឃើញថា វិស័យសុខាភិបាលនៅសម័យនោះមិនសូវជាមានការរីកចំរើនណាស់ ណានោះទេ ដោយសារតែធនធានមនុស្សត្រូវបានបាត់បង់ស្ទើតែទាំងស្រុង នៅក្នុងសម័យ កម្ពុជាប្រជាធិបតេយ្យ ដោយហេតុនេះដើម្បីឲ្យវិស័យនេះមានការកើនឡើងឡើងវិញ គឺ ត្រូវទាមទារពេលវេលា ដើម្បីធ្វើការអភិវឌ្ឍន៍វិស័យនេះឡើងវិញ ។ ដូច្នេះហើយ វិស័យសុខាភិបាលនាសម័យកាលនេះមិនសូវមានការីកចំរើនខ្លាំងក្លានោះទេ ដោយតាមតួរលេខរបស់មន្ទី សុខាភិបាល និងសង្គមកិច្ច បានបង្ហាញឲ្យឃើញថា ៖ ចំនួនមន្ទីពេទ្យនាសម័យនោះមានត្រឹម តែចំនួន ០១ តែប៉ុន្នោះ ចំណែកឯបន្ទប់ពិនិត្យជម្ងឺក្រៅមន្ទីពេទ្យមានចំនួន ២៦ បន្ទប់ នឹងមាន ឪសថាល័យមានចំនួន ៦ កន្លែង មានគិលានដ្ឋានចំនួន ១៨ កន្លែង មន្ទីសម្ភព មានចំនួន ០១ ចំណែកចំនួនគ្រែសរុបវិញមានចំនួន ៣៤០ គ្រែ។

## ជំពូកទី ២ ការអភិវឌ្ឍន៍ និង ការកែលំអរទីក្រុងសោភ័ណ្ឌភាពទីក្រុង

### ១.ការរៀបចំក្រុងតាមបែបយុគសម័យទំនើប

#### ក.សោភ័ណភាពរាជធានីភ្នំពេញ និងការប្រែមុខមាត់ថ្មី

ការស្តារការថែរក្សា និងការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុងភ្នំពេញ ចាប់ពីក្រោយពេលមានការបង្រួបបង្រួមជាតិ១៩៩១ មកពុំសូវមានសកម្មភាពទេធ្វើឲ្យអ្វីៗ ដែលមានពីមុនមកត្រូវ ទទួលរងនូវការខូចខាត និងចេះតែទ្រុឌទ្រោមទៅៗ និងធ្វើឲ្យភ្នំពេញ លែងដូចជាទីក្រុងដែលជាបេះដូង របស់ប្រទេស ។

នៅពេលយប់ វិថីក៏ដូចមហាវិថី ដែលពោរពេញទៅដោយចរាចរណ៍សែនអនាធិតេយ្យ និងមានធូលីហុយឡើងងងឹតមេឃនៅរដូវប្រាំងនោះ ពុំមានភ្លើង អគ្គីសបំភ្លឺ ពុំមានភ្លើស្តុបនៅតាមផ្លូវត្រឡែង កែងឡើយហើយនៅរដូវវស្សា ត្រូវទឹកលិចដក់ត្រាំជាច្រើនថ្ងៃដោយសារលូទឹកស្អុយកកស្ទះ បណ្តាល ឲ្យផ្លូវត្រូវខូចខាតជាច្រើនកន្លែង ។

រមណីយដ្ឋាន សួនច្បារសាធារណៈ ដែលជាទីលំហែកាយ របស់សាធារណៈជនបានក្លាយជាកន្លែចាក់សំរាម និងជាជម្រកស្នាក់នៅបណ្តោះអាសន្ន របស់ជនឪកាសនិយម[86] ។ បន្ទាប់ពីការបោះឆ្នោត ១៩៩៣ រួចមក ការរៀបចំទីក្រុងឡើងវិញ ការប្រឹងប្រែង នាពេលនោះពុំសូវទទួលបានលទ្ធផលល្អទេ

[86]ឪកាសនិយម គឺ មានន័យថា ជនដែលចូលមកគោលចំណាង កាន់កាប់ យកជារបស់ខ្លួនក្នុងស្ថានភាពណាមួយ

ដោយសារតែសភាពការណ៍សន្តិសុខ នយោបាយផ្ទៃក្នុងនៃរដ្ឋាភិបាលចម្រុះអាណត្តិតទី១ ពុំសូវអនុគ្រោះឲ្យ ។

ភាពទ្រុឌទ្រោមនៃហេដ្ឋានរចនាសម្ព័ន្ធ ទីក្រុងភ្នំពេញ ត្រូវបានរៀបចំគម្រោងការស្តារឡើងវិញក្នុងប៉ុន្មានសប្តាហ៍បន្ទាប់ពី ព្រឹត្តិការណ៍ថ្ងៃទី ៥-៦ កក្កដា ១៩៩៧ ដោយអាជ្ញាធរក្រុងភ្នំពេញ គម្រោងការស្តារឡើងវិញនូវ ហេដ្ឋានរចនាសម្ព័ន្ធក្រុងភ្នំពេញ ត្រូវបានលើកយកមកពិភាក្សា នៅក្នុង សន្និបាតការងារស្តារហេដ្ឋានរចនាសម្ព័ន្ធរាជធានីភ្នំពេញនៅព្រឹកថ្ងៃទី ១៥ តុលា ឆ្នាំ១៩៩៧ ។ យុទ្ធនា ការបូមស្តារប្រឡាយ លូទឹក ស្អុយ នៅក្រុងភ្នំពេញ បានចាប់ផ្តើមនៅស្ទើរគ្រប់ទីកន្លែង ក្នុងទីក្រុងដោយអាជ្ញាធរខ័ណ្ឌជាអ្នកដឹកនាំធ្វើ ក្រុងជាអ្នកដឹកនាំធ្វើ ក្រុងជាអ្នកចេញលុយ សង្កាត់ជាអ្នកទទួលខុសត្រូវ បន្ទាប់ពីលូទាំងនោះស្តាររួចមិនត្រូវឲ្យមានកកស្ទះ ម្តងទៀតទេ បើមានត្រូវធ្វើដោយខ្លួនឯង ។

ក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ផ្លូវសំខាន់ៗ មួយចំនួនត្រូវបានធ្វើរួចហើយ បានបំពាក់ទៅដោយបង្គោលភ្លើងស្តុបថ្មី តាមបែបទីក្រុងរបស់ប្រទេសជឿនលឿន មានគំនូសបែងចែកចរាចរណ៍ មានភ្លើង ពណ៌ លឿងព្រឿង បំភ្លឺពេលយប់នៅលើផ្លូវដែល ធ្លាប់តែងងឹតសូន្យ និងភ័យខ្លាចពីមុនមក ។ សួនច្បារសាធារណៈ មានស្មៅ មានផ្កាស្រស់បំព្រង គ្មានក្លិនស្អុយ និងភាពងងឹត គួរឲ្យខ្លាចដូចមុនទៀតឡើយ ។

ប្រឡាយទឹក និងលូទឹកស្អុយដែលបានស្តាររួច ហើយដែល ៨០ភាគរយ សាលាក្រុងអាចធានាបានហើយប៉ុន្តែ នៅតំបន់មួយចំនួនអាចនៅមាន ការលិចលង់ទៀត តែលិចមិនយូរទេ ហើយសាលាក្រុងនៅតែ បារម្ភថាកន្លែងខ្លះ ដែលគេបានយកសំរាមទៅចាក់ចូលលូ ឬក៏លូណាមួយបាក់ហើយ សាលាក្រុងមិនបានដឹង នោះក៏អាចនាំឲ្យមានការលិចលង់ទៅទៀតដែរ ។ បន្ទាប់ពីលូ និងប្រឡាយត្រូវស្តាររួច ផ្លូវនៅក្នុងក្រុង ចំនួន ២៣ ខ្សែស្មើនិង ២៩ គីឡូម៉ែត្រត្រូវបានធ្វើរួចរាល់ក្នុងរយៈ ពេលមួយយ៉ាងខ្លី ។បញ្ហាចរាចរណ៍នៅក្នុងទីក្រុងភ្នំពេញ ត្រូវបានទទួលស្គាល់វាថាជាការពិតគឺ វាស្មុគស្មាញ មែនតែ ឥឡូវ យើងបានធូរស្រាលជាងមុនហើយបន្ទាប់ពីផ្លូវសំខាន់ៗ មួយចំនួនបានធ្វើរួច និងដាក់ឲ្យមានភ្លើង បំភ្លឺ ពេលយប់ ដាក់ភ្លើងស្តុប និងរៀបចំគំនូសចរាចរណ៍ នៅលើទ្រូងផ្លូវមួយចំនួនមក ។ សាលាក្រុង បានរៀបចំភ្លើងស្តុប ចំនួន ៣៧ កន្លែង និងបង្គោលភ្លើងថ្មីនៅតាមមហាវិថីកម្ពុជាក្រោម ព្រះមុន្នីវង្ស ផ្លូវ ជាតិលេខ២ វិថីសុធារស និងនៅតាមសួនច្បារសាធារណៈជាច្រើន ។ ការដាក់ភ្លើងបំភ្លឺផ្លូវនេះ វាបានសម្រួលដល់ការធ្វើចរាចរណ៍ នៅពេលយប់ជាការលំអរទីក្រុង និងកាត់បន្ថយបាននូវបទល្មើសផ្សេងៗ មួយចំនួនផងដែរ ។ក្នុងឆ្នាំ២០០១ ក្រោមទិសដៅយុទ្ធសាស្ត្ររបស់សាលាក្រុងភ្នំពេញ គេបានបើកយុទ្ធនាការអភិវឌ្ឍន៍និងលំអរ

សោភ័ណ្ឌភាពទីក្រុង បន្ថែមទៀត ដែលជាចំនុចមួយបង្ហាញឲ្យ ឃើញពីភាពរីក ចំរើនរបស់ រាជធានីភ្នំពេញ ។

## ខ.ការរៀបចំក្រុងត្រូវគោរពទៅតាមច្បាប់នគរូបនីយកម្ម

នៅក្នុងប្រទេសនីមួយៗតែងតែមានច្បាប់ សំរាប់គ្រប់គ្រងប្រទេស ដូចគ្នានេះ ប្រទេសកម្ពុជាយើងក៏ដូច្នេះដែរ ការធ្វើការរៀបចំក្រុង ត្រូវគោរពទៅតាមច្បាប់នគរូបនីយកម្ម ពោលគឺ ធ្វើយ៉ាងណាដើម្បីឲ្យក្រុងភ្នំពេញ មើលទៅមានរបៀបរៀបរយ និងមានសណ្តាប់ធ្នាប់ជាពិសេសគឺត្រូវ គោរពទៅតាម ប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី និង សំណង់ និង លិខិតអនុញ្ញាតិសាងសង់ ។

### ខ.១.ប្លង់គោល

ប្លង់គោលត្រូវបានគេចាត់ទុកថាជា ប្លង់គ្រឹះ សំរាប់រៀបចំដែនដីនៃក្រុងនីមួយៗ ពីព្រោះថាប្លង់គោល នេះជាអ្នកតំរង់ទិស ក្នុងការបែងចែក ។ រឺកំណត់ផ្ទៃដីសំរាប់តំបន់សំណង់ តំបន់ទេសចរណ៍ តំបន់ឧស្សាហ៍កម្ម តំបន់សណ្ឋាគារ កន្លែងសួនសាធារណៈ តំបនើសំរាប់ចាក់សំរាម តំបន់ដែលត្រូវ ការពារ តំបន់ដែលត្រូវអភិវឌ្ឍន៍។ល។ ប្លង់គោលជាទូទៅ គឺគេចែងអំពីទស្សនៈវិស័យ នៃការអភិវឌ្ឍន៍ដីធ្លី នៅក្នុងតំបន់ខេត្ត រឺក្រុង តែប៉ុណ្ណោះ ។ រាល់ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ និងលិខិតអនុញ្ញាតិសាងសង់ ត្រូវគោរពទៅ តាមប្លង់គោលជានិច្ច ។

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពុំទាន់ឃើញមានការឲ្យនិយមន័យណាមួយជាក់ លាក់ទៅលើប្លង់គោលនេះ ប៉ុន្តែប្លង់នេះត្រូវបានយកមកប្រើប្រាស់ នៅក្នុងច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ឆ្នាំ១៩៩៤ នៅត្រង់មាត្រា ៥ ដែលបានចែងថា គណកម្មា ធិការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់រាជធានីភ្នំពេញ រឺអនុគណកម្មាធិការរៀបចំទឹកដី និង សំណង់ ខេត្ត ក្រុង នីមួយៗត្រូវគូសប្លង់គោល ដើម្បីធ្វើការរៀបចំ និងអភិវឌ្ឍន៍នៃ ខេត្តក្រុង របស់ខ្លួនហើយការរៀបចំប្លង់គោលនេះទៀតសោតត្រូវមានការយល់ព្រមពីគណកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និងត្រូវកំណត់ដោយអនុក្រិត្យ[87]។ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ មានភារៈរៀបចំប្លង់គោលសំរាប់តំបន់ពិសេសណាដាក់ជូនគណៈរដ្ឋមន្ត្រីអនុមត័ ដោយតំបន់ពិសេសនោះត្រូវបានកំណត់ដោយគណៈរដ្ឋមន្ត្រី ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាននិងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ចំពោះរាជធានីភ្នំពេញ ការរៀបចំប្លង់គោល ត្រូវបង្កើតគណកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់សំរាប់ក្រុងភ្នំពេញ ហើយគណកម្មាធិការនេះ ត្រូវដឹកនាំដោយប្រធានគណកម្មាធិការជាតិរៀបចំ

[87]ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ចុះថ្ងៃទី ១០ សីហា ១៩៩៤ នៅត្រង់មាត្រា ៥

ទឹកដី នគរូបនីយកម្មនិងសំណង់ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំក្រុងភ្នំពេញ ឬអភិបាល អភិបាលរង ព្រម ទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជា សមាជិកផង។ នៅក្នុងខេត្តក្រុងនីមួយៗ ត្រូវ បង្កើត អនុគណកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ដែលដឹកនាំដោយអភិបាលខេត្ត ក្រុង និងអង្គភាពបច្ចេកទេសខេត្តក្រុងដែលមានសមត្ថកិច្ចចូលរួមជាសមាជិក[88]។ ជាទូទៅប្លង់គោលនេះមិន ត្រូវបានប្រជាពលរដ្ឋយកមកធ្វើជាកម្មវត្ថុនៃបណ្ដឹង តាមផ្លូវច្បាប់បានឡើយ ពីព្រោះប្លង់គោលចែងតែអំពី ទស្សនៈវិស័យ នៃការអភិវឌ្ឍន៍ដីធ្លី នៅក្នុង តំបន់ដែលត្រូវរៀបចំតែប៉ុណ្ណោះ ដូច្នេះភ្នាក់ងាររដ្ឋបាលដែល មានសមត្ថកិច្ច ត្រូវធ្វើការពិនិត្យទៅលើ អត្ថន័យនៃប្លង់គោលជាមុនសិន មុននិងធ្វើការរៀបចំប្លង់ប្រើ ប្រាស់ដីធ្លី និងសំណង់តំបន់ណាមួយ ។

### ខ.២.ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់

ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ គឺជាប្លង់មួយដែលដើរតួនាទីសំខាន់ មួយដែរនៅការរៀបចំក្រុង ឲ្យ មានសណ្ដាប់ធ្នាប់ និងពោរពេញទៅដោយសោភ័ណភាព ហើយមានលក្ខណៈត្រឹមត្រូវ តាមច្បាប់ នគរូប នីណកម្ម ។ ប្លង់នេះមានចែងអំពី កំពស់សំណង់ គំលាតសំណង់ ជួររត់តំរង់នៃសំណង់ ក្នុងគោលបំណង ជួយកែលំអរ សោភ័ណភាពទីក្រុង ឲ្យកាន់តែប្រសើរឡើង ។ រាល់សំណង់ទាំង ឡាយដែលបានស្ថាបនា ឡើងត្រូវគោរពទៅតាមប្លង់ប្រើប្រាស់ដីធ្លី និង សំណង់[89]។

ប្លង់នេះក៏ត្រូវបានទាមទារ ឲ្យមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈ ក្នុង កិច្ចការសំណង់របស់ខ្លួន មិនតែប៉ុណ្ណោះប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ ផងដែរ អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហ៍ កម្ម សំរាប់សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំង សំរាប់សំណង់នៃរដ្ឋភិបា ល និង បរិក្ខាសាធារណៈ ។ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សំរាប់រាជធានី និងខេត្ត នីមួយៗដែលត្រូវ បានរៀបចំឡើងក៏តំរូវឲ្យមានការទទួលយល់ព្រមពីគណកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់រាជធានី ឬ អនុគណកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ខេត្តក្រុង រួចត្រូវមានការ យល់ព្រមពីគណកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត ។ នៅក្នុងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ក៏ត្រូវឲ្យមានបទបញ្ញត្តិមួយចំនួនទៀត ក្នុងគោលបំណងដើម្បីការពារ និងលើកតំលៃរមណីយ ដ្ឋាន ឬអចលនវត្ថុណាដែល នឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែក បុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ និង

[88]សៀវភៅ នីតិនគរូបនីយវិទ្យា សាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ទំព័រ ១២០

[89]សៀវភៅ នីតិនគរូបនីយវិទ្យា សាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ទំព័រ ១៥០

សោភ័ណភាពរបស់តំបន់ជាក់ស្តែងដូចជា សៀមរាបអង្គរ យើងឃើញថា អាជ្ញាធរអប្សរា ដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តនូវច្បាប់ប្រើប្រាស់ដីធ្លី និងសំណង់ដោយអាជ្ញាធរនេះជាអ្នកធ្វើការកំណត់តំបន់នៅក្នុងខេត្តសៀមរាប ឲ្យក្លាយទៅជាតំបន់សណ្ឋាគារ តំបន់ទេសចរណ៍ តំបន់ធម្មជាតិ ដែលត្រូវថែរក្សាតំបន់ស្រះទឹកបុរាណ នៅតាម ផ្លូវជាតិលេខ ៦ តំបន់នៅសងខាងស្ទឹងសៀមរាប ដែលតំបន់ទាំងអស់នេះត្រូវគ្រប់គ្រងដោយអនុក្រឹត្យស្តី ពីការប្រើប្រាស់ដីធ្លី និង សំណង់នៅតំបន់សៀមរាបអង្គរ ហើយអនុក្រឹត្យនេះក៏បានចែងនូវបទបញ្ញត្តិ មួយចំនួន ដែលទាក់ទងទៅនិង ទិដ្ឋភាពរួម នៃតំបន់ប្រភេទនៃការប្រើប្រាស់ដី ផ្លូវចេញចូល បណ្តាញផ្សេងៗ ចំណតរថយន្ត ផ្ទៃអប្បរមានៃដីឡូត៍ ការបោះទីតាំងនៃសំណង់ ផ្ទៃនៃសំណង់ដែលអនុញ្ញាតការរៀបចំទិដ្ឋភាពខាងក្រៅ (សួនច្បារ និងដើមឈើ) ហើយរាល់ការអនុវត្តន៍នូវបទបទបញ្ញាតិ ទាំងនេះ ត្រូវគោរពទៅតាមប្លង់គោល និងសៀវភៅបន្ទុក និងការឯកភាពពីអាជ្ញាធរអប្សរា ពីព្រោះអាជ្ញាធរនេះ ជាអ្នកទ្រទ្រង់រមណីដ្ឋានអង្គរ ជាអ្នកអនុវត្តន៍សិទ្ធិផ្តាច់មុខ នៅក្នុងការចេញលិខិតអនុញ្ញាត សាងសង់ ច្បាប់ប្រើប្រាស់ដីធ្លី និងសំណង់ ចំពោះវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

**ខ.៣.លិខិតអនុញ្ញាតសាងសង់**

យោងតាមអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ឆ្នាំ១៩៩៧ បានបញ្ញតិពីកាតព្វកិច្ចនិង លក្ខខណ្ឌនិងសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់។[90]

រាល់រូបវន្តបុគ្គល និងនីតិបុគ្គលសាធារណៈ មានសិទ្ធិសាងសង់អាគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួនដែលសិទ្ធិនេះត្រូវបានកំណត់និង ការពារដោយអនុក្រឹត្យ។ លិខិតអនុញ្ញាតឲ្យសាងសង់ត្រូវចេញបានមុនការសាងសង់ ព្រោះវាជាគ្រិះដែលធ្វើឲ្យអាគារវាមានលក្ខណៈស្រប់ច្បាប់ នៃសំណង់។

ដើម្បីធានានូវសុខមាលភាពនៃសំណង និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈចាំបាច់សំរាប់ធានាដល់ដំណើការនៃការរៀបចំទីក្រុង និង តំបន់កសិកម្មបានល្អប្រសើរ បទបញ្ញតិទូទៅនៃសំណងមានកំណត់អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈក្នុងការសាងសង់សំណង់សាធារណៈនិង សំណង់ឯកជន។ បទបញ្ញតិទាំងនេះត្រូវយកមកអនុវត្តក្នុងពេលពុំទន់មានប្លង់ប្រើប្រាស់ដីធ្លី និង ប្លង់គោលអនុម័តដោយរាជរដ្ឋាភិបាល។[91] ចំពោះអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់មិនត្រូវបានគេយកមកអនុវត្តន៍ ទៅលើសំណង់ដែលមានស្រាប ដែលមានការអនុញ្ញាតនោះទេ ប៉ុន្តែ

[90] នីតិនគរូបនីយកម្ម និងការរៀបចំទីក្រុង សាស្ត្រចារ្យ ឆាន់ ឡេងចាន់ឆាយ៉ា ឆ្នាំសិក្សា២០០៩-២០១០ ទំព័រ ៦៤

[91] នីតិនគរូបនីយកម្ម និងការរៀបចំទីក្រុង សាស្ត្រចារ្យ ឆាន់ ឡេងចាន់ឆាយ៉ា ឆ្នាំសិក្សា២០០៩-២០១០ ទំព័រ ៦៤

ចំពោះសំណង់ដែលមានការអនុញ្ញាតរួចហើយ បែជាមានការផ្លាស់ប្តូរទ្រង់ទ្រាយរូបនៃសំណង់នៅគេក៏យកមកអនុវត្តន៍ដូចគ្នាផងដែរ។

### គ. ការថែរក្សា និង កែលំអរសំណង់បេតិកភណ្ឌ

ការថែរក្សាសំណង់បេតិកភណ្ឌ ក៏ជាកត្តាមួយជួយធ្វើឲ្យរាជធានីភ្នំពេញមានសោភ័ណ្ឌភាពមួយកំរិតទៀតហើយ ក៏ជាប្រយោជន៍មួយក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ ឲ្យមកទស្សនា ហើយក្នុងគោលបំណងធ្វើឲ្យការជួសជុល និង ការថែរក្សាសំណង់ចាស់ៗ ទាំងអស់នោះ ដើម្បីកុំឲ្យមានការបាត់បង់ គឺដើម្បីការពារនូវអត្តសញ្ញាណរបស់ខ្លួន។ តួយ៉ាងដូចជាក្នុងឆ្នាំ២០០២ ការិយាល័យកិច្ចការនគរូបនីយកម្មរបស់សាលាក្រុងភ្នំពេញមានគោលដៅកែលំអរសំណង់បេតិកភណ្ឌនៅក្នុងរាជធានីភ្នំពេញដូចជា គំម្រោងជួសជុលផ្សារចំនួន៣ ក្នុងរាជធានីភ្នំពេញដោយចាប់ផ្តើម ធ្វើការជួសជុលផ្សារថ្មី ដែលផ្សារនេះបានសាងសង់កាលពីឆ្នាំ១៩៣៧ ហើយកំពុង មានភាពទ្រុឌទ្រោម ដោយស្ថានភាពបាក់ស្រុត ផ្សារកណ្តាល និង ផ្សារចាស់ក្រោមជំនួយពីទីភ្នាក់ងារ អភិវឌ្ឍន៍របស់បារាំង ( A F D) ដែលបានផ្តល់លុយប្រហែល ៥.៣ លានដុលារ សំរាប់ជំហានទីមួយនៃ កំរោងនេះដែលចាប់ផ្តើមនៅឆ្នាំនេះ។ មិនតែប៉ុណ្ណោះ សាលាក្រុងក៏មានគំម្រោងធ្វើការកែរលំអរ និង ជួសជុលផ្លូវ និង ទីលានសាធារណៈក្នុងខ័ណ្ឌដូនពេញ គំម្រោងកែលំអរ និងជួសជុលសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រក្នុងខ័ណ្ឌដូនពេញនិង គំម្រោងជួសជុលអាគារមួយចំនួននៅក្បែរមាត់ទន្លេរដែលសាងសង់តាំងពីទស្សវត្ស ១៩៦០ និង ១៩៧០ ដោយ ធ្វើឲ្យអាគារទាំងនោះ ជាកន្លែងរស់នៅបានប្រសើរជាងមុនសំរាប់ប្រជាជន និងជាកន្លែងទាក់ទាញអ្នកទេសចរណ៍ផងដែរ។[92]ទទឹមនិងនេះដែរសាលាក្រុង ក៏បានធ្វើការជួសជុល និងស្តារឡើងវិញនូវអតីត សាលមហាស្រពចេនឡាដែលជាបេតិកភណ្ឌជាតិក្នុងទស្សវត្សទី៦០ ហេតុនេះហើយទើបសាលាក្រុងបានធ្វើការស្តារនិងកែ លំអរសាលនេះឡើងវិញពីព្រោះក្នុងគោលគំនិតដើម្បីពង្រីកវប្បធម៌ខ្មែរឲ្យសមស្របតាមទីផ្សារសេដ្ឋកិច្ចក្នុងអន្តរជាតិ និង ជាជំហានមួយជួយស្តារឡើងវិញនូវវិស័យវប្បធម៌របស់ខ្មែរ ដែលត្រូវខូចខាតដោយបោះបង់យូឆ្នាំមកហើយ។ ចំណែកឯវត្តភ្នំក៏ជាបេតិកភណ្ឌមួយប្រវត្តិសាស្ត្រមួយដែលសាលាក្រុងបានធ្វើការជួសជុលកែរលំអរ ហើយបានធ្វើបុណ្យឆ្លងយ៉ាងអធឹកអធម នៅថ្ងៃទី ៩ ខែ មេសាឆ្នាំ១៩៩៨ ។ ការជួសជុលកែរលំអររួមមានដូចជា ការលាភពណ៌ ព្រះវិហារ និងចេតិយជាថ្មី ដាក់បង្គោលភ្លើងថ្មី ចាក់ដីដាំស្មៅ និងក្រាលថ្មបាយក្រៀមនៅ តាមផ្លូវព័ទ្ធជុំវិញជើងភ្នំ ធ្វើការសាងសង់ ស្តូរធំមួយទំហំរង្វង់មួយម៉ែតបណ្តោយតួរស្តូរពីម៉ែត ដាក់លើព្រះវិហារនៅលើកំពូលភ្នំ ។ រីឯចំលាក់និង ក្បាច់រចនាក៏ត្រូវធ្លាប់លាភពណ៌ឲ្យមាន សភាព

[92]ការសែត ឌីឃែមបូឌា ដេលីចុះថ្ងៃទី២៤ ខែ មិនា ឆ្នាំ ២០០៣ ច្បាប់ទី០៤៣

ដូចដើមកន្លែងណារលុប ក៏ត្រូវបានឆ្លាក់ឡើងវិញផងដែរ ។ បង្គោលរបងដែលបានដាក់ព័ទ្ធជុំវិញបរិវេណវត្តភ្នំ មានចំនួន២០០០បង្គោលភ្ជាប់គ្នាដោយច្រវាក់ ចំណែករូបសំណាក់ ព្រះបាទស៊ីសុវត្ថិក៏ត្រូវយកមកតំម្កល់នៅកន្លែងដើមវិញដែរ ។ ការរៀបចំសំអិតសំអាងវត្តភ្នំ ដែលជាបេតិកភណ្ឌជាតិឲ្យមានសោភ័ណភាពកាន់តែល្អប្រណិតឡើងវិញហើយបានប្រែក្លាយកន្លែងដ៏ក្រកាលនេះទៅជាទីសក្ការៈបូជាឧទ្យានសួនកុមាររមណីយដ្ឋានភេសជ្ជៈដ្ឋាន បណ្ឌលទេសរណ៍ គេដើម្បីបំរើការសំរាកលំហែរកំសាន្តរៀងរាលថ្ងៃជូនដល់ប្រជាពលរដ្ឋក្នុងក្នុងរាជធានីភ្នំពេញទាំងអស់និងភ្ញៀវទេសចរណ៍អន្តរជាតិជាពិសេសរទៅទៀតទីតាំងនេះត្រូវបានគេ សំរេច ជាកន្លែងប្រារព្ធធ្វើពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ខ្មែរ ជារៀងរាល់ឆ្នាំផងដែរ។

## ២. ទិសដៅនៃការពង្រីកក្រុង

### ក. មូលហេតុនៃការពង្រីកក្រុង

ជាការពិតណាស់ ដើម្បីធ្វើឲ្យរាជធានីភ្នំពេញ មានភាពវិវត្តទៅមុខសាលាក្រុងក៏បាន ដាក់ចេញនូវគំម្រោងអភិវឌ្ឍន៍ពង្រីកទីក្រុងដែលមានដូចជាគំម្រោងអភិវឌ្ឍន៍តំបទជ្រោយចង្វារអភិវឌ្ឍន៍តំបន់ឬស្សីកែវអភិវឌ្ឍន៍ តំបន់ឆ្នេរបី ( ទន្លេរបាសាក់) អភិវឌ្ឍន៍ និងបង្កើតខ័ណ្ឌថ្មី( អរិយក្សត្រ)។ គោលបំណងរបស់សាលាក្រុង ក្នុងការរៀបចំតំបន់អភិវឌ្ឍន៍ ពង្រីកទីក្រុងនេះឡើង ដើម្បីឆ្លើយតបទៅនិង តំរូវការរបស់ ប្រជាពលរដ្ឋ គឺ សំដៅដោះស្រាយលំនៅដ្ឋាន ប្រជាពលរដ្ឋក្រីក្រដែលរស់នៅតាមតំបន់ស្នាក់ នៅបណ្ដោះអាសន្នទាំងអស់ ក្នុងរាជធានីភ្នំពេញ ហើយម្យ៉ាងវិញទៀត ដើម្បីឲ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលគឺ គោលនយោបាយកាត់បន្ថយភាពក្រីក្រី របស់ប្រជាជន ក្នុងក្រុងនិង ធ្វើឲ្យការរស់នៅរបស់ប្រជាជនក្រីក្ររ មានលក្ខណៈល្អប្រសើនិង មានលំនៅពិតប្រាកដ និង លុបបំបាត់ចោលនូវតំបន់សំណង់ស្នាក់នៅបណ្ដោះអាសន្ន របស់ប្រជាជនក្រីក្រ ទាំងអស់ នៅក្នុងរាជធានីភ្នំពេញដោយរៀបចំតំបន់ទាំងនេះ ឲ្យមានលក្ខណៈសមស្រប តាមទិសដៅនៃការអភិវឌ្ឍន៍ និង ការរីកចំរើនរបស់ទីក្រុង។

ម្យ៉ាងទៀតការពង្រីកក្រុងក៏ជាកត្តាមួយផ្នែកមួយកែលំអរនិងធ្វើឲ្យសោភ័ណ្ឌភាពទីក្រុងកាន់តែមានភាពស្រស់បំព្រងបន្ថែមទៀតនិងប្រកបដោយអត្ថន័យសេដ្ឋកិច្ច ដែលមានន័យថា ក្រោយពីផែនការរៀបចំអភិវឌ្ឍន៍ពង្រីកទីក្រុងត្រូវបានបញ្ចប់សាលាក្រុងសង្ឃឹមថានិងមានអ្នកវិនិយោគបរទេសជាច្រើននាំគ្នាចូលមកធ្វើការវិនិយោគ ក្នុងតំបន់អភិវឌ្ឍន៍ទាំងនេះដែលជាប្រយោជន៍មួយដ៏ប្រសើបំផុត ក្នុងការជួយសំរួលដល់ប្រជាពលរដ្ឋក្រីក្រ ភាគច្រើននៅក្នុងរាជធានីភ្នំពេញ ដែលពុំមានការងារធ្វើ អាចមានលទ្ធិភាពប្រកបការងារ សំរាប់ដោះស្រាយ និង ជីវភាពប្រចាំថ្ងៃរបស់ពួកគេហើយវាជាកត្តាមួយ ក្នុងការទាក

ទាញភ្ញៀវទេសចរណ៍ឲ្យចូលមកទស្សនាក្នុងរាជធានីភ្នំពេញ កាន់តែច្រើនថែមទៀតក្នុងគោលដៅជួយលើកស្ទួយវិស័យទេសចរណ៍ក្នុងរាជធានីភ្នំពេញឲ្យមានភាពរីកចំរើនដើម្បីអាចប្រៀបធៀបជាមួយប្រទេសជិតខាងជាមិត្តជាពិសេសប្រទេសដែលជាសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍តែម្តង។ការពង្រីកទីក្រុងក៏សំដៅដោះស្រាយទៅនិងបញ្ហាកំណើនប្រជាពលរដ្ឋ ទាំងនោះភាគច្រើន ជាប្រជាជនក្រីក្រ រស់នៅតាមទីជនបទ និងខេត្តនានា ហើយបាននាំគ្នាធ្វើដំណើរ មកទីក្រុងដើម្បីរកការងារធ្វើ ហើយប្រជាពលរដ្ឋខ្លះ ក៏មកតាំងលំនៅបណ្តោះអាសន្ន នៅក្នុងរាជធានីដែលជាហេតុធ្វើឲ្យបាត់បង់នូវសណ្តាប់ធ្នាប់សាធារណៈនិងសោភ័ណភាពរបស់រាជធានីភ្នំពេញ។ គំម្រោងការអភិវឌ្ឍន៍ពង្រីកទីក្រុង ដែលសាលាក្រុងបានដាក់ចេញក៏ជាវិធានការណ៍ ដែលមានទិសដៅអភិវឌ្ឍន៍ឡើងវិញនូវលមនៅដ្ឋានក្នុងតំបន់ទាំងនោះដែលសំនង់ខ្លះក៏ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់និងការស្តារហេដ្ឋារចនាសម្ព័នមួយចំនួននៃតំបន់ទាំងនោះដែលកំពុងជួបប្រទះនូវបញ្ហាខ្វះខាតសំរាប់ជាតំម្រូវការរបស់ប្រជាពលរដ្ឋហើយនេះក៏ជាសមិទ្ធិផលមួយដែលសាលាក្រុងសម្រេចបានសំដៅទៅដល់ការកាត់បន្ថយភាពក្រីក្រយ៉ាងពិតប្រាកដហើយក៏ជាវិធានការណ៍ដែលជួយលើកស្ទួយនូវកំរិតជីវភាពជនទីទល់ក្រ ក្នុងរាជធានី ក៏ដូចជាដើម្បីរៀបចំសណ្តាប់ធ្នាប់សោភណ័ភាពទីក្រុង ភ្នំពេញឲ្យកាន់តែមានភាពស្រស់បំព្រងឡើង។

### ខ. ការពង្រីកទីក្រុង

- ការអភិវឌ្ឍន៍នហេដ្ឋារចនាសម្ព័ន

ចំពោះបញ្ហាប្រព័ន្ធហេដ្ឋារចនាសម្ព័ន ក្នុងតំបន់នេះ នៅមានភាពខ្វះខាតគ្រប់យ៉ាង ដែលជាហេតុធ្វើឲ្យតំបន់នេះមិនអាចអភិវឌ្ឍន៍ន៍ឡើងវិញនូវប្រព័ន្ធហេដ្ឋារចនាសម្ព័នក្នុងតំបន់នេះ ហើយវាក៏ជាផែនការមួយក្នុងចំណោមផែនការមេ ផ្សេងទៀតរបស់សាលាក្រុងក្នុងការអភិវឌ្ឍន៍ និង ស្តារប្រព័ន្ធហេដ្ឋារចនាសម្ព័ន ទីក្រុង ដែលមានទិសដៅដូចជា៖

- គំម្រោងការពារទឹកជំនន់

ដូចអ្វីដែលបានរៀបរាប់ខាងលើរួចមកហើយថាតំបន់ជ្រោយចង្វារជាតំបន់ដែលងាយទទួលរងគ្រោះធម្មជាតិ ទឹកជំនន់ជារាងរាលឆ្នាំ ហើយដែលបានធ្វើឲ្យប្រជាជនដែលរស់នៅទីនោះ មានភាពលំបាកក្នុងការរស់នៅ និង ការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ ដែលជាកត្តាមួយធ្វើឲ្យកំរិតជីវភាព ប្រជាពលរដ្ឋក្នុងតំបន់នោះកាន់តែធ្លាក់ចុះដុនដាប់ជាខ្លាំងឡើង។ដោយសារតែមើលឃើញពីបញ្ហាទុកលំបាករបស់ប្រជាជនក្នុងតំបន់នេះ និង ចង់កែប្រែជីវភាពប្រជាពលរដ្ឋផងនោះ ឲ្យមានភាពធូរធារជាងមុនដែលស្របទៅតាមគោលនយោបាយរាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋសលាក្រុង

ក៏បានធ្វើការសម្រេចកសាងទំនប់មួយសំរាប់ការពារទឹកជំនន់ដែលសាលាក្រុងបានស្តាបនាឡើងនេះ ដែលមានកម្ពស់តាមកូដទំនប់១២ម៉ែតប្រវែង១៧៧៥ម៉ែតចាប់ពីសង្កាត់ជ្រោយចង្វាររហូតដលចុងកោះ ជាមួយគ្នានេះដែរក៏មានការរៀបចំចាក់ច្រាំងទន្លេរបានប្រវែង១០៦៤ម៉ែត សំរាប់ការពារទឹកជំនន់ដោយ សាលាក្រុងបានផ្តោតក្តីសង្ឃឹមយ៉ាងមុតមាំថា ទំនប់ដ៏រឹងមាំនេះ និងអាចការពារតំបន់នេះមិនឲ្យមានការ លិចលុងបាន ហើយនិងអាចធ្វើឲ្យប្រជាពលរដ្ឋរស់នៅតំបន់នេះ លែងព្រួយបារម្ភទៀតពីបញ្ហាទំជំនន់ ដែលតែងតែបំផ្លាញពួគេធ្វើឲ្យពួកគេមានស្ថានភាពល្អប្រសើជាងមុន។

- គំម្រោងសាងសង់ប្រព័ន្ធលូ

ប្រព័ន្ធលូក៏ជាចំនុចមួយសំខាន់ដែរ ដែលសាលាក្រុងត្រូវយកចិត្តទុកដាក់ធ្វើការរៀបចំស្ថាបនា និងកែលំអរឡើងវិញពីព្រោះវាជាផ្នែកមួយក្នុងការជួយការកែលំអរបរិស្ថានក្នុងតំបន់ដោយការនាំយកទឹក កង្វក់ចេញពីក្នុងតំបន់នេះ និង ជួយកាត់បន្ថយជន់លិច។ ហេតុនេះហើយការងារបន្តទៀតរបស់សាលា ក្រុងត្រូវធ្វើការរៀបចំព្រព័ន្ធលូបង្ហូទឹកចេញពីតំបន់ តាមប្រសាសន៍របស់ លោក ពេជ្រ សារឿន ចៅ សង្កាត់ជ្រោយចង្វារបានមានប្រសាសន៍ថាលោកនិងស្នើរសុំទៅសាលាក្រុងឲ្យរៀបចំម៉ាស៊ីនបូមទឹកចេញ ពីក្នុងតំបន់ទំនាបក្នុងតំបន់នៅពេលមានភ្លៀងធ្លាក ដោយក្នុងនោះសាលាក្រុងក៏មានគំម្រោង រៀបចំលូប ង្ហូទឹកដែលមានមុខកាត់៦០០ មីលីម៉ែត អណ្តូងទំហំ៧០០ មីលីម៉ែត គុណនិង ៧០០មីលីម៉ែតនៅសងខាង ជ្រោយចង្វារដោយមានប្រវែង១១២០០ម៉ែត។ ការស្ថាបនាប្រព័ន្ធលូនេះបានធ្វើឲ្យតំបន់ជ្រោយចង្វារ ដោយពីមុនមិនមានប្រព័ន្ធលូបង្ហូរទឹកកង្វក់ និងចេះតែជន់លិចឥតឈប់ឈរ ជះឥទ្ធិពលអាក្រក់ដលបរិ ដ្ឋានក្នុងតំបន់ ប្រែក្លាយទៅជាតំបន់មួយល្អរបរិសុទ្ធ ប្រកបដោយផាសសុខភាពសំរាប់ប្រជាពលរដ្ឋ។

- គំម្រោងសាងសង់ប្រព័ន្ធផ្លូវ

ផ្លូវថ្នលគឺ ជាកត្តាមួយដែលបង្ហាញពីស្ថានភាពនៃការអភិវឌ្ឍន៍ន៍នៅក្នុងតំបន់ដល់កំរិតណា ហើយក៏ជាកត្តាមួយដែលបង្ហាញពីការរីកលូតលាស់ និងបង្កើនកីរិតជីវភាពប្រជាជនក្នុងតំបន់ទាំងមូល។ ដោយយល់ឃើញពីសារៈសំខាន់ នៃផ្លូវថ្នលនិងដើម្បីជួយសំរួលដល់ការធ្វើតំណើររបស់ប្រជាពលរដ្ឋនៅ ក្នុងតំបន់ដែលមានភាពលំបាក និង ដោយឈរលើទស្សនៈមួយថា " មានផ្លូវគឺ មានក្តីសង្ឃឹម មានផ្លូវគឺ មានការអភិវឌ្ឍន៍ " មន្ទីរសាធារណៈការនិង ដឹកជញ្ជូនរាជធានីភ្នំពេញ ដែលស្ថិតក្រោមចំណុះសាលា ក្រុងភ្នំពេញ បានរៀបចំស្ថាបនា ជាតំបូងនូវផ្លូវទំនប់មួយដោយអុតកៅស៊ូ ( Asphalt Concrete ) ដែលជាផ្លូវ ព័ទ្ធជុំវិញតំបន់អភិវឌ្ឍន៍ជ្រោយចង្វារចាប់ពីផ្លូវជាតិលេខ៦ A រហូតដល់មាត់ទន្លេសាប និង ចាប់ពីកែងផ្លូវ

មាត់ទន្លេមេគង្គទល់ និង ផ្លូវជាតិលេខ៦ Aវិញដែលមានប្រវែង ៥៦០០ម៉ែត និង ក្រឡាផ្ទៃសរុប ៧៦៨០០ ម៉ែត្រ ការេ ដោយមានគំម្រោងការអនុវត្តន៍:

- ចាប់បីផ្លូវជាតិលេខ៦ Aដល់ផ្លូវមាត់ទន្លេសាប និង ចាប់ពីកែងផ្លូវទន្លេមេគង្គទល់៦ Aវិញដោយមានទទឹង១៧ម៉ែត និងចាក់អ៊ុតកៅស៊ូ និង មានចិញ្ចើម១ ម៉ែត សងខាងផ្លូវ។ ៥.
- ចាប់ពីកែងមុខសង្កាត់ជ្រោយចង្វារ ដែលស្ថិតនៅតាមបណ្ដោយដងទន្លេសាប ព័ទ្ធទៅតាមដងទន្លេមេគង្គដលត្រឹមកែងផ្លូវជាតិលេខ ៦ Aមានទទឹង ១២ម៉ែត ដោយចាក់អ៊ុតកៅស៊ូមានចិញ្ចើម១ម៉ែ ១៥.តសងខាងផ្លូវ។

ម្យ៉ាងវិញទៀតដើម្បីធានាគុណភាពផ្លូវឲ្យប្រើប្រាស់បានយូរការស្ថាបនាត្រូវធ្វើទៅតាមបទដ្ឋានបច្ចេកទេសដូចខាងក្រោមៈ

- ☞ ឈូសឆាយកៀរសំរួលដីគំរូវកូដថ្នល ដោយឈូសឆាយដីជ្រាយចេញ
- ☞ ចាក់ដីពង្រីកផ្លូវប្រវែង ២០០ម៉ែត ចាប់ពីកែងផ្លូវមាត់ទន្លេសាប មានប្រវែង ៦២០ ម៉ែតដោយពង្រីកទៅជើងឲ្យបានទទឹង១៧ម៉ែតចាក់អ៊ុតកៅស៊ូនិងចាក់ចិញ្ចើម១ម៉ែតសងខាងផ្លូវ។៥.
- ☞ ចាក់ដីធ្វើគ្រិះ បាតក្រោម Sub_gradeកំរាស់៣០ សង់ទីម៉ែត
- ☞ ចាក់គ្រួសក្រហមSub_Base កំរាស់៣០ សង់ទីម៉ែត
- ☞ ចាក់ថ្មM30ធ្វើSub_Courge កំរាស់៣០ សង់ទីម៉ែត

ពេលធ្វើឃឿនផ្លូវបានរួចរាលហើយ មន្ទីរសាធារណៈការ និង ដឹកជញ្ជូនរាជធានីភ្នំពេញ និង ធ្វើការអ៊ុតកៅស៊ូកំរាស៦០ សង់ទីម៉ែត ឲ្យស្របទៅនិងបទដ្ឋានបច្ចេកទេស ដោយមានរៀបចំគំនូសចរាចរណ៍បែងចែកករធ្វើតំណើរ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើតំណើរ របស់ប្រជាពលរដ្ឋ និងដើម្បីជៀសវាងនូវគ្រោះថ្នាក់ចរាចរណ៍ ។ ជាងនេះទៅទៀតប្រជាពលរដ្ឋនៅត្រើយខាងលិច ក៏ដូចជាភ្ញៀវទេសចរណ៍មួយផងដែរ អាចធ្វើតំណើរទៅទស្សនា នៅក្នុងតំបន់នេះ ហើយអាចឲ្យគេមើលឃើញពីវិសាលភាពនៃទន្លេចតុមុខ និង សោភណ័ភាពរបស់ត្រើយខាងលិច ហើយក៏ជាជំហ៊ានមួយបង្កើតនូវទំនាក់ទំនងរវាងត្រើយខាងកើត និង ត្រើយខងលិច ដែលពុំធ្លាប់មានពីមុនទាល់តែសោះ។

- គំម្រោងរៀបចំប្រព័ន្ធទឹកស្អាត

ទឹកស្អាតជាសាធាតុមួយសំរាប់ទ្រទ្រង់រាង្គកាយរបស់មនុស្សក្នុងការរស់ និងត្រឹមតែប៉ុណ្ណោះ វាក៏សំរាប់ធម្មជាតិ ប៉ុន្តែវាក៏ចូលរួមបំផ្លាញជិវិតមនុស្ស និង ធ្វើឲ្យបរិស្ថានមានភាពកង្វក់បានដែរ ប្រសិនបើទឹកដែលប្រជាពលរដ្ឋយកទៅប្រើប្រាស់ដងចេញពីទន្លេផ្ទាល់តែម្ដង ដោយមិន បានធ្វើការសមអាត ឬ

យកទៅក្នុងអាងរួចសំលាប់មេរោគជាមុនទេនោះ។ ជាក់ស្តែងក្នុងតំបន់ជ្រោយចង្វារគឺ នៅពុំទាន់មានប្រព័ន្ធចែកចាយទឹកស្អាតប្រើប្រាស់នៅឡើយទេហើយប្រព័ន្ធលូបង្ហូរទឹកកង្វក់ក៏ពុំទាន់មានផងដែរ ។ ប្រជាជនក្នុងតំបន់នេះនាំគ្នាបង្ហូរទឹកកង្វក់ ចូលទៅក្នុងទន្លេ រួចហើយពួកគេក៏នាំគ្នាដងទឹកនោះយកមកប្រើប្រាស់វិញ ដែលជាហេតុនាំឲ្យពួកគេមានជម្ងឺ និង បរិស្ថានមិនស្អាត់ក្នុងតំបន់នេះ។ក្នុងគំម្រោងនេះគឺគេបានរៀបចំបណ្តាញប្រព័ន្ធទឹកស្អាត់សំរាបប្រជាជនក្នុងតំបន់នេះប្រើប្រាស់ ដោយយកថ្លៃថោកសមរម្យ។ ការរៀបចមឲ្យមានប្រព័ន្ធទឹកស្អាត វាក៏បានជួយសំរាលនូវទុកលំបានរបស់ប្រជាពលរដ្ឋមួយកំរិតផងដែរ ហើយវាជាកត្តាមួយផងដែរ ដែលជួយជំរុញឲ្យប្រជាពលរដ្ឋរស់នៅប្រកបដោយអនាម័យ ផាស់សុខភាព បរិស្ថានល្អបរិសុទ្ធ។

- ការរៀបចំភ្លើងបំភ្លឺសាធារណៈ

ការរៀបចំភ្លើងបំភ្លឺសាធារណៈ ក៏ជាផ្នែកមួយជួយបង្ហាញពីសោភ័ណ្ឌភាពនៃតំបន់ជ្រោយចង្វារ នាពេលរាត្រី ដែលធ្លាប់តែសំលឹងមើលពីមុខព្រះបរមរាជវាំង ទៅពុំឃើញអ្វីសោះ បានប្រែក្លាយទៅជាតំបន់មួយដែលមានភ្លើងបំភ្លឺចំរុះពណ៌ ហើយគួជាទីចាប់អារម្មណ៍ពីសំណាប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ និង ភ្ញៀវទេសចរណ៍ ដែលមកកំសាន្តក្នុងរាជធានីភ្នំពេញ។ គំម្រោងរបស់សាលាក្រុងបានចាប់ផ្តើមតំណើការដោយបានរៀបចំដាក់បណ្តាញអគ្គីសនីបំភ្លឺតាមទីសាធារណៈ និង ចែកចាយទៅឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះប្រើប្រាស់ជាបណ្តើរៗ ហើយ ដែលធ្វើឲ្យប្រជាជនមានអគ្គីសនីបំភ្លឺគ្រប់ផ្ទះ ដែលគេមើលពីត្រើយខាងលិច មកមានភ្លើងបំភ្លឺព្រោងព្រាតខុសប្លែកពីមុន។ សាលាក្រុងនិងមានគំម្រោងដាំបង្គោលភ្លើងលើផ្លូវទំនប់ចំនួន ១៨៨ បង្គោលដោយដាំចន្លោះពីបង្គោលមួយទៅបង្គោលមួយមានប្រវែង ៦០ម៉ែត ដោយចាក់គ្រិះបេតុង ការដាក់បង្គោលភ្លើង នេះសំរាប់បំភ្លឺតាមផ្លូវសាធារណៈនៅពេលរាត្រី ហើយសាលាក្រុងក៏មានគំម្រោងនិង ធ្វើបន្តទៀតស្របពេលនិងការកសាងផ្លូវថ្មីៗក្នុងតំបន់នេះបន្ថែមទៀតដើម្បីឲ្យមានការអភិវឌ្ឍន៍ដូចត្រើយខាងលិច។

- ការរៀបចំសួនសារធារណៈ

ដើម្បីឲ្យតំន់នេះក្លាយទៅជាកន្លែង ដែលមានបរិស្ថានល្អ និងមានលំហាបៃតង់ជាប់ជានិច្ចហើយមានសោភណ្ឌភាពដូចត្រើយខាងលិច និងជាទីកន្លែងកំសាន្តមួយយ៉ាងល្អ ប្រសើសម្រាប់ប្រជាពលរដ្ឋក្រោយពេលសម្រាក់ពីរកាងារ៕ សាលាក្រុងបានដាក់ចេញនូវគម្រោងរៀបចំសួន និងដាំដើមឈើការរៀបចំបង្គោលភ្លើងលំអរ និងការរៀបចំផ្លូវសម្រាប់អ្នកថ្មើរជើង និងយឿនអង្គុយតាមមាត់ទន្លេ៕ តាមរបាយការណ៍ របស់ការដ្ឋានជ្រោយចង្វាគម្រោងរៀបចំសួនសារធារណៈ ត្រូវធ្វើឲ្យបានក្រឡាផ្ទៃសរុប ៤ ហិចតា

ក្នុងទិសដៅរបស់សាលាក្រុងដើម្បីពង្រីកលំហាបៃតង ឲ្យត្រូវតាមបទដ្ឋាន ៧ ម៉ែត្រការ៉េ ក្នុងមួយនាក់ ហើយរហូតដល់ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០២ ការងារធ្វើសួន និងដាំស្មៅសម្រាចបាន ២០៧២៤ ម៉ែត្រការ៉េ ការដាំដើមឈើបានចំនួន២៤០ ដើមដោយមានប្រភេទខុសគ្នា ដូចជាកកោះលឿង ត្របែកព្រៃ ក្ងោក រំដួល។ ដោយធ្វើការដាំឆ្លាស់គ្នា ហើយការដាំដើមឈើរបៀបនេះ គោលគំនិតរបស់សាលាក្រុង គឺដើម្បីឲ្យមើលពីរត្រើយខាងលិចមកឃើញទីនេះ ខែណាក៏មានដើមឈើចេញផ្កាដោយប្រែប្រួលទៅតាមរដូវកាលផងដែរ ។ ស្របពេលជាមួយ និងការរៀបចំសួនច្បារសាលាក្រុងក៏មានគំម្រោងរៀបចំដាំបង្គោលភ្លើងធ្វើពីរបេតុង ស្ថិតនៅចម្ងាយ ៧ ម៉ែត្រពីរមាត់ច្រាំង និងមានកម្ពស់៧ ម៉ែត្រលំអរទៅដោយក្បាច់គ្របកឈូកយ៉ាងស្អាតសម្រាប់លំអរនាពេលរាត្រី។ម្យ៉ាងទៀតដើម្បីជួយសម្រួលការកកស្ទះចង្អៀតដោយសារតែមានមនុស្សច្រើនកុះករ ជាពិសេសរនៅពេលមានបុណ្យទានផ្សេង ពិសេសរនាពេលបុណ្យអុំទូក សាលាក្រុងក៏មានគម្រោងរៀបចំផ្លូវសំរាប់អ្នកថ្មើរជើង តាមមាត់ទន្លេ ដោយរៀបឥដ្ឋការ៉ូ ក្រឡាក្បាច់ និងយឿនសម្រាប់ឲ្យ ភ្ញៀវមកអង្គុយស្រូបយកខ្យល់អាកាសពីរមាត់ទន្លេ និងជួយកាត់បន្ថយនូវភាពចង្អៀតណែន នាពេលបុណ្យទានដែលកើតមានស្ទើតែរាល់ឆ្នាំ។

យោងតាមរបាយការណ៍របស់ការដ្ឋានជ្រោយចង្វារការងាដែលសម្រាចបានមានដូចជាៈ

- ការរៀបចំឥដ្ឋការីឡា ដែលមានលក្ខណៈជាក្បាច់ទំហំធំបាន ២៤៨៩ ម៉ែត្រការេ ទំហំតូចបាន ៤៧៤២ ម៉ែត្រការេ ដោយរៀបនៅតាមមាត់ផ្លូវថ្មើរជើង តាមមាត់ទន្លេបានរួចរាល់ ហើយទិសដៅ និងធ្វើបន្តទៀតរហូតដល់ចប់គម្រោងដែលបានគ្រោងទុក។
- ការរៀបចំយឿនអង្គុយបាន ៩០០ ម៉ែត្រ ដោយក្រាលថ្មរម៉ាបទំហំទទឹង ០.៧០ម៉ែត្រនៅអមសងខាងយឿនអង្គុយ មានរៀបចំបិទក្បាច់ (ចក) រចនាបទភ្ញំដាដែលបានចំលងចេញពីរប្រាសាទសំបូរណ៍ព្រៃគុហ៍ ក្នុងនោះក៏មានរៀបចំដាក់ដងទង់ជាតិ ផលិតពីដែកអ៊ីណុកដាក់នៅចំកណ្តាលបង់ថ្មរមានកម្ពស់ ២០.២០ ម៉ែត្រ ឃ្លាត់ពីរមួយដើមទៅមួយដើមប្រវែង ២០ម៉ែត្រការរៀបចំយឿនអង្គុយនេះ មិនត្រឹមតែទុកសម្រាប់ភ្ញៀវមកលំហែកាយអង្គុយលេងប៉ុណ្ណោះទេតែវាក៏ជាទំនប់សំរាប់ការពារទឹកជំនន់មួយយ៉ាងប្រសើរ។

### គ.គម្រោងការអភិវឌ្ឍន៍ខណ្ឌថ្មី(អរិយក្សត្រ)

### គ.១.លក្ខណៈទូទៅនៃតំបន់អរិយក្សត្រ

តំបន់អរិក្សត្រមានទីតាំងស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្តាល គឺស្ថិតនៅពីមុខរាជធានីភ្នំពេញ ។

តំបន់នេះមានផ្ទៃក្រលាស្មើរ ៧៨០៨ ហិចតា ដែលផ្ទៃដីភាគីច្រើនជាទំនាបលិចទឹកមានប្រហែល ៨០ ភាគរយ ចំណែកការប្រើប្រាស់ដីធ្លីរបស់តំបន់វិញ ត្រូវបានចែកចេញជា៣ តំបន់គឺៈ

- តំបន់កសិកម្មមានប្រហែល ៨០ ភាគរយ នៃផ្ទៃដីទាំងមូលដែលត្រូវបានចែកចេញជា២ផ្នែក គឺទី១ ដំណាំបន្លែដែលភាគច្រើនដាំនៅតាមបណ្តោយទន្លេ នឹងទី២តាមតំបន់ដែលមានបឹងបួរ និងនៅជិតលំនៅដ្ឋាន ហើយដំណាំស្រូវភាគច្រើន គឺជាស្រូវវស្សារ និងមួយភាគតូចជាស្រូវប្រាំង
- តំបន់លំនៅដ្ឋានមាន ២០ ភាគរយ នៃផ្ទៃដីប្រទេសទាំងមូលភាគច្រើនស្ថិតនៅតាមបណ្តោយទន្លេ និងផ្លូវសំខាន់ប៉ុណ្ណោះ។
- តំបន់ពាណិជ្ជកម្មមានប្រហែល ៧ ភាគរយ ដែលមានទីតាំងនៅតាមទីប្រជុំជនតាមឃុំនីមួយ និង នៅជុំវិញផ្សារធំអរិយក្សត្រ។ ចំពោះផ្នែកសិប្បកម្មវិញភាគច្រើនមានលក្ខណៈជាសិប្បកម្មគ្រួសារ រីឯផ្នែកឧស្សាហកម្មវិញគឺពុំទាន់មាននៅក្នុងតំបន់នោះទេ។
- ចំពោះវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច គេសង្កេតឃើញថា តំបន់នេះមានចំនួនប្រជាជនច្រើនសរុបនៃតំបន់ទាំងមូល មានចំនួន ២៧២៧០ នាក់ដែលក្នុងនោះបុរសមានចំនួន ២២៩៤០នាក់ហើយស្រីមានចំនួន ២៤២០នាក់ និងចែកជា៤៤២៤គ្រួសារ ដង់ស៊ីតេ ៤៤៩.៧ នាក់ក្នុងមួយគីឡូម៉ែតការេ។

តំបន់នេះត្រូវបានចែកចេញជាបួនឃុំ ហើយចំនួនឃុំនីមួយៗមានដូចជាៈ

- ឃុំសារិការកែវ មានចំនួនប្រជាជនសរុប៧៨៧៤ នាក់ មានគ្រួសារ ២២៤៨គ្រួសាដែលក្នុងនោះបុរសមានចំនួន២៨៨៤នាក់ស្ត្រីមានចំនួន២៩៩២ នាក់ មានដង់ស៊ីតេ ៤៤៧នាក់ក្នុងមួយគីឡូម៉ែត្រការេ ក្នុងនោះ ៧៧ ភាគរយកសិករ០.៤ ភាគរយពាណិជ្ជករ ២៤ភាគរយជាសិប្បកម្មមានលក្ខណៈគ្រួសារ។
- ឃុំអរិយក្សត្រ មានប្រជាជនសរុប៩៩៧នាក់មានចំនួនគ្រួសារ ២០៩៤ គ្រួសារបុរសមានចំនួន ៤៧២៧ នាក់ស្ត្រីមានចំនួន ៤៧៧៧នាក់មានដង់ស៊ីតេ ៧០៨នាក់ ក្នុងមួយគីឡូម៉ែត្រការេ ដែលក្នុងនោះ៩២ ភាគរយជាកសិករ ០.៧៩ ភាគរយ ជាពាណិជ្ជករ និង០.០៩៤ជាសិប្បករខ្នាតធំ។

ឃុំស្វាយជ្រុំមានប្រជាជនសរុបចំនួន៨៤៧៤ នាក់ មានចំនួនគ្រួសារ៧៤០ គ្រួសារសរុបមានចំនួន ២៧៨៤ នាក់ ស្ត្រីមានចំនួន ២៨៨៩នាក់ មានដង់ស៊ីតេ ២៩២ ក្នុងមួយគីឡូម៉ែត្រការេដែលក្នុងនោះ ៨០ ភាគរយ ជាកសិករ ២.២៧ ភាគរយ ជាពាណិជ្ជករ ២០ ភាគរយេ ជាសិប្បកម្មលក្ខណៈគ្រួសារ និង ០.២៧ ភាគរយជាសិប្បកម្មខ្នាតធំ។

- ឃុំព្រែកកូវមានប្រជាជនសរុបចំនួន ៤៧៤៤ នាក់ មានចំនួនគ្រួសារ ២៤០៨ គ្រួសារបុរសមាន

ចំនួន ២៧៧៧ នាក់ ស្ត្រីមានចំនួន ២៩៨៨នាក់ ដែលមាន៨០ ភាគរយជាកសិករ ២.៩៧ភាគរយជាពាណិជ្ជករ ៩២ ភាគរយជាសិប្បកម្មលក្ខណៈគ្រួសារ ០.៩២ ភាគរយចាំសិប្បកម្មខ្នាត ធំនិងដងស៊ីតេមាន ២៨នាក់ក្នុងមួយគីឡូម៉ែត្រការេ។

ចំណែកឯអាគារសាធារណៈក្នុងតំបន់អារិយក្សត្រមានដូចជាៈ

- សាលាឃុំមានចំនួន ៤សំរាប់ ឃុំដែលមានបុគ្គលិកទាំងអស់ ២នាក់
- មណ្ឌលសុខភាពមានចំនួន ៤សំរាប់បុគ្គលិកទាំងអស់ និងមានឪសថស្ថានចំនួន ២កន្លែង។
- ចំពោះសាលារៀនឃុំសារិកាកែវ មានសាលាបឋមសិក្សាចំនួន ដែលមានគ្រូបង្រៀន ចំនួន ២ នាក់ ឃុំអរិយក្សត្រ២ កន្លែងបឋមសិក្សាមានបី កន្លែង វិទ្យាល័យមាន១ កន្លែង សរុបសិស្សទាំងអស់ មាន ២៩២ នាក់ និងគ្រូមាន ៧៧នាក់ឃុំស្វាយជ្រុំមានបឋមសិក្សាចំនួន២កន្លែង មានគ្រូ ចំនួន ១៦នាក់និងឃុំព្រែកតាកូវមានមតេយ្យសាលាចំនួនមួយបឋមសិក្សាចំនួន១ និងគ្រូចំនួន២៩នាក់ ។
- នៅតំបន់នេះមានផ្សារតែមួយទេ សំរាប់ឃុំទាំង៤ ខាងលើដោយស្ថិតនៅក្នុងឃុំអរិយក្សក្រ នៅតាម បណ្ដាដងទន្លេមេគង្គ ដែលសរុបចំនួនអាជីវករទាំងអស់ មានចំនួន ២៩៩ នាក់ ដែលជាហេតុធ្វើឲ្យផលិតផល ភាគច្រើនត្រូវបានប្រជាពលរដ្ឋយកមកលក់នៅផ្សារនានាក្នុងក្រុងភ្នំពេញដោយមធ្យោបាយតាមផ្លូវទឹក។
- ប្រពន្ធ័ផ្លូវគមនាគមនដែលជាផ្លូវសំខាន់ មានប្រវែង ៧.គីឡូម៉ែត្រ។ផ្លូវពីអារីយក្សត្រទៅពោធំ មាន (........) គីឡូម៉ែត្រ ពីអារិយក្សត្រទៅសារិកាកែវ មាន(.........)ម៉ែត្រ។ ឃុំស្វាយជ្រុំមានផ្លូវប្រវែង គីឡូម៉ែត្រ ឃុំព្រែកតាកូវមានប្រវែង គីឡូម៉ែត្រ ឃុំអារិយក្សត្រ មានផ្លូវប្រវែង គីឡូម៉ែត្រ ។
- ប្រពន្ធ័ទឹកស្អាតជាប្រពន្ធ័ឯកជន ដែលមានតំលៃថ្លៃ ជាងប្រជាជននៅក្នុងទីក្រុងភ្នំពេញ ហើយប្រជាជន ភាគច្រើនប្រើប្រាស់ទឹកទន្លេ បឹង បួរ អណ្ដូងខួង ដែលនៅក្បែរទីលំនៅ ។
- ប្រពន្ធ័អគ្គីសនី ជាប្រពន្ធ័ ឯកជន ដែលមានខ្សែប្រព័ន្ធ ស្ថិតនៅតាមបណ្ដោយផ្លូវសំខាន់និងទីប្រជុំជន។
- ប្រព័ន្ធធារាសាស្ត្រមានទំនប់ និងប្រឡាយទឹក ដែលបានហូចាក់ទៅតាមព្រែកប្រឡាយដែលមានលក្ខណៈជាធម្មជាតិ និងមនុស្សជីក ។ បឹងបួរ ព្រែកមានទូនាទី សុះខាន់ជាអាងស្ដុបទឹកជំនន់ ទឹកភ្លៀង និងទន្លេយ៉ាងសំខាន់ និងជាប្រភពផ្ដល់នូវជីវិតដល់វិស័យកសិកម្ម ក្នុងតំបន់ ។

**គ.២. បញ្ហាជាក់ស្តែងនៃតំបន់អរិយក្សត្រ ដែលតម្រូវឲ្យមានសាលាក្រុងមានគម្រោងអភិវឌ្ឍន៍**

តំបន់អារិយក្សត្រ ជាតំបន់មួយដែលនៅ កៀក និងរាជធានីភ្នំពេញ គឺស្ថិតនៅចំពីមុខរាជធានីភ្នំពេញតែម្តងប៉ុន្តែកំរិតជីវភាព របស់ប្រជាពលរដ្ឋក្នុងតំបន់នោះ មានភាពអន់ថយយ៉ាងខ្លាំង នេះដោយសារតែប្រជាពលរដ្ឋក្នុងតំបន់ជួបប្រទះនូវបញ្ហាមួយចំនួន ដែលជាបញ្ហាចំបង ដែល រាជរដ្ឋាភិបាលគួរតែយកចិត្តទុដាក់ និងផ្ទុការដោះស្រាយជូនប្រជាពលរដ្ឋ។

បញ្ហាសង្គមដែលជាផលប៉ះពាល់ ដល់ប្រជាពលរដ្ឋមានជាអាទិ:

-លំនៅស្ថាន

លំនៅស្ថានរបស់ប្រជាពលរដ្ឋ ក្នុងតំបន់នេះភាគច្រើន ជាលំនៅស្ថានធ្វើពីស្លឹកនិងឈើហើយ ច្រើនលិចទឹកនៅរដូវវស្សា និងពេលដែលទឹកជន់ ទន្លេមេគង្គឡើងខ្លាំងលំនៅស្ថានក្នុងតំបន់ ភាគច្រើន ខ្វះនូវប្រពន្ធ័បង្ហូទឹក ស្អុយនិងបង្គន់អណាម័យ ឲ្យបានត្រឹមត្រូវ ចំណេកឯស្ថានភាព ភូមិសាស្រ្ត ក្នុងតំបន់មិនបានអំណោយផល ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ដោយសារតំបន់នេះជាទំនាប់លិចទឹក។

-សុខភាពសាធារណ:

សុខភាពសាធារណ: គឺជាផ្នែកមួយយ៉ាងសំខាន់ សំរាប់ជួយទ្រទ្រុងការរស់នៅ របស់ប្រជាពលរដ្ឋក្នុងតំបន់ ឲ្យរស់នៅប្រកបដោយផាសុខភាព និងអនាម័យ និងជួយសង្គ្រោះជីវិតប្រជាពលរដ្ឋ នៅពេលមានជំងឺដង្កាត់ម្តងៗ ផ្ទុយទៅវិញមណ្ឌលសុខភាព ក្នុងតំបន់នេះពុំបានបំពេញ ទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ឲ្យបានគ្រប់គ្រាន់ទេ ដោយកន្លែងសុខភាព ទាំងអស់នៅឆ្ងាយ ពីផ្ទះប្រជាពលរដ្ឋពេក ចំណេកឪសថស្ថាន ក៏ពុំសូវមាន ថ្នាំពេទ្យព្យាបាលក៏មានការខ្វះខាត ដែលជាហេតុធ្វើឲ្យ ថ្នាំពេទ្យនៅក្នុងតំបន់មានតំលៃថ្លៃ គ្រូពេទ្យក៏មានការខ្វះខាត ជាពិសេសគ្រូពេទ្យជំនាញនិងគ្រូពេទ្យមូលដ្ឋាន តាមឃុំ ដែលធ្វើឲ្យប្រជាពលរដ្ឋគ្មានជំនឿ លើសេវាព្យាបាលនៅជនបទអ្នកជំងឺភាគច្រើនបានសម្រេចមកព្យាបាលជម្ងឺនៅភ្នំពេញ ។

- ការអប់រំ

សាលាមត្តេយ្យ បឋមសិក្សា វិទ្យាល័យមានការខ្វះខាតថ្នាក់ តាមតំរូវការ។ សិស្សដែលគ្រប់អាយុចូលរៀនក៏ពុំបានចូលសាលារៀនព្រោះដោយសាតែបញ្ហាកង្វះខាតលើជីវភាព ហើយសាលារៀនភាគច្រើន ស្ថិតនៅឆ្ងាយពីផ្ទះប្រជាពលរដ្ឋ គួបផ្សំនិងផ្លូវធ្វើដំណើរមានការពិបាកផង។ បញ្ហាកង្វះខាតគ្រូបង្រៀន មិនគ្រប់គ្រាន់សំរាប់តំរូវការ ឯគ្រូបង្រៀនខ្លះទៀត មិនសូវបានទៅបង្រៀនទៀងទាត់ ទេពីព្រោះសំអាងលើប្រាក់ខែមិន គ្រប់គ្រាន់ ។

- ទីផ្សារ

ផ្សារធំមានតែមួយសំរាប់៥ឃុំ នៅតំបន់អារិយក្សត្រ និងមានលក្ខណៈតូចចង្អៀត ដែលមិនអាចបំពេញតាមតម្រូវការ គ្រប់គ្រាន់ សេវាសាធារណៈ ដែលជាហេតុធ្វើឲ្យទំនិញ ភាគច្រើនត្រូវបានដឹកជញ្ជូនមកលក់ នៅទីក្រុងភ្នំពេញ។ ដោយសារផ្សារស្ថិតនៅឆ្ងាយពីលំនៅស្ថានរបស់ប្រជាពលរដ្ឋ បានធ្វើឲ្យប្រជាពលរដ្ឋ១ចំនួនធំមានការលំបាក ក្នុងការធ្វើដំណើរដែរជាពិសេស ពេលរដូវវស្សា ចំណែកអាជីវកម្មក្នុងតំបន់មួយភាគធំជាសិប្បកម្មលក្ខណៈគ្រួសារ តែងតែប្រឈមមុខ ជាមួយបញ្ហាកង្វះខាតប្រាក់ចំនូលដោយសារតែបញ្ហាតំលៃ នៅលើទីផ្សារ។

- បណ្តាញហេដ្ឋារចនាសម្ព័ន្ធ

បញ្ហាដែលចោទ ឡើងចំពោះ បណ្តាញ ហេដ្ឋារចនាសម្ព័ន្ធ មានពីរៈ

១. បញ្ហាចរាចរណ៍ប្រពន្ធ័ផ្លូវ

ប្រពន្ធ័ផ្លូវថ្នល់ នៅតំបន់នេះពុំសូវមានទេ គឺមានតែ ផ្លូវសំខាន់ៗ មួយចំនួន តូចតែប៉ុណ្ណោះ ហើយ ក៏មិនត្រូវបានថែទាំដែរ ចំណែកផ្លូវនៅតាមដងទន្លេ តែងតែទទូលរង ច្រាំងបាក់ ជាញឹកញាប់ដោយសារផ្លូវភាគច្រើន មាននីវូទាប ងាយធ្វើឲ្យលិចទឹក នៅរដូវវស្សា ការប្រើប្រាសផ្លូវទៀតសោតពុំមានការថែទាំនិងជួសជាប្រចាំទេ។ ចំណែកឯប្រពន្ធ័គមនាគមន៍ផ្លូវទឹកវិញគឺមានតែទូកដចំម្លង ពុំមានស្ពានឡើយ ការប្រើប្រាស់ទូកដចម្លង ក៏មិនទៀងទាត់ពេលវេលា និងមិនឆ្លើយតប់ពេលវេលា ឆ្លើយតបតាមតំម្រូវការរបស់ប្រជាពលរដ្ឋជាពិសេសនូវរដូវបុណ្យទាននិងពេលមានបញ្ហាបន្ទាន់ឬគ្រោះថ្នាក់ផ្សេងៗ។

២. បញ្ហាប្រពន្ធ័ទឹកស្អាត

ប្រជាពលរដ្ឋនៅតាមតំបន់នេះ ប្រើប្រាស់ទឹក៥ប្រភេទដូចជាៈ

- អណ្តូងស្នប់ អណ្តូងខូង នៅក្នុងបរិវេណផ្ទះ របស់ប្រជាជន
- ប្រជាជនមួយចំនួនប្រើប្រាស់ទឹកស្រះ ត្រពាំង
- ប្រជាជនដែលរសើនៅតាម ដងទន្លេ យកទឹកទន្លេ ប្រើប្រាស់ផ្ទាល់តែម្តង
- ប្រជាជនដែលនៅក្នុងតំបន់ ទីប្រជុំជនប្រើប្រាស់ បណ្តាញទឹកឯកជន

គ្រង់នេះបញ្ជាក់ឲ្យឃើញថា ទឹកប្រើប្រាស់នៅតំបន់នេះ មានការខ្វះខាតច្រើន គឺពុំមានទឹក ស្អាតគ្រប់គ្រាន់ ដើម្បីបំពេញតាមតំម្រូវការប្រជាពលរដ្ឋ ចំណែក ឯបណ្តាញទឹកឯកជន មានតំលៃថ្លៃ១$M^៣$ តម្លៃ ១៥០០រៀលគឺមានតម្លៃថ្លៃជាងទឹករបស់រដ្ឋករទឹកកម្ពុជាក្នុងទីក្រុង។

៣.បណ្តាញអគ្គិសនី

នៅតំបន់នេះពុំមានភ្លើងអគ្គិសនី រដ្ឋប្រើប្រាស់ទេ គឺមានតែបណ្តាញអគ្គិសនីឯកជន នៅតាម ដងផ្លូវសំខាន់ ៗ និងនៅទីប្រជុំជន់ប៉ុណ្ណោះ ហើយបណ្តាញអគ្គិសនី ឯកជន មានចាប់ពីម៉ោង ដប់ប្រាំបីទៅម៉ោង ម្ភៃបី ហើយការប្រើប្រាស់អគ្គិសី គិតទៅតាមចំនួនអំពូល បើប្រៀបធៀបតំលៃប្រើ ប្រាស់ នៅតំបន់នេះទៅ និងទីក្រុងភ្នំពេញ គឺមានភាពខុសគ្នាឆ្ងាយ។ ម្យ៉ាងទៀតសេវាអគ្គសី នៅតំបន់នេះ ពុំគ្រប់គ្រាន់សំរាប់តំម្រូវការរបស់ប្រជាពលរដ្ឋ ប្រើប្រាស់ទេ ពិសេសប្រជាជនភាគច្រើន ដែលរស់នៅឆ្ងាយ ពីតំបន់ទីប្រជុំជន ពុំមានអគ្គីសនីប្រើប្រាស់ឡើយ។

### ឃ. ទិសដៅនៃការអភិវឌ្ឍន៍

ដោយសារតែមើលឃើញពីភាពលំបាករបស់ប្រជាពលរដ្ឋក្នុងតំបន់ដែលជួបប្រទះនូវកង្វះខាតខាងលើគ្រប់វិស័យ និងដោយសារកំនើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញសាលាក្រុងមានទិសដៅធ្វើការពង្រីកក្រុង ដោយធ្វើការសិក្សាបង្កើតឲ្យមានខ័ណ្ឌថ្មី (អរិយក្សត្រ)។ ទិសដៅរបស់សាលាក្រុងក្នុងការអភិវឌ្ឍន៍ក្នុងតំបន់នេះ ផ្តោតទៅលើវិស័យ១ចំនួនដូចជា កែលំអរទៅលើប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងសុខភាពសាធារណៈ ការអប់រំទូទៅ សេដ្ឋកិច្ចនិងសង្គមកិច្ចប្រព័ន្ធផ្លូវគមនាគមន៍ លូ ប្រឡាយ និងទំនប់ បណ្តាញទឹកស្អាត និងបណ្តាញអគ្គីសនី ដើម្បីធានាឲ្យមានការអភិវឌ្ឍន៍ន៍ដោយនិរន្តភាព។ចំពោះគំម្រោងការអភិវឌ្ឍន៍តំបន់ អរិយក្សត្រ គឺស្ថិតក្នុងរយៈពេលកំពុងសិក្សារបស់ការិយាល័យកិច្ចការនគរូបនីយកម្មរាជធានីភ្នំពេញនូវឡើយពុំទាន់មានការដាក់ជូនទៅគណៈរដ្ឋមន្ត្រីដើម្បីធ្វើការអនុម័តលើគំម្រោងនៅឡើយ។ ក្នុងកិច្ចការអភិវឌ្ឍន៍តំបន់នេះ ការិយាល័យកិច្ចការនគរូបនីយកម្មរាជធានីភ្នំពេញ បានធ្វើការសិក្សាលើគំម្រោងជាពី ប្រភេទគឺ គំម្រោងជាអាទិភាពដែលត្រូវអភិវឌ្ឍន៍ជាបន្ទាន់ និងគំម្រោងដែលត្រូវអភិវឌ្ឍន៍រយៈពេលវែង ហើយគំម្រោងដែលត្រូវធ្វើជាអាទិភាព គឺការរៀបចំធ្វើជាប្លង់មេនៃតំបន់សំរាប់បំរើដល់ការងារអភិវឌ្ឍន៍។ គំម្រោងដែលតំរូវឲ្យធ្វើការសិក្សា ដើម្បីអភិវឌ្ឍន៍តំបន់នេះមានដូចជា៖

១. លំនៅដ្ឋាន

នៅតំបន់នេះត្រូវរៀបចំលើកគំម្រោងគំរូដល់ផ្ទះទាំងឡាយណាដែលងាយរងគ្រោះដោយទឹកជំនន់ដូចជាបញ្ហាការពារមិនឲ្យលំនៅដ្ឋាន របស់ប្រជាពលរដ្ឋមានការជន់លិចដូចពេលមុន។ ការរៀបចំបណ្តាញប្រឡាយបង្ហូរទឹកភ្លៀងដល់ផ្ទះទាំងឡាយណា ដែលសង់លើនីវ៉ូ នៅលើដីទាបជាងគេមិនតែប៉ុណ្ណោះ លំនៅដ្ឋាននៅតំបន់នោះក៏ត្រូវរៀបចំធ្វើឲ្យមានជា បង្គន់អនាម័យ ត្រឹមត្រូវនិងគ្រប់គ្រាន់ដើម្បីជៀសវាងនៅបញ្ហាផ្សេងៗដូចជាសុខភាពជាដើម។

២. ការអប់រំ

សាលាក្រុងមានគពោងបន្ថែមចំនួនអាគារសិក្សាដើម្បីតំរូវការដល់ថ្នាក់វិទ្យាល័យ អនុវិទ្យាល័យ និងមត្តេយ្យសិក្សា ឲ្យបានជាស្តង់ដានៃការសិក្សាគឺដើម្បីឲ្យសិស្សនៅតំបន់នេះ រៀនបានពីថ្នាក់តូចរហូតដល់វិទ្យាល័យ។ បន្ទាប់មកត្រូវធ្វើការជំរុញលើកទឹកចិត្តកុមារ ទាំងពីរភេទដែលត្រូវគ្រប់អាយុចូលរៀនឲ្យចូលសាលារៀននៅក្នុងភូមិឃុំរបស់ពួកគេ។

៣.សុខភាពសាធារណៈ

សាលាក្រុងមានគំម្រោងបង្កើតបន្ថែមនូវមណ្ឌលសុខភាពសាធារណៈក្នុងតំបន់នេះបន្ថែមដើម្បីបំពេញតំរូវការដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់នេះ ពីព្រោះភាគច្រើនប្រជាជន រស់នៅឆ្ងាយពីមណ្ឌលសុខភាព ហើយនិងបង្កើតបន្ថែមនូវឪសថស្ថានមួយដែលមានថ្នាំគ្រប់គ្រាន់ដើម្បីបំពេញតំម្រូវការរបស់ប្រជាជននៅតំបន់នេះតំម្រូវការគ្រូពេទ្យជំនាញឲ្យមានរហូតទៅដល់ថ្នាក់ភូមិឬ ឃុំដើម្បីបង្កើតនូវជំនឿទុកចិត្ត ពីរប្រជាពលរដ្ឋលើគ្រូពេទ្យមូលដ្ឋាន។

៤. អាជីវកម្ម និងទីផ្សារ

សាលាក្រុងមានគំម្រោងបង្កើតទីផ្សារបន្ថែមទៀតសំរាប់ជាតំម្រូវការដល់ប្រជាជនដើម្បីមានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម ខ្នាតតូច និងសំរាប់លក់ផលិតផលរបស់ប្រជាជនដែលធ្វើបាននៅតំបន់នោះ។ គំម្រោងជំរុញនិងលើកទឹកចិត្តដល់អាជីវកម្ម ដែលមានលក្ខណៈជាគ្រូសារ ក្នុងគោលបំណងដើម្បីធ្វើឲ្យកម្រិតសេដ្ឋកិច្ចគ្រូសាររបស់ប្រជាពលរដ្ឋក្នុងតំបន់កើនឡើង មួយកំរិត និងធ្វើឲ្យជីវភាពប្រជាពលរដ្ឋចាកផុតពីភាពក្រីក្រលំបាកដែល ធ្លាប់មានកន្លង មក។ គំម្រោងកែលំអរទីផ្សារ ដែលមានស្រាប់ដោយមានលក្ខណៈត្រឹមត្រូវតាមស្តង់ដាទីផ្សារនៅជនបទ និង ប្រកបទៅដោយដោយបរិស្ថានល្អ បរិសុទ្ធគំម្រោងសាងសង់អគារផ្សារថ្មី លើផ្ទៃដី១ ហិចតាដែលមានតំលៃស្មើ ២០០០.០០០ ដុល្លារ។

៥. បណ្តាញអគ្គីសនី

ដើម្បីជួយលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ឲ្យមានលក្ខណៈល្អប្រសើ និងជួយដោះស្រាយនូវទុក្ខលំបាករបស់ប្រជាពលរដ្ឋ ដោយសារតែបញ្ហាកង្វះខាតបណ្តាញអគ្គីសនី សាលាក្រុងមានគំម្រោងធ្វើការតបណ្តាញខ្សែកាបអគ្គីសនីកាត់តាមខាងក្រោមទន្លេ មេគង្គនិងកាត់តាមដងផ្លូវសំខាន់ៗ។ គំម្រោងបណ្តាញអគ្គីសនីកាត់ក្រោមទន្លេមេគង្គ គឺវាជាគំម្រោងមួយដែលការពិបាកដែលសាលាក្រុងកំពង់ធ្វើការសិក្សា ចំណែកការតបណ្តាញអគ្គីសនី តាមដងផ្លូវសំខាន់ មានតំលៃប្រហែលស្មើ៥០.០០០ដុល្លារក្នុង១គីឡូម៉ែត្រ ហើយបណ្តាញនេះត្រូវតប្រវែង ១៧.៧គីឡូម៉ែត្រ។ ម្យ៉ាងទៀតការតបណ្តាញអគ្គីសនីទាំងពីរត្រូវប្រើត្រង់ស្វ័មាទ័រ ដែលមានតំលៃ ១៦០០០ដុល្លារក្នុង ១គ្រឿង រីឯបន្ទប់អគ្គីសនីមានទំហំ ស្មើ៤

គុណានិង៥ គុណានិង ៩មានតំលៃស្មើ ២០០០០ដុល្លារ ក្នុង១គ្រឿង ហើយបណ្តាញអគ្គីសនីនៅតំបន់ នេះត្រូវការត្រង់ស្វូមាទ័រចំនួន ១៧គ្រឿង។

៦. បណ្តាញទឹកស្អាត

ចំពោះគំម្រោងរៀបចំទឹកស្អាត ជាជំហានដំបូងសាលាក្រុងមានគំម្រោងរៀបចំធ្វើប្លង់មេនៃបណ្តាញទឹកស្អាតតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវដើម្បីកំណត់តំបន់ដែលជាអទិភាពត្រូវរៀបចំមុនគេនិងចាត់ចែងរៀបចំជួសជុលបណ្តាញទឹកដែលមានស្រាប់ឲ្យមានដំណើរការល្អដែលធានានូវតំលៃមួយសមស្របទៅតាមជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់។ទន្ទឹមគ្នានេះដែរដើម្បីធានាឲ្យមានការប្រើប្រាស់ទឹកស្អាត និងប្រកបដោយអនាម័យហើយផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ សាលាក្រុងមានគំម្រោងតំឡើងនូវ អាងចំពោះទឹកមួយសំរាប់ចែកចាយតាមបំពង់ឲ្យដល់ទីប្រជុំជននានាក្នុងតំបន់។

៧. រៀបចំទីផ្លាកំសាន្តសាធារណៈ

ទាក់ទង និងការរៀបចំទីផ្លារកំសាន្តសាធារណៈតាមដងមាត់ទន្លេ សាលាក្រុងបានធ្វើការសិក្សាលើគំម្រោងហើយប៉ាន់តំលៃនីមួយៗដោយយកគំរូតាមតំលៃសួនច្បារតាមផ្លូវស៊ីសុវត្ថិជាប់និងមាត់ទន្លេដែលមានដូចជា៖

- ការឺឡា ក្រាលតំលៃ ៧ដុល្លារក្នុងមួយម៉េត្រការេ
- បង្គោលភ្លើងតំលៃ ៥០០ដុល្លារក្នុងមួយបង្គោល
- បង់អង្គុយធម្មតាតំលៃ ២៥ដុល្លារក្នុងមួយបង់
- បង់អង្គុយវែងតាមច្រាំងទន្លេតំលៃ ៧០ដុល្លារក្នុងមួយម៉ែត្រការេ
- ដើមឈើតូចមួយដើមតំលៃ មួយដុល្លារ
- ដើមឈើកំពស់មួយម៉ែត្រតំលៃ ៥ដុល្លារ
- ដើមឈើធំតំលៃ ៥០ដុល្លារ
- កម្រាលស្មៅមួយម៉ែត្រការេតំលៃ ៣ដុល្លារ។

៨. ចរាចរណ៍ និងប្រព័ន្ធផ្លូវ

ចំពោះប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវសាលាក្រុងមានគំម្រោងធ្វើការកែលំអរ និងជួសជុល ផ្លូវដែលមានស្រាប់ ដើម្បីបម្រើដល់ការអភិវឌ្ឍន៍នានានៅតំបន់និងរៀបចំប្លង់មេនៃប្រព័ន្ធផ្លូវ និង ចរាចរណ៍ និងការលើកឡើងនូវគំម្រោងអំពីផ្លូវណាដែលជាអទិភាពត្រូវធ្វើការជួសជុល។ចំណែកផ្លូវទឹកវិញ ការិយាល័យ

នគរូបនីយកម្មរាជធានីភ្នំពេញ មានគំម្រោងបង្កើតស្ថាន១ដើម្បីធ្វើឲ្យមានលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងតំបន់នេះ។

## សេចក្ដីសន្និដ្ឋាន

សរុបមកយើងសនិដ្ឋានជារួមបានថាការរៀបចំទីក្រុងតាមបែបយុគសម័យទំនើបហើយ សោភ័ណភាពរាជធានីភ្នំពេញ និងការប្រែមុខមាត់ថ្មី ដូចជា ការស្តារការថែរក្សា និងការអភិវឌ្ឍ ហេដ្ឋានរចនាសម្ព័ន្ធរបស់ទីក្រុងភ្នំពេញ ចាប់ពីក្រោយពេលមានការបង្រួបបង្រួមជាតិឆ្នាំ១៩៩១ មកពុំសូវមានសកម្មភាពអ្វីទេ ហេតុទទួលរស់នៅការខូចខាត និងទ្រុឌទ្រោមទៅៗ ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ រួចមក ទីក្រុងបានស្តារឡើងវិញ ដែលការប្រឹងប្រែង នាពេលនោះពុំសូវទទួលបានលទ្ធផលល្អទេ ដោយសារតែគ្មានសភាពការណ៍សន្តិសុខ នយោបាយផ្ទៃក្នុងនៃរដ្ឋាភិបាល ចម្រុះអាណត្តិទី១ ពុំអនុគ្រោះឱ្យ ។

បន្ទាប់ពីព្រឹត្តិការណ៍ថ្ងៃទី៥-៦ កក្កដា ឆ្នាំ១៩៩៧ ត្រូវបានរៀបចំគម្រោងការស្តារឡើងវិញ នៃក្រុងភ្នំពេញ ដោយអាជ្ញាធរក្រុងភ្នំពេញ នូវហេដ្ឋារចនាសម្ព័ន្ធក្រុងភ្នំពេញ នៅក្នុងសន្និបាតការងារស្តារហេដ្ឋារចនាសម្ព័ន្ធថ្ងៃទី១៥ តុលា ឆ្នាំ១៩៩៧ ។ យុទ្ធនាការបូមស្តារប្រឡាយ លូទឹក ស្អុយ ផ្លូវ នៅក្រុងភ្នំពេញបានប្រសើរជាងមុន ហើយមួយរយៈពេលក្រោយមក ទីក្រុងភ្នំពេញបានក្លាយទៅជាទីក្រុង ស្រស់បំព្រងគ្មានក្លិនស្អុយ មានភ្លើងពណ៌ខ្វាតខ្វែង និងមិនមានភាពងងឹតខូចមុនឡើយ ។

ក្នុងឆ្នាំ២០០១ សាលាក្រុងភ្នំពេញបានបើកយុទ្ធនាការអភិវឌ្ឍ និងលម្អសោភ័ណភាពទីក្រុងបន្ថែមទៀត និងបង្ហាញពីភាពរីកចម្រើនរបស់ទីក្រុងភ្នំពេញ ។ រហូតមកដល់បច្ចុប្បន្ន យើងឃើញថា មានការរីកចម្រើននៃការរៀបចំក្រុង ត្រូវគោរពទៅតាមច្បាប់នគរូបនីយកម្ម ច្បាប់ភូមិបាល ដែលក្នុងនោះមានការរៀបចំប្លង់គោល ជាទូទៅគឺគេចែងអំពីទស្សនៈវិស័យ នៃការអភិវឌ្ឍដីធ្លី និងសំណង់ និងលិខិតអនុញ្ញាតសាងសង់ ត្រូវគោរពទៅតាមប្លង់គោលជានិច្ច ។ សម្រាប់ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ គឺជាប្លង់មួយដែលដើរតួនាទីសំខាន់មួយដែរ នៅការរៀបចំទីក្រុងឱ្យមានសណ្តាប់ធ្នាប់ និងពោរពេញទៅដោយ

សោភ័ណភាព ហើយមានលក្ខណៈត្រឹមត្រូវតាមច្បាប់នគរូបនីយកម្ម រាល់សំណង់ទាំងឡាយ ដែលបានស្ថាបនាឡើងត្រូវគោរពទៅតាមប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ។ ហើយនៅក្នុងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ក៏ត្រូវឱ្យមានបទប្បញ្ញត្តិមួយចំនួនទៀត ក្នុងគោលបំណងដើម្បីការពារ និងលើតម្លៃរមណីយដ្ឋាន ឬអចលនទ្រព្យណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ និងសោភ័ណភាពរបស់តំបន់ជាក់ស្តែងដូចជា សៀមរាបអង្គរ នៅក្នុងខេត្តសៀមរាបឱ្យក្លាយទៅជាតំបន់សណ្ឋាគារ តំបន់ទេសចរណ៍ តំបន់ធម្មជាតិ ដែលត្រូវខេត្តសៀមរាប តំបន់ស្រះទឹកបុរាណ នៅតាមផ្លូវជាតិលេខ៦ តំបន់នៅសងខាងស្ទឹងសៀមរាប ដែលតំបន់ទាំងអស់នេះ ត្រូវគ្រប់គ្រងដោយអនុក្រឹត្យស្តីពីការប្រើប្រាស់ដីធ្លី និងសំណង់ នៅតំបន់សៀមរាប ហើយអនុក្រឹត្យនេះ ក៏បានចែងនូវបទប្បញ្ញត្តិមួយចំនួនដែលទាក់ទងនិងទិដ្ឋភាពរួម នៃប្រភេទតំបន់ នៃការប្រើប្រាស់ដីផ្លូវចេញចូល និងការរៀបចំលិខិតអនុញ្ញាតសាងសង់វិញ ក៏ជាផ្នែកមួយក្នុងការជួយថែរក្សាសណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាពសោធារណៈ សុវត្ថិភាពសាធារណៈ និងបរិដ្ឋានទីក្រុង ឱ្យមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ ដោយស្នើលិខិតអនុញ្ញាតសាងសង់ និងមានការពង្រីកទីក្រុង ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានាទៀត ហើយអភិវឌ្ឍន៍តំបន់មួយចំនួន ឱ្យក្លាយទៅជាតំបន់អភិរក្សដូចសព្វថ្ងៃ ៕

## ឯកសារយោង

- ច្បាប់នគរូបនីយកម្មឆ្នាំ ១៩៩៤
- អនុក្រឹត្យលេខ ៨៦ អនប្រក បក ស្តីពីលិខិតសាងសង់
- សារណា "ការអភិវឌ្ឍ និងការកែលំអរាជធានីភ្នំពេញក្រោយ១៩៩៣"
- ឯកសារផ្សេងពាក់ព័ន្ធ

# គន្លឹះទី៥

# គុណសម្បត្តិនៃការផ្តល់សម្បទានដីសង្គមកិច្ច

## សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ ។ បន្ទាប់ពីបានសន្តិភាព និងស្ថេរភាពនយោបាយបានតាមរយៈការបញ្ចប់សង្គ្រាមស៊ីវិល រ៉ាំរ៉ៃដែលបានអូសបន្លាយជាងពីទសវត្សន៍កន្លងទៅពោលគឺចាប់ឆ្នាំង១៩៧០រហូតមកដល់ចុងឆ្នាំ ១៩៩៨ ប្រទេសមួយ នេះបានទទួលរងគ្រោះពីសង្គ្រាមរាំរ៉ៃយ៉ាងធ្ងន់ធ្ងរបំផុតពិបាននិងថ្លែង។ ទាំងធនធានធម្មជាតិទាំងហេដ្ឋារចនាសម្ព័ន្ធ និងទាំងជីវិតមនុស្សរាប់លាននាក់ត្រូវបានបាត់បង់ ហិនហោចខ្លោចផ្សា ដែលយើងមិនអាចសោកស្តាយមិនបាន។បន្ទាប់ពីបញ្ចប់សង្គ្រាមស៊ីវិលនៅចុងឆ្នាំ ១៩៩៨ ភ្លាម ប្រទេសកម្ពុជានិយាយជាទូទៅនិយាយបែបផ្សេងប្រជាជនខ្មែរ គ្រប់រូបផ្តើមស្គាល់ក្លិនសន្តិភាព ដែលខ្លួនតែងតែប្រាថ្នាស្រមើស្រមៃចង់បានគ្រប់វិនាទី។ សន្តិភាពគឺគ្រាន់តែជាតម្រូវការចំបងបំផុតមួយនៅក្នុងកាលៈទេសៈឬបរិបទនៃសង្គ្រាមប៉ុណ្ណោះ។ ក្រៅពីសុខសន្តិភាព និងស្ថេរភាពនយោបាយនារយៈពេលជាង១៥ឆ្នាំចុងក្រោយនេះចាប់រាប់ពីឆ្នាំ១៩៩៨ រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រជាជនខ្មែរគ្រប់រូបចង់បានការរស់នៅមួយប្រកបដោយភាពសមរម្យ និង ថ្លៃថ្នូរនិយាយចចំទៅគឺចង់បានស្តង់ដារស់នៅមួយដែលមានលក្ខណៈល្អប្រសើរ។

ដើម្បីបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋខ្លួនថ្នាក់ដឹកនាំប្រទេសមួយនេះមិនបានប្រងើយកន្តើយសោះឡើយ ពោលគឺបានបង្កើតស្ថាប័នសំខាន់ៗជាច្រើន ដែលមានទួនាទី និងភារកិច្ចក្នុងការស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្លួនឲ្យមានលក្ខណៈកាន់តែល្អប្រសើរជាងមុនប្រកបដោយសន្តិភាព ចីរភាព វិបុលភាព និងវឌ្ឍភាព នោះគឺការបង្កើត

សម្បទានដីសង្គមកិច្ចដើម្បីកាត់បន្ថយភាពក្រីក្រ ។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្តើមស្គាល់ការរីកលូតលាស់សេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចខ្លាំងជាពិសេសនៅអំឡុងពេលឆ្នាំ២០០៥ ល់ឆ្នាំ២០០៨ ទោះបីជាវាបានស្ទុះឡើងក្នុងភាពអនាធិបតេយ្យ ទោះបីជាវាបានធ្វើឲមានគម្លាតកាន់តែធំរវាងអ្នកមាននិងអ្នកក្រ និងទោះបីជាវាបានបង្កើនអំពើពុករលួយនៅក្នុងសង្គមយ៉ាងណាក៏ដោយក្តី ក៏វាបានធ្វើឲ្យជីវភាពប្រជាជនទូទៅស្គាល់ការរីកចំរើនមិនតិចដែរ នេះក៏ជាលទ្ធផលបានមកពីថ្នាក់ដឹកនាំជាពិសេសគឺគណៈកម្មាធិការសម្បទានដីសង្គមកិច្ច ទាំងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិទាំងមូល ។

## ជំពូកទី១ សញ្ញាណទូទៅ និង ការបង្កើតសម្បទានដីសង្គមកិច្ច

### ១.សញ្ញាណទូទៅ

#### ១.១.ប្រវត្តិនៃសម្បទានដីសង្គមកិច្ច

អនុលោមតាមច្បាប់ខ្មែរកាលពីសម័យដើម ព្រះមហាក្សត្រគឺជាម្ចាស់លើដីទាំងអស់ នៅក្នុងប្រទេសទាំងមូល ។ ទោះបីយ៉ាងណាក៏ដោយ សិទ្ធិភោគៈរបស់ប្រជារាស្ត្រនៅលើដីធ្លីត្រូវបានទទួលស្គាល់និងការពារ ។ អនុសញ្ញាឆ្នាំ១៨៨៧ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសបារាំងបានផ្ទេរ ឬប្រគល់អំណាច ផ្នែករដ្ឋបាលរបស់រដ្ឋទៅឲ្យបារាំង ។ នៅក្នុងឆ្នាំ១៩២០ ក្រមរដ្ឋប្បវេណីកម្ពុជាត្រូវបានប្រកាលឲ្យប្រើ ដែលបទបញ្ញត្តិទាំងឡាយ នៃក្រមនេះទាក់ទងទៅនឹងសិទ្ធិលើទ្រព្យសម្បត្តិ ដែលភាគីច្រើនយកតាមក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំង ។ បទបញ្ញត្តិទាំងនេះ បានចែងអំពីភាពខុសគ្នារវាងចលនវត្ថុ និងអចលនវត្ថុ និយមន័យនៃកម្មសិទ្ធិ និងសិទ្ធិភោគៈ។ ក្រោមព្រះរាជបូជនីយកិច្ចរបស់ព្រះបាទ នរោត្តម សីហនុ ប្រទេសកម្ពុជាបានទទួលឯករាជ្យ ក្នុងឆ្នាំ១៩៥៣ ប៉ុន្តែប្រទេសកម្ពុជាជាប្រទេសដែលប្រើប្រព័ន្ធច្បាប់ រ៉ូម៉ាណូ-ហ្សេម៉ានិក (Romano-Germanic) អស់រយៈពេលជាង៣០ ឆ្នាំ និងបន្តអភិវឌ្ឍជាលំដាប់។ បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែល ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនៅតែអនុវត្តក្នុងរយៈពេលនេះ។របបដីបានផ្លាស់ប្តូរយ៉ាងគំហុកពីឆ្នាំ ១៩៧៥-១៩៧៩ ជាប្រវត្តិសាស្ត្រ កម្ពុជាក្នុងសម័យនោះមិនមានច្បាប់ស្តីពីទ្រព្យសម្បត្តិទេ។ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់។ រាល់ទ្រព្យសម្បត្តិទាំងអស់ គឺជាទ្រព្យសម្បត្តិរបស់សមូហភាព។

ចាប់ពីឆ្នាំ១៩៧៩មក សិទ្ធិលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនមិនត្រូវបានទទួលស្គាល់ដោយច្បាប់ឡើយ ប៉ុន្តែមានការកែទម្រង់ក្នុងឆ្នាំ ១៩៨៩ មុនការអនុម័តរដ្ឋធម្មនុញ្ញថ្មីបន្តិច តាមរយៈ ការអនុម័តអនុក្រឹត្យលេខ២៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើផ្ទះសំបែង ជូនប្រជាជន។ ក្រោយ

មកទៀត តាមរយៈការអនុម័តសេចក្តីណែនាំលេខ០៣ សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពីការអនុវត្តគោលនយោបាយប្រើប្រាស់ និងគ្រប់គ្រងដីធ្លីបានទទួលស្គាល់សិទ្ធិកម្មសិទ្ធិលើដីធ្លីលំនៅឋាន។ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ភូមិបាលថ្មី (ច្បាប់ភូមិបាលឆ្នាំ ១៩៩២)។ និយមន័យនៃពាក្យកម្មសិទ្ធិ អនុលោមតាមមាត្រា១៩ បានចែងឡើងវិញអំពីគោលការណ៍ ច្បាប់នៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ។ នៅឆ្នាំ១៩៩៣ ជាមួយនឹងការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញថ្មី កម្ពុជាបានក្លាយជាព្រះរាជាណាចក្រ កម្ពុជាទី២ ហើយបានបង្កើតឲ្យមានរដ្ឋាភិបាលថ្មីមួយ។ មាត្រា៤៤ នៃរដ្ឋធម្មនុញ្ញនេះបានបញ្ជាក់អះ អាងសាជាថ្មីស្តីពីសិទ្ធិក្នុងការធ្វើជាម្ចាស់លើដីធ្លី ។ ដូច្នេះ ប្រភពនៃសម្បទានដីសង្គមកិច្ចមានឯកសារជាច្រើនដូចជាៈ

-សេចក្តីព្រាងច្បាប់សម្រាប់ជំនួសច្បាប់ភូមិបាលឆ្នាំ ១៩៩២ ត្រូវបានរៀបរៀងឡើងដោយផ្អែកភាគច្រើនលើច្បាប់ភូមិបាលឆ្នាំ១៩៩២ និងបានដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងខែតុលា ឆ្នាំ ១៩៩៨ ។ មានការជំទាស់យ៉ាងច្រើនគួរឲ្យកត់សម្គាល់ទៅលើសេចក្តីព្រាងនេះ ទើបជំរុញឲ្យមានការតាក់តែងសេចក្តីព្រាងថ្មីមួយទៀត ។

-សេចក្តីព្រាងច្បាប់ភូមិបាល ខែមេសា ឆ្នាំ២០០០។

-សេចក្តីព្រាងច្បាប់ភូមិបាល ខែសីហា ឆ្នាំ២០០០។

-សេចក្តីព្រាងច្បាប់ភូមិបាល ខែវិច្ឆិកា ឆ្នាំ២០០០។

-សេចក្តីព្រាងច្បាប់ភូមិបាល ខែកក្កដា ឆ្នាំ២០០១ នេះត្រូវបានដាក់ជូនព្រឹទ្ធសភាពិនិត្យ ។ នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ព្រឹទ្ធសភាបានអនុម័តសេចក្តីព្រាងច្បាប់នេះ។ នៅថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០០១ ព្រះមហាក្សត្រព្រះបាទសម្តេចនរោត្តម សីហនុ បានឡាយព្រះហស្តលេខាប្រកាសឲ្យប្រើ ច្បាប់ភូមិបាលនេះ ។

### ១.២.និយមន័យនៃសម្បទានដីសង្គមកិច្ច

សម្បទានដីសង្គមកិច្ច ត្រូវបានផ្តល់ឲ្យដើម្បីឆ្លើយតបទៅនឹងប្រយោជន៍សង្គម ដែលអនុញ្ញាត ឲ្យអ្នកកាន់កាប់ទទួលយកប្រយោជន៍នេះទៅសង់ជាលំនៅឋាន ឬ ដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ដើម្បីធានាការចិញ្ចឹមជីវិតដែលយើងអាចនិយាយបានថា វាជាយន្តការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ច ដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។ ចំពោះការធ្វើកសិកម្មជាលក្ខណៈគ្រួសារ សំដៅដល់សកម្មភាពដាំដំណាំ ឬចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ដើម្បីបំពេញសេចក្តីត្រូវជាមូលដ្ឋាន។ ការដាំដំណាំចិញ្ចឹមជីវិតនេះ គឺអាច

និយាយបានថា មុខសញ្ញាអ្នកទទួលដីអាចដាំដំណាំប្រភេទផ្សេងៗគ្នា និងចិញ្ចឹមសត្វបានមិនត្រឹមតែដើម្បីចិញ្ចឹមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចរកប្រាក់ចំណូលសម្រាប់គ្រួសារ និងធ្វើ ឲ្យស្ថានភាពសេដ្ឋកិច្ចគ្រួសារប្រសើរឡើងថែមទៀតផង។

**១.៣. មូលដ្ឋានច្បាប់នៃសម្បទានដីសង្គមកិច្ច**

សម្បទានដីសង្គមកិច្ចនេះត្រូវគ្រប់គ្រងតាមច្បាប់ភូមិបាល ២០០១ មាតិកាទី ២ ជំពូកទី ៥ ស្តីពីសម្បទានដី និងអនុក្រឹត្យលេខ ១៩ អនក្រ.ប.ក ចុះថ្ងៃទី ១៩ មិនា ឆ្នាំ ២០០៣ ស្តីពី សម្បទានសង្គមកិច្ច។

**១.៤. គោលដៅនៃសម្បទានដីសង្គមកិច្ច**

សម្បទានដីសង្គមកិច្ចគឺ អនុញ្ញាតឲ្យអ្នកទទួលប្រយោជន៍(សម្បទានិក) រៀបចំដី ដើម្បីសាងសង់លំនៅស្ថាន និង/ឬ ដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីធានាការចិញ្ចឹមជីវិត។ គោលដៅនៃការផ្តល់ដីសម្បទានសង្គមកិច្ចមានដូចជាៈ

- ផ្តល់ដីដល់គ្រួសារក្រីក្រគ្មានទីលំនៅសម្រាប់សង់លំនៅស្ថាន
- ផ្តល់ដីដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ
- ផ្តល់ដីដល់គ្រួសារផ្លាស់ប្តូរទីលំនៅ បណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សម្រាប់តាំងទីលំនៅជាថ្មី
- ផ្តល់ដីដល់គ្រួសារមាតុភូមិនិវត្តន៍
- ផ្តល់ដីដល់គ្រួសារដែលរងគ្រោះដោយធម្មជាតិ
- ផ្តល់ដីដល់យោធិនរំសាយ និងគ្រួសារយុទ្ធជនពលីពិការ
- ជួយសម្រួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច
- ជួយសម្រួលសម្បទានសេដ្ឋកិច្ច ដោយផ្តល់ដីឡូតិ៍ដល់កម្មករចំការធំៗសម្រាប់សង់លំនៅស្ថាន ឬសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ
- អភិវឌ្ឍន៍តំបន់ដែលពុំទាន់អភិវឌ្ឍន៍សមស្រប។

**២. ការបង្កើតសម្បទានដីសង្គមកិច្ច**

**២.១. ការធ្វើផែនការសម្បទានដីសង្គមកិច្ច**

នៅក្នុងផែនការសម្បទានដីសង្គមកិច្ចនេះតម្រូវឲ្យបញ្ចូលនូវចំនុចសំខាន់គឺការធ្វើអត្តសញ្ញាណកម្មដី និងព័ត៌មាននៅក្នុងផែនការសម្បទានដីសង្គមកិច្ច។

**ក.ការធ្វើអត្តសញ្ញាណកម្មដី**

ដំណើការនៃផែនការសម្បទានដីអាចប្រព្រឹត្តទៅបានលុះត្រា តែអាជ្ញាធរមានសមត្ថកិច្ច ធ្វើ អត្តសញ្ញាណកម្មដីទៅលើដីនោះជាមុនសិនដូចដែលយើងដឹងរួចហើយថាការធ្វើ សម្បទានដី សង្គមកិច្ចច្បាប់អនុសញ្ញាតឲ្យធ្វើទៅលើដីឯកជនរបស់រដ្ឋតែប៉ុណ្ណោះដូច្នេះ ដោយអនុលោមទៅ តាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ គឺក្រុមប្រឹក្សា ឃុំ សង្កាត់ មានតួនាទីត្រូវធ្វើ អត្តសញ្ញាណកម្មដីនៅទំនេរដែលអាប្រើប្រាស់សម្រាប់សម្បទានដីសង្គមកិច្ចតាមរយៈ ការរៀប ចំផែនការប្រើប្រាស់ដី ឃុំ សង្កាត់ ក្រោមការត្រួតពិនិត្យរបស់កម្មាធិការប្រើប្រាស់ និង បែងចែក ដីថ្នាក់ខេត្ត ក្រុង។

ក្នុងការធ្វើអត្តសញ្ញាណកម្មដី ដែលស្ថិតក្នុងទ្រព្យឯកជនរបស់រដ្ឋតម្រូវឲ្យធ្វើ ចំណាត់ដី ។ ទ្រព្យឯកជនរបដ់រដ្ឋ ត្រុវបានកំណត់ជាដីនៅទំនេរបន្ទាប់ពីបានធ្វើ អត្ត សញ្ញាណកម្ម ដីសាធារណៈ និងដីឯកជនរបស់រដ្ឋរួចហើយ។តាមការសង្កេតជាទូទៅដីជាច្រើនដែលស្ថិតនៅក្នុង ទ្រព្យសម្បត្តិ ឯកជនរបស់រដ្ឋត្រូវបានប្រើប្រាស់រួចហើយ ឧទាហរណ៍ ដីសម្បទានកសិកម្ម ។ ដីខ្លះទៀតដែល កំពុងស្ថិតនៅក្នុងទ្រព្យសាធារណៈ របស់រដ្ឋ ប៉ុន្តែលែងបម្រើគោលដៅសាធារណៈទៀតហើនោះ បើចាំបាច់គួរផ្ទេរមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋវិញ ឧទាហរណ៍ តំបន់ព្រៃរេចរិលដែលមិន អាចបង្ករជាព្រៃឡើងវិញបាន។ នៅតំបន់ខ្លះទៀត ដីឯកជនរបស់រដ្ឋត្រូវកាន់កាប់ដោយខុសច្បាប់ ឬត្រូវបានរំលោភយក។នៅក្នុងច្បាប់ភូមិបាលត្រង់មាត្រា ១៩ បានកំណត់ចំពោះលទ្ធកម្មណាមួយ ដោយខុសច្បាប់ និងដោយចេតនាឬ ដោយប្រើប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬ របស់នីតិបុគ្គលសាធារណៈត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់ ភូមិបាលចែងថា ការប៉ះពាល់កម្មសិទ្ធិនៃទ្របព្យសម្បត្តិសាធារណៈត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលានរៀល ដល់ ៥០.០០០.០០០(ហាសិបលានរៀល) ឬ ផ្តន្ទាទោសដាក់ពន្ធធានាគារពី ១ (មួយ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ។

នៅតំបន់ជាច្រើន ដីធ្លីមិនទាន់បានធ្វើចំណាត់ថ្នាក់ជា ដីសាធារណៈរបស់ ឬជា ដីឯកជន នៅឡើយ។នៅតំបន់ដែលបានកំណត់អត្តសញ្ញាណកម្មដីទើបធ្វើបានតិចតួច ឬ ពុំទាន់ធ្វើនៅតំបន់ នោះ គួរជ្រើសរើសយកនីតិវិធីនៃការចុះបញ្ជីជាលក្ខណៈប្រពន្ធ័ជា ជំរើស ទី១ ដើម្បីកំណត់ទំហំ និងលក្ខណៈច្បាប់នៃតំបន់ទាំងនោះ ។ នីតិវិធីរួមមាន ការកំណត់អត្តសញ្ញាណកម្មនៃតំបន់ ដែលប៉ានស្មានថាជាដីរបស់រដ្ឋ និង ជាដីឯកជន ដោយប្អែកលើឯកសារដែលមានស្រាប់ ដូចជា ផែនទីរូបថតនិងការវាយតម្លៃនៅនឹងកន្លែង ។ តាមនីតិវិធីនេះ គេអាចសាងព្រំប្រទល់ទូទៅប៉ុណ្ណោះ ដែលអាចប្រើប្រាស់បានសម្រាប់ គោលដៅធ្វើផែនការ និង សម្រាប់អនុវត្តន៍ការ ចុះបញ្ជី សារពើភណ្ឌដីរដ្ឋ ។ ដើម្បីធ្វើ អត្តសញ្ញាណកម្មដី ចំណាត់ថ្នាក់ដី និងផែនការប្រើប្រាស់ដី ក្រុមប្រឹក្សាឃុំ សង្កាត់ អាច ទទួលយកបច្ចេកទេសពីមន្ត្រីថ្នាក់ខេត្ត

ក្រុង និងស្រុក ខណ្ឌ កន្លែងដែលមានក្រុមបច្ចេក ទទេសដូចជា PULU ឬ LUMU ធនធានរបស់គេអាចប្រើប្រាស់ ដើម្បីជួយដល់ការងារនេះ ។ PULU គឺជាអង្គភាពដែលមានភរកិច្ចធ្វើផែនការប្រើប្រាស់ដី ដែលត្រូវបានបង្កើតឡើងនៅខេត្តបាត់ដំបងដើម្បីធ្វើការទាក់ទងនឹងបញ្ហាអន្តរវិស័យ ពាក់ព័ន្ធនឹងដីដោះមីនរួចហើយផ្តល់ដីនោះដល់ប្រជាពរដ្ឋក្រីក្រ សម្រាប់សង់លំនៅដ្ឋាន និងធ្វើកសិកម្ម ។ ចំណែកឯអង្គភាពមួយទៀតឈ្មោះថា LUMU គឺជាអង្គភាពដែលមានភារកិច្ចគ្រប់គ្រងការ ប្រើប្រាស់ដី ហើយត្រូវបានបង្កើតឡើងនៅ ខេត្តបន្ទាយមានជ័យ និង មានគោលដៅដូចគ្នា ពាក់ព័ន្ធនឹងដីដោះមីនរួចហើយ។ ទស្សនៈរបស់ PULU ឬ LUMU ត្រូវបានបើកទូលាយ ដោយនៅពេលថ្មីៗនេះ ខេត្តក្រុងចំនួន ៨ ផ្សេងបានបហ្កើត PULU ឬ LUMU ដូចគ្នា នេះដែរ ។ ចំពោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ត្រូវធ្វើផែនទីសុរិយាដី ផែនទីឋានលេខ និង រូបថតសម្រាប់ឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមការងារថ្នាក់ស្រុក ខណ្ឌ និង គណៈកម្មាធិការ ប្រើប្រាស់ និង បែងចែកដីថ្នាក់ ខេត្ត ក្រុង អាចប្រើប្រាស់បាន ដើម្បី រៀបចំផែនការប្រើប្រាស់ដី ។ ផែនការប្រើប្រាស់ដីដែលបានរៀបចំរួចត្រូវបង្ហាញពីចំណាត់ ថ្នាក់ដីនិងពី ដីទំនេដែលរក្សាទុក ហើយត្រូវបិទផ្សាយដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។ ច្បាប់ចម្លងត្រូវរក្សាទុកដោយក្រុមការងារថ្នាក់ ស្រុក ខណ្ឌ័ និងគណៈកម្មការប្រើប្រាស់និង បែងចែកដីថ្នាក់ខេត្ត ក្រុងនិងគណៈកម្មការសម្បទាន ដីសង្គមកិច្ចថ្នាក់ជាតិ ។

**ខ.ព័ត៌មាននៅក្នុងផែនការសម្បទានដីសង្គមកិច្ច**

ដំណើការនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលបានដី ដូចជា តើមុខសញ្ញាអ្នកទទួល ដីនោះបានជ្រើសរើសដោយរបៀបណាអត្តសញ្ញាណដី ដែលមុខសញ្ញាអ្នកទទួលដីម្នាក់ៗត្រូទទួល ដីនិង? ថាតើត្រូវធ្វើការបែងចែកយ៉ាងដូចម្តេចជាដើម (ចំនុចទាំងនេះនឹងបញ្ជាក់យ៉ាងពិស្តារនៅក្នុង ផ្នែកទី២) និង ការកំណត់ដីទំនេរត្រូវបានគិតគូរ នៅក្នុងផែនការបែងចែកដីសម្បទានសង្គមកិច្ច ដោយក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមការងារថ្នាក់ស្រុក ខណ្ឌ័។ ផែនការនេះត្រូវមានការលំអិតលើក្បាល ដីជាក់លាក់ សម្រាប់ធ្វើសម្បទាន និង លើសំណុំឯកសារពេញលេញរបស់អ្នកសុំម្នាក់ៗ ។ ផែនការនោះត្រូវបានដាក់ជូនទៅ គណៈកម្មាធិការ ប្រើប្រាស់និងបែងចែកដីថ្នាក់ ខេត្ត ក្រុង ដើម្បីសុំការសម្រេចយល់ព្រមឬកែសម្រួលនៅក្នុងកិច្ចប្រជុំនៅទីស្នាក់ការនៃក្រុមការងារស្រុក ខណ្ឌ័។ផែនការបែងចែកដីសម្បទានសង្គមកិច្ចត្រូវបញ្ជាក់អំពីទីតាំងទំហំ និង ចំនួនក្បាលដីដែល ត្រូវបែងចែកនិងបញ្ជីឈ្មោះមុខសញ្ញាអ្នកទទួលដីដែលបានទទួលអាទិភាពត្រូវទទួល ដីមុនគេ ដោយ មានចំនួនស្មើនឹងក្បាលដីហើយ "បញ្ជីរងចាំ" នៃអ្នកសុំ ដីត្រូវបានទទួលអាទិភាពបន្តទៀត ។ក្បាលដីទំនេរនឹងត្រូវផ្តល់ដល់មុខសញ្ញាអ្នកទទួលដីទៅតាមលំដាប់នៃបញ្ជីអាទិភាពមុខ

សញ្ញា អ្នកទទួលដី ។ បញ្ជីឈ្មោះអ្នកសុំសម្បទានដី ដែលមានអាទិភាព ដែលត្រូវបានជ្រើសរើស ដើម្បីទទួលបានដីសម្បទានសង្គមកិច្ចត្រូវបិទផ្សាយជាសាធារណៈ។ ផែនការបែងចែកដីសម្បទាន សង្គមកិច្ចក៏ត្រូវភ្ជាប់ជាមួយនូវការវាយតម្លៃអំពីលទ្ធផលហេដ្ឋារចនាសម្ព័ន្ធរូបវ័ននិងសង្គមព្រម ទាំងការវាយតម្លៃអំពីផលប៉ះពាល់សង្គមនិងបរិស្ថាន។គណៈកម្មាធិការប្រើប្រាស់និងបែងចែក ដីថ្នាក់ខេត្តក្រុង ត្រូវធ្វើការវាយតម្លៃផែនការ ដោយផ្អែកលើអនុសាសន៍ របស់ក្រុមការងារថ្នាក់ស្រុក ខណ្ឌហើយគិតគូរទៅតាមលទ្ធភាពដីដែលនៅទំនេរ និង តម្រូវការដី ទូទាំខេត្ត ក្រុង ។

គណៈកម្មធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវផ្តល់ការសម្រេចយល់ព្រម ឬ កែសម្រួលផែនការបែងចែកដីសម្បទានសង្គមកិច្ចដែលបានស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងហោចណាស់មួយឆ្នាំម្តង ។ នៅពេដែផែនការត្រូវបានយល់ព្រម ឬ កែសម្រួលរួចហើយ ក្រុមប្រឹក្សា ឃុំ សង្កាត់ ជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ផែនការនេះដោយមានជំនួយបច្ចេក ទេស ពីក្រុមការងារស្រុក ខណ្ឌ ។ ការអនុវត្តន៍មាន ៣ ដំណាក់កាលគឺ

១.ចេញឯកសារដីសម្បទានសង្គមកិច្ចដែលជាការទទួល ខុសត្រូវរបស់អង្គភាពគាំទ្របច្ចេកទេសការងារដីធ្លីនៃគណៈកម្មាធិការប្រើប្រាស់ និង បែងចែក ដីថ្នាក់ខេត្តក្រុង

២.ធានាថាសេវាសាធារណៈសមស្របផ្សេងៗត្រូវបានរៀបចំនៅនឹងកន្លែង សម្រាប់ មុខសញ្ញាអ្នកទទួលដីដើម្បីប្រើប្រាស់ឲ្យបានសមស្រប ។ កាងារនេះជាការទទួលខុសត្រូវរបស់ អង្គភាពគាំទ្របច្ចេកទេសសម្រាប់ការអភិវឌ្ឍន៍នៃគណៈកម្មាធិការប្រើប្រាស់ និង បែងចែកដីថ្នាក់ ខេត្ត ក្រុង

៣.ការតាមដានត្រួតពិនិត្យលើលក្ខខណ្ឌនៃការប្រើប្រាស់ដីសម្បទានសង្គមកិច្ចដែលជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ដូចបានបញ្ជាក់ពីខាងដើមរួចមកហើយថា ការរៀបចំផែនការសម្បទានដីសង្គមកិច្ច ទាមទារឲ្យមានការធ្វើផែនការយ៉ាងលំអិតបំផុតព្រោះបើ ផែនការមិនច្បាស់លាស់ សមិទ្ធិផលក៏មិនអាចទទួលបានដែរ ។ អាស្រ័យហេតុនេះផែនការ សម្បទានដីសង្គមកិច្ច ត្រូវតែធ្វើការវាយតម្លៃ អំពីសម្ភារៈដែលចាំបាច់ ដើម្បីអនុវត្តន៍ផែនការ ដូចជា ផ្លូវ សាលារៀន ផ្សារមណ្ឌលសុខភាព ឧបករណ៍ផ្សេងៗទៀត ព្រមទាំងសម្ភារៈសម្រាប់អភិវឌ្ឍន៍ដី ហើយត្រូវតែផ្តល់ព័ត៌មានដល់មុខសញ្ញាអ្នកទទួលដីអំពីរបៀប និងពេលវេលា ដែលពួកគេត្រូវបាន សម្ភារៈទាំងនោះ។ប្រសិនបើគ្មានធនធានទាំងនោះទេកម្មវិធីសម្បទានដីសង្គមកិច្ចទំនង ជាមិនអាចសម្រេចបានលទ្ធផល់ដែលចង់បានក្នុងការផ្តល់ដីសម្រាប់សង់លំនៅឋាននិង ដីសម្រាប់ ធ្វើកសិកម្ម ជាលក្ខណៈគ្រួសារក្រីក្របានឡើយ ។ នៅក្នុងផែនការសម្បទានដីសង្គមកិច្ច មិនអាចគ្រាន់តែនិយាយថាយើងនឹងស្នើសុំឲ្យអង្គការក្រៅរដ្ឋាភិបាលណាមួយជួយ

សាសង់ សាលា រៀនឲ្យប្រសិនបើផែនការដីសម្បទានសង្គមកិច្ចបានទទួលការអនុម័តយល់ព្រម។ ដូច្នេះ ផែនការ សម្បទានដីសង្គមកិច្ចត្រូវតែបង្ហាញថាអង្គការក្រៅរដ្ឋាភិបាលមួយនេះឬ មួយនោះបានផ្ញើលិខិត មកហើយថាពួកគេនេងជួយសាងសង់សាលារៀនឲ្យយើង ។ ផែនកានេះនឹងត្រូវបញ្ជូននូវពត៌ មានផ្សេងៗ ទៀតដូចជាផែនទីបង្ហាញពីទីតាំងសាលារៀន គម្រោងប្លង់សាលារៀន កាលវិភាគនៃ ការសាងសង់ សាលារៀនព័ត៌មានស្តីពីការបើកឲ្យចូលរៀន និង កិច្ចព្រមព្រៀងសម្រាប់ផ្តល់ ឲ្យលោកគ្រូ និង ប្រភព ធនធានផ្សេងៗទៀតសម្រាប់សាលារៀន ។ ជាលក្ខណ:ទ្រឹស្តី ផែនការសម្បទានដីសង្គមកិច្ច មិនគួរត្រូវ បានអនុម័តយល់ព្រម ឡើយប្រសិនបើមិនបានដាក់ បញ្ជូននូវព័ត៌មានលំអិតឲ្យបានប្រហាក់ប្រហែល ដូចដែលបានរៀបរប់នេះ ។

អាស្រ័យហេតុនេះ នៅក្នុងផែនការនីមួយៗដែលបានស្នើឡើង ត្រូវបញ្ជាក់ឲ្យច្បាស់ពីដីមុខ សញ្ញា អ្នកទទួលដី ។ ក្នុងករណីសម្បទានដីសង្គមកិច្ចសម្រាប់ដាំដំណាំកសិកម្មនៅតំបន់ណា មួយដែលស្នើ ឡើងហើយ តែត្រូវរដ្ឋាភិបាលមិនអាចអនុម័តលើផែនការនោះបានទេ អាស្រ័យ ដោយមូលហេតុថាតំបន់ ដែលអាជ្ញាធរមានសម្តកិច្ចដាក់ផែនការដី ឧទាហរណ៍ អាជ្ញាធរមាន សមត្ថកិច្ចបានស្នើនៅក្នុងផែនការ សម្បទានដីសង្គមកិច្ច អំពីការផ្តល់ដល់ប្រជាពល រដ្ឋក្រីក្រជា សម្បទានដីសង្គមកិច្ចប្រភេទកសិកម្ម សម្រាប់ដាំ ពោត នៅខេត្តកំពង់ចាម យ៉ាងណាមិញ សំណើនេះ ថ្នាក់ជាតិមិនអាចផ្តល់ដីនៅតំបន់នោះឲ្យ បានទេ ព្រោះដីនៅ កំពង់ចាមជាប្រភេទដី មានជីវជាតិ ដែលតម្រូវចំពោះដំណាំកៅស៊ូ ដូច្នេះ អាទិភាព ដំណាំក៏ត្រូវរាប់បញ្ចូលជាលក្ខណ្ឌមួយ ក្នុងការផ្តល់កម្មវិធីសម្បទានដីសង្គមកិច្ចនេះដែរ។

### ២.២. នីតិវិធីនៃការធ្វើសម្បទានដីសង្គមកិច្ច

#### ក. កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន

ក្រុមប្រឹក្សាឃុំសង្កាត់ ជាអ្នកផ្តួចផ្តើមកម្មវិធីសម្បទានដីសង្គមកិច្ច ដោយរៀបចំផែនការសម្បទាន ដីសង្គមកិច្ច ស្របតាមលក្ខខណ្ឌចាំបាច់ នៃផែនការដីសម្បទានដីសង្គមកិច្ច ។ប្រជាពលរដ្ឋម្នាក់ ឬច្រើន នាក់ ឬអង្គការដែលធ្វើការជាមួយប្រជាពលរដ្ឋ ឬតំណាងប្រជា ពលរដ្ឋនៃឃុំសង្កាត់នោះ ក៏អាចផ្តួចផ្តើម កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានបានដែរ ប៉ុន្តែ ត្រូវធ្វើតាមរយះក្រុមប្រឹក្សាឃុំ សង្កាត់នៃឃុំ សង្កាត់ដែលដីសម្បទានសង្គមកិច្ចនោះបិតនៅ ដោយ រៀបចំផែនការសម្បទានដីសង្គមកិច្ច ស្របតាម លក្ខខណ្ឌចាំបាច់ នៃផែនការសម្បទានដី សង្គមកិច្ច ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យផែនការសម្បទាន ដីសង្គមកិច្ចប្រចាំឆ្នាំ ដោយអនុលោម តាមនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ដែលមានចែង ជំពូកទី៦នៃច្បាប់ ស្តីពីការគ្រប់ គ្រងរដ្ឋបាលឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ជូនផែនការ

សម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន តាមរយៈ ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ទៅគណៈកម្មាធិការប្រើប្រាស់ និង បែងចែងដីថ្នាក់ខេត្ត ក្រុង ដើម្បី សុំការសម្រេចយល់ព្រម ។គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង អាចផ្តល់ការសម្រេចយល់ព្រម លើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ប្រសិនបើផែនការសម្បទានដីសង្គមកិច្ចនោះ ត្រឹមត្រូវតាមលក្ខណវិនិច្ឆ័យដែលបានកំណត់ដោយ អនុក្រឹត្យនេះ និងប្រសិនបើពិនិត្យឃើញថាដីនោះ ជាដីឯកជនរបស់រដ្ឋដែលនៅទំនេរ ហើយសមស្របសម្រាប់ផែនការសម្បទានដីសង្គមកិច្ច ។

គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង ត្រូវជូនដំណឹង ដល់គណៈ កម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អំពីផែនការនីមួយៗ ដែលគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង បានផ្តល់ការសម្រេចយល់ព្រម ។ គណៈកម្មាធិការ សម្បទានដី សង្គមកិច្ចថ្នាក់ជាតិ អាចពិនិត្យកែសម្រួលផែនការ ឬលុបចោលសេចក្តីសម្រេចយល់ព្រម របស់ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង រយៈពេលហុកសិប(៦០)ថ្ងៃ គិតពីថ្ងៃបាន ទទួលផែនការសម្បទានដីសង្គមកិច្ចនេះ ប្រសិនបើ :

ក-ផែនការសម្បទានដីសង្គមកិច្ចនោះ មិនស្របនឹងអាទិភាពនៃការប្រើប្រាស់ដីថ្នាក់ជាតិ មានកំហុសបច្ចេកទេស ឬរំលោភបទបញ្ញត្តិទាំឡាយនៃអនុក្រឹត្យនេះ ឬច្បាប់ផ្សេងទៀត ។

ខ-ផែនការដែលបានយល់ព្រម មិនស្រមនឹងលក្ខខណ្ឌចាំបាច់ នៃកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ។

បន្ទាប់ពីបានយល់ព្រម ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានជំនួយបច្ចេកទេស ពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ ជាអ្នកអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន ដែលបានទទួលការសម្រេចយល់ព្រមរួចហើយ ត្រូវបើកជំហាជាសាធារណៈនៅសាលាឃុំ សង្កាត់ពាក់ព័ន្ធ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មាធិការសម្បទាមដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងអំឡុងពេលម៉ោងធ្វើការ ។

**ខ. កម្មវិធីសម្បទានសង្គមកិច្ចថ្នាក់ជាតិ**

កម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ អាចត្រូវបានផ្តួចផ្តើមឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធមួយឬច្រើន ក្នុងស្ថានភាពដែលកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋានមិនអាចធ្វើ បាន ពិសេសក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

- កន្លែងដែលមានកម្មវិធីអភិវឌ្ឍដីនៅតាមតំបន់ដាច់ស្រយាល ដែលពុំមានប្រជាជនមូលដ្ឋានគ្រប់គ្រង ដើម្បីអភិវឌ្ឍដីនោះ
- កន្លែងដែលមានកម្មវិធីតាំងទីលំនៅថ្មីសម្រាប់គ្រួសារច្រើនដូចករណីដំណោះស្រាយសំណង់បណ្តោះអាសន្ននៅតាមទីប្រជុំជនឬគ្រួសារដែលត្រូវផ្លាស់ប្តូរទីកន្លែង
- កន្លែងដែលមានកម្មវិធីអភិវឌ្ឍថ្មីឬមានកម្មវិធីអភិវឌ្ឍស្រាប់ដែលត្រូវសម្របសម្រួលដោយថ្នាក់ជាតិក៏ដូចជាកម្មវិធីដែលគាំទ្រដោយនាក់ផ្តល់ជំនួយឬនាក់វិនិយោគ
- កន្លែងដែលតម្រូវអោយមានសម្បទានដីសង្គមកិច្ចដែលថ្នាក់មូលដ្ឋានមិនអាចធ្វើបាន។

ក្រសួងស្ថាប័នពាក់ពន្ធ័ត្រូវបានដាក់ផែនការសម្បទានដីសង្គមកិច្ចដែលបានបំពេញលក្ខខណ្ឌចាំបាច់នៃផែនការសម្បទានដីសង្គមកិច្ច។

នៅក្នុងការផ្តួចផ្តើម ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិត្រូវមានការចូលរួមអោយយោបល់ពីគណ:កម្មការធិការប្រើប្រាស់និងចែកដីថ្នាក់ខេត្តក្រុងដែលពាក់ពន្ធ័ ក្រុមប្រឹក្សា សង្កាត់ និងប្រជាជន ដែលរស់នៅក្នុងតំបន់។

គណៈកម្មាធិការសម្បទានសេដ្ឋកិច្ច ថ្នាក់ជាតិ អាចផ្តល់ការយល់ព្រម លើផែនការដែលបានការស្នើរឡើងឬ អាចកែសម្រួល ផែនការនេះ ដោយពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ពន្ធ័។កម្មវិធីសម្បទានសង្គមកិច្ចថ្នាក់ជាតិ ដែលទទួលការសម្រេច យល់ព្រម រួចហើយត្រូវអនុវត្តដោយក្រសួងស្ថាប័នឬ ម្ចាស់សំនើរតាមការកំនត់នៅក្នុងផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដោយមានផែនការនិងការសម្របសម្រួលជាមួយ គណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្ត ក្រុង ក្រុមប្រឹក្សាឃុំសង្កាត់និងប្រជាពលរដ្ឋនៅក្នុងតំបន់ពាក់ពន្ធ័ លើកលែងតែកម្មវិធីសម្បទានដីសង្គមកិច្ចថ្នាក់ជាតិចែកផ្សេងពីនេះ។ ផែនការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិដែលទទួលបានការសម្រេច យល់ព្រមរួចហើយត្រូវបើកចំហរ ជាសាធារណៈ នៅសាលាឃុំសង្កាត់ ពាក់ពន្ធ័ នៅគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង និងទៅគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិក្នុងអំឡុងពេលម៉ោងធ្វើការ។

### ២.៣. ការជ្រើសរើសមុខសញ្ញាអ្នកទទួលដី

#### ក. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស

ដោយច្បាប់ភូមិបាលបានចែងតម្រូវថារាល់សម្បទានដីសង្គមកិច្ចត្រូវផ្តល់ទៅគ្រួសារក្រីក្រ ប៉ុន្តែនៅក្នុងអនុក្រឹត្យលេខ ១៩ មិនបានកំណត់ពីលក្ខខណ្ឌណា ដែលអាចចាត់ទុកថាជាគ្រួសារក្រីក្រទេ គ្រាន់តែបានកំណត់នូវលក្ខណៈវិនិច្ឆ័យសម្រាប់អ្នកដាក់ពាក្យសុំដីសម្បទានសង្គមកិច្ចដែលរួមមាន៖

- មានសញ្ជាតិខ្មែរ និងសមត្ថភាពផ្លូវច្បាប់ក្នុងការធ្វើជាម្ចាស់ដី
- ជាមេគ្រួសារដែលមានសមាជិកពីរនាក់ ឬច្រើននាក់ដែលជាប់សាច់សាលោហិតជាមួយគ្នាក្នុងលំនៅតែមួយ
- បានត្រៀមខ្លួនមានឆន្ទៈ និងមានលទ្ធភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ចមិនធ្លាប់ទទួលបានសម្បទានដីសង្គមកិច្ចពីមុន ។

បន្ថែមពីលើលក្ខខណ្ឌខាងលើសម្បទានិកត្រូវសមស្របទៅនឹងគោលដៅដែលបានកំណត់នៅក្នុងមាត្រា២ អនុក្រឹត្យលេខ ១៩ ថែមទៀត។

**ខ. ជនដែលអនុគ្រោះបំផុត**

លក្ខណៈវិនិច្ឆ័យនៃភាពអនុគ្រោះបំផុតមានៈ

- គ្រួសារធំដែលមានសមាជិកចាប់ពី៦នាក់ឡើងទៅ
- រយៈពេលដែលគ្រួសាររស់នៅក្នុងតំបន់ដីសម្បទាន
- មេគ្រួសារជាស្ត្រី បាត់បង់សមត្ថភាព ឬយោធិនរំសាយ ឬគ្រួសារយុទ្ធជនពិការ។

រយៈពេលជ្រើសរើសមុខសញ្ញាអ្នកទទួលដីត្រូវបានកំណត់ ១៥ថ្ងៃ បន្ទាប់ពីផុតរយៈពេលបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះអ្នកសុំសម្បទានដីសង្គមកិច្ចទាំងអស់។

## ២.៤. ការបែងចែកដីសម្បទានសង្គមកិច្ច និងការតាមដានវាយតំលៃលើដំណើរការអនុវត្តន៍

បន្ទាប់ពីផុតរយៈពេលបិតផ្សាយបញ្ជីឈ្មោះអ្នកទទួលដីសម្បទាន ក្នុងករណីគ្មានការជំទាស់តវ៉ា ឬបន្ទាប់ពីផុតរយៈពេលបិតផ្សាយសេចក្តីបំភ្លឺ ឬសេចក្តីសំរេចរបស់គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្តក្រុង របស់គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ក្នុងករណីគ្មានការជំទាស់តវ៉ាទេ ក្រុមព្រឹក្សាឃុំសង្កាត់ ត្រូវធ្វើការបែងចែកដីដល់អ្នកដែលមានឈ្មោះអ្នកត្រូវទទួលដីសម្បទាន។ការបែងចែកដីសម្បទានសង្គមកិច្ច ត្រូវបានធ្វើឡើងតាមរយៈការចាប់ឆ្នោតយកលេខក្បាលដី ដែលរៀបចំឡើងដោយ ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយបច្ចេកទេសពីក្រុមការងារថ្នាក់ស្រុក ខណ្ឌ និងក្រោមការត្រួតពិនិត្យពីអង្គភាពគាំទ្របច្ចេកទេសកា រងារជ្រើសរើសមុខសញ្ញាអ្នកត្រួតពិនិត្យដី។ការចាប់ឆ្នោតយកលេខក្បាលដី ត្រូវជូនដំណឹងយ៉ាងតិច ៧ ថ្ងៃ មុនកាលបរិច្ឆេទនៃការចាប់ឆ្នោត ហើយត្រូវធ្វើជាសារធារណៈនៅក្នុងដីសម្បទានចំពោះមុខប្រជាពលរដ្ឋនិងអ្នកត្រូវទទួលដីដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកត្រូវទ ទូលដី សម្បទានទាំងអស់។មុនធ្វើការចាប់ឆ្នោ តយក លេខក្បាលដីក្រុ មប្រឹក្សាឃុំ

សង្កាត់ ត្រូវធ្វើបង្ហាញពីប្លង់ក្បាលដីដែលត្រូវធ្វើការបែងចែកក្នុងផែនការសម្បទានដីសង្គមកិច្ចដែលអនុម័តយល់ព្រមហើយអំពីលេខក្បាលដីដែលត្រូវចាប់ឆ្នោតយកនិង អំពីរបៀបចាប់ឆ្នោត។អ្នកមានសិទ្ធិក្នុងការចាប់ឆ្នោតយកក្បាលដីត្រូវតែមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីសម្បទានរបៀបចា ប់ឆ្នោតយកលេខក្បាលដីអាស្រ័យលើក្រុមប្រឹក្សាឃុំសង្កាត់និងក្រុមការងារថ្នាក់ស្រុកខណ្ឌកំណត់តាមភាពជាក់ស្តែង។ ក្រោយពេលចាប់ផ្តើមយកលេខក្បាលដីរួចក្រុមប្រឹក្សាឃុំសង្កាត់ ដោយមានជំនួយបច្ចេកទេស ពីក្រុមការងារស្រុក ខណ្ឌ ត្រូវស្រង់ឈ្មោះនិង លេខក្បាលដីចាប់ឆ្នោតបាន ដោយធ្វើជាបញ្ជីឈ្មោះអ្នកទទួលដី(សម្បទាន) និង លេខក្បាលដី។

**ក. កិច្ចសន្យាសម្បទានដីសង្គមកិច្ច**

នៅពេលដែលផែនការសម្បទានដីសង្គមកិច្ច ត្រូវបានអនុម័តជាស្ថាពរ ដែលត្រូវបែងចែកទៅឲ្យមុខសញ្ញាអ្នកទទួលដី ត្រូវឲ្យមុខសញ្ញាអ្នកទទួលដីនេះធ្វើកិច្ចសន្យាជាលាយល័ក្ខអក្សរជាមួយអាជ្ញាធរមានសមត្ថកិច្ចផ្តល់ដីដែលបានបញ្ជាក់ពីលក្ខខណ្ឌនៃការផ្តល់សម្បទាននេះ ។ក្រុមប្រឹក្សាឃុំ សង្កាត់ និង ក្រុមការងារថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញមុខសញ្ញាអ្នកទទួលដី ឬសម្បទាននិកទាំងអស់មកប្រជុំផ្សព្វផ្សាយអំពីខ្លឹមសារនៃកិច្ចសន្យាដែលត្រូវចុះហត្ថលេខា ដូចជាអំពីការទទួលបានសិទ្ធិកម្មសិទ្ធិ នៅពេលលក្ខខណ្ឌនៃការកាន់កាប់ដីត្រូវបានបំពេញរួច និងអំពីការដកហូតដីមកវិញ ប្រសិនបើសម្បទាននិកមិនបំពេញបានលក្ខខណ្ឌ និងកាតព្វកិច្ចក្នុងកិច្ចសន្យា។បន្ទាប់ពីបានពន្យល់ផ្សព្វផ្សាយខ្លឹមសារនៃកិច្ចសន្យារួចហើយ មុខសញ្ញាអ្នកទទួលដី ឬ សម្បទានិកត្រូវចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំសង្កាត់តាមគំរូពាក្យសុំហើយកិច្ចសន្យាសម្បទាននេះត្រូវចាត់ជាផ្លូវការដែលភាគីហត្ថលេខីត្រូវអនុវត្តតាម។

**ខ. កាតព្វកិច្ចរបស់សម្បទានិក**

ក្រោយពីកាចុះកិច្ចសន្យារួចភាគី នៃកិច្ចសន្យាត្រូវបំពេញកាតព្វកិច្ចដូចដែលមានបញ្ជាក់នៅក្នុងកិច្ចសន្យានោះយ៉ាងណាមិញដីបន្ទាប់ពីទទួលបានមិនអាចលក់ជួលឬឲ្យអោយទៅអ្នកដទៃដោយគ្មានការយល់ព្រពីអាជ្ញាធរក្នុងរយៈពេល៥ឆ្នាំដំបូងទេបើមិនដូច្នោះទេមុខសញ្ញាអ្នកទទួលដីនិងត្រូវបាត់បង់ដីនេះជាមិនខាន។ នៅក្នុងល្ខខណ្ឌនៃកាកាន់កាប់ត្រូវបានបែងចែកដាច់ពីគ្នារវាងដីសំរាប់សងលំនៅដ្ឋាន និងដីសំរាប់កសិកម្មដោយមុខសញ្ញាអ្នកទទួលដីសំរាប់សាងសង់លំនៅដ្ឋានចាំបាច់ត្រូវសាងសង់យ៉ាងហោចណាស់នូវចំណោកណាមួយជាជំរកស្នាក់នៅអចិន្ត្រៃយ៍ក្នុងរយៈពេល៣ខែបន្ទាប់ពីបានទទួលដីហើយយ៉ាងហោចណាស់សមាជិកនៃគ្រួសារនោះត្រូវរស់នៅលើពី៦ខែក្នុងមួយឆ្នាំ។

ការទាមទារនោះជាមូ លដ្ឋានសំខាន់ហើយ ពុំមានបំណងដាក់ទណ្ឌកម្មដាក់អ្នកក្រីក្រនោះទេប៉ុន្តែជាកាការពារនូវការរំលោភនិងការកេងប្រវ័ញ្ច។ចំពោះដីសម្បទានសង្គមកិច្ចសំរាប់កសិកម្មជាលក្ខណៈគ្រួសារវិញ ត្រូវប្រើប្រាស់សំរាប់គោលដៅនេះ នៅក្នុងរយៈពេល ១២ខែ បន្ទាប់ពិបានទទួលដី ។ បន្ទាប់ពីបានសង់លំនៅដ្ឋាននិងដាំដុះក្នុងរយៈពេល ៥ឆ្នាំ ហើយមុខសញ្ញាអ្នកទទួលដី អាចស្នើរសំប័ណ្ណកម្មសិទ្ធនៅក្រសួងផដនដី នគរូបនីកម្ម និង សំណង់ តាមនិតិវិធីដូចសេចក្តីណែនាំរបស់ក្រសួង។លក្ខខណ្ឌអំពីការសាងសង់លំនៅដ្ឋាននិងការប្រកបរបរចិញ្ចឹមជីវិតអាចមានករណីលើកលែងតែក្នុងករណីប្រធានសក្តិឬករណីអ្នកកាន់កាប់មានជំងឺធ្ងន់ធ្ងរប៉ុណ្ណោះ។ប្រសិនបើមុខសញ្ញាអ្នកទទួលដីខកខានមិនបានបំពេញតាមលក្ខខណ្ឌ នៃកាកាន់កាប់និងប្រើប្រាស់ដីសម្បទានសង្គមកិច្ចនោះទេ
ដូច្នេះដីដែលផ្តល់ទៅឲ្យនិងប្រែក្លាយមកជាដីរដ្ឋវិញ ដើម្បីធ្វើការបែងចែកជាថ្មីម្តងទៀតទៅឲ្យមុខសញ្ញាអ្នកទទួលដីក្នុងបញ្ជីឈ្មោះអ្នកត្រូវទទួលដីបំរុង ។

## ជំពូកទី២ គុណសម្បត្តិនៃសម្បទានដីសង្គមកិច្ច

កម្មវិធីសម្បទានដីសង្គមកិច្ចត្រូវផ្តល់ឲ្យដោយមានការចូលរួមសហការពីសំណាក់ក្រសួងស្ថាប័នដែលពាក់ព័ន្ធជាច្រើន។ កម្មវិធីនេះជាប្រតិបត្តិការមួយដែលប្រើរយៈពេលយូរ រួមទាំងមានការចូលរួមពីដៃគូអភិវឌ្ឍ និងអង្គការក្រៅរដ្ឋាភិបាលស៊ីវិលជាច្រើនទៀតដើម្បីជួយជំរុញឲ្យដំណើរការដីសម្បទានសង្គមកិច្ចអាចទទួលបានលទ្ធផលល្អ។ ទន្ទឹមនឹងនេះការឲ្យអនុវត្តគម្រោងសម្បទានដីសង្គមកិច្ចនេះ យើងឃើញថា មានអត្ថប្រយោជន៍ដែលទទួលបានពីការផ្តល់ដីសម្បទាននេះ គឺបានជួយដល់ប្រជាពលរដ្ឋដែលក្រីក្រដែលគ្មានដី ឬខ្វះដីឲ្យពួកគេបានសង់លំនៅស្ថាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។ ទន្ទឹមនឹងគុណសម្បត្តិទាំងនេះ ក៏នៅមានចំណុចខ្វះខាតជាច្រើនដែលទាមទារឲ្យមានការពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីធ្វើឲ្យសម្បទានដីសង្គមកិច្ចកាន់តែមានប្រសិទ្ធិភាព។ការផ្តល់ដីសម្បទានសង្គមកិច្ចបានចូលរួមកាត់បន្ថយភាពក្រីក្រដែលស្របទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជានៅក្នុងពេលបច្ចុប្បន្ន ដោយផ្តល់ដីឲ្យប្រជាពលរដ្ឋកាន់កាប់ដោយស្របច្បាប់នឹងលើកស្ទួយសេដ្ឋកិច្ចគ្រួសារ និងជាតិ។ ខាងក្រោមនេះនឹងបង្ហាញពីគុណសម្បត្តិនៃការផ្តល់សម្បទានដីសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា៖

### ១. គុណសម្បត្តិនៃការផ្តល់ដីសម្បទានដោយផ្ទាល់

#### ១.១. ការផ្តល់ដីឲ្យប្រជាពលរដ្ឋកាន់កាប់ដីដោយស្របច្បាប់

ក្នុងមួយឆ្នាំៗ មានកងកម្លាំងប្រដាប់អាវុធដល់អាយុចូលនិវត្តន៍ ហើយកងកម្លាំងប្រដាប់អាវុធខ្លះបាត់បង់សមត្ថភាពការងារ ពិការ ទទួលមរណភាព និងពលីជីវិត ដើម្បីបុព្វហេតុជាតិ ការពារសន្តិភាព

បូរណភាពទឹកដី និងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ។ រាជរដ្ឋាភិបាលបានអនុវត្តន៍ចំពោះកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ដោយគោរពដឹងគុណូបការៈដ៏ថ្លៃថ្លារបស់បងប្អូនជនរួមជាតិមាតុភូមិ និងប្រជាជន ជាមួយនឹងការយកចិត្តទុកដាក់ដោះស្រាយជីវភាពខាងសំភារៈ ថវិកា ជាបន្តបន្ទាប់ រួមមានការបើកផ្តល់នូវរបបឧបត្ថម្ភផ្សេងៗ ព្រមទាំងផ្តល់កិត្តិយស ការគោរព និងការថែរក្សាសេចក្តីថ្លៃថ្នូរជូនបងប្អូនស្របតាមស្ថានភាពនៃសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានអនុវត្តរួចមកហើយនូវវិធានការ និងគំនិតផ្តួចផ្តើមសម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសាររួមមានជាអាទ៍៖

- ទី១ ការផ្តល់សម្បទានដីសង្គមកិច្ចនៅក្នុងក្របខណ្ឌនៃការអនុវត្តគម្រោងវិស័យកងទ័ព
- ទី២ ការផ្តល់សម្បទានដីសង្គមកិច្ចសម្រាប់អភិវឌ្ឍយោធិន
- ទី៣ ការផ្តល់ផ្ទៃដីព្រៃឈើទំហំ ២.៥០៧ហិចតា ដើម្បីជូនខេត្តសៀមរាបចំនួន ១.៣១៧ ហិចតាសម្រាប់គោលដៅសម្បទានដីសង្គមកិច្ច និងជូនក្រសួងការពារជាតិចំនួន ១.១៩០ ហិចតា សម្រាប់បែងចែកជូនគ្រួសារយុទ្ធជនតាមរយៈអនុក្រឹត្យលេខ ៣៣ អនក្រ បក ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០០៧
- ទី៤ ការរៀបចំបង្កើតភូមិស្ថាន សម្រាប់គ្រួសារយុទ្ធជនកំពុងបំពេញការប្រយុទ្ធ ជនពលីជីវិត និងមរណៈដែលត្រូវបានដាក់ចេញ និងជំរុញឲ្យអនុវត្តសម្តេចនាយករដ្ឋមន្ត្រី នៅតំបន់មួយចំនួនរួមមាន ការផ្តល់សម្បទានដីសង្គមកិច្ចសម្រាប់យោធិននៅតំបន់តាកែន កោះស្លា នៅខេត្តកំពត ចំនួន ២៥០គ្រួសារ លើផ្ទៃដី ១២០០ហិចតា ជូនគ្រួសារយោធិននៅស្រុកសេសាន ខេត្តស្ទឹងត្រែងចំនួន ១០០គ្រួសារលើផ្ទៃដី ១៧៣ ហិចតាជូនគ្រួសារកងទ័ពនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារចំនួន ១៩១២ គ្រួសារលើផ្ទៃដី ១៦៤០០ ហិចតា។
- ទី៥ ការកសាងលំនៅស្ថានជូនអតីតជនមានស្នាដៃឆ្នើម ក្នុងចលានាប្រលងប្រណាំង ៣ល្អ នៅតាមសហគមន៍របស់សមាគមអតីតជនកម្ពុជាក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី។
- ទី៦ ការដាក់បញ្ចូលក្នុងគម្រោងវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០១០ -២០១២ នូវគម្រោងសាងសង់ផ្ទះ និងភូមិអភិវឌ្ឍអតីតយុទ្ធជននៅខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ធំ និងកំពង់ចាម ។
- ទី ៧ ការរៀបចំបង្កើតភូមិស្ថានគ្រួសារយោធានៅតំបន់តាមបណ្តោយព្រំដែនភាគខាងជើងដែលថ្មីៗនេះ ត្រូវបាន និងកំពុងអនុវត្តដោយគណៈកម្មការអន្តរក្រសួងជាអ្នកសម្របសម្រួលរៀបចំ និងអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា។ល។

ដោយហេតុនេះហើយដើម្បីសម្រេចគោលដៅខាងសង្គម-សេដ្ឋកិច្ច ព្រមទាំងព្រឹង និងពង្រីកសំណាញ់សុវត្ថិភាពសង្គមដូចគូសបញ្ជាក់ខាងលើរាជរដ្ឋាភិបាលឈរលើគោលការណ៍ចំបងមួយចំនួនដុចតទៅ៖

- គោលការណ៍សមធម៌: រាជរដ្ឋាភិបាលនឹងរៀបចំជាអាទិភាពនៅក្នុងការរៀបចំជាអាទិ៍ភាពនៅក្នុងការរៀបចំគោលនយោបាយរបស់ខ្លួនដោយកំណត់មុខសញ្ញានៃអ្នកទទួលបាននូវសម្បទានដីសង្គមកិច្ចនេះដោយច្បាស់លាស់ ។ រាជរដ្ឋាភិបាលមិនអាចផ្តល់សម្បទានសង្គមកិច្ចដោយឈរលើគោលការណ៍សមភាព ជូនដល់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធនេះទេ ដោយសារមូលហេតុ:
- ធនធានហិរញ្ញវត្ថុរបស់រដ្ឋមានកម្រិត
- ការអនុវត្តគោលនយោបាយជាតិស្តីពីការគ្រប់គ្រងដីតាមគោលការណ៍ប្រសិទ្ធិភាព
- ស្ថានភាពជីវភាពនៃអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសាររបស់គេ នីមួយៗមិនដូចគ្នាទាំងអស់នោះទេ បានន័យថាមានអ្នកមានជីវភាពធូរធារមិនត្រូវការដី និងមានអ្នកក្រដែលត្រូវការដី
- សេចក្តីត្រូវការរបស់គ្រួសារនីមួយៗក៏មិនអាចដូចគ្នាដែរ។

### ១.២. ការលើកស្ទួយសេដ្ឋកិច្ចជាតិ និងគ្រួសារ

គោលការណ៍ប្រសិទ្ធិភាពសេដ្ឋកិច្ចក្នុងការប្រើប្រាស់ដីសម្បទានសង្គមកិច្ច គោលដៅចម្បងមួយនៃការផ្តល់ដីសម្បទានសង្គមកិច្ចជូនដល់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ គឺសំដៅបង្កើតឡើងនូវសំណាញ់សុវត្ថិភាពសម្រាប់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធដែលទីទាល់ក្រពិតប្រាកដ ដើម្បីសាងសង់លំនៅស្ថាន និងប្រកបរបរកសិកម្មផ្សេងៗដែលជាការរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារផង និងជាការលើកកម្ពស់នៃផលិតភាព និងនគរូបនីយកម្មកសិកម្មក្នុងគោលដៅនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចផង។ ដូច្នេះដើម្បីធានាប្រសិទ្ធិភាពសេដ្ឋកិច្ចនៅក្នុងការប្រើប្រាស់ដីសម្បទានសង្គមកិច្ចនេះផង រាជរដ្ឋាភិបាលមិនអនុញ្ញាតឲ្យទទួលការយកសម្បទានដីសង្គមកិច្ចពីរដ្ឋរួចហើយ រួចយកទៅរក្សាទុកចំណែក ឬយកទៅជួល ឬប្រវាស់ ឬព័ទ្ធរបងទុកចោលមិនប្រើប្រាស់វាជាដើមឡើយ។

គោលការណ៍ធ្វើសមាហរណកម្ម អតីតកងកម្លាំងប្រដាប់អាវុធចូលទៅក្នុងសង្គមជាតិ ដោយគោលដៅសំខាន់មួយក្នុងក្របខណ្ឌនៃកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលគឺការធានាធ្វើសមាហរណកម្មកងកម្លាំងប្រដាប់អាវុធ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពិការ ពលី និងមរណភាពចូលទៅក្នុងសង្គមជាតិ ដើម្បីឲ្យពួកគេរស់នៅបានក្នុងជីវភាពជាជនស៊ីវិលក្នុងភាពសុខដុមរមនា ជាមួយនឹងគ្រួសារ និងសហគមន៍។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងមានវិធានការជាប្រព័ន្ធ គ្រប់ជ្រុងជ្រោយដោយលើកផែនការរៀបចំភូមិដ្ឋាន សម្រាប់តាំងទីលំនៅ និងការប្រកបរបរអាជីវកម្មនៅតាមទីតាំងដែលនឹងត្រូវបានផ្តល់ជាសម្បទានដីសង្គមកិច្ច ក្នុងនោះមានការរួមបញ្ចូលនូវការរៀបចំ

បណ្តាញហេដ្ឋារចនាសម្ព័ន្ធ សង្គម-សេដ្ឋកិច្ចជារូបវន្ត មានជាអាទិ៍ៈ បណ្តាញផ្លូវគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ សាលារៀន មណ្ឌលសុខភាព វត្តអារាម ព្រមទាំងការផ្តល់ជំនួយឧបត្ថម្ភសម្រាប់ការសាងសង់ទីលំនៅ និងសម្រាប់ការស្នាក់នៅក្នុងដំណាក់កាលដំបូង តាមការចាំបាច់ និងការផ្តល់សេវាសង្គមកិច្ចទាំងការបណ្តុះបណ្តាលផ្សេងៗសម្រាប់ការកសាងជីវភាពរស់នៅក្នុងរយៈពេលវែង។

**២. គុណសម្បត្តិនៃការផ្តល់ដីសម្បទានដោយប្រយោល**

ជាការពិតណាស់ក្នុងការផ្តល់សម្បទានដីសង្គមកិច្ច ពិតជាបានចូលរួមក្នុងការទប់ស្កាត់ក្នុងការទន្ទ្រានកាប់ព្រៃដោយខុសច្បាប់ និងបញ្ចៀសកំណើនប្រជាជនតែមួយកន្លែង។

**២.១. ការទប់ស្កាត់ក្នុងការទន្ទ្រានកាប់ព្រៃដោយខុសច្បាប់**

គោលការណ៍ប្រសិទ្ធិភាពក្នុងការគ្រប់គ្រងដីៈ ដី គឺមានកំណត់ និងមិនងាយនឹងពង្រីកបាន គឺជាធនធានធម្មជាតិសំខាន់ជាមូលដ្ឋានដែលអាចយកមកប្រើប្រាស់សម្រាប់អភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចដែលទាមទារឲ្យមានការគ្រប់គ្រងដោយមានប្រសិទ្ធិភាព និងវិចារណភាព ដើម្បីធានាដោះស្រាយប្រកបដោយចេរភាពនូវសេចក្តីត្រូវការរបស់ប្រទេសជាតិ និងប្រជាជនរាប់ជំនាន់តទៅមុខទៀត។ ក្នុងស្មារតីនេះក្នុងការផ្តល់ដីសម្បទានសង្គមកិច្ចជូនដល់អតីតយុទ្ធជន និងក្រុមគ្រួសាររាជរដ្ឋាភិបាល និងផ្សារភ្ជាប់ទៅនឹងតម្រូវការចាំបាច់ក្នុងការពង្រឹងប្រសិទ្ធិភាព និងផលិតភាពក្នុងការគ្រប់គ្រងធនធានដីបម្រុងទុករបស់រដ្ឋក្នុងលក្ខណៈជាប្រព័ន្ធជាពិសេសក្នុងទិដ្ឋភាពគោលនយោបាយទាក់ទងនឹងការកំណត់ និងគ្រប់គ្រងដីបម្រុងរបស់រដ្ឋ ការកំណត់ និងបែងចែកឡើងវិញនូវប្រភេទដីគម្របព្រៃ និងដីព្រៃរិចរិល ដែលអាចកាត់យកមកប្រើប្រាស់សម្រាប់គោលដីនៃសម្បទានដីសង្គមកិច្ច ការកាត់យកមកវិញនូវដីសម្បទានសេដ្ឋកិច្ចដែលមិនត្រូវបានប្រើប្រាស់តាមគោលដៅសម្បទានសង្គមកិច្ច និងការពង្រឹងទំនាក់ទំនងរវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានសង្គមកិច្ចដូចមានចែងនៅក្នុងយុត្តសាស្ត្រចតុកោណ។

**២.២. ការបញ្ចៀសកំណើនប្រជាជនតែមួយកន្លែង**

សម្បទានដីសង្គមកិច្ចត្រូវបានយកចិត្តទុកដាក់ជាខ្លាំងពីសំណាក់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតជាប់ជាមួយគោលនយោបាយ បញ្ចៀសកំណើតនៃប្រជាជនតែកន្លែងទីប្រជុំជន ហេតុនេះហើយទើប លោកម៉ុង ឬទី្វដែលទទួលបានដីសម្បទាន លោកបានបង្កើតជាភូមិឋានថ្មី នៅនឹងចំការដូងប្រេង របស់គាត់ជូនកម្មករដែលនៅធ្វើចំការរបស់គាត់ទៀតផង។ ទោះបីជាយ៉ាងណាក៏ដោយ ដោយយល់ឃើញថា ដីនៅព្រះរាជាណាចក្រកម្ពុជាសំបូរទៅដោយអត្ថប្រយោជន៍ ហេតុនេះហើយនៃចលនារបស់ប្រជាពលរដ្ឋក្នុងការទៅកាន់ទីតាំងថ្មីនេះ កើតមានបានមួយភាគធំតាមរយៈគោល

នយោបាយដោះដូរជាសំណងជូនប្រជាពលរដ្ឋណាដែលទទួលរងនូវការប៉ះពាល់ដែលបណ្តាលមកពីការអភិវឌ្ឍន៍ ចំនួនលំនៅដ្ឋានរបស់ពួកគាត់ ឬក៏ដោយសារតែគ្រោះធម្មជាតិដែលជាហេតុធ្វើឲ្យរាជរដ្ឋាភិបាលដោះស្រាយបញ្ហានេះជាចំបងដូចជាការបាក់ដី ច្រាំងទន្លេជាដើម ។ ការផ្តល់សម្បទានដីសង្គមកិច្ចបានចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ ដែលស្របទៅនឹងគោលដៅរបស់រដ្ឋាភិបាលកម្ពុជា នៅពេលបច្ចុប្បន្ននេះ ។ ដោយការផ្តល់ដីសម្បទានសង្គមកិច្ចត្រូវបានយកមកប្រើក្នុងស្ថានភាពជាច្រើនដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ និងការចាត់ចែងដីក្នុងគោលដៅប្រើប្រាស់ដីនៅក្នុងសង្គមកិច្ចរួមមានការខ្វះខាតដីសង់លំនៅស្ថាន ភាពគ្មានដី ការអភិវឌ្ឍន៍លំនៅស្ថាន និងសម្រាប់ដីឡូត៍ដល់ការធ្វើកសិកម្មចិញ្ចឹមជីវិតរបស់កម្មករចំការធំៗ ។

## សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវនូវប្រធានបទខាងលើរួចមកសមាជិកក្រុមទី៥ សូមធ្វើការរួមថាការផ្តល់ដីសម្បទានសង្គមកិច្ចពិតជាផ្តល់នូវគុណសម្បត្តិជាច្រើនដល់ប្រជាពលរដ្ឋដែលគ្មានដីធ្លីឬ លំនៅដ្ឋាន សម្រាប់ប្រើប្រាស់តាមតម្រូវការ។ មិនតែប៉ុនោះការផ្តល់ដីសម្បទានសង្គមកិច្ចបានកាត់បន្ថយនូវសំនង់អាណាធិបតេយ្យ ដែលជាហេតុធ្វើឲ្យទីក្រុងមានសោភ័ណភាពនិងមានសណ្តាប់ធ្នាប់មួយកម្រិត។ជាក់ស្តែងគុណសម្បត្តិនៃការផ្តល់សម្បទានសង្គមកិច្ច អាចផ្តល់នូវគុណសម្បត្តិ២ប្រភេទគឺ ដោយផ្ទាល់និងដោយប្រយោល។ គុណសម្បត្តិដោយផ្ទាល់នោះគឺ បានផ្តល់នូវដីធ្លីសមរម្យនិងស្របច្បាប់ ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ដែលជាកត្តាសំខាន់ក្នុងការលើកស្ទួយដល់ជីវភាពគ្រួសារ របស់ប្រជាពលរដ្ឋថែមមួយកម្រិត។ចំនែកឯគុណសម្បត្តិដោយប្រយោល មានដូចជា ការទប់ស្កាត់ការទន្ទ្រានកាប់ព្រៃឈើខុសច្បាប់ និងបញ្ចៀស ប្រជាជនកុំឲ្យកកកុញនៅមួយកន្លែង ដែលជាផលប៉ះដល់សម្បត្តិធម្មជាតិនិងសណ្តាប់ធ្នាប់សាធារណៈ។ ផ្អែកលើករណីខាងលើអាចបញ្ជាក់បានថាការផ្តល់ដីសម្បទានសង្គមកិច្ចពិតជាផ្តល់នូវគុណសម្បត្តិគួរឲ្យកត់សំគាល់និងមិនអាចមើលរំលងបាន ទាំងបច្ចុប្បន្ន និងអនាគត ។

## ឯកសារយោង


- អនុក្រឹតស្តីពីសម្បទានសេដ្ឋកិច្ច លេខ១៩អនក្រ.បក
- ច្បាប់ភូមិបាលឆ្នាំ២០០១
- មាត្រា៣៧នៃប្រកាសលេខ២០០ឆ្នាំ២០០៣

# គន្លឹះទី៦

# គុណសម្បត្តិ និងគុណវិបត្តិសម្បទានដីសេដ្ឋកិច្ច

## សេចក្តីផ្តើម

ការផ្តល់ដីសម្បទានសេដ្ឋកិច្ច បើគ្រាន់តែឮពាក្យនេះភ្លាមអ្នកបានស្តាប់ ឬអានអ្វីដែលទាក់ទងក្នុងរឿងនេះ ពិតជាមានចំណាប់អារម្មណ៍ចង់ដឹង ចង់យល់ ពីបញ្ហានេះជាមិនខាន ព្រោះថានៅប្រទេសកម្ពុជាសព្វថ្ងៃកំពុងតែមានវិវាទជាច្រើនដែលទាក់ទងក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋ ទៅដល់ក្រុមហ៊ុនវិនិយោគ ហើយបានប៉ះពាល់ដល់ការតាំងនៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះហើយបានជា រាល់ប្រជាពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់ទាំងអស់មានការចាប់អារម្មណ៍ ចង់ស្វែងយល់អំពីរឿងនេះឲ្យបានច្បាស់លាស់ អំពីមូលហេតុដែលបានកើតឡើង ក៏ដូចជានីតិវិធីដោះស្រាយរបស់រដ្ឋាភិបាលទៅលើបញ្ហាទាំងអស់នេះ ថាតើមានការវិវត្តន៍ដល់កម្រិតណា ហើយសមស្របទៅតាមតម្រូវការចង់បានរបស់ប្រជាពលរដ្ឋសម្រាប់សិទ្ធិតាំងទីលំនៅរបស់ពួកគាត់ដែរ ឬទេ ? ព្រោះថាក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់អំពីសិទ្ធិតាំងទីលំនៅរបស់ប្រជាពលរដ្ឋដោយគ្មានការរុករាន ឬបៀតបៀនពីបុគ្គលណាម្នាក់បានឡើយ ។ ហេតុនេះប្រជាពលរដ្ឋទាំងអស់ត្រូវការស្វែងយល់ឲ្យបានច្បាស់អំពី៖

- គោលដៅនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច
- ឫសគល់ដែលនាំឲ្យកើតឡើងនូវវិវាទ
- វិធីសាស្ត្រក្នុងការដោះស្រាយរបស់រដ្ឋាភិបាល

កាលណាយើងយល់អំពីមូលហេតុទាំងនេះហើយ នឹងងាយស្រួលចូលរួមក្នុងការរកច្រកចេញមួយដ៏ប្រកបដោយប្រសិទ្ធភាព ព្រោះថាអ្វីៗ ទាំងអស់ដែលកើតឡើងនេះ គឺកើតចេញពីការជ្រើសរើសរបស់

ប្រជាពលរដ្ឋរាល់រូបក្នុងការជ្រើសតំណាង (តាមរយៈការបោះឆ្នោត៥ឆ្នាំម្តង) ដូច្នេះបើយើងសម្លឹងឃើញថារដ្ឋាភិបាលជាតំណាងរៀបចំបញ្ហាទាំងនេះមិនបានល្អ យើងអាចពិចារណាក្នុងការជ្រើសអ្នកដែលមានសមត្ថភាព អាចបំពេញទៅតាមតម្រូវការមួយដ៏សមស្របសម្រាប់យើងនៅអាណត្តិក្រោយៗ ទៀតបាន ។

ជាការពិតណាស់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច គឺជាតម្រូវការចាំបាច់ណាស់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ ។ ដូច្នេះហើយបានជា រាជរដ្ឋាភិបាលបានស្វះស្វែងរកអ្នកវិនិយោគជាដៃគូរក្នុងការបង្កើតក្រុមហ៊ុនកសិឧស្សាហកម្មផ្សេងៗ មកវិនីយោគដែលជាកត្តាជម្រុញដល់ការអភិវឌ្ឍប្រទេស ។ ហេតុនេះប្រជាពលរដ្ឋត្រូវតែចូលរួមយល់ដឹងពីបញ្ហានេះ ដើម្បីជួយសម្រួលដល់រដ្ឋាភិបាល ក៏ដូចជាចូលរួមរិះគុនដើម្បីកែតម្រូវនូវពេលមើលឃើញថា ការអនុវត្តផ្តល់ដីសម្បទាននេះបានប៉ះពាល់ដល់ធនធានប្រទេសជាតិធ្ងន់ធ្ងរ ជៀសជាងអត្ថប្រយោជន៍តិចតួច ដែលចូលមកក្នុងថវិកាជាតិវិញ ជាពិសេសប៉ះពាល់ដល់លំនៅដ្ឋានប្រជាពលរដ្ឋតែម្តង ( រាជរដ្ឋាភិបាលជាឪពុកម្តាយ ត្រូវផ្តល់សេចក្តីសុខដល់កូនដែលជាប្រជាពលរដ្ឋក្នុងការរស់នៅប្រកបដោយសេចក្តីសុខ) ។ យើងសង្កេតឃើញថានីតិវិធីក្នុងការផ្តល់ដីសម្បទាននាពេលបច្ចុប្បន្ននេះ នៅមានកម្រិតមួយមិនទាន់ទទួលយកបាននៅឡើយ ព្រោះថាមានបញ្ហាមួយចំនួនបានកើតឡើងជាវិវាទ ហើយវិវាទមួយចំនួននោះទៀតសោតក៏មិនទាន់ត្រូវបានដោះស្រាយរួចរាល់នៅឡើយ ។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចមិនមែនជារឿងមួយ ដែលធ្វើទៅឲ្យតែបានៗ នោះទេ វាអាចរំលោភដល់សិទ្ធិតាំងទីលំប្រជាពលរដ្ឋដែលស្របច្បាប់ ប៉ះពាល់ដល់ធនធានធម្មជាតិដូចជាព្រៃឈើ រ៉ែមានតម្លៃផ្សេងៗ ជាពិសេសការផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យប្រទេសជិតខាងដែលមានបំណងមិនល្អអាចនឹងឈានទៅដល់ការបាត់បង់ដីទៅឲ្យប្រទេសគេផងក៏ថាបាន ។ ទាំងនេះជាកត្តាចាំបាច់ណាស់ ដែលប្រជាពលរដ្ឋខ្មែរយើងត្រូវតែយល់ដឹងទាំងអស់គ្នា ដើម្បីជៀសវាងបញ្ហាខាងលើនេះកើតឡើង ដែលធ្វើឲ្យបាត់បង់ដល់ផលប្រយោជន៍ជាតិយើង ព្រោះថាអ្នកដែលចូលមកវិនិយោគទាំងអស់ មិនសុទ្ធតែមានបំណងល្អនោះទេ ហេតុតែគេមើលឃើញផលចំណេញហើយ ទើបគេចូលមកវិនិយោគ ដូចនេះរដ្ឋាភិបាល ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធទាំងអស់ត្រូវត្រិះរិះឲ្យបានល្អិតល្អន់មុននឹងផ្តល់ឲ្យជនទាំងនោះ ។ ហេតុនេះដើម្បីឲ្យយល់កាន់តែច្បាស់អំពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា ថាតើបានផ្តល់ផលប្រយោជន៍ និងមានសកម្មភាពល្អប្រសើរ ឬយ៉ាងណានោះ ? តាមរយៈការសិក្សាស្រាវជ្រាវអំពីឯកសារដែលពាក់ព័ន្ធផ្សេងៗ យើងនឹងលើកយកអំពីទិដ្ឋភាពទូទៅនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច (ជំពូកទី១) និងគុណសម្បត្តិ និងគុណវិបត្តិ (ជំពូកទី២) ដែលកើតឡើងអំពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ មកបង្ហាញជាសេចក្តីដូចមានខ្លឹមសារខាងក្រោយនេះ ។

## ជំពូកទី១ និដ្ឋភាពទូទៅនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច

### ១.និយមន័យ

ដីសម្បទានសេដ្ឋកិច្ច គឺសំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឲ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់អាជីវកម្មកសិកម្ម និងកសិឧស្សាហកម្ម ដើម្បីឆ្លើយតបទៅនិងប្រយោជន៍ផ្នែកសេដ្ឋកិច្ច ។

ចំពោះកាធ្វើអាជីវកម្មកសិកម្ម និងកសិឧស្សាហកម្មក្នុងអត្ថន័យនេះ គឺចង់សំដៅដល់៖

- ការដាំដំណាំស្បៀង ឬដំណាំឧស្សាហកម្មរាប់ទាំងការដាំដើមឈើជាចំការឈើ ។
- ការចិញ្ចឹមសត្វ និងវារីវប្បកម្មដែលមានទ្រង់ទ្រាយធំ ។
- ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសំរាប់ក្នុងការកែច្នៃវត្ថុធាតុដើមដែលជាកសិផលក្នុងស្រុក ។
- សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ ។

### ២.លក្ខខណ្ឌនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច

#### ២.១.លក្ខខណ្ឌទូទៅ

១.ត្រូវបានកំណត់យកច្រើនបំផុតត្រឹមតែ ១0000 (មួយម៉ឺន) ហិចតាប៉ុណ្ណោះ ។93

២.ចំពោះរយៈពេលនៃសម្បទានដីសេដ្ឋកិច្ចវិញមានរយៈអតិបរមា ៩៩ឆ្នាំ ។94

៣.សម្បទាននោះតម្រូវឲ្យមានកិច្ចសន្យាសម្បទានរវាងម្ចាស់សម្បទាន និង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទដោយមានចែងច្បាស់ពីគោលបំណងនៃសម្បទានមានរយៈពេល និង ទីកន្លែង ព្រមទាំងកំណត់ពីលក្ខខ័ណ្ឌនៃការប្រើប្រាស់ដី ហើយការប្រើប្រាស់មួយណាមិនសមស្របទៅតាមលក្ខខ័ណ្ឌកំណត់ក្នុងកិច្ចសន្យាអាចបណ្តាលឲ្យមានការដកហូតដីនោះ តាមសេចក្តីសម្រេចរបស់រដ្ឋបាល ។95

៤.សម្បទាននិក មិនអាចកែប្រែដីតាមវិធីដែលនាំឲ្យដីនោះមិនអាចយកមកប្រើប្រាស់វិញបាន ឬធ្វើអាជីវកម្ម ដែលបំផ្លាញដល់រចនាសម្ព័ន្ធធម្មជាតិ ឬការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ ។

៥.សម្បទាននិក មិនមានសិទ្ធិផ្ទេរដីសម្បទានរបស់ខ្លួនឲ្យទៅជនដ៏ទៃទៀតទេ ។ តែសម្បទាននិកអាចផ្ទេរបានតាមរបៀបផ្ទេរកិច្ចសន្យាសម្បទានទាំងមូល ដោយឲ្យសម្បទាននិកថ្មីចុះកិច្ចសន្យាជាមួយអាជ្ញាធ

93 មាត្រា៥៩ នៃច្បាប់ភូមិបាល ២០០១។

94 មាត្រា៦១ នៃច្បាប់ភូមិបាល ២០០១។

95 មាត្រា ៥៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១។

រពាក់ព័ន្ធតែម្តង ។ ពោលគឺតម្រូវឲ្យមានការបញ្ចប់កិច្ចសន្យាសម្បទានដែលមានជាធរមាន ហើយបន្ទាប់មកត្រូវរៀបចំកិច្ចសន្យាសម្បទានថ្មីដោយមានការអនុញ្ញាតពីអាជ្ញាធរដែលពាក់ព័ន្ធ ។

៦.បន្ទាប់ពីមានការផ្តល់ដីសម្បទានមក ការធ្វើអាជីវកម្មត្រូវបានចាប់ផ្តើមក្នុងរយៈពេល១២ ខែ ។ បើមានការខកខាន មិនអាចធ្វើអាជីវកម្មលើសពីរយៈពេល ១២ខែ នាំឲ្យមានមោឃភាពសម្បទាន ។

៧.សិទ្ធិកម្មសិទ្ធិលើដីសម្បទានសេដ្ឋកិច្ចនៅតែជារបស់រដ្ឋដដែល ។ នេះមានន័យថានៅពេលចប់ រយៈពេលកិច្ចសន្យាសម្បទាន សិទ្ធិក្នុងការគ្រប់គ្រង និងកាន់កាប់ទ្រព្យសម្បត្តិនោះត្រូវ បង្វិលឲ្យរដ្ឋវិញ ។

៨.សិទ្ធិលើដីសម្បទានសេដ្ឋកិច្ចមិនអាចក្លាយជាសិទ្ធិកម្មសិទ្ធិបានទេ ។ នេះមានន័យថានៅពេលផុតរយៈពេលកំណត់ក្នុងកិច្ចសន្យាសម្បទានសេដ្ឋកិច្ច ការកាន់កាប់ក៏ត្រូវចប់ដែរ ។

### ២.២.លក្ខខណ្ឌដី

យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ ១៤៦ សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ជូនដោយស្របច្បាប់ទៅលើដីឯកជនរបស់រដ្ឋ ។ ដីឯកជនរបស់រដ្ឋជាដីដែលមិនផ្តល់ការប្រើប្រាស់ជាសេវាសាធារណៈ ឬស្ថិតនៅក្រោមប្រភេទនៃដីសាធារណៈរបស់រដ្ឋដទៃទៀត ។ ក្រៅពីនេះដីសម្បទានសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឲ្យចំពោះតែដីដែលមានលក្ខណៈវិនិច្ឆ័យ៥យ៉ាងដូចខាងក្រោម៖

១.ដីដែលបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរបស់រដ្ឋ និងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

២.ដីដែលមានការប្រើប្រាស់ ដែលអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ហើយប្រើប្រាស់មានលក្ខណៈសមស្របទៅតាមផែនការនោះ ។

៣.ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន ។

៤.ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាធានាថា មិនមានការបង្ខំឲ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន ។

៥.ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈ ឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដីមានសមត្ថកិច្ច និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់នោះ ។

### ៣. លក្ខខណ្ឌក្នុងការទទួលដីសម្បទានសេដ្ឋកិច្ច

លក្ខខ័ណ្ឌក្នុងការទទួលដីសម្បទានសេដ្ឋកិច្ចរួមមានដូចជា៖

១.ដីសម្បទានសេដ្ឋកិច្ចមិនអាចប្រគល់ដោយឥតគិតថ្លៃទៅឲ្យសម្បទានិកបានទេ ។

២.សម្បទានិកត្រូវបានគោលរពតាមលក្ខខ័ណ្ឌ ដើម្បីសម្រេចគោលបំណងដូចជា៖

- អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិឧស្សាហកម្ម ដែលតម្រូវឲ្យមានការវិនិយោគដើមទុនដំបូងក្នុងអាត្រាខ្ពស់ និងកម្រិតសមស្រប។
- សម្រេចបាននៅការព្រមព្រៀងមួយចំនួន ពីអ្នកវិនិយោគសម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាព ដោយផ្អែកលើការប្រើប្រាស់ដីនៃតំបន់នោះ ។
- បង្កើនភាពមានការងារធ្វើក្នុងក្របខណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើឲ្យមានកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសំបូរបែប និងក្នុងក្របខណ្ឌក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប ។
- លើកកម្ពស់លើការវិនិយោគក្នុងគ្រោងដីសម្បទានសេដ្ឋកិច្ច ។
- បង្កើនចំណូលជូនរដ្ឋតាមរយៈថ្លៃពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធនានា ។

៣.ត្រូវគោរពតាមនិតិវិធីការផ្តួចផ្តើមគម្រងសម្បទានសេដ្ឋកិច្ចទាំងពីររូបភាពដូចខាងលក្រោមនេះ៖

- សំណើមានការអំពាវនាវដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកលើកគម្រោងដើម្បីអំពាវនាវឲ្យអ្នកវិនិយោគដាក់សំណើ ។
- សំណើមិនមានការអំពាវនាវ ដែលអ្នកវិនិយោគជាអ្នកលើកគម្រោងស្នើទៅរដ្ឋដើម្បីការអនុញ្ញាត។

៤.សុំសម្បទានសេដ្ឋកិច្ចអាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០(មួយម៉ឺន)ហិចតា ។

៥.ចំពោះរយៈពេលនៃសម្បទានដីនេះត្រូវកំណត់៩៩(កៅសិបប្រាំបួន) ឆ្នាំយ៉ាងច្រើន ។

## ជំពូកទី២ គុណសម្បត្តិ និងគុណវិបត្តិនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច

ក្នុងការផ្តល់ដីសម្បទានដីសេដ្ឋកិច្ច បានផ្តល់នូវផលប្រយោជន៍ជាច្រើនចំពោះជាតិ និងប្រជាជនដោយក្នុងនោះក៏សម្រួលឲ្យប្រជាពលរដ្ឋមានជីវភាពសមរម្យ មិនចាំបាច់ធ្វើចំណាក់ស្រុក និងមានហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងមូលដ្ឋានរបស់ខ្លួន ។ ម្យ៉ាងទៀតបានបង្កើនឲ្យមានចំណូលរដ្ឋ ឬចំណូលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ផ្សេងៗ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដីពន្ធ និងកម្រៃលើសេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធ ។ ដូច្នេះឃើញថាការធ្វើសម្បទានដីសេដ្ឋកិច្ច គឺជាការណ៍ល្អសម្រាប់ការអភិវឌ្ឍប្រទេសជាតិអោយមានភាពរីកចំរើនប្រកបដោយចីរភាព ។ ទន្ទឹមនឹងនេះ ការធ្វើសម្បទានដីសេដ្ឋកិច្ចក៏

រងនូវផលប៉ះពាល់ផងដែរក្នុងនោះមានដូចជា ការជម្លៀសប្រជាជនចេញដែលធ្វើអោយប៉ះពាល់ដល់ជីវភាព ការបាត់បង់ព្រៃឈើ និងការបាត់បង់សត្វព្រៃដែលមានស្រាប់ ។

យើងឃើញថាការធ្វើសម្បទានដីសេដ្ឋកិច្ច មានគុណសម្បត្តិជាច្រើន ប៉ុន្តែក៏មានគុណវិបត្តិផងដែរ ។ ដូច្នេះដើម្បីអោយកាន់តែជ្រាបច្បាស់ក្នុងជំពូកនេះ ជាដំបូងយើងនឹងលើកឡើងពីគុណសម្បត្តិនៃការធ្វើសម្បទានដីសេដ្ឋកិច្ច បន្ទាប់មកយើងនឹងលើកឡើងគុណវិបត្តិនៃការធ្វើសម្បទានដីសេដ្ឋកិច្ច ។

## ១.គុណសម្បត្តិ

### ១.១.រដ្ឋទទួលបានចំនូលពីការបង់ពន្ធ

ចំណូលសម្រាប់រដ្ឋក្នុងន័យនេះ គឺសំដៅទៅលើការប្រមូលពន្ធ កម្រៃនៃការប្រើប្រាស់ដី និងសេវាពាក់ព័ន្ធផ្សេងៗ ដែលក្នុងនោះធ្វើឲ្យមានការអភិវឌ្ឍផលិតកម្ម កសិកម្ម ប្រពលវប្បកម្ម និងកសិឧស្សាហកម្មដែលតម្រូវឲ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់ និងមានកម្រិតសមស្របតាមច្បាប់ ។ ដូច្នេះបើការវិនិយោគដើមទុនដំបូងមានអត្រាខ្ពស់ រដ្ឋទទួលបានកម្រៃច្រើន នឹងអាចវាយតម្លៃបានថាក្រុមហ៊ុនមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ដំណើរការទៅលើផែនការរបស់ខ្លួនដែលមិនអាចនាំឲ្យបានការក្ស័យធន ហើយរដ្ឋទទួលបានកម្រៃទៀងទាត់សម្រាប់ផែនការប្រចាំឆ្នាំ ។

បើយោងតាមកិច្ចសន្យាស្តីពីការវិនិយោគដាំដំណាំកសិឧស្សាហកម្ម ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃ ស្ករអំពៅ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុនកោះកុងផ្លេនថេសិនខមភេនីលីមីធីត ដែលបានកំណត់ពីការបង់ថ្លៃឈ្នួលដីប្រចាំឆ្នាំតាមអត្រាដូចខាងក្រោម៖

- ចាប់ពីឆ្នាំទី៥ ដល់ឆ្នាំទី ១៥ ១ហិចតា ១ដុល្លាក្នុងមួយឆ្នាំ
- ចាប់ពីឆ្នាំទី១៦ ដល់ឆ្នាំទី៣០ ១ហិចតា ២ដុល្លាក្នុងមួយឆ្នាំ
- ចាប់ពីឆ្នាំទី៣១ ដល់ឆ្នាំទី៥០ ដុល្លាក្នុងមួយឆ្នាំ៣ហិចតា ១
- ចាប់ពីឆ្នាំទី៥១ ឡើងទៅដល់ចប់កិច្ចសន្យា ១ហិចតា ៤ដុល្លាក្នុងមួយឆ្នាំ ។

ដោយប្រាក់ឈ្នួលត្រូវបង់ជាប្រចាំឆ្នាំចូលថវិការរដ្ឋនោះតាមរយ:គណនីរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ឲ្យបានមុនថ្ងៃទី៣១ ខែ មករា នាឆ្នាំនីមួយៗ ។ ម្យ៉ាងវិញទៀតក្នុងករណីមានការយឺតយ៉ាវក្នុងការបង់ប្រាក់ឈ្នួលតាមការកំណត់នោះ ក្រុមហ៊ុនត្រូវទទួលពិន័យ ២% ក្នុងមួយខែលើទឹកប្រាក់ឈ្នួលប្រចាំឆ្នាំនីមួយៗ តាមចំនួនខែដែលយឺតយ៉ាវ ។ ក្រុមហ៊ុនត្រូវមានកាតព្វកិច្ចបង់ពន្ធផ្សេងៗទៀត ជូនរដ្ឋតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាន ។

ដូច្នេះយើងឃើញថារដ្ឋមិនត្រឹមតែទទួលចំណូលលើពន្ធនៃការប្រើប្រាស់ដីតែប៉ុណ្ណោះទេ គឺរដ្ឋអាចទទួលចំណូលតាមរយៈពន្ធនាំចេញ នាំចូលផ្សេងៗទៀត ដូចជាឧបករណ៍គ្រឿងចក្រ វត្ថុធាតុគីមី និង សម្ភារៈផ្សេងៗ ដែលនាំចូលមកក្នុងស្រុក ហើយបើចង្វាក់ផលិតកម្មនោះមានដំណើរការបានល្អ លើសពីការផ្គត់ផ្គង់ក្នុងស្រុក ដែលអាចនាំឲ្យក្រុមហ៊ុននាំចេញផលិតផលរបស់ខ្លួនទៅក្រៅប្រទេសនោះធ្វើឲ្យរដ្ឋទទួលបានចំណូលពន្ធសម្រាប់ការនាំចេញបន្ថែមទៀត ។

### ១.២.កាត់បន្ថយអត្រាអ្នកអត់ការងារធ្វើ

ការធ្វើសម្បទានដីសេដ្ឋកិច្ចបានចូលរួមចំណែកយ៉ាងច្រើន ក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា ។ ដោយការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់ចំណេះដឹងខាងបច្ចេកទេសទៅដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននៃតំបន់ដែលត្រូវធ្វើសម្បទានដីសេដ្ឋកិច្ចនោះ ឲ្យទទួលបានចំណេះដឹងដើម្បីបម្រើការងារនៅក្នុងក្រុមហ៊ុន ។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ គឺអាចផ្តល់ការងារជូនដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននៃគម្រោងអភិវឌ្ឍន៍ឲ្យមានការងារធ្វើគ្រប់ៗគ្នា កាត់បន្ថយបានទាំងអំពើចោរកម្មផ្សេងៗ ។ ជាក់ស្តែងនៅក្នុងកិច្ចសន្យាស្តីពីការវិនិយោគដាំដំណាំកសិឧស្សាហកម្ម ដំណាំផ្សេងៗ និងសាងសង់រោងចក្រកែច្នៃ ស្ករអំពៅ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង*ក្រុមហ៊ុនកោះកុងផ្លេនថេនិនខមភេនីលីមីធីត*នេះដែលបានចែងយ៉ាងច្បាស់ គឺត្រូវប្រើប្រាស់កម្លាំងពលកម្មក្នុងស្រុកជាចាំបាច់ ក្នុងករណីគ្មានអ្នកឯកទេសខ្មែរក្នុងស្រុក ក្រុមហ៊ុនអាចជ្រើសរើសអ្នកឯកទេសបទេសដើម្បីជួយណែនាំ ឬបង្ហាត់បង្ហាញអំពីការងារបច្ចេកទេសអាជីវកម្ម ផលិតកម្មតាមសេចក្តីត្រូវការចាំបាច់របស់ខ្លួន ដោយគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ជាពិសេសយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាព និងការអប់រំដល់បុគ្គលិកកម្មករ និងគ្រួសាររបស់គេ ។

### ១.៣.កសាងហេដ្ឋារចនាសម្ព័ន្ធថ្មីៗ នៅតាមមូលដ្ឋាននៃគម្រោង

នៅក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺតម្រូវឲ្យមានការអភិវឌ្ឍន៍នៅក្នុងតំបន់មូលដ្ឋានដែលជាកត្តាចាំបាច់ ។ នៅក្នុងការអភិវឌ្ឍន៍នេះសំដៅការធ្វើស្ពានថ្នល់កសាងលំនៅដ្ឋានសមស្របជូនប្រជាពលរដ្ឋ មន្ទីរពេទ្យ ព្រះវិហារ(វត្តអារាម) សាលារៀន មណ្ឌលកំសាន្ត និងការប្រើប្រាស់ដីដោយគោរពតាមលក្ខខ័ណ្ឌនិរន្តភាព ធនធានធម្មជាតិរបស់ទីតាំង និងពិនិត្យមើលលើផលប៉ះពាល់បរិស្ថាន ដែលបណ្តាលមកពីការធ្វើអាជីវកម្ម ផលិតកម្ម ។

ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ គឺជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងសង្គម ពីព្រោះតំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច ម្យ៉ាងវិញទៀតដើម្បីឲ្យប្រជាពលរដ្ឋនៅក្នុងតំបន់អភិវឌ្ឍន៍ទទួលបាននូវ

ការអភិវឌ្ឍន៍ពិតប្រាកដ តម្រូវការចាំបាច់របស់ពួកគេ គឺដូចជាសាលារៀន មណ្ឌលសុខភាព ប្រព័ន្ធទឹកភ្លើង វត្តអារាម រោងចក្រគួរត្រូវបានឆ្លើយតប ។ តម្រូវការទាំងនេះ គឺជាចំណែកដ៏សំខាន់សម្រាប់ទ្រទ្រង់ដល់ជីវភាពប្រចាំថ្ងៃ សម្រាប់ប្រជាពលរដ្ឋក្នុងតំបន់នោះរស់នៅដោយមានលក្ខណៈសមរម្យ ។

កិច្ចសន្យាសម្បទាន ដែលមានទំនាក់ទំនងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់សេវាដោយផ្ទាល់ ឬដោយប្រយោលដើម្បីជាប្រយោជន៍សាធារណៈហេតុ ដូចនេះស្ថាប័នទាក់ទងនឹងវិស័យនេះរួមមានៈ

- ការផលិត ការជញ្ជូន និង ការចែកចាយថាមពលអគ្គិសនី
- ហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធ ដឹកជញ្ជូន មានជាអាទិ៍ ផ្លូវថ្នល់ ស្ពាន ព្រលានយន្ត ហោះ កំពង់ផែ ផ្លូវដែក ព្រែកជីក ។
- ការផ្គត់ផ្គង់ទឹកស្អាត អនាម័យ
- ហេដ្ឋារចនាសម្ព័ន្ធប្រើឱ្យវិស័យឧស្ម័ន និងប្រេងដូចជា បំពង់បង្ហូរប្រេងនិង ឧស្ម័ន ។
- ប្រព័ន្ធលូ ប្រព័ន្ធបង្ហូរទឹក និង ប្រព័ន្ធបូមស្តារ
- ព្រឹត្តិកម្ម និងការគ្រប់គ្រងកាកសំណល់
- ហេដ្ឋារចនាសម្ព័ន្ធ បម្រើឲ្យប្រព័ន្ធធារាសាស្រ្ត និងការងារកសិកម្ម
- វិស័យផ្សេងៗទៀត ដែលច្បាប់ដោយឡែកណាមួយអនុញ្ញាតឲ្យមានការផ្តល់នូវសម្បទាន ។

### ១.៤. នាំមកនូវបច្ចេកវិទ្យាថ្មីៗ ដល់កម្ពុជា

នៅក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា គេឃើញមានយុទ្ធសាស្រ្តជាច្រើន ដើម្បីទាក់ទាញវិនិយោគទុនឱ្យមកវិនិយោគនៅកម្ពុជាដែលក្នុងនោះ យុទ្ធសាស្រ្ត មួយនៃយុទ្ធសាស្រ្តដ៏ទៃច្រើនទៀតនោះ គឺការផ្តល់ដីសម្បទានសេដ្ឋកិច្ច ។

នៅពេលដែលសម្បទានិក ទទួលបាននូវទំហំដីដែលបានកំណត់ពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចរួចមកសម្បទានិក ត្រូវចាប់ផ្តើមធ្វើការអភិវឌ្ឍន៍ក្នុងរយៈពេលមួយឆ្នាំនូវវិស័យដែលខ្លួនបានស្នើអភិវឌ្ឍន៍ ។ ក្នុងដំណើរការអភិវឌ្ឍចាប់តាំងពីដំណើរការនៃការដាំដុះការថែទាំ ការប្រមូលផលការកែឆ្នៃ ការចម្រាញ់ ការផលិត និងការវេចខ្ចប់សុទ្ធសឹងតែតម្រូវឲ្យមានបច្ចេកទេស អ្នកជំនាញច្បាស់លាស់ និងឧបករណ៍ទំនើបៗ ដើម្បីបម្រើឲ្យចង្វាក់ផលិតកម្មនីមួយៗ ។

សកម្មភាពទាំងនេះបញ្ជាក់ឱ្យឃើញថា សម្បទានិកបាននាំមកនូវបច្ចេកវិទ្យាថ្មីៗ មកដល់កម្ពុជា ពិសេសសម្រាប់ប្រជាពលរដ្ឋកម្ពុជាបានរៀន មានចំណេះដឹង និងមានវិជ្ជាជីវៈទៅតាមជំនាញរៀងៗខ្លួន ។

### ១.៥.សោភ័ណភាព និងសណ្តាប់ធ្នាប់ល្អ

ចំពោះការធ្វើសម្បទានដីសេដ្ឋកិច្ច មិនត្រឹមតែមានហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ សម្រាប់តំបន់ដែលអភិវឌ្ឍន៍ប៉ុណ្ណោះទេ គឺត្រូវមានសោភ័ណភាពផងដែរ ។ ដើម្បីឲ្យក្លាយទៅជាតំបន់មួយដែលទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនា ឬកំសាន្តដែលប្រកបដោយបរិយាកាសបរិសុទ្ធ ។ ចំនុចនេះហើយដែលនាំឲ្យរដ្ឋទទួលបានអត្ថប្រយោជន៍ពីការធ្វើសម្បទានដីសេដ្ឋកិច្ចផង ព្រមទាំងប្រែក្លាយតំបន់សម្បទានដីសេដ្ឋកិច្ច ឲ្យទៅជាតំបន់ទេសចរណ៍មួយបែបទៀតដែលអាចធ្វើទៅបាន ។

ជាក់ស្តែងនៅក្នុងកិច្ចសន្យាស្តីពីការជួលទីតាំងក្នុងភូមិសាស្ត្រ ស្រុកគីរីសាគរ និងស្រុកបុទុមសាគរនៅក្នុងខេត្តកោះកុងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន *UNION DEVELOPMENT GROUP CO,LTD* ។ យ៉ាងណាមិញក្រុមហ៊ុន *UNION DEVELOPMANT GROUP CO,LTD* ជាក្រុមហ៊ុនបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មលេខ Inv;១៣២៣/០៨E ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៥ មានបំណងធ្វើការអភិវឌ្ឍន៍ភូមិសាស្ត្រ ស្រុកគីរីសាគរ និងស្រុកបុទុមសាគរ ខេត្តកោះកុងឲ្យក្លាយទៅជាតំបនពាណិជ្ជកម្ម និងរមណីយដ្ឋានទេសចរណ៍ ស្របតាមស្តង់ដារអន្តរជាតិដែលទាក់ទាញភ្ញៀវទេសចរណ៍ និងការវិនិយោគ ។

ក្រោយពីរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងធ្វើឲ្យតំបន់សម្បទានដីសេដ្ឋកិច្ចមានសោភ័ណភាពរួចហើយនោះគឺត្រូវមានគោលការណ៍គ្រប់គ្រងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការការពារតំបន់ដែលត្រូវការពារព្រមទាំងចូលរួមទទួលខុសត្រូវចំពោះការខូចខាតបរិស្ថាននានានៃទីតាំងជួល ។ម្យ៉ាងវិញទៀតត្រូវមានវិធានការប្រុងប្រយ័ត្នក្នុងការការពារបរិស្ថានទាំងនៅក្នុង និងក្រៅទីតាំងជួល ដោយទប់ស្កាត់ការខូចខាត ការរំខានដល់មនុស្ស សត្វ រុក្ខជាតិ ការបំពុលការធ្វើឲ្យកខ្វក់ការរំខានដោយសម្លេង និងផលផ្សេងៗទៀតនៃការសាងសង់ ។ ដូច្នេះក្រុមហ៊ុនត្រូវគោរពតាមការតម្រូវនៃក្រសួងពាក់ព័ន្ធដែលបានចេញនៅគោលការណ៍សម្រាប់អនុវត្ត ដូចមានចែងក្នុងកិច្ចសន្យា ច្បាប់ និងលិខិតបទដ្ឋាននានាដែលទាក់ទងជាមួយ ការទទួលខុសត្រូវចំពោះការគ្រប់គ្រងកាកសំណល់រឹង រាវ និងផលប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលមានលើទីតាំងជួល និងជុំវិញតំបន់ដែលធ្វើសម្បទានដីសេដ្ឋកិច្ចនោះ ។

ដោយមានកត្តាខាងលើនេះ បានធ្វើឲ្យតំបន់ធ្វើសម្បទានដីសេដ្ឋកិច្ចមានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អបានធ្វើឲ្យវិស័យទេសចរណ៍រីកចំរើន និងភ្ញៀវទេសចរណ៍មានការកើនឡើង ។

### ១.៧.ជម្រុញកំណើនសេដ្ឋកិច្ចជាតិលើគ្រប់វិស័យ

នៅឆ្នាំ១៩៩២ ស្ថានភាពសេដ្ឋកិច្ចជាតិនៃប្រទេសកម្ពុជាត្រូវបានគេផ្ទេរពីការធ្វើផែនការទៅមូលដ្ឋានទីផ្សារសេរីនេះ ។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានបើកសម្រាប់ទាំងការវិនិយោគឯកជនក្នុងស្រុក និងបរទេសនៅក្នុងវិស័យកសិកម្ម ។ ក្នុងវិស័យនេះរាជរដ្ឋាភិបាលកម្ពុជាបានផ្តោតទៅលើការវិនិយោគនៅក្នុងដីសម្បទានសេដ្ឋកិច្ចសម្រាប់ដាំដំណាំកសិឧស្សាហកម្ម ។ នេះជាគោលដៅដ៏សំខាន់មួយនៃការបើកនេះ គឺដើម្បីផ្តល់នូវការប្រើប្រាស់ដោយគិតថ្លៃសម្រាប់ដីកសិកម្ម និងចំការកន្លងមកឧស្សាហកម្ម និងដំណើរការសម្រាប់ការនាំចេញដែលត្រូវបាន គេរំពឹងថានឹងកើនឡើង ។ ដោយរដ្ឋាភិបាលបង្កើតការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ជនបទ ។ ការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចបានរួមចំណែកយ៉ាងសំខាន់ ក្នុងការធ្វើឲ្យសេដ្ឋកិច្ចប្រទេសជាតិមានការរីកចម្រើន ។

ប្រសិនបើយើងនិយាយពីការធ្វើសម្បទានដីសេដ្ឋកិច្ច មិនមែនចេះតែផ្តល់ឲ្យ និងទទួលវាដោយមិនមានគោលបំណង ឬទិសដៅច្បាស់លាស់នោះទេ ព្រោះវាអាចផ្តល់មកវិញនូវផលអវិជ្ជមាន ត្រឡប់មកវិញ ។ ហេតុនេះការផ្តល់សម្បទានដីសេដ្ឋកិច្ច វាបានបង្ហាញនូវទិសដៅមួយរបស់ខ្លួនក្នុងការធ្វើយ៉ាងណាឲ្យមានការអភិវឌ្ឍប្រកបដោយភាពវិជ្ជមានដោយទិសដៅជារួមនៃសម្បទានដីសេដ្ឋកិច្ច គឺមានដូចខាងក្រោមៈ

- ធ្វើឲ្យមានការអភិវឌ្ឍតាមរយៈ ការអភិវឌ្ឍសកម្មភាពកសិកម្ម និងកសិឧស្សាហកម្មដែលពឹង ផ្អែកខ្លាំងតម្រូវឲ្យមានអត្រាការប្រាក់ខ្ពស់ និងកម្រិតសមស្របនៃការវិនិយោគដើមទុនដំបូង ។
- ធ្វើឲ្យសម្រេចបាននូវសំណុំជាក់លាក់មួយនៃកិច្ចព្រមព្រៀងពីការវិនិយោគសម្រាប់ការអភិវឌ្ឍដីធ្លីនៅក្នុងលក្ខណៈសមស្រប និងដោយផ្អែកលើផែនការប្រើប្រាស់ដីសម្រាប់តំបន់នោះបាន ។
- បង្កើនការងារនៅតាមតំបន់ជនបទក្នុងក្របខ័ណ្ឌនៃប្រពលវប្បកម្ម និងឱកាសនៃការប្រកបរបរចិញ្ចឹមជីវិត និងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិ ដែលមានមូលដ្ឋាននៅលើប្រព័ន្ធអេកូឡូស៊ីសមរម្យមួយ ។
- ធ្វើឲ្យមានការលើកទឹកចិត្តដល់ការវិនិយោគតូច ឬធំនៅក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច
- ដើម្បីបង្កើតប្រាក់ចំណូលរបស់រដ្ឋ ឬចំណូលខេត្ត ឬសហគមន៍តាមរយៈថ្លៃដីសេដ្ឋកិច្ច ប្រើប្រាស់ពន្ធ និងការទាក់ទងនឹងការផ្តល់សេវា ។
- នៅក្នុងការបង្កើនផលិតកម្មកសិកម្ម និងកសិឧស្សាហកម្មដោយប្រើបច្ចេកវិទ្យាទំនើប
- ការបង្កើតការបង្កើនការងារ
- ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន

- ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ជៀសវាង ឬតិចតួចបំផុតនៃផលប៉ះពាល់សង្គមអវិជ្ជមាន
- ទំនាក់ទំនង និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសង្គមកិច្ច និងសម្បទានដីសេដ្ឋកិច្ច
- រមណីដ្ឋានទេសចរណ៍ស្របតាមស្តង់ដារអន្តរជាតិ ដែលអាចជាកត្តាទាក់ទាញភ្ញៀវទេសចរណ៍ និងវិនិយោគិន ព្រោះថាមានស្ថានថ្នល់ គឺជាកត្តាចម្បងក្នុងការធ្វើដំណើរ និងដឹកជញ្ជូនផលិតផលទៅកាន់ទីផ្សារ ឬ សំរាប់នាំចេញ។

## ២. គុណវិបត្តិ

### ២.១.ប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ

ព្រៃឈើ គឺជាផ្នែកមួយនៃបរិស្ថាន ការកាប់ព្រៃឈើ នឹងនាំមកនូវផលអាក្រក់ដល់មនុស្ស និងសត្វជាច្រើនដូចជា បាត់ជំរកសត្វ អាកាសធាតុឡើងក្តៅ គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះ អាកាសធាតុប្រែប្រួលខុសប្រក្រតី សំណឹកដី ឬទឹកហូរជាច់ដីជាដើម។ល។ សម្បទានដីសេដ្ឋកិច្ចបានជំរុញឲ្យមានសកម្មភាពកាប់ព្រៃឈើកើនឡើង គួរឲ្យកត់សំគាល់ និងមានលក្ខណៈគគ្រឹកគគ្រេង បើតាមរបាយការណ៍ឆ្នាំ២០០៤ បានលើកឡើងនូវកង្វល់អំពីការកាប់ព្រៃឈើមានតម្លៃនៅក្នុងសម្បទានដីសេដ្ឋកិច្ចរួមទាំងសម្បទានក្រុមហ៊ុនហ្គ្រីនរិច(Green Rich) ក្នុងខេត្តកោះកុង និងសម្បទានក្រុមហ៊ុនផលិតម្សៅតំឡូងមី (Flour Manufacturing) ក្នុងខេត្តស្ទឹងត្រែង ដែលបើតាមសេចក្តីរាយការណ៍ថា ការកាប់ឈើនូវតែបន្តមានក្នុងឆ្នាំ២០០៧ ។96

សេចក្តីរាយការណ៍ ដែលបានទទួលជាបន្តបន្ទាប់ ថាការកាប់ឈើកំពុងតែប្រព្រឹត្តទៅក្នុងដីសម្បទានសេដ្ឋកិច្ច ដែលបានផ្តល់ឱ្យនៅតំបន់ព្រៃឈើ។ ក្រុមហ៊ុន អេច.អឹម.អេឆ លីមីធីត (H.M.H) បាននឹងកំពុងកាប់ឈើនៅក្នុងសម្បទានរបស់ខ្លួននៅខេត្តកំពង់ធំ ស្ថិតនៅក្នុងទីតាំងព្រៃសម្បទានរបស់ក្រុមហ៊ុនហ្គេត អ៊ិនធឺណាស្យូណាល (Gat International) ។ សេចក្តីរាយការណ៍បានបញ្ជាក់ផងដែរថា មានការកាប់ឈើបានកើតមាននៅក្នុងសម្បទានដីសេដ្ឋកិច្ច ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែងជាពិសេស ក្នុងស្រុកសំបូរ និងស្រុកសេសាន ដែលជាកន្លែងដែលសម្បទានជាច្រើនត្រូវផ្តល់នៅលើតំបន់ព្រៃក្រាស់ រួមទាំងនៅលើអតីតទីតាំងព្រៃសម្បទាន យីងវូត (Kingwood) ផងដែរ។

96 ការវិភាគលំអិតជាងនេះ អំពីផលប៉ះពាល់នៃក្រុមហ៊ុន អ៊ូ ជី សាន មាននៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍ឆ្នាំ២០០៤ ដែលត្រូវបានបន្ថែមបន្ទាប់ពីការចុះផ្សាយដំបូងនៃរបាយការណ៍នេះ ។
របាយការណ៍អាចរកបាននូវ http://cambodia.ohchr.org/report_subject.aspx.

ផលប៉ះពាល់ផ្សេងទៀតរបស់ដីសម្បទានសេដ្ឋកិច្ចលើបរិស្ថាន រួមមានការប្រើថ្នាំសំលាប់សត្វល្អិត និងសារជាតិគីមីដទៃទៀតដែលធ្វើឲ្យទឹកកខ្វក់ និង បានធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់សមាជិកសហាគមន៍ និងសត្វពាហណៈរបស់ពួកគេ នៅក្នុងសម្បទានក្រុមហ៊ុន អ៊្វជីសាន និងសម្បទានក្រុមហ៊ុនផលិតម្សៅតំឡូងមី ។

## ២.២. ប៉ះពាល់ដល់កម្មសិទ្ធិឯកជននៅក្នុងគម្រោងអភិវឌ្ឍ

ប្រសិនបើរដ្ឋមានគោលបំណងចង់ធ្វើ គំម្រោងអភិវឌ្ឍនៅដីមួយដែលផ្តល់ទៅឲ្យក្រុមហ៊ុននូវដី សម្បទានសេដ្ឋកិច្ច ប៉ុន្តែដីដែលរដ្ឋបានផ្តល់ឲ្យនោះជាដីដែលពុំមែនជាដីសាធារណៈរបស់រដ្ឋទេ ប៉ុន្តែវាជាដីឯកជនរបស់រដ្ឋ ដែលមានប្រជាពលរដ្ឋរស់នៅស្នាក់អាស្រ័យរស់នៅអាស្រ័យផលជាយូរមកហើយ ដូច្នេះហើយការផ្តល់ដីសម្បទាននេះ បានបង្កនូវផលប៉ះពាល់ដល់កម្មសិទ្ធិឯកជន ដូច្នេះហើយរដ្ឋត្រូវធ្វើការដោះដូរមួយដែលសមរម្យ ឬផ្តល់នូវការដោះដូរនូវដីថ្មី ឬធ្វើការអភិវឌ្ឍនៅនឹងកន្លែង ។ ប៉ុន្តែដើម្បីឲ្យប្រជាពលរដ្ឋធ្វើការផ្លាស់ប្តូរទៅរកដីលំនៅដ្ឋានថ្មី សម្រាប់គោលនយោបាយរបស់រដ្ឋាភិបាល គឺមានគោលនយោបាយបីដើម្បីអោយធ្វើការផ្លាស់ប្តូរដល់ប្រជាពលរដ្ឋ ។ មុននឹងធ្វើការផ្តល់ដីសម្បទានដល់ក្រុមហ៊ុន រដ្ឋត្រូវធ្វើការសិក្សានៅលើដីកន្លែងភូមិសាស្ត្រដែលផ្តល់ដីសម្បទានសេដ្ឋកិច្ចជាមុនសិន ។ ផលប៉ះពាល់ដល់កម្មសិទ្ធិឯកជននៅក្នុងគម្រោងអភិវឌ្ឍ គឺអាចធ្វើឲ្យប្រជាពលរដ្ឋបាត់បង់ទីលំនៅ ឬដីសម្រាប់ធ្វើកសិកម្ម ឬក៏ជាដីកេរ្តិ៍របស់ឪពុកម្តាយ ដែលពួកគេរស់នៅតាំងពីក្មេងហើយពួកគេរស់នៅជាមួយនឹងអនុស្សាវរីយ៍ជាច្រើនជាមួយនឹងគេ ។ ដូច្នេះរដ្ឋត្រូវមានគោលនយោបាយដោះដូរឲ្យសមរម្យ ឬផ្តល់ដីសម្រាប់ដោះដូរជាមួយ និងទីតាំងល្អ ដើម្បីឲ្យការតាំងទីលំនៅថ្មីមានលក្ខណៈល្អប្រសើរជាងកន្លែងចាស់ ឬប្រហាក់ប្រហែលនឹងកន្លែងចាស់ដោយមិនបង្កការលំបាក ។

## ២.៣.ប៉ះពាល់ដល់ជីវភាពរបស់ប្រជាជនដែលអាស្រ័យអនុផលព្រៃឈើ

ក្រៅពីផលប៉ះពាល់ដូចដែលបានរៀបរាប់ខាងលើ សម្បទានដីសេដ្ឋកិច្ចក៏មានផលប៉ះពាល់ផងដែរដល់ប្រជាជនដែលអាស្រ័យអនុផលព្រៃឈើ ។ ដូចដែលយើងបានដឹងហើយថា សម្បទានដីសេដ្ឋកិច្ចគឺផ្តល់ជូនទៅឲ្យក្រុមហ៊ុនឯកជនសម្រាប់ធ្វើការវិនិយោគ និងអភិវឌ្ឍន៍ ។ ជាការពិត នៅពេលដែលសម្បទានដីសេដ្ឋកិច្ច គឺមានការចាប់ផ្តើមគម្រោងវិនិយោគផ្សេងៗ ការវាទទីយកដី និងការកាប់បំផ្លាញព្រៃឈើនៅក្នុងតំបន់ទាំងនោះ គឺជារឿងដែលត្រូវធ្វើដោយមិនអាចជៀសផុតបានឡើយ ។ ការកាប់បំផ្លាញព្រៃបានផ្តល់នូវផលវិបាកយ៉ាងច្រើនសម្រាប់សង្គម ដូចជាផលប៉ះពាល់ដល់សេដ្ឋកិច្ច សង្គម និង បរិស្ថានជាដើម ។ អ្វីដែលគួរឲ្យយកចិត្តទុកដាក់ និងគួរឲ្យបារម្ភណ៍ជាងគេបំផុតនោះ គឺផលប៉ះពាល់ដល់ប្រជាជនដែលមាន

ចំណេះដឹងទាបដែលរស់នៅតាមទីជនបទដាច់ស្រយាល និងប្រកបមុខរបរតាមរយៈការអាស្រ័យអនុផលព្រៃឈើ ។

នៅពេលដែលមានការផ្តល់សម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកក្នុងការផ្តល់សម្បទាន និងសម្បទានិកតែងតែមានការព្រមព្រៀងគ្នាក្នុងការវាស់វែង និងកំណត់ព្រំប្រទល់ឲ្យបានជាក់លាក់នូវទីតាំង ឬផ្ទៃក្រឡាដីដែលត្រូវផ្តល់ជូនទៅឲ្យសម្បទានិក (ក្រុមហ៊ុន) ។ ក្រោយពីមានការកំណត់ទីតាំង និងព្រំប្រទល់បានជាក់លាក់ហើយក្រុមហ៊ុននឹងចាប់ផ្តើមគម្រោងវិនិយោគនៅក្នុងអំឡុងពេលសមស្របណាមួយ ។ ជាលទ្ធផលក្រោយពេលមានកំណត់ព្រំប្រទល់ និងចាប់ផ្តើមគម្រោងវិនិយោគហើយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ មិនអាចចូលទៅប្រកបរបរចិញ្ចឹមជីវិតជាធម្មតាដូចពីមុនទៀតឡើយ ។ មានន័យ ប្រជាជនដែលរស់នៅក្នុងតំបន់នោះ មិនអាចចូលទៅអាស្រ័យអនុផលព្រៃឈើដូចជា ការរកអុស រកជ័រ បេះផ្លែឈើ រកក្លូច ឬត្រពាំង ។ល។ នៅក្នុងតំបន់ទាំងនោះទៀតឡើយ ។ ទន្ទឹមគ្នានេះ សម្រាប់ប្រជាជនដែលមានចិញ្ចឹមសត្វពាហនៈក៏មិនអាចប្រើប្រាស់តំបន់ទាំងនោះ ដើម្បីឲ្យសត្វពាហនៈរបស់ខ្លួនដើរស៊ីស្មៅនៅតំបន់ទាំងនោះផងដែរ ។

លើសពីនេះទៀត សម្បទានដីសេដ្ឋកិច្ចក៏ធ្វើឲ្យមានផលប៉ះពាល់ដល់ការប្រកបរបរកសិកម្មតាមបែបប្រពៃណី ប៉ះពាល់ដល់ប្រពៃណី ទំនៀមទម្លាប់ ប៉ះពាល់ដល់ដែនបម្រុងធម្មជាតិ ព្រៃទាក់ទាញទឹកភ្លៀង និង ព្រៃការពារទីជម្រាលជាដើម ។

ជារួមមក យើងអាចសន្និដ្ឋានបានថា ការផ្តល់សម្បទានដីសេដ្ឋកិច្ចពិតជាបានផ្តល់នូវផលប៉ះពាល់យ៉ាងច្រើនដល់ប្រជាជនទាំងឡាយណាដែលប្រកបរបរអាស្រ័យអនុផលព្រៃឈើ ។ អាស្រ័យហេតុនេះ ដើម្បីធ្វើការកាត់បន្ថយនូវផលប៉ះពាល់ដូចដែលបានរៀបរាប់ខាងលើឲ្យបានជាអតិប្បរមាគ្រប់តួអង្គដែលមានការពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការសិក្សា និងវាយតម្លៃពីផលប៉ះពាល់ឲ្យបានម៉ត់ចត់ជាពិសេសត្រូវអនុញ្ញាតឲ្យមានការពិគ្រោះយោបល់ពីប្រជាពលរដ្ឋ និងសង្គមស៊ីវិលជាដើម ។

### ២.៤.ការប៉ះពាល់ដល់វប្បធម៌ និងជំនឿ

កង្វល់អំពីការទន្ទ្រាននៃក្រុមហ៊ុនសម្បទានមកលើដីប្រពៃណី ឬដីដែលជាកន្លែងគោរពសក្ការៈត្រូវបានលើកឡើងពាក់ព័ន្ធនឹងសម្បទានចំនួន៩ក្នុង៦ខេត្តដែលប៉ះពាល់ទាំងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិច ។ 97 ឧទាហរណ៍៖ ដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន អ៊ូជីសាន បានប៉ះពាល់ដល់ដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងក្នុងស្រុកអូរាំង ខេត្តមណ្ឌលគីរី

[97] គេហទំព័រក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ http://www.elc.maff.gov.kh/index.php/objective

ចាប់តាំងពីឆ្នាំ ២០១៤ មក ។ ក្រុមហ៊ុននេះបានបំពានលើព្រៃអ្នកតា និងជីកប់សពបុព្វបុរសរបស់សហគមន៍ក្នុងដែលពួកគេមានជំនឿថាអារក្សអ្នកតាគ្រប់គ្រងលើជីវិតរបស់ពួកគេនៅផ្ទះសម្បែង នៅក្នុងព្រៃ និងនៅតាមដីស្រែចំការរបស់ពួកគេ ។ សកម្មភាពការងាររបស់ក្រុមហ៊ុនបានធ្វើអោយប៉ះពាល់ដល់ដីបម្រុងវាលស្មៅសម្រាប់ចិញ្ចឹមសត្វ និងដីស្រែចំការ ។ ទោះជាសហគមន៍បានសម្តែងកង្វល់របស់ខ្លួនប្រាប់ក្រុមហ៊ុន និងអាជ្ញាធរខេត្តរដ្ឋាភិបាលបានចុះកិច្ចសន្យាសម្បទានជាមួយក្រុមហ៊ុន នៅខែធ្នូ ឆ្នាំ២០០៥ ហើយក្រុមហ៊ុនបានបន្តសកម្មភាពការងាររហូត ។

សម្បទានទេសចរណ៍សេដ្ឋកិច្ចមួយ ត្រូវបានផ្តល់ឲ្យក្រុមហ៊ុន ញូកូស្វ ឌីវីឡុបមិន ( ខេមបូឌា) ក្នុងខែឧសភា ឆ្នាំ២០០៤ ដើម្បីបង្កើតរមណីយដ្ឋាន និងកន្លែងវាយកូនហ្គូលដែលធ្វើអោយប៉ះពាល់ដីប្រពៃណីរបស់ជនជាតិដើមភាគតិចសួយ និងខាងជំនឿរបស់ជនជាតិសួយ ។ ក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋានបានព្យាយាមជាច្រើនលើកច្រើនសារដើម្បីធ្វើការរុះរើរបសំណាក់របស់ជនជាតិដើមភាគតិចសួយ ឈ្មោះយាយតេ ពីរទីតាំងដែលស្ថិតនៅតេទឹកពុះធម្មជាតិ ហើយបុច្ចុប្បន្ននេះសមាជិកសហគមន៍ដែលជាចាស់ទុំនៃជនជាតិដើមភាគតិចសួយ បាននៅឃ្លាំមើលជាប្រចាំនៅទីនោះ ដើម្បីរាំងការរុះរើសំណាក់សមាជិកសហគមន៍ត្រូវបានអនុញ្ញាតឲ្យចូលទៅត្រឹមតែទីដែលរូបសំណាក់តាំងនៅ ប៉ុន្តែសន្តិសុខប្រដាប់អាវុធរបស់ក្រុមហ៊ុនមិនអោយពួកគេចូលកន្លែងដ៏ទៃទៀត នៅតំបន់សម្បទាន ដែលក៏ជាទីកន្លែងសារៈសំខាន់ខាងផ្នែកជំនឿ និងផ្នែកជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចសួយ ។

រៀងរាល់ឆ្នាំនៅស្រុកក្រគរ ខេត្តពោធិ៍សាត់ សហគមន៍រៀបចំពិធីបុណ្យប្រពៃណី ដើម្បីថ្លែងអំណរគុណដល់អារុកអារក្សអ្នកតា និងព្រៃឈើ ដែលបានការពារ និងជួយដល់ពួកគេក្នុងឆ្នាំកន្លងមក និងដើម្បីទទួលបានពរជ័យសម្រាប់ឆ្នាំបន្ទាប់ ។ នៅដើមឆ្នាំ២០០៥ នៅពេលដែលក្រុមហ៊ុន ភាពីម៉ីច កំពុងធ្វើសកម្មភាពក្នុងឃុំនេះអាជ្ញាធរមូលដ្ឋានបានតម្រូវឲ្យអ្នកស្រុកសុំការអនុញ្ញាត ដើម្បីរៀបចំពិធីបុណ្យប្រពៃណីនេះ ។ ព្រះគ្រូអនុគុណាស្រុកក្រគរ និងអ្នកស្រុក និងព្រះសង្ឃបានប្រារព្ធពិធីបុណ្យនេះឡើងដោយមានការឃ្លាំមើលពីនគរបាលនិងអាជ្ញាធរមូលដ្ឋាន។ នគរបាលបានកត់ឈ្មោះព្រះសង្ឃដែលចូលរួមក្នុងពិធីនេះ។

## ៣. ដំណោះស្រាយលើបញ្ហាដីសម្បទានសេដ្ឋកិច្ច

### ៣.១. ការត្រួតពិនិត្យពីសំណាក់រដ្ឋាភិបាលលើក្រុមហ៊ុនទទួលបានដីសម្បទានសេដ្ឋកិច្ច

#### ៣.១.១. កំណត់ពីចំនុចបញ្ហានៃដីសម្បទាន

- ពិនិត្យការកំណត់ពីអាជ្ញាយុកាលរបស់ក្រុមហ៊ុនដែលការទទួលបានដីសម្បទាននោះ

- ធ្វើការវាយតម្លៃក្រុមហ៊ុន
- លក្ខខណ្ឌដែលបង្កអោយមានបញ្ហា ឬចំនុចវិវាទរបស់ក្រុមហ៊ុន
- ពិនិត្យមើលពាក្យបណ្តឹងចំពោះក្រុមហ៊ុនដែលទទួលបាន

**៣.១.២. តស្តុតាង**

- ពិនិត្យគ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងក្នុងស្រុក និងក្រៅស្រុកដែលទាក់ទងនឹងក្រុមហ៊ុន
- ប្រមូលរាល់ព័ត៌មានដែលពាក់ព័ន្ធ
- ការចុះអង្កេតដោយផ្ទាល់ ឬតាមរយៈមន្ត្រីពាក់ព័ន្ធ

**៣.១.៣. លក្ខៈវិនិច្ឆ័យ**

- ថាក្រុមហ៊ុនត្រូវគោរពតាមគោលការណ៍នៃកិច្ចព្រមព្រៀងដែរ ឬអត់
- គោរពតាមច្បាប់ ក៏ដូចជានីតិវិធីដែរបានកំណត់
- អ្នកទទួលបានផលវិជ្ជមាន និងអវិជ្ជមាន (ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល......។ល។.)

**៣.១.៤. លទ្ធផល**

- លទ្ធផលស្របច្បាប់ និងកិច្ចព្រមព្រៀង
- លទ្ធផលនៃគម្រោងដែលទទួលបានពីក្រុមហ៊ុន ចំពោះប្រជាជន សហគមន៍ រដ្ឋាភិបាល
- ការប៉ាន់ប្រមាណទុកចំពោះលទ្ធផល និងការអនុវត្តន៍របស់ក្រុមហ៊ុន

**៣.១.៥. កិច្ចពិភាក្សា** ៖ រដ្ឋាភិបាល មន្ត្រីពាក់ព័ន្ធ និង ក្រុមហ៊ុន

- ប្រៀបធៀបពីគម្រោងរបស់ក្រុមហ៊ុន និង លទ្ធផលដែលទទួលបានពីដីសម្បទានសេដ្ឋកិច្ច
- រាល់បញ្ហាប្រឈមទាំងអស់ (ទំនាស់ ក្រុមហ៊ុននឹងប្រជាជន, ក្រុមហ៊ុននឹងក្រុមហ៊ុន....។ល។)
- ស្វែងរកដំណោះស្រាយ

**៣.១.៦. ការសម្រេចរបស់រាជរដ្ឋាភិបាល**

ការសម្រេចរបស់រដ្ឋាភិបាលត្រូវផ្អែកលើកចំនុចដូចខាងក្រោម៖

- កិច្ចព្រមព្រៀង ច្បាប់ និងលទ្ធផលជាក់ស្តែង
- ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ

### ៣.២.ក្រសួងបរិស្ថានដកហូតដីសម្បទានពីក្រុមហ៊ុន

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចេញអនុក្រឹត្យមួយ សម្រេចលុបចោលនូវគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៣ ដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិស្ថិតនៅក្នុងភូមិ

សាស្ត្រ នៃខេត្តចំនួនបីរួមមានខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង ។ ការសម្រេចលុបចោលនូវគម្រោងវិនិយោគដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនចំនួន៣នោះ បានធ្វើឡើងតាមរយៈអនុក្រឹត្យស្តីពី "និរាករណ៍អនុក្រឹត្យ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យការធ្វើអនុប្រយោគផ្ទៃដី ក្នុងតំបន់ការពារធម្មជាតិក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង" ចុះហត្ថលេខាដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាកាល ពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៨កន្លងមកថ្មីៗនេះ ។

តាមរយៈអនុក្រឹត្យនោះត្រង់មាត្រា ១ បានបញ្ជាក់ឲ្យដឹងថា ទី១- ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា ដែលពាក់ព័ន្ធនិងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន វិមានសិលា អិលធីឌី (VIMEAN SEILA LTD) លើផ្ទៃដីទំហំ៩៨៧ (ប្រាំបួនរយប៉ែតសិបប្រាំពីរ)ហិចតា លើកោះថ្មីនៃឧទ្យានជាតិព្រះសីហនុ "រាម" ភូមិសាស្ត្រខេត្តព្រះសីហនុ ។ ទី២- ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា ដែលពាក់ព័ន្ធនិងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ ក្រុមហ៊ុនសួន វឌ្ឍនៈ ខូ អិលធីឌី(SUON VATANAK CO.,LTD) លើផ្ទៃដីទំហំ ៥៨៥ (ប្រាំរយប៉ែតសិបប្រាំ) ហិចតា ក្នុងតំបន់ទ្រនាប់សត្វឆ្លងកាត់រវាងតំបន់ឧទ្យានជាតិព្រះសុរាម្រិតកុសមៈ "គិរីរម្យ" និងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ និងទី៣- ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យ ដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន ច័ន្ទរតន៍ គ្រុប លើផ្ទៃដី ទំហំ ៦៣ (ហុកសិបបី) ហិចតាក្នុងតំបន់ប្រើប្រាស់ដងពែងក្នុងភូមិសាស្ត្រ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ។ នៅមាត្រា ២ នៃអនុក្រឹត្យដដែលនេះក៏បានបញ្ជាក់ឲ្យដឹងបន្ថែមទៀតថា ផ្ទៃដីដែលគ្របដណ្តបដោយបណ្តាអនុក្រិត្យ ដែលត្រូវបាននិរាករណ៍ដូចមានចែងនៅក្នុងមាត្រា១ ត្រូវដាក់បញ្ចូលជាដីឧទ្យានជាតិព្រះសីហនុ "រាម" ឧទ្យានជាតិព្រះសុរាម្រិត កុសុមៈ "គិរីរម្យ" និងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ដែលស្ថិតនៅក្រោមការគ្រប់ គ្រងរបស់ក្រសួង បរិស្ថាន ហើយបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះនឹងត្រូវចាត់ទុកជានិរាករណ៍។

សូមបញ្ជាក់ថា កន្លងមករាជរដ្ឋាភិបាលកម្ពុជាបានសម្រេចលុបអាជ្ញាប័ណ្ណពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន៨ ហើយមូលហេតុធំបំផុត ដែលរាជរដ្ឋាភិបាលលុបចោលនូវអាជ្ញាប័ណ្ណវិនិយោគ គឺដោយសារក្រុមហ៊ុននោះបានទទួលសម្បទានយូរហើយ តែមិនធ្វើការអភិវឌ្ឍន៍នៅលើដីនោះ ហើយដីដែលដកហូតមកវិញនេះ ត្រូវដាក់ទៅជាដីសម្រាប់អភិរក្សស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានជាមួយគ្នានោះ រាជរដ្ឋាភិបាលក៏បានទម្លាក់រយៈពេលវិនិយោគលើក្រុមហ៊ុនមួយចំនួនមកត្រឹម៥០ ឆ្នាំ ផងដែរ ៕

### ៣.៣. ការចូលរួមពីសំណាក់សង្គមស៊ីវិល

ក្នុងពេលបច្ចុប្បន្ននេះ មានសង្គមស៊ីវិលជាច្រើនចូលពាក់ព័ន្ធ ក្នុងបញ្ហាជាច្រើនក្នុងប្រទេសកម្ពុជា ជាក់ស្តែងក្នុងបញ្ហា ដីសម្បទានសេដ្ឋកិច្ច ការចូលពាក់ព័ន្ធរបស់ពួកគេ មានតាមរូបភាពជាក់ស្តែងនិងមាន ដោយប្រយោល។ ចំពោះរូបភាពជាក់ស្តែង គឺពួកគេចុះទៅដល់កន្លែងដែលមានបញ្ហាតែម្តង ឧទាហរណ៍ ការចុះទៅយកពត៌មានរបស់ភ្នាក់ងារវិទ្យុអាស៊ីអាគ្នេយ៍ ហៅកាត់ RFI ចុះទៅយកពត៌មានពីការតវ៉ាក្នុងការ ទាមទារឲ្យរដ្ឋសភា និងរដ្ឋាភិបាលដោះស្រាយរឿងដីធ្លីឲ្យអ្នកភូមិឡពាងនៅទីលានប្រជាធិបតេយ្យ នៅ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៤ និងការទៅយកពត៌មាន របស់ VOA សំលេងសហរដ្ឋអាមេរិច ពីអ្នកភូមិ បឹងកក ចាប់ពីខែ វិច្ឆិកា ឆ្នាំ ២០១២ រហូតដល់បច្ចុប្បន្ន ។ តាមប្រយោបល់ គឺសង្គមស៊ីវិលតែងតែចេញ ផ្សាយជាការសែត ឬទស្សនាវដ្តីជាតិ អន្តរជាតិ និងតាមប្រព័ន្ធវេបសាយរបស់ពួកគេរៀងៗខ្លួន ដូចជា Facebook YouTube និង គេហទំព័រផ្ទាល់របស់ពួកគេជាដើម ។

### ៣.៤.ដំណោះស្រាយរបស់សង្គមស៊ីវិលក្នុងបញ្ហាដីសម្បទានសេដ្ឋកិច្ច

សង្គមស៊ីវិលដោះស្រាយបញ្ហាតាមរយៈការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ិនធ័រណេត ដូចជាតាម វេបសាយ ឬ គេហទំព័ររបស់អង្គការសង្គមស៊ីវិលនីមួយៗ និងការចូលរួមផ្សព្វផ្សាយ និងយកពត៌មានពីការ ដង្ហែជាក្បួនទៅតវ៉ា របស់ប្រជាជនដែលមានបញ្ហាពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច និងការចុះទៅ ស្រាវជ្រាវរកមូលហេតុនៃបញ្ហាដែលពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចដល់ទីកន្លែងតែម្តងជាដើម ។ ជាក់ ស្តែងនៅថ្ងៃ១២ ខែសីហា ឆ្នាំ២០១៤ អង្គការលីកាដូ បានចុះទៅយកពត៌មានដល់ទីកន្លែងកើតហេតុ នៅ ភូមិឡពាង នៅខេត្តកំពង់ឆ្នាំង ដែលអ្នកភូមិឡពាង ចំនួន៥០នាក់ មានបំណងដង្ហែក្បួនដោយអហិង្សាពី ចម្ងាយ ៦០ គីឡូម៉ែត មកកាន់រាជធានីភ្នំពេញដើម្បីអំពាវនាវរកដំណោះស្រាយ សម្រាប់ទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃ របស់ពួកគេ ។ ប៉ុន្តែពួកគេត្រូវបានកំលាំងប៉ូលីសខេត្តកំពង់ឆ្នាំងបំបែកយ៉ាងហិង្សាទៅលើក្រុមរបស់ពួកគេ ។ ហើយមាន អ្នកភូមិឡពាង ចំនួន ៣នាក់ ត្រូវបានចាប់ខ្លួនទៅសាលាដំបូងខេត្តកំពង់ឆ្នាំងថែមទៀតផង ។ លើសពីនេះទៀតមាន អ្នករាយការណ៍ពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក ស៊ូរី យ៉ា ស៊ូប៊ែឌី បានចុះមកស្រាវជ្រាវពីបញ្ហាដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា ហើយបានបញ្ចប់បេសកកម្ម លើកទី៧របស់លោកនៅកម្ពុជាហើយ ស្តីពីផលប៉ះពាល់ដល់សិទ្ធិមនុស្សពីគម្រោងសម្បទានដីសេដ្ឋកិច្ច (១១/០៥/២០១២ ដោយ RFI លាង ដីលុច)។ ក្រុមអ្នកតាមដានស្ថានការណ៍នយោបាយនៅកម្ពុជា បាន លើកឡើងថា ការធ្វើរបាយការណ៍អំពីការបណ្តេញចេញ និងការរំលោភសិទ្ធិមនុស្សរបស់លោក សុរិយ៉ា ស៊ូប៊ែឌី នៅក្នុងអំឡុងពេលធ្វើទស្សនកិច្ចរបស់លោកនេះ វាមានសារសំខាន់ណាស់សម្រាប់ឲ្យរដ្ឋាភិបាល

កម្ពុជាធ្វើការពិចារណាលើបញ្ហាទាំងនោះ ពីព្រោះថាបច្ចុប្បន្ននេះក្នុងនាមរដ្ឋាភិបាលជាប្រធានសមាគមអាស៊ាន (ASEAN) ផង និងនៅពេលរដូវកាលប្រកួតប្រជែងការបោះឆ្នោតជិតមកដល់ផង។

## សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាទៅលើខ្លឹមសារអត្ថបទខាងលើ យើងសង្កេតឃើញថាការរៀបចំផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅកម្ពុជា មិនទាន់មានរបៀបរបបមួយដែលអាចទទួលយកបាននៅឡើយព្រោះថារាល់វិវាទអំពីបញ្ហានេះ បានកើតឡើងជាបន្តបន្ទាប់ ហើយថែមទាំងគ្មានដំណោះស្រាយសមរម្យសម្រាប់គូវិវាទព្រមទទួលយក ជាពិសេសប្រជាពលរដ្ឋ ដោយហេតុមិនមានស្ថាប័នណាមួយក្នុងការដោះស្រាយឲ្យច្បាស់លាស់ក្នុងរឿងនេះ ។ ម្យ៉ាងទៀតការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះទៀតសោតរដ្ឋាភិបាលដូចជាមិនបានសិក្សាឲ្យបានច្បាស់លាស់ អំពីទីតាំងដែលបានផ្តល់ឲ្យនោះថាតើមានប្រជាពលរដ្ឋរស់នៅស្របច្បាប់បានតាំងទីលំនៅ ឬនៅក្នុងទីកន្លែងនោះ ? កត្តាដែលមិនបានសិក្សាអំពីទីតាំងភូមិសាស្ត្រក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះហើយទើបបណ្តាលឲ្យមានវិវាទកើតឡើងជាបន្តបន្ទាប់ ដូចមានហេតុការណ៍ដែលបានលើកមកបង្ហាញខាងលើនេះ ។ ជាបញ្ហាចោទជាចម្បងផងដែរ ទៅលើការដោះស្រាយក្នុងរឿងទាំងនេះ គឺមិនបានស្របតាមនីតិវិធីដែលច្បាប់បានចែងនោះឡើយ បែរជាយកបុគ្គលមានអំណាចជាធំទៅវិញ ដែលជាហេតុបណ្តាលឲ្យមិនមានភាពរលូន ក្នុងការអនុវត្តន៍ទៅតាមរចនាសម្ព័ន្ធនៃសិទ្ធដែលបានផ្តល់ឲ្យដោយច្បាប់ក្នុងការដោះស្រាយ ។ ជាការពិតទៅវិវាទរឿងការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ វាមិនមែនជាបញ្ហាធ្ងន់ធ្ងរដែលពិបាកដោះស្រាយទេ ឲ្យតែមានការរៀបចំច្បាប់មួយដែលមានភាពត្រឹមត្រូវដែលមានការត្រួតពិនិត្យតាមរចនាសម្ព័ន្ធនៃអង្គនីតិបញ្ញត្តិហើយនោះ សិទ្ធិ និងអំណាចដែលផ្តល់ឲ្យស្ថាប័នណាស្ថាប័ននោះគ្រាន់តែអនុវត្តន៍ទៅតាមអ្វីដែលច្បាប់បានចែង ដោយគ្មានការរំលោភអំណាចពីបុគ្គលណាម្នាក់នោះជាការស្រេច ។ រឿងវិវាទកើតឡើង គឺដោយសារបុគ្គលអ្នកអនុវត្តន៍មិនមានការយកចិត្តទុកដាក់ និងគ្មានភាពទទួលខុសត្រូវនូវទង្វើររបស់ខ្លួនប៉ុណ្ណោះ ។

ក្រុមខ្ញុំបាទក៏ចង់បញ្ជាក់ផងដែរថា ការផ្តល់ដីសម្បទានសេដ្ឋកិច្ចជារឿងមួយដែលប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាយើងត្រូវតែអនុវត្តន៍ដោយអាចអាក់ខានបាន ប៉ុន្តែការអនុវត្តន៍ត្រូវតែឲ្យមានប្រសិទ្ធភាព បើមិនដូច្នោះទេ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនឹងនាំឲ្យវិវាទចលាចលពេញប្រទេស ធ្វើប្រទេសអន់ថយទៅវិញគួរចងចាំថា ទឹកដីសម្បត្តិធនធានធម្មជាតិទាំងមូលនេះ មិនមែនជារបស់ជនណាឬក្រុមណា

មួយឡើយ គឺជាទ្រព្យសម្បត្តិរួមរបស់ប្រជាពលរដ្ឋខ្មែរទាំងអស់គ្នា ដូចនេះខ្មែរគ្រប់រូបត្រូវចូលរួមថែរក្សា និងការពារដើម្បីជាប្រយោជន៍សម្រាប់កូនខ្មែរជាន់ក្រោយៗ ទៀត ។

## ឯកសារយោង

### ក. ច្បាប់ និងអនុក្រឹត

- ច្បាប់ភូមិបាល ឆ្នាំ២០០១ ។
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ។
- អនុក្រឹត្យលេខ១៤៦ស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥ ។

### ខ. សៀវភៅ និងអត្ថបទផ្សេងៗ

- បណ្ឌិត អ៊ុន សកក្កដា, នីតិនគររូបនីយវិទ្យា៖ ។
- របាយការណ៍របស់តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា, សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាទស្សនៈវិស័យខាងសិទ្ធិមនុស្ស៖ខែមិថុនា ឆ្នាំ២០០៧ ទំព័រទី២៦ ។

### គ.គេហទំព័រ

- http://www.elc.maff.gov.kh/index.php/objective

## គន្លឹទី៧
## ប្រវត្តិនៃការរៀបចំទីក្រុងនៅក្នុងបណ្តាប្រទេសអាស៊ាន
## សេចក្តីផ្តើម

កំណើនប្រជាជនជាប្រធានបទមួយ ដែលចោទជាបញ្ហាដល់រដ្ឋាភិបាលគ្រប់បណ្តាប្រទេសទាំងអស់ទាំងប្រទេសអភិវឌ្ឍន៍ ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសកំណើនប្រជាជននៅតាមទីក្រុង ឬទីប្រជុំជនសំខាន់ៗ ព្រោះកន្លែងទាំងនោះជាកម្មវត្ថុចម្បងនៃចលនាចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ ការសិក្សា ទេសចរណ៍ ពាណិជ្ជកម្មជាដើម ។ ហេតុនេះដើម្បីជាកិច្ចឆ្លើយតបទៅនឹងបញ្ហាដែលចោទឡើងខាងលើ ដំណោះស្រាយដ៏ប្រសើរដែលបណ្តាប្រទេសជាច្រើនបានអនុវត្ត គឺការធ្វើការរៀបចំទីក្រុង ឬទីប្រជុំជនធ្វើយ៉ាងណាបញ្ចៀសបញ្ហាទាំងឡាយនៅទីក្រុង ឬទីប្រជុំជន ដូចជាសណ្តាប់ធ្នាប់ សន្តិសុខសុវត្ថិភាព បរិស្ថាន ក៏ដូចជាបញ្ហាផ្សេងៗទៀត ។ ស្ថិតនៅក្នុងបរិបទនៃការរៀប ចំទីក្រុងនេះមានលក្ខណៈពុំដូចគ្នាទេពីប្រទេសមួយទៅប្រទេសមួយទៀត មានលក្ខណៈផ្សេងៗគ្នា ដោយផ្អែកទៅតាមកត្តាភូមិសាស្ត្រ-ប្រជាសាស្ត្រជាដើម ។ ជាធម្មតាដើម្បីរៀបចំទីក្រុងមួយឲ្យមានសោភ័ណភាព និងមិនប៉ះពាល់ដល់សម្បត្តិធម្មជាតិ និងបេតិកភណ្ឌជាតិ ចាំបាច់ត្រូវតែមានក្បួនខ្នាត ឬក៏គម្រោងព្រាងនៃការរៀបចំទីក្រុងនោះជាមុនសិន ពោលគឺដំណើរការនៃការរៀបចំទីក្រុង ។ ជាមួយគ្នានេះផងដែរ ការរៀបចំទីក្រុងមួយ តែងតែជួបប្រទះ នូវផលប៉ះពាល់មួយចំនួនដែលពុំអាចជៀសផុតរួចឡើយ ។

ចំពោះបញ្ហាចោទខាងលើ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងកិច្ចការស្រាវជ្រាវមួយច្បាប់នេះ ។ ជាមួយគ្នានេះផងដែរ ក្រុមយើងខ្ញុំនឹងលើកយកតែការរៀបចំទីក្រុងរបស់ប្រទេសមួយចំនួនក្នុងបណ្តាប្រទេសអាស៊ានតែប៉ុណ្ណោះ ដែលមានដូចជាប្រទេសសិង្ហបុរី(ជំពូកទី១) និងម៉ាឡេស៊ី(ជំពូកទី២) ។

### ជំពូកទី១ ប្រវត្តិនៃការរៀបចំទីក្រុងនៃប្រទេសសិង្ហបុរី

ដើម្បីងាយស្រួលយល់អំពីប្រវត្តិនៃការរៀបចំទីក្រុងនៅប្រទេសសិង្ហបុរី យើងបានធ្វើការបែងចែកដំណាក់កាលជា២ធំៗ នៃការរៀបចំទីក្រុងគឺៈ សិង្ហបុរីក្រោមអាណានិគមអង់គ្លេស និង ក្រោយអាណា

និគមអង់គ្លេស (២.ដំណើរការនៃការរៀបចំទីក្រុង)។ ទន្ទឹមនឹងនោះផងដែរ ដើមចងដែលនាំឲ្យរដ្ឋាភិបាលសិង្ហបុរី យកចិត្តទុកដាក់ជាខ្លាំងទៅលើការរៀបចំទីក្រុងនេះ ក៏ដោយសារមានកត្តាជំរុញសំខាន់ៗ មួយចំនួនផងដែរ (៣.កត្តាដែលជំរុញឲ្យមានការរៀបចំទីក្រុង)។ ប៉ុន្តែមុននឹងចូលដល់ការពន្យល់រៀបរាប់ទៅលើផ្នែកទាំងពីរខាងលើ យើងនឹងធ្វើការរៀបរាប់ពីទិដ្ឋភាពទូទៅជាមុនសិន (១.ទិដ្ឋភាពទូទៅនៃប្រទេសសិង្ហបុរី) ។

## ១. ទិដ្ឋភាពទូទៅនៃប្រទេសសិង្ហបុរី

សិង្ហបុរីត្រូវបានរកឃើញនៅឆ្នាំ១៨១៩ ហើយដែលស្ថិតក្រោមអាណានិគមរបស់ចក្រភពអង់គ្លេសរហូតដល់ឆ្នាំ១៩៦៣ ។ ប្រទេសនេះក៏ធ្លាប់ជាទឹកដីមួយនៃសម្ព័ន្ធភាពម៉ាឡេស៊ី ចាប់ពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៦៥ បានសេចក្តីថាសិង្ហបុរីក្លាយជារដ្ឋឯករាជ្យនៅឆ្នាំ១៩៦៥ ។ ប្រទេសដែនដីកោះមួយនេះ មានផ្ទៃដី៥៨៧គ.ម២នៅឆ្នាំ១៩៦៧ ហើយទំហំដីមានការកើនឡើងខ្លះដែរ-ដោយការពានដីសមុទ្រ-ដូចជា នៅឆ្នាំ១៩៩១ មាន៦២៦គ.ម$^{២}$ ។

បើនិយាយពីប្រជាជានមានការកើនឡើងជាបង្គួរ គឺនៅឆ្នាំ១៨២០មានចំនួនត្រឹម១០០០០០នាក់ តែមកដល់ឆ្នាំ១៩០០ កើនដល់២២០០០០នាក់ ឆ្នាំ១៩៥០ មានចំនួន១០២០០០០នាក់ មកដល់ឆ្នាំ១៩៧០ មានចំនួន២០៧០០០០នាក់ ហើយនៅឆ្នាំ២០០០កើនដល់៤០០០០០០នាក់ ។ ដោយសារការកើនឡើងចំនួនប្រជាជនយ៉ាងច្រើននៅលើដីកោះដ៏តូចមួយនេះហើយ ទើបនាំឲ្យសិង្ហបុរីមានដង់ស៊ីតេខ្ពស់ដោយនៅឆ្នាំ១៩៧០ មានដង់ស៊ីតេ៣៥០០នាក់/គ.ម២ ហើយកើនដល់៦៣០០នាក់/គ.ម២ ក្នុងឆ្នាំ២០០០ ។ ចំណែកវិស័យសេដ្ឋកិច្ចវិញ សិង្ហបុរីមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចយឺត បើគិតចាប់ពីការកកើតដំបូង។ ប៉ុន្តែមកដល់ពាក់កណ្តាលសតវត្សទី២០ សេដ្ឋកិច្ចសិង្ហបុរីក៏ចាប់ផ្តើមមានការកើនឡើងយ៉ាងឆាប់រហ័សវិញ ។ ប្រទេសសិង្ហបុរីជាប្រទេសដែលមានធនធានធម្មជាតិក្រខ្សត់ ដូច្នេះសេដ្ឋកិច្ចសិង្ហបុរីមិនពឹងផ្អែកទៅលើវិស័យកសិកម្មឡើយ ដោយគេពឹងផ្អែកតែទៅលើវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ជាចំបងតែប៉ុណ្ណោះ។

## ២. ដំណើរការនៃការរៀបចំទីក្រុង

### ២.១. ក្រោមការគ្រប់គ្រងរបស់ចក្រភពអង់គ្លេស

#### ២.១.១. ផែនការរៀបចំទីក្រុងរបស់លោករ៉ាសហ្វល

ផែនការរៀបចំទីក្រុងនៅសិង្ហបុរី បានចាប់ផ្តើមនៅក្នុងឆ្នាំ១៨២២ នៅពេលលោក Stamford Raffles បានអនុវត្តនូវគម្រោងប្រើប្រាស់ដីធ្លីមួយ ដែលត្រូវបានគេឲ្យឈ្មោះថា "ផែនការរៀបរៀបចំទីក្រុង

រ៉ាស់ហ្វូល (Raffle Town Plan)" ដើម្បីជានាការរីកលូតលាស់ជារូបវន្តនៃទីក្រុងនេះ គោរពតាមគំរូ ដ៏មានសណ្តាប់មួយ ។ ហើយលក្ខណៈពិសេសនៃផែនការនេះ គឺការរៀបចំតំបន់នៃលំនៅដ្ឋាននៃសហគមន៍នីមួយៗ ឲ្យដាច់ចេញពីគ្នាដោយក្នុងនោះរួមមានសហគមន៍ប្រជាជនចិន អឺរ៉ុប ម៉ាឡេស៊ី ឥណ្ឌា និងសហគមន៍អារ៉ាប់ ។ ក្រៅពីតំបន់លំនៅដ្ឋាន គម្រោងនេះក៏ធ្វើការរៀបចំឲ្យមានជាតំបន់ ពាណិជ្ជកម្ម តំបន់ស្ថាប័នរដ្ឋ ព្រមទាំងធ្វើការរៀបចំបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ផ្លូវសាធារណៈ បណ្តាញលូ ឬប្រព័ន្ធទឹកស្អាត ។[98] ទោះជាយ៉ាងណា ផែនការនៃការរៀបចំទីក្រុង Raffles ត្រូវបានយកទៅអនុវត្តសំរាប់ការរៀបចំទីក្រុងមិនដល់មួយទស្សវត្សផង ។ ដូច្នេះបានសេចក្តីថា ផែនការ មួយនេះមិនបានសម្រេចចេញជាផ្លែការអ្វីជាដុំកុំភួននោះទេ ។

### ២.១.២.ច្បាប់អភិវឌ្ឍន៍សិង្ហបុរី

មកដល់ដើមទស្សវត្សឆ្នាំ១៩០០ ទីក្រុងសិង្ហបុរី ពោរពេញទៅដោយមនុស្សរស់នៅណែនណាំតាន់តាប់សំណង់អនាធិបតេយ្យរីកដូចផ្សិតនៅពាសពេញទីក្រុង និងការកកស្ទះចរាចរណ៍ ដោយសារការ កើនឡើងនូវចំនួនទោចក្រយានយន្ត ។ មូលហេតុដែលនាំឲ្យកើតមានបញ្ហាទាំងអស់នេះ គឺកើតឡើងដោយសារតែ ភាពមិនមាននូវផែនការរៀបចំទីក្រុងថ្មី ដែលអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែង និងកម្សោយនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលអង់គ្លេស ។ ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ នៅឆ្នាំ១៩២៧ រដ្ឋាភិបាលបានបង្កើតច្បាប់អភិវឌ្ឍន៍ ប្រទេសសិង្ហបុរីមួយ (The Singapore Improvement Ordinance) និងអង្គភាពមួយដែលហៅថា The Singapore Improvement Trust (SIT) ដែលទទួលខុសត្រូវអនុវត្តច្បាប់ខាងលើ ។ ប៉ុន្តែមកដល់ឆ្នាំ ១៩៥៩ SIT ត្រូវបានគេរំលាយចោល ដោយជំនួសមកវិញដោយនាយកដ្ឋានផែនការ ។ មូលហេតុនៃការរំលាយ SIT ដោយសារវាទទួលបានសមិទ្ធិផលតិចតួចពេកពោលគឺអង្គភាពមួយនេះ មិនអាចដោះស្រាយបញ្ហាសំខាន់ៗបាន ។ ជាក់ស្តែងវាបង្កើតលំនៅដ្ឋានបានត្រឹមតែចំនួន២៣០០០អាគារប៉ុណ្ណោះ ដែលជាចំនួនដ៏តិចតួចមិនឆ្លើយតបនឹងកំណើនប្រជាជនដ៏សន្ទឹកសន្ទាប់ ហើយការពង្រីកផ្លូវក៏មិនអាចបញ្ចៀសការកកស្ទះចរាចរណ៍បាន ។ ស្របពេលជាមួយគ្នានេះដែរច្បាប់ខាងលើក៏ត្រូវបាននិរាករណ៍ចោល ដោយជំនួសមកវិញនូវច្បាប់ផែនការមួយ (The Planning Ordinance) ដែលបានអនុម័ត ដោយរដ្ឋាភិបាលអង់គ្លេស ។ ក្នុងចន្លោះឆ្នាំ១៩៥១ដល់១៩៥៨នេះផងដែរ រដ្ឋាភិបាលបានធ្វើការរៀបចំ បង្កើត និង អនុម័តនូវប្លង់ប្រើប្រាស់ដីមួយ ដែលហៅថា"ប្លង់មេ" ដែលយើងនឹងធ្វើការសិក្សាពីវានៅផ្នែកបន្ទាប់ ។

[98] *https://* www.eresources.nlb.gov.sg/infopedia/articles/SIP_1564_2009-09-08.html

### ២.២. ក្រោយសម័យអាណានិគមអង់គ្លេស

នៅឆ្នាំ១៩៥៩ សិង្ហបុរីបានទទួលឯករាជ្យពីចក្រភពអង់គ្លេស ហើយធ្វើការដឹកនាំប្រទេសដោយខ្លួនឯង ។ បញ្ហារៀបចំទីក្រុងនៅតែជាកង្វល់ដ៏ធំមួយរបស់ប្រទេសនេះ។ ការអភិវឌ្ឍន៍ទីក្រុងដែលអនុវត្តតាមប្លង់មេឆ្នាំ១៩៥៨ ដោយមាននាយកដ្ឋានផែនការជាអ្នកទទួលបន្ទុក និងមានអំណាចក្នុងការពិនិត្យឡើងវិញ ។ ដោយប្លង់មេនេះ ហាក់ដូចជាមិនមានប្រសិទ្ធិភាពគ្រប់គ្រាន់ដើម្បីដោះស្រាយបានទៅនឹងការរីកចម្រើនផ្នែកសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសខ្លួន ទើបរដ្ឋាភិបាលសិង្ហបុរី បានស្វែងរកជំនួយ ពីអង្គការសហប្រជាជាតិ (UN) ដើម្បីបង្កើតគោលការណ៍គ្រឹះសំរាប់ការអភិវឌ្ឍន៍ទីក្រុងក្នុងរយៈពេលវែង ។ អ្នកជំនាញប៉ុន្មានរូបរបស់ UN បានមកធ្វើទស្សនកិច្ចនៅប្រទេសសិង្ហបុរី នៅក្នុងឆ្នាំ១៩៦២-១៩៦៣ ។ ក្រោយពីធ្វើការសិក្សាអស់រយៈ៤ឆ្នាំ នៅឆ្នាំ១៩៦៧ អ្នកជំនាញទាំងនោះបានផ្តល់អនុសាសន៍ឲ្យសិង្ហបុរី លើគម្រោងរៀបចំទីក្រុងមួយ ។ ចំពោះរដ្ឋាភិបាលខ្លួនឯងផ្ទាល់យល់ឃើញថា បញ្ហាអាទិភាព ដែលចោទសម្រាប់រដ្ឋឯករាជ្យថ្មីមួយនេះ គឺការសាងសង់ផ្ទះឲ្យឆ្លើយតបតាមតម្រូវការ និងការបង្កើតការងារឲ្យបានគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋ ។ ការធ្វើផែនការប្រើប្រាស់ដីធ្លីត្រូវតែធ្វើការដោះស្រាយបញ្ហាទាំងនេះ ។

ដោយមានការជួយជ្រោមជ្រែងពីអ្នកជំនាញរបស់ UN នោះ រដ្ឋាភិបាលប្រទេសសិង្ហបុរីក៏បានរៀបចំរួចរាល់នូវប្លង់មេ នៅឆ្នាំ១៩៧១ ហើយបង្កើតបានចេញជារូបរាងនូវ Concept Plan ដំបូងមួយនៅក្នុងប្រទេសនេះ ។

#### ២.២.១. ប្លង់គំនិត

ប្លង់គំនិត គឺជាផែនការរៀបចំទីក្រុងរយៈពេលវែងមួយ ដែលត្រូវបានបង្កើតឡើងសម្រាប់ណែនាំនូវការអភិវឌ្ឍន៍ផ្នែករូបវន្តរបស់ទីក្រុងក្នុងរយៈពេល៤០ទៅ៥០ឆ្នាំទៅមុខទៀត ។ ប្លង់គំនិតបានធ្វើការចែងយ៉ាងទូលាយអំពីការបែងចែកដីធ្លី និងគោលនយោបាយផ្នែកគមនាគមន៍របស់រដ្ឋាភិបាលតែប៉ុណ្ណោះ ។ ប្លង់នេះមិនមែនជាឯកសារដែលមានចែងនៅក្នុងច្បាប់នោះទេ ក៏ប៉ុន្តែគម្រោងការរបស់វាភាគច្រើនសុទ្ធតែត្រូវបានយកមកអនុវត្ត ។ ប្លង់គំនិតនេះ ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នាយកដ្ឋានផែនការទីក្រុង តែចាប់ពីឆ្នាំ១៩៨៩មក វាជាការទទួលខុសត្រូវរបស់អាជ្ញាធរអភិវឌ្ឍន៍ទីក្រុង ដែលនៅជាធរមានមកដល់បច្ចុប្បន្ន ។ ចាប់តាំងពីការបង្កើតលើកដំបូងក្នុងឆ្នាំ១៩៧១មក ប្លង់នេះត្រូវបានពិនិត្យសើរើនៅឆ្នាំ១៩៩១និង ២០០១។[99]

[99] ប្លង់គំនិត ដែលចេញផ្សាយដោយUrban Redevelopment Authority តាមរយៈ:*https:// www.ura.gov.sg*

❖ **ទស្សនៈវិស័យ**

"ទីក្រុងមួយដ៏ល្អឥតខ្ចោះ" នេះជាវត្ថុបំណងចុងក្រោយរបស់សិង្ហបុរីក្នុងដំណើរការអភិវឌ្ឍទីក្រុងរបស់ខ្លួន។ ទីក្រុងដ៏ល្អឥតខ្ចោះមួយ ដែលការអភិវឌ្ឍន៍មានតុល្យភាពរវាងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គមកិច្ច និង បរិស្ថាន។

❖ **ចក្ខុវិស័យ**

- ទីក្រុងមួយដែលមាន City Center និងបែងចែកជាមជ្ឈមណ្ឌលតាមតំបន់ (Regional Centers) ដោយរាល់តំបន់នីមួយៗ អាចមានមនុស្សរហូតដល់៨សែននាក់ ហើយអនុញ្ញាតឲ្យពួកគេមាន ការងារនៅជិតផ្ទះរបស់ខ្លួន ។
- ទីកន្លែងដែលមានបរិស្ថានល្អ មានកន្លែងកំសាន្ត ទេសភាពបៃតង និង មរតកវប្បធម៌
- ប្រទេសមួយ ដែលប្រជាពលរដ្ឋរបស់ខ្លួនមានលំនៅដ្ឋានគ្រប់គ្រាន់ មានសោភណភាព និងផាសុកភាព ។
- ប្រព័ន្ធមធ្យោបាយធ្វើដំណើរងាយស្រួល

❖ **យុទ្ធសាស្ត្រ**

ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យទាំងនោះ ការកំណត់យុទ្ធសាស្ត្រ គឺជារឿងសំខាន់មួយ ។ នៅក្នុងប្លង់គំនិតចាប់ពីការបង្កើតដំបូង និងការសើរើពិនិត្យចំនួនពីរលើកមកហើយ ប្រទេសសិង្ហបុរីបានសម្រេចចេញនូវយុទ្ធសាស្ត្រដូចខាងក្រោមៈ

- <u>ផ្តល់លំនៅដ្ឋានដ៏ល្អប្រសើរ</u>ៈប្លង់គំនិតនៅឆ្នាំ១៧៧១បានដាក់ចេញនូវយុទ្ធសាស្ត្រពីរ គឺ ទី១ Ring Plan ដែលផែនការនេះមានគម្រោងអភិវឌ្ឍជុំវិញ City Centre និង ទី២ គម្រោងសាង សង់អាគារខ្ពស់ៗ ដែលវាជួយកាត់បន្ថយសំណង់គ្មានរបៀបរៀបរយ ។ ការបញ្ឈរអាគារទៅលើអាកាសនេះ រដ្ឋមានគោលនយោបាយមួយគឺ ជាន់ផ្ទាល់ដីផ្តល់ជូនដល់ប្រជាពលរដ្ឋដោយឥតគិតថ្លៃ ។ ការសើរើប្លង់គំនិតឆ្នាំ១៩៩១ បានបន្ថែមគម្រោងមួយទៀតគឺ ការផ្តល់ជម្រើសទៅលើ លំនៅដ្ឋាន ដូចជាទីតាំង ប្រភេទ និងកម្ពស់។ រាល់លំនៅដ្ឋានទាំងអស់ សុទ្ធតែមានភាពងាយ ស្រួលទទួលបានការកម្សាន្ត កីឡា ការអប់រំ និងមានលក្ខណៈជាសហគមន៍។ មកដល់ប្លង់ គំនិតឆ្នាំ២០០១ នៅរក្សាផែនការនេះដដែល ដោយបានបង្កើតចំនួនលំនៅដ្ឋានពី១លាន ដល់ ១លាន ៨សែន លំនៅដ្ឋានសំរាប់ប្រជាជន ៥លាន ៥សែននាក់។

- <u>ការរក្សាឲ្យសិង្ហបុរីបៃតង</u>(អាងទឹកសាធារណៈ មានឧទ្យាន តំបន់ធម្មជាតិ)ៈប្លង់គំនិតឆ្នាំ១៩៩១ បាន ដាក់ចេញនូវ Green Blue Plan ដែលកំណត់នូវបណ្តាញលំហបៃតង កន្លែងទំនេរ ឧទ្យាន និងផ្លូវ ទឹក ដើម្បីជួយធ្វើឲ្យប្រសើរឡើងនូវអារម្មណ៍នៃការរស់នៅ បែបលំអដោយសួន និងកោះ ។ គំនិត នេះត្រូវបានអភិវឌ្ឍបន្ត ដោយប្លង់គំនិតឆ្នាំ២០០១ តាមរយៈផែនការ Parks and Waterbodies ។ នៅក្នុងនេះ ទីលំហានឹងបង្កើនពី២៥០០ហិចតា ទៅ ៤៥០០ហិចតា ។
- <u>ការទ្រទ្រង់ការលូតលាស់សេដ្ឋកិច្ច</u>ៈប្លង់គំនិតឆ្នាំ១៩៧១ មានគោលដៅបង្កើតតំបន់ពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុខ្លាំងក្លាមួយ ដែលនឹងទាក់ទាញបាននូវវិនិយោគិនបរទេស ។ ការសើរើឆ្នាំ១៩៩១ ប្លង់ គំនិត បានដាក់ផែនការកសាងមជ្ឈមណ្ឌលពាណិជ្ជកម្មនៅតាមតំបន់ Tampines, Jurong និងក សាងមជ្ឈមណ្ឌល CBD ដ៏ខ្លាំងក្លា ។ មូលហេតុនៃគំនិតនេះ គឺដើម្បីបង្កើនសកម្មភាព ពាណិជ្ជកម្ម និងដើម្បីការពារ ការកកស្ទះចរាចរណ៍ ។ ប្លង់គំនិតឆ្នាំ១៩៧១ បានកំណត់តំបន់ឧស្សាហកម្មមួយ កន្លែងនៅ Jurong។ តែប្លង់គំនិតនៅឆ្នាំ ១៩៩១ និង ២០០១ បានបង្កើតឲ្យមានឧទ្យានពាណិជ្ជកម្ម វិទ្យាសាស្ត្រ និងវិទ្យាស្ថានស្រាវជ្រាវ ដើម្បី លើកកម្ពស់ការផ្លាស់ប្តូរគំនិត និងការរកឃើញថ្មីៗ ។
- <u>ផ្តល់ឲ្យការដឹកជញ្ជូននិងការធ្វើដំណើរមានភាពងាយស្រួល</u>ៈ ប្លង់គំនិតបានដាក់គម្រោងស្តីពី បណ្តាញផ្លូវ (Expressways) និង ផ្លូវតភ្ជាប់( Arterial roads) ដោយរួមមាន Pan-Island Expressway , East Coast Parkway និង Bukit Timah Expressway ។ ហើយការសើរើ ក្រោយទៀតនៅតែបន្តអនុវត្តគម្រោងនេះដដែល ដោយគ្រាន់តែពង្រីកទំហំរបស់ផ្លូវប៉ុណ្ណោះ ។ ក្នុងនេះ ផងដែរ គេបានរៀបចំផែនការកាត់បន្ថយការកកស្ទះចរាចរណ៍ ដោយការបន្ថែម មធ្យោបាយដឹកជញ្ជូនសាធារណៈ ឡានក្រុង រថភ្លើង នាវាចម្លងជាមួយនឹងតម្លៃថោក ។ ទន្ទឹមនឹង នេះ ការអភិវឌ្ឍន៍តំបន់ជុំវិញ City Centre ការជម្លៀសប្រជាពលរដ្ឋចេញពី City Centre តាមរយៈ ការរៀបចំលំនៅដ្ឋាននៅជាយៗ ការសង់អាគារខ្ពស់ៗ ក៏ជាកត្តាកាត់បន្ថយការកកស្ទះចរាចរណ៍ ដោយផ្ទាល់ផងដែរ ។
- <u>ការការពារបេតិកភណ្ឌ និងអត្តសញ្ញាណជាតិ</u>ៈ ប្លង់គំនិតមានគម្រោងមួយ ក្នុងគម្រោងផ្សេងៗ ទៀត គឺការថែរក្សាសម្បត្តិវប្បធម៌ ដោយការអភិរក្សតំបន់វប្បធម៌មិនឲ្យមានការបាត់បង់ដោយ ការអនុវត្តគម្រោងផ្សេងៗ ។

❖ ការរៀបចំអភិវឌ្ឍន៍ទីក្រុងរបស់សិង្ហបុរី ក៏មិនអាចសម្រេចបាននូវលទ្ធផលល្អ ដូចការចង់បានដែរ បើសិនណាគ្មានការចូលរួមរបស់ប្រជាពលរដ្ឋខ្លួននោះ ។ ដូច្នេះហើយទើបការពិនិត្យសើរើប្លង់

គំនិតនៅឆ្នាំ២០០១ អាជ្ញាធរបានចាប់ផ្តើមឲ្យមានការរៀបចំកិច្ចពិភាក្សា ដេញដោល និងធ្វើការស្ទាបស្ទង់មតិ មុននឹងដាក់ចេញនូវប្លង់ផ្លូវការមួយ ។ ព្រោះថាការស្តាប់មតិប្រជាពលរដ្ឋ វាធ្វើឲ្យការរៀបចំប្លង់កាន់តែមានភាពសព្វជ្រុងជ្រោយ ឆ្លើយតបទៅនឹងតម្រូវការរបស់គាត់ និងចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋ ។ លើសពីនេះទៀត ការធ្វើបែបនេះវានឹងងាយស្រួលឲ្យគម្រោងការដែលនឹងត្រូវយកទៅអនុវត្តនោះ មានភាពរលូន គ្មានភាពរកាំរកូសពីសំណាក់ប្រជាពលរដ្ឋ។

**២.២.២.ប្លង់មេ**

**-អ្វីទៅជាប្លង់មេ**?

ប្លង់មេ សំដៅដល់ប្លង់ដែលធ្វើការចែងយ៉ាងលំអិតអំពីការប្រើប្រាស់ដីធ្លីទៅតាមតំបន់នីមួយៗ ដោយស្របទៅតាមចក្ខុវិស័យ និងយុទ្ធសាស្ត្រដែលមានក្នុងប្លង់គំនិត ។ បើយោងទៅតាមប្លង់គំនិតតែមួយ គេមិនទាន់អាចធ្វើការរៀបចំទីក្រុងបាននៅឡើយទេ គឺគេត្រូវមានប្លង់មួយទៀត ដើម្បីដឹងថាកន្លែងណាត្រូវធ្វើអ្វី ហើយត្រឹមកំរិតណានោះ ។ ដូច្នេះបានសេចក្តីថា ប្លង់មេ និងប្លង់គំនិត ត្រូវទៅជាមួយគ្នាជានិច្ច ដោយមិនអាចខ្វះមួយណាបានឡើយ ។ ប្លង់មេត្រូវបានបង្កើតលើកដំបូងគឺនៅឆ្នាំ១៩៥៨ ដោយប្លង់នេះ គេតាក់តែងឡើងសំរាប់រៀបចំទីក្រុងក្នុងរយៈពេលពី១០ទៅ១៥ឆ្នាំខាងមុខ ហើយគេធ្វើការសើរើប្លង់នេះជារៀងរាល់៥ឆ្នាំម្តង ។ ប្លង់នេះធ្វើការកំណត់បែងចែកដីប្រើប្រាស់មានជាអាទិ៍ ដីសម្រាប់លំនៅដ្ឋាន ពាណិជ្ជកម្ម រដ្ឋបាលសាធារណៈ កន្លែងកម្សាន្ត និងកំណត់អំពីកម្ពស់អាគារដែលអាចសង់បានទៅតាមតំបន់នីមួយៗ ។[100]

❖ **ការអនុវត្តប្លង់មេ**

ដើម្បីឲ្យប្លង់មេ ដែលជាឯកសារច្បាប់គោលនៃការរៀបចំទីក្រុងសិង្ហបុរីនេះ មានប្រសិទ្ធិភាពខ្ពស់ គេបានធ្វើការបង្កើតនូវប្រព័ន្ធគ្រប់គ្រងការអភិវឌ្ឍន៍មួយ ។ តាមរយៈប្រព័ន្ធនេះ រដ្ឋាភិបាលបានធ្វើការគ្រប់គ្រងយ៉ាងតឹងរ៉ឹងទៅលើការប្រើប្រាស់គ្រប់ប្រភេទដីនៅសិង្ហបុរី តាមរយៈអាជ្ញាធរអភិវឌ្ឍន៍ទីក្រុង (URA) ។ រាល់ការសាងសង់អាគារ ការកែប្រែអាគារ ដាច់ខាតត្រូវតែមានការអនុញ្ញាតពីអាជ្ញាធរអភិវឌ្ឍទីក្រុងជាមុនសិន ។ រាល់ការចេញការអនុញ្ញាតពីអាជ្ញាធរនេះទៅបាន លុះត្រាតែការស្នើរសុំនោះ ស្របតាមបញ្ញត្តិដែលមានចែងក្នុងប្លង់មេ ។

## ៣.កត្តាដែលជំរុញឲ្យមានការរៀបចំទីក្រុង

### ៣.១. កត្តាភូមិសាស្ត្រ

[100] *https:// www.eresources.nlb.gov.sg/infopedia/articles/SIP_1564_2009-09-08.html*

សិង្ហបុរី កើតឡើងពីកោះសរុប ៦៣កោះ ដែលកោះធំជាងគេ គឺកោះសិង្ហបុរី ។ កោះសិង្ហបុរីមានឈ្មោះជាផ្លូវការថា *ពូឡៅអ៊ូជុង* (ជាភាសាម៉ាឡេដែលមានន័យថា *កោះនៅចុងដី [នៃឧបទ្វីប]*) ។ កោះ សិង្ហបុរីភ្ជាប់ទៅខេត្តចូហរ ដោយផ្លូវសិប្បនិម្មិត២ គឺ (ម៉ាឡេស៊ី) Johor–Singapore Causeway នៅខាងជើង និង Tuas Second Link នៅខាងលិច ។ កោះសំខាន់ៗ ផ្សេងទៀតមាន កោះជូរុង (Jurong Island) កោះតេកុង (Pulau Tekong) កោះ អ៊ូប៊ីន (Pulau Ubin) និង កោះសេនតូសា (Sentosa)។ ចំណុច ធម្មជាតិខ្ពស់ជាងគេនៅសិង្ហបុរីគឺ កូនភ្នំ ប៊ូគីត ទីម៉ា (Bukit Timah Hill) ដែលមានកំពស់១៦៦ម៉ែត្រ។ តាំងពីឆ្នាំ ១៩៦០ រដ្ឋាភិបាលសិង្ហបុរីបានខិតខំប្រឹងប្រែងក្នុងការកសាងទីក្រុង ដែលជាលទ្ធផលសិង្ហបុរីបច្ចុប្បន្នមានទេសភាពជាទីក្រុងទាំងស្រុង។ សិង្ហបុរីមានគម្រោងវាតដីពីសមុទ្រ ដោយយកដីពីកូនភ្នំនានារបស់ខ្លួន ដីពីបាតសមុទ្រ និងពីប្រទេសជិតខាងមកចាក់បំពេញ ។ ជាលទ្ធផលផ្ទៃដីសិង្ហបុរីបានកើនឡើងពី ៥៨១,៥គម.២ ក្នុងឆ្នាំ១៩៦០ មក ៧០៤ គម.២ នាពេលបច្ចុប្បន្ន ។ សិង្ហបុរីមានគម្រោងនឹងពង្រីក១០០ គម.២ បន្ថែមទៀតមុនឆ្នាំ២០៣០។ គម្រោងនេះក៏បានតភ្ជាប់កោះតូចៗនានាទៅកាន់កោះធំៗតាមរយៈការចាក់ដីតភ្ជាប់ផងដែរ។ ប្រហែល២៣%នៃផ្ទៃដីសិង្ហបុរី ត្រូវបានរក្សាឲ្យនៅជាព្រៃ និងឧទ្យានជាតិ ។ ឧទ្យានជាតិធំជាងគេ ដែលត្រូវបានគេការពារគឺ ឧទ្យានរុក្ខជាតិសិង្ហបុរី (Singapore Botanic Gardens) ដែលមានទំហំ ៦៧,៣ ហិកតា។ សិង្ហបុរីគ្មានស្ទឹង ឬបឹងទឹកសាបធម្មជាតិទេ ។ ប្រភពផ្គត់ផ្គង់ទឹកសាបក្នុងស្រុកនឹងចំបងជាងគេគឺ ទឹកភ្លៀងដែលត្រូវបានស្តុកទុកក្នុងអាងសិប្បនិម្មិត។ ទឹកភ្លៀងផ្គត់ផ្គង់ទឹកសាបប្រមាណ៥០% ហើយនៅសល់ ៥០%ទៀត គឺនាំចូលពីប្រទេសជិតខាង និងបានពីរោងចក្រចំរាញ់ទឹកស្អាតប្រើប្រាស់ឡើងវិញ ។ រដ្ឋាភិបាលមានគម្រោងបង្កើនចំនួនរោងចក្រ ចំរាញ់ទឹកសមុទ្រដើម្បីកាត់បន្ថយការពឹងផ្អែកលើទឹកនាំចូល ។[101]

### ៣.២.ភក្តាវិស័យទេសចរណ៍

វិស័យទេសចរណ៍ជាឧស្សាហកម្មដ៏ធំមួយរបស់សិង្ហបុរី ។ សិង្ហបុរីគឺជាគោលដៅទេសចរណ៍ដ៏ពេញនិយម ។ គ្រាន់តែក្នុងឆ្នាំ២០០៧ ចំនួនអ្នកទេសចរណ៍១០,២លាននាក់ បានមកទស្សនាសិង្ហបុរី ។ កន្លែងដែលទាក់ទាញទេសចរណ៍ល្បីជាងគេនៅសិង្ហបុរី គឺទីប្រជុំហាងលក់ទំនិញនៅផ្លូវអកឆាដ (Orchad Road shopping districts)។ ដើម្បីទាក់ទាញទេសចរណ៍បន្ថែម នៅឆ្នាំ២០០៥ រដ្ឋាភិបាលបានសម្រេចចិត្តអនុញ្ញាតឲ្យការលេងល្បែងស៊ីសងក្លាយជាស្របច្បាប់ ។ រដ្ឋបានអនុញ្ញាតអោយមានការបើកបនល្បែង២

[101]https://www.cia.gov/library/publications/the-world-factbook/geos/sn.html

នៅតំបន់ម៉ារីណាខាងត្បូង (Marina South) និងតំបន់សេនតូសា (Sentosa)។102 ដើម្បីប្រកួតប្រជែងជាមួយទីក្រុងផ្សេងៗទៀត ក្នុងតំបន់ដូចជា ហុងកុង តូក្យូ និង សៀងហៃ រដ្ឋបាន ប្រកាសបង្កើនភាពទាក់ទាញតាមរយៈការបំភ្លឺ លំអ អាគារនានា។ ចំណីអាហារក៏ត្រូវបានជំរុញឲ្យក្លាយជាធនធានទេសចរណ៍ផងដែរ ដោយរដ្ឋរៀបចំអោយមាន បុណ្យម្ហូបអាហារ នៅរាល់ខែមិថុនា ព្រឹត្តិការណ៍ប្រចាំឆ្នាំផ្សេងទៀតមានដូចជា បុណ្យព្រះអាទិត្យ ការតុបតែងភ្លើងលំអបុណ្យណូអែល និង-បុណ្យអលង្ការ-ជាដើម ។ សិង្ហបុរីមានភាពរហ័សរហួនក្នុងការប្រែក្លាយខ្លួនឲ្យទៅជាស្នូល ទេសចរណ៍វេជ្ជសាស្ត្រ ។ មានអ្នកទេសចរណ៍ប្រមាណ២សែននាក់ក្នុងមួយឆ្នាំ ចូលមកស្វែងរកសេវាសុខាភិបាលក្នុងប្រទេសសិង្ហបុរី ។ សិង្ហបុរីមានបំណងពង្រីកសេវាសុខាភិបាល អោយមានលទ្ធភាពទទួលអ្នកជំងឺបរទេស១លាននាក់ក្នុងមួយឆ្នាំឲ្យបានមុនឆ្នាំ២០១២ ដែលអាចរកចំណូលជូនរដ្ឋយ៉ាងច្រើន ។ រដ្ឋាភិបាលសង្ឃឹមថាការផ្តួចផ្តើមនេះ នឹងផ្តល់ការងារថ្មីចំនួន១៣០០០ទៀតក្នុងវិស័យសុខាភិបាល ។

### ៣.៣.ធនធានធម្មជាតិ*(ធនធានទឹក)*

ដោយសារគ្មានទឹកសាបពីបឹងបួរ ឬទន្លេ ទឹកភ្លៀងជាប្រភពផ្គត់ផ្គង់ទឹកសាបក្នុងស្រុក ជាបឋម នៅសិង្ហបុរី ។ ទឹកពាក់កណ្តាលនៅសិង្ហបុរីបានពីទឹកភ្លៀងដែលត្រូវបានគេត្រង និងរក្សាទុកក្នុងអាងហើយសល់ពីនោះជាទឹកនាំចូលពីម៉ាឡេស៊ី ។ ក៏ប៉ុន្តែកិច្ចសន្យាស្តីពីផ្គត់ផ្គង់ទឹក២ នឹងត្រូវអស់សុពល ភាព នៅឆ្នាំ២០១១ និងឆ្នាំ២០១៦ជាបន្តបន្ទាប់ ។ ភាពមិនចុះសម្រុងពីតម្លៃទឹកធ្វើឲ្យរដ្ឋាភិបាលសិង្ហបុរី ងាកមករកវិធានការដោះស្រាយការខ្វះខាតទឹកផ្សេងទៀត ។ បច្ចុប្បន្នរដ្ឋកំពុងសាងសង់តំបន់ត្រងទឹក ភ្លៀង រោងចក្រសំអាតទឹក និងរោងចក្រកែច្នៃទឹកសមុទ្រជាទឹកសាបបន្ថែមទៀត ។[103]

### ៣.៤. កត្តាប្រជាសាស្ត្រ

តាមស្ថិតិរបស់រដ្ឋាភិបាលសិង្ហបុរី ប្រជាជនសិង្ហបុរីនៅឆ្នាំ២០០៩មានចំនួនប្រហែល៤,៩៩លាននាក់ និងមានដង់ស៊ីតេ៧០២២នាក់/គម២ ។ ៣,៧៣លាននាក់ជាពលរដ្ឋសិង្ហបុរី និង អ្នកមានសិទ្ធិរស់នៅ អចិន្ត្រៃយ៍ដែលក្នុងនោះ៣,២ លាននាក់ជាពលរដ្ឋមានសញ្ជាតិសិង្ហបុរី ។ អ្នករស់នៅសិង្ហបុរី៧៤,២% មានដើមកំនើតចិន ១៣,៤៩% មានកំណើតម៉ាឡេ ២៣%មានដើមកំណើតឥណ្ឌា ២%ជាជនជាតិដទៃ ។

[102] *ក្រសួងពាណិជ្ជកម្មនិងឧស្សាហកម្ម, សិង្ហបុរី* http://app.mti.gov.sg/data/pages/606/doc/Ministerial%20Statement%20-%20PM%2018apr05.pdf.

[103] សៀវភៅ Assignment ដែលសិក្សាស្រាវជ្រាវអំពីប្រទេសសិង្ហបុរិ ដែលបាន រៀបរៀងនិងចងក្រងដោយ និសិត្ស ឆ្នាំទី ២ ជំនាន់ទី៣ នៃសកលវិទ្យាល័យ សាខាខេត្តក្រចេះ( ដកស្រង់ភាគច្រើន)

នៅមុនឆ្នាំ២០១០ពលរដ្ឋម្នាក់ៗ អាចជ្រើសរើសសាសន៍របស់ខ្លួនបានតែមួយប៉ុណ្ណោះ (ដែលជាទូទៅ ដូច ឪពុក) ។ ប៉ុន្តែបច្ចុប្បន្នគេអាចដាក់ »ជាតិសាសន៍ទី១«និង»ជាតិសាសន៍ទី២«បាន ។[104]

### ៣.៥. កត្តាវិស័យគមនាគមន៍ និងដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ក្នុងស្រុក មានបណ្តាញផ្លូវថ្នល់ពាសពេញកោះទាំងមូលប្រវែងសរុប ៣៣៥៦គម រាប់បញ្ចូលទាំងបណ្តាញផ្លូវអិចស្រ្តេសវេយ(Express way) ប្រវែង១៦១គមផងដែរ ។ បណ្តាញដឹកជញ្ជូនសាធារណៈ បំរើការដោយសេវាកម្មឡានក្រុងរបស់រដ្ឋ និងក្រុមហ៊ុនតាក់ស៊ី មានអាជ្ញាប័ណ្ណមួយចំនួន ។ ប្រជាជនសិង្ហបុរីអាស្រ័យខ្លាំងលើសេវាកម្មឡានក្រុង ក្នុងការធ្វើដំណើរទៅសាលា ឬកន្លែងធ្វើការ ។ បណ្តាញផ្លូវដែកចែកចេញជា MRT (Mass Rapid Transit បណ្តាញដឹក ជញ្ជូនផ្លូវដែកខ្នាតធំ) និង LRT(Light Rail Transit បណ្តាញដឹកជញ្ជូនផ្លូវដែកខ្នាតតូច) ។ ជារៀងរាល់ថ្ងៃ ប្រជាជន២១លាននាក់ប្រើប្រាស់ឡានក្រុង ៨៥,៥លាននាក់ប្រើប្រាស់LRT ឬ MRT និងប្រហែល ១លាននាក់ប្រើប្រាស់តាក់ស៊ី ។ ការប្រើប្រាស់មធ្យោបាយធ្វើដំណើរឯកជន មិនត្រូវបានគេលើកទឹកចិត្តទេ ដោយរដ្ឋបានដាក់អោយមានប្រព័ន្ធប្រមូលថ្លៃប្រើប្រាស់ផ្លូវអេឡិចត្រូនិក នៅម៉ោងដែលមាន ចរាចរណ៍មមាញឹកបង្ខំឲ្យបង់ពន្ធយានយន្តក្នុងតម្លៃថ្លៃ និងដាក់ឲ្យមានកូតាក្នុងការទិញយានយន្ត ។ នៅឆ្នាំ២០០១ បណ្តាញគមនាគមន៍សាធារណៈបានដាក់ប្រើប្រព័ន្ធ EZ-Link ដែលអនុញ្ញាត ឲ្យគេប្រើកាតអាចបញ្ចូលទឹកប្រាក់បានធ្វើជាសំបុត្រ ។[105]

## ជំពូកទី២ ប្រវត្តិនៃការរៀបចំទីក្រុងនៃប្រទេសម៉ាឡេស៊ី

### ១. ទិដ្ឋភាពទូទៅនៃការរៀបចំទីក្រុង

បទពិសោធន៍នៃការរៀបចំទីក្រុងប្រទេសម៉ាឡេស៊ី គឺពឹងផ្អែកទៅលើទម្រង់រចនាសម្ព័ន្ធ និងមុខងារនៃទីក្រុង ។ ការរៀបចំទីក្រុងចាប់ផ្តើមឡើង នៅពេលដែលមានការរកឃើញនៅតំបន់ទីក្រុងនានា (Urban Areas) និងការរីកលូតលាស់នៃទីក្រុង (Urban Growth) ក្នុងអំឡុងពេលដែលប្រទេសម៉ាឡេស៊ីស្ថិតនៅក្រោមអាណានិគមរបស់ចក្រភពអង់គ្លេស ក្នុងឆ្នាំ១៨៨៧-១៩៥៦ ។ ពួកចក្រភពអង់គ្លេសបានជួយស្វែងរកនូវប្រពន្ធ័រៀបចំទីក្រុងនៅក្នុងប្រទេសម៉ាឡេស៊ី ពោលគឺទីក្រុងនីមួយៗត្រូវបានបង្កើតដោយមានការជួយជ្រោមជ្រែងរបស់អង់គ្លេស ទាំងមុខងារខាងពាណិជ្ជកម្ម ហិរញ្ញវត្ថុ រដ្ឋបាល និងសង្គមជាដើម ។ ទីក្រុងទាំងអស់នោះមានដូចជា ទីក្រុងកូឡាឡាំពួរ (Kuala Lampur) សារអាឡាំ(Shah Alam)

---

[104] http://www.singstat.gov.sg/news/news/press12012011.pdf

[105] https://www.cia.gov/library/publications/the-world-factbook/rankorder/2127rank.html

កូតាគីណាបាលូ (Kota Kinabalu) សារ៉ាវ៉ាត់ (Sarawak) សាបា (Sabah) ។ល។ បន្ទាប់ពីទទួលបានឯករាជ្យពីចក្រភពអង់គ្លេសនៅឆ្នាំ១៩៥៧ រដ្ឋាភិបាលឯករាជ្យរបស់ប្រទេសម៉ាឡេស៊ី បានខិតខំប្រឹងប្រែងកែលំអនូវគម្រោងរៀបចំទីក្រុងរបស់ចក្រភពអង់គ្លេស ដោយបានបង្កើតនូវផែនការអភិវឌ្ឍន៍មួយ (Development Plan) សម្រាប់ប្រទេសម៉ាឡេស៊ី ដែលផែនការនោះត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់ស្តីពីការរៀបចំទីក្រុង និងប្រទេស ( Town and Country Planning Act) ឆ្នាំ១៩៧៦ ។

ប្រទេសម៉ាឡេស៊ីបានធ្វើការផ្លាស់ប្តូរនៃការរៀបចំប្រទេសឡើងវិញ ដូចជាការរៀបចំជីវភាពរស់នៅរបស់ប្រជាជន បរិស្ថាន ការប្រើប្រាស់ដីធ្លីជាដើម ។ ប្រទេសម៉ាឡេស៊ី បានជួបប្រទះនឹងភាពស្មុគស្មាញមួយចំនួន ពិសេសទៅលើការគ្រប់គ្រងប្រព័ន្ធរៀបចំទីក្រុងអោយមានភាពកាន់តែប្រសើរឡើង ។ តែទោះជាយ៉ាងណា ការរៀបចំគ្រប់គ្រងនេះតែងតែមានភាពអវិជ្ជមានមួយចំនួនហើយសម្រាប់ប្រទេសនេះ ។ ទិដ្ឋភាពទូទៅនៃការរៀបចំទីក្រុងនេះ គឺការគ្រប់គ្រងផែនការរៀបចំទីក្រុងអោយទៅរកការអភិវឌ្ឍន៍ដោយមាននិរន្តរភាព ។ ហើយការអភិវឌ្ឍនេះ ស្ថិតនៅក្នុងផែនការថ្នាក់ជាតិសម្រាប់ឆ្នាំ២០០០-២០០៥ និងផែនការនៃឆ្នាំបន្តបន្ទាប់ទៀត។នៅក្នុងផែនការទីមួយ គឺការនិយាយអំពីតួនាទីនៃការគ្រប់គ្រងផែនការអភិវឌ្ឍន៍ និងទីពីរគឺ ផែនការយុទ្ធសាស្ត្រនៃការរៀបចំគ្រប់គ្រង បរិស្ថាន និងអេកូឡូស៊ី(ការថែរក្សាដើមឈើជាដើម) ។[106]

## ២.ដំណើរការនៃការរៀបចំទីក្រុង

គម្រោងនៃការរៀបចំផែនការសំរាប់ទីក្រុង ត្រូវបានធ្វើឡើងដោយមានការពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់ ក្រោមគម្រោងផែនការដ៏ម៉ត់ចត់ និងមានភាពច្បាស់លាស់ដើម្បី ធ្វើអោយទីក្រុងនេះមានភាពរីកចំរើនយ៉ាងឆាប់រហ័ស ។ សព្វថ្ងៃនេះគម្រោងនៃការអភិវឌ្ឍត្រូវធ្វើឡើងទៅតាមលំដាប់លំដោយតាំងពីថ្នាក់មូលដ្ឋាន ក្រសួង និង រដ្ឋាភិបាល ដើម្បីរៀបចំទីក្រុងអោយក្លាយទៅជាប្រទេសអភិវឌ្ឍន៍ ដូចបណ្តាប្រទេសផ្សេងៗទូទាំងសកលលោក ។

ប្រព័ន្ធនៃគម្រោងអភិវឌ្ឍនៅក្នុងប្រទេសម៉ាឡេស៊ី ត្រូវបានជួយសម្រួលដោយគោលការណ៍សំខាន់ៗរបស់សភាThe Legislation Fundamental ដែលធានាបានថា គម្រោងអភិវឌ្ឍនោះរៀបចំបាន ត្រឹមត្រូវ និងមានស្តង់ដារដោយផ្អែកទៅលើគោលនយោបាយជាតិ និងយុទ្ធសាស្ត្រដើម្បីធ្វើឲ្យមាន តុល្យភាពនៃការអភិវឌ្ឍតំបន់នានា ។ គម្រោងអភិវឌ្ឍនោះ ត្រូវបានអនុវត្តតាមក្របខណ្ឌដែលបានផ្តល់ ឲ្យក្រោមគម្រោងអភិវឌ្ឍជាតិ (The National Development Planning) ដែលស្ថិតក្រោមច្បាប់ស្តីពីការ រៀបចំ

[106] http://www.ide.go.jp/English/Publish/Download/Apec/pdf/1997_15.pdf

ផែនការទីក្រុង និងប្រទេស ឆ្នាំ១៩៧៦ (The Town and Country Planning Act) ដែលបានអនុម័តដោយសភា ដែលបានប្រគល់តួនាទីឲ្យអាជ្ញាធរតំបន់(Local Authority) ក្នុងការត្រួតពិនិត្យនូវដំណាក់កាលនៃការអភិវឌ្ឍន៍(Development Process ) ។

ជាទូទៅគម្រោងអភិវឌ្ឍ(Development-Plan)នោះមានឋានានុក្រមដូចជា៖

- ផែនការនៃទម្រង់ជាតិ ( The National Physical Plan )
- ផែនការរចនាសម្ព័ន្ធ ( A Structure Plan )
- ផែនការថ្នាក់តំបន់ ( A Local Plan )
- ផែនការតំបន់ពិសេស ( A Special Area Plan )

### ២.១. ផែនការនៃទម្រង់ជាតិ

ការរៀបចំនូវគោលនយោបាយដីធ្លីថ្នាក់ជាតិត្រូវបានបង្កើតឡើង ។ ផែនការនេះ គឺជាការចាំបាច់ដើម្បីជួយដល់មុខងារសំខាន់របស់ក្រុមប្រឹក្សាក្នុងការធ្វើផែនការថ្នាក់ជាតិក្នុងការលើកកម្ពស់ក្របខ័ណ្ឌនៃគោលនយោបាយជាតិ ។[107]

ផែនការនេះ គឺជាគម្រោងការមួយដែលធ្វើការសង្ខេបនូវ គោលនយោបាយយុទ្ធសាស្ត្រ (Strategic Policios) ក្នុងការកំណត់លំហូរទិសដៅនៃរូបរាងអភិវឌ្ឍ (The Direction Flow of Physical Development) គំរូជាតិ (National Pattern) និងគំរូនៃការប្រើប្រាស់ដី (Land Use Pattern) ក៏ដូចជា របៀបនៃការការពារនូវធនធានធម្មជាតិ(The Conservation Of National Resources) ។

ផែនការនេះត្រូវបានផ្តល់មតិយោបល់ដោយក្រុមប្រឹក្សានៃផែនការនៃរូបរាងជាតិ(The National Physical Planning Council) ដែលទទួលខុសត្រូវក្នុងការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានធម្មជាតិ (The National Physical Environment) ឆ្ពោះទៅរកការសម្រេចបាននូវការអភិវឌ្ឍជានិរន្ត (Sustainable Development)។ ផែនការនេះនឹងត្រូវបានគេពិនិត្យជារៀងរាល់៥ឆ្នាំម្តង ដោយមានការចង្អុលបង្ហាញពីក្រុមប្រឹក្សា ។ វាគួរតែជាតួនាទីទូទៅរបស់រដ្ឋាភិបាលរដ្ឋសហព័ន្ធ (Federal government ) និងរដ្ឋាភិបាលនៃ រដ្ឋនីមួយៗ ដើម្បីជួយសម្រួលដល់ការធានាថាកម្មវត្ថុរបស់ផែនការនៃការរៀបចំទម្រង់ជាតិ (NPP) នឹងសម្រេចបាន ។

### ២.២. ផែនការរចនាសម្ព័ន្ធ(SP)

[107] http://core.kmi.open.ac.uk/download/pdf/11782413.pdf

ផែនការរចនាសម្ពន្ធ័[108] នេះបានរៀបចំឡើងតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់លើក្នុងការរៀបចំរចនាសម្ព័ន្ធនៃការរៀបចំទីក្រុង ។ នៅក្នុងរចនាសម្ពន្ធ័នេះផងដែរគឺមានការទាក់ទងទៅនឹងការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចរបស់ប្រទេសផងដែរ ។[109]

ផែនការរចនាសម្ព័ន្ធនេះ ក៏ជាផែនការមួយដែលកំណត់អំពីគោលនយោបាយទូទៅ និងការស្នើសុំនៃការអភិវឌ្ឍន៍ និងការប្រើប្រាស់ដីរបស់រដ្ឋ ដើម្បីធ្វើឲ្យមានលក្ខណៈប្រសើរឡើងនូវបរិស្ថានជុំវិញនៃការរស់នៅ ការធ្វើដំណើរ ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ឆ្ពោះទៅរកការអភិវឌ្ឍន៍ជានិរន្ត ។ ផែនការនេះត្រូវបានភ្ជាប់មកជាមួយនឹងដ្យាក្រាម(Diagrams) និងការបង្ហាញរូបភាព(Illustration) ។ ម្យ៉ាងវិញទៀតផែនការនេះត្រូវតែអនុម័តដោយគណៈកម្មការនៃគម្រោងរៀបចំរដ្ឋ (State Planning Committee) តាមរយៈការពិគ្រោះមតិយោបល់ ជាមួយក្រុមប្រឹក្សានៃផែនការនៃទម្រង់ជាតិ(NPP) ។ ជាពិសេសគម្រោងនេះត្រូវតែធ្វើឡើងដោយអនុលោមទៅតាមផែនការនៃការរៀបចំទម្រង់ជាតិ ។ នៅពេលណាដែលផែនការរចនាសម្ពន្ធ័ (SP) បានចូលជាធរមានហើយផែនការនេះនឹងត្រូវធ្វើការពិនិត្យជារៀងរាល់៥ឆ្នាំម្តងដោយប្រធានរដ្ឋ (State Director) និងត្រូវបានបញ្ជូនផែនការនេះទៅឲ្យក្រុមប្រឹក្សានៃផែនការនៃការរៀបចំទម្រង់ជាតិ(NPP) ។

### ២.៣.ផែនការថ្នាក់តំបន់(LP)

ជាផែនការដែលកំណត់អំពីការស្នើសុំលម្អិតរបស់អាជ្ញាធរនៃផែនការថ្នាក់តំបន់ (LPA) នៅក្នុងការអភិវឌ្ឍន៍និងការប្រើប្រាស់ដីដែលធ្វើឲ្យមានភាពប្រសើរឡើងនូវបរិស្ថានធម្មជាតិ (Physical Environment) ការពារនូវទីតាំងភូមិសាស្ត្រ (Topography) ការពារនូវទេសភាព អភិវឌ្ឍដីទំនេរ និងការការពារនូវអាគារនានាឲ្យមានសោភ័ណភាពនៅក្នុងតំបន់ ។

ផែនការថ្នាក់តំបន់គឺធ្វើការ គ្រប់គ្រងទៅលើដីដែលមានដើម្បី ប្រើប្រាស់អោយមានភាពទូលំទូលាយ ដោយអនុលោមទៅតាមច្បាប់ដែលបានកំណត់ និងការដាក់បញ្ចូលនូវរចនាសម្ព័ន្ធជាសាធារណៈដើម្បីធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការប្រើប្រាស់ធនធាននៅក្នុងតំបន់ដែលមាន ។[110]

នៅពេលដែលផែនការរចនាសម្ពន្ធ័(SP)បានចូលជាធរមានហើយ អាជ្ញាធរនៃផែនការថ្នាក់តំបន់(LP)នឹងចាប់ផ្តើមរៀបចំសេចក្តីព្រាងនៃផែនការថ្នាក់តំបន់ ។ ដោយនៅក្នុងនោះរួមមានផែនទី និងលិខិតបទដ្ឋានគតិយុត្តិ និងត្រូវភ្ជាប់មកជាមួយនូវដ្យាក្រាម(Diagram) និងគំនូររូបភាព(illustration) ។

[108] http://www.kpkt.gov.my/kpkt_2013/akta/Act172y1976bi.pdf
[109] http://core.kmi.open.ac.uk/download/pdf/11782413.pdf
[110] http://core.kmi.open.ac.uk/download/pdf/11782413.pdf

ផែនការនេះត្រូវបានអនុម័តដោយគណៈកម្មការនៃផែនការរដ្ឋ (State Planning Committee) ។ ម្យ៉ាងវិញទៀតផែនការនេះត្រូវធ្វើឡើងដោយយោងទៅតាមគោលការណ៍ដែលមាននៅក្នុងផែនការ រចនាសម្ព័ន្ធ(SP) ។[111] ស

### ២.៤.ផែនការតំបន់ពិសេស(SP)

ជាផែនការមួយ ដែលកំណត់អំពីគម្រោងអភិវឌ្ឍលម្អិត (Detailed Development Planning) និងរៀបចំធ្វើយ៉ាងណា មិនឲ្យប៉ះពាល់ដល់បរិស្ថាន ។ នៅពេលដែលផែនការរចនាសម្ព័ន្ធ (SP) ឬផែនការស្ដីពីការរៀបចំថ្នាក់តំបន់ (LP) បានចូលជាធរមាន ប្រធានរដ្ឋ (Director State) ឬអាជ្ញាធរនៃផែនការថ្នាក់តំបន់ (A Local Planning Authority) ក្រោមការផ្តួចផ្តើមគំនិតរបស់ពួកគាត់ ឬក្រោមការចង្អុលបង្ហាញដោយគណៈកម្មការ ត្រូវផ្ញើរទៅឲ្យគណៈកម្មការសម្រាប់ធ្វើការកែប្រែនូវតំបន់ពិសេស ទាំងគម្រោងការអភិវឌ្ឍន៍ ឬការអភិវឌ្ឍន៍ឡើងវិញ ។[112]

## ៣. កត្តាដែលជំរុញឲ្យមានការរៀបចំទីក្រុង

### ៣.១. ការរីកចម្រើននៃសេដ្ឋកិច្ច

បន្ទាប់ពីទទួលបានឯករាជ្យពីចក្រភពអង់គ្លេស សេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ី មានការរីកចម្រើនយ៉ាងខ្លាំង ចន្លោះពី៥-៩ ភាគរយក្នុងមួយឆ្នាំ ។ សេដ្ឋកិច្ចរបស់ប្រទេសម៉ាឡេស៊ីមានការផ្លាស់ប្តូរពីការពឹងផ្អែកទៅលើវិស័យកសិកម្ម និងរករ៉ែ ទៅជាការពឹងផ្អែកទៅលើវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដែលវាជាកត្តារុញច្រានដ៏សំខាន់សម្រាប់សេដ្ឋកិច្ចជាតិ។ ដោយការរីកចម្រើនផ្នែកវិស័យទាំងអស់នេះហើយ ទើបនាំឲ្យមាននូវការរៀបចំទីក្រុងដើម្បីទាក់ទាញនូវវិយោគិន និងភ្ញៀវទេសចរណ៍នានាក្នុងបណ្តាប្រទេសលើសកលលោក ។[113]

### ៣.២. កំណើនប្រជាជន

យោងទៅតាមទិន្នន័យនៃការរៀបចំនគរូបនីយកម្ម នៃប្រទេសម៉ាឡេស៊ីបានបង្ហាញថាចំនួនប្រជាជនដែលរស់នៅក្នុងតំបន់ទីក្រុង(ពោលគឺតំបន់ដែលមាន ប្រជាជនចាប់ពី១០០០០នាក់ ឬច្រើនជាងនេះឡើងទៅ)បានកើនឡើងពី២៥.៧៥០នាក់ក្នុងឆ្នាំ១៩១១ ទៅ១៣.៧២៥,៦០៩នាក់ក្នុងឆ្នាំ ២០០០ ។ តួរលេខទាំងនេះបានចង្អុលបង្ហាញថាក្នុងរយៈពេល៩០ឆ្នាំ ពោលគឺពីឆ្នាំ១៩៩១-២០០០ មានចំនួនប្រជាជន

[111] http://www.kpkt.gov.my/kpkt_2013/akta/Act172y1976bi.pdf
[112] https://www.academia.edu/1849615/A_STUDY_ON_MALAYSIA_CITY_PLANNING_The_Effectiveness_of_Shah_Alam_City_Development_Plans_Implementation?login=&email_was_taken=true&login=&email_was_taken=true
[113] http://www.ide.go.jp/English/Publish/Download/Apec/pdf/1997_15.pdf

ប្រមាណជា១៣,៧លាននាក់បានទៅតាំងទីលំនៅនៅខាងក្រៅក្រុង ជាហេតុនាំឲ្យមានការពង្រីកតំបន់ទីក្រុងនេះនៅទូទាំងប្រទេស ជាពិសេសគឺបានរួមចំណែកដល់ការអភិវឌ្ឍន៍ទីក្រុងកើនឡើង ។ ជាមួយគ្នានេះផងដែរ កំនើនប្រជាជនដែលកើនឡើងយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់នៅប្រទេសម៉ាឡេស៊ី គឺនៅក្នុងអំឡុងឆ្នាំ១៩៨០ដល់ឆ្នាំ១៩៩០ ដែលការកើនឡើងនេះបណ្តាលមកពីការធ្វើចំណាក ស្រុករបស់ប្រជាជនពីជនបទទៅរស់នៅឯទីក្រុង ដើម្បីស្វែងរកការងារធ្វើ ក៏ដូចជាការធ្វើអន្តោប្រវេសន៍ របស់ប្រជាជនចិននេះមួយចំនួនផងដែរ ។ ស្របពេលនឹងការកើនឡើងនូវចំនួនប្រជាជននេះ វាក៏បាន បង្កើតនូវបញ្ហាជាច្រើននៅក្នុងទីក្រុង ដែលទាក់ទងនឹងតម្រូវការចាំបាច់របស់ប្រជាជាន ដូចជាបញ្ហាសាងសង់ ការអប់រំ ភាពអនាម័យ និងបញ្ហាខាងផ្នែកសុខាភិបាលជាដើម ។ ដូច្នេះដើម្បីឆ្លើយតបទៅនឹងតម្រូវទាំងនេះ ចាំបាច់ត្រូវតែមានការរៀបចំនូវទីក្រុងមួយដែលមានសោភណភាព មានសណ្តាប់ធ្នាប់ និងមានសន្តិសុខ ។ល។

## សេចក្តីសន្និដ្ឋាន

តាមរយៈការធ្វើការបកស្រាយទៅលើប្រធានបទខាងលើ យើងសង្កេតឃើញថាការរៀបចំទីក្រុងនៃប្រទេសទាំងពីរ បានទទួលរងឥទ្ធិពលពីអាណានិគមដែលវាជាសញ្ញាណមួយនៃការចាប់គិតគូរទៅលើការរៀបចំទីក្រុង ហើយជាមូលហេតុដែលជាចលករក្នុងការជម្រុញឲ្យធ្វើការរៀបចំទីក្រុង ។ ដោយហេតុមានបញ្ហាចោទជាច្រើនដូចជា: កំណើនប្រជាជន កំណើនសេដ្ឋកិច្ច ទេសចរណ៍ ធនធាន ធម្មជាតិដោយកត្តាទាំងនេះខាងលើមានលក្ខណ:ទាក់ទងគ្នា ពោលគឺនៅពេលដែលមានកំណើនប្រជាជន ការពង្រីកតម្រូវការក៏កើនឡើង ហើយដើម្បីជម្រុញតម្រូវការនេះ ការជម្រុញវិស័យសេដ្ឋកិច្ចអោយមានការរីកចម្រើនកំណើននៃអ្នកទេសចរណ៍ក៏មិននៅថេរដែរ ។ ការរៀបចំទីក្រុងជារឿងដែលត្រូវយកចិត្តទុកដាក់ ។ ជាក់ស្តែងវិស័យទេសចរណ៍នៅ ប្រទេសសិង្ហបូរីនៅឆ្នាំ២០០៧មាន រហូតដល់ ១.២លាននាក់ ។ វិស័យនោះក៏ទាក់ទងជាមួយបញ្ហាធម្មជាតិ ទឹក ខ្យល់ បរិស្ថាន ...។ ដើម្បីសម្រេចនូវការរៀបចំទីក្រុងឲ្យមានលក្ខណ:ប្រសើរឡើង ការខិតខំប្រឹងប្រែងជាច្រើនត្រូវបានបំពេញដូចជាយន្តការមួយចំនួនរួមមាន: ផែនការ យុទ្ធសាស្ត្រ ច្បាប់ ការបង្កើតអោយមានប្លង់ក្នុងការ រៀបចំទីក្រុងជាដើម ។ ការរៀបចំនេះរដ្ឋាភិបាលប្រទេសទាំងពីរ មានកម្មវត្ថុដូចគ្នា គឺធ្វើយ៉ាងណា និមិត្តទីក្រុងមួយ ដ៏ល្អឥតខ្ចោះ ដែលការអភិវឌ្ឍន៍មានតុល្យភាពរវាងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គម និងបរិស្ថាន ព្រមទាំងភ្ជាប់នូវចក្ខុវិស័យមួយចំនួនដូចជា ប្រទេសមួយដែលពលរដ្ឋរបស់ខ្លួន មានលំនៅដ្ឋាន គ្រប់គ្រាន់ សោភណភាព ផាសុកភាព ប្រព័ន្ធមធ្យោបាយធ្វើដំណើរមានលក្ខណ:ងាយស្រួល មាន ទេសភាពបៃតង មានមជ្ឈមណ្ឌលទំនើបជាដើម។ ការរៀបចំទីក្រុងនេះមិនមែនមានលក្ខណ:ងាយ ស្រួល ដោយគ្មានជួបប្រទះឧបសគ្គនោះទេ ទិដ្ឋភាពជាក់

ស្តែងដូចជា ការរៀបចំទីក្រុង សិង្ហបុរី និងទីក្រុងកូឡាឡាំពូរ បញ្ហានោះមានថវិកា ធនធានមនុស្ស បច្ចេកទេស ស្ថានភាពដី និងករណីប្រធានស័ក្តិជាដើម ។ សរុបសេចក្តីមកវិញ រាល់ប្រតិបត្តិការលើកាតព្វកិច្ចរហូតដល់សម្រេចលទ្ធផលដូចបានធ្វើបទ បង្ហាញខាងលើ ហើយក្រុមយើងខ្ញុំរំពឹងទុកថាការស្រាវជ្រាវនេះ នឹងក្លាយជាជំនួយផ្លូវគំនិតបានកម្រិត ទៀត ទៅលើមុខវិជ្ជានីតិនគរូបនីយកម្ម និងសំណង់ជាពិសេសក្នុងក្របខណ្ឌនៃការរៀបចំទីក្រុងទាំងពីរខាងលើ ។

# ឧបសម្ព័ន្ធ

CONCEPT PLAN 1971 OF SINGAPORE



CONCEPT PLAN 1991 OF SINGAPORE







CONCEPT PLAN 2001 OF SINGAPORE




# ឯកសារយោង

## ក. ប្រទេសសិង្ហបុរី


- *https:// www.eresources.nlb.gov.sg/infopedia/articles/SIP_1564_2009-09-08.html*
- *https:// www.ura.gov.sg*
- *https://* www.sgpolcom.com/.../a-history-of-singapores-population-control-1947
- *https://* www.tradingeconomics.com/singapore/population-density-people-per-sq
- *https:// www.eresources.nlb.gov.sg/history/.../c4c0b6bf-d674-4851-a3d4-fcc0b9d785*
- https://sites.google.com/a/macalester.../worldurbanization-singapore/history
- http://www.populstat.info/Asia/singapoc.htm
- http://geography.about.com/od/economic-geography/a/Singapore-Economic-Development.htm
- http://www.globalurban.org/GUD%20Singapore%20MES%20Report.

## ខ.ប្រទេសម៉ាឡេស៊ី


- http://www.kpkt.gov.my/kpkt_2013/akta/Act172y1976bi.pdf
- http://core.kmi.open.ac.uk/download/pdf/11782413.pdf
- https://www.academia.edu/1849615/A_STUDY_ON_MALAYSIA_CITY_PLANNING_The_Effectiveness_of_Shah_Alam_City_Development_Plans_Implementation?login=&email_was_taken=true&login=&email_was_taken=true
- http://www.ide.go.jp/English/Publish/Download/Apec/pdf/1997_15.pdf